សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

## ឧបសគ្គ និងបញ្ហាប្រឈមក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ច័ន្ទ ពេជ្រថូនីដែត**

លោក **ហោង ម៉េងស្រេង**

ណែនាំដោយ

សាស្ត្រាចារ្យរងបណ្ឌិត **ស្រ៊ុន សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**

ជំនាន់ទី ៨

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរបាយការណ៍ ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ច័ន្ទ ពេជ្រថូនីដែត** និង **ហេង ម៉េងស្រេង** ជានិស្សិតបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ឆ្នាំទី៤ ជំនាន់ទី៨ ក្នុងឆ្នាំសិក្សា២០២៣-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាបឋមយើងខ្ញុំទាំងពីរនាក់ សូមសម្តែងនូវការដឹងគុណដោយកតញ្ញូតាធម៌ និងដោយការគោរពដ៏ខ្ពង់ខ្ពស់បំផុតជូនទៅដល់លោកឪពុក និងអ្នកម្តាយដែលលោកទាំងពីរបានផ្តល់កំណើតព្រមទាំងចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅយើងខ្ញុំពោរពេញដោយក្តីស្រឡាញ់ ការសន្តោសប្រោសប្រណី និងព្រហ្មវិហារធម៌ដ៏ធំធេងមិនអាចកាត់ថ្លៃបាន ជាពិសេសលោកទាំងពីរតែងតែលះបង់កម្លាំងញើសឈាម ផ្គត់ផ្គង់ធនធានដើម្បីទំនុកបម្រុង ជ្រោមជ្រែងការសិក្សាយើងខ្ញុំទាំងពីររូប ចាប់តាំងពីថ្នាក់បឋមសិក្សារហូត ដល់ថ្នាក់បរិញ្ញាបត្រនេះ។ គុណលោកទាំងពីរពិតជាមិនអាចរកអ្វីមកប្រៀបផ្ទឹមបានឡើយសម្រាប់រូបកូន ដោយកូនៗគ្មានអ្វីតបស្នងក្រៅពីការខិតខំរៀនសូត្រក្រេបយកចំណេះដឹងដើម្បីអភិវឌ្ឍន៍ខ្លួនឯង គ្រួសារ និងសង្គមជាតិឱ្យរីកចម្រើន។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង** ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ និងលោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយទាំងពេលវេលា និងកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន ផ្ទេរចំណេះដឹង និងផ្តល់ដំបូន្មានល្អៗជាច្រើនដល់យើងខ្ញុំបាទ។

ជាពិសេស យើងខ្ញុំសូមធ្វើការថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកសាស្ត្រាចារ្យរង បណ្ឌិត **ស្រ៊ុន សុភ័ក្ត្រ** ដែលបានខិតខំយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយណែនាំ ផ្តល់ការប្រឹក្សាយោបល់ ផ្តល់ជាគន្លឹះសម្រាប់ការសរសេរសារណា និងកែតម្រូវនូវរាល់កំហុសខុសឆ្គងទាំងលើខ្លឹមសារ និងអក្ខរាវិរុទ្ធ ដែលកើតមានឡើងក្នុងដំណើរការសរសេរ ដើម្បីឱ្យកិច្ចការនេះលេចចេញជារូបរាងរហូតទទួលបានជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរដល់លោកឪពុក អ្នកម្តាយ ព្រមទាំងឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យណែនាំ លោក លោកស្រី ដែលជាសាស្ត្រាចារ្យនិងបុគ្គលិកទាំងអស់សូមជួបប្រទះនូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# អារម្ភកថា

ប្រទេសកម្ពុជាបានចាប់ផ្តើមកសាងប្រទេសពីបាតដៃទទេ បន្ទាប់ពីបានឆ្លងកាត់ភ្នក់ភ្លើងសង្គ្រាមរ៉ាំរ៉ៃ មុននឹងទទួលបានសុខសន្តិភាព និងស្ថិរភាពនយោបាយពេញលេញនាឆ្នាំ ១៩៩៨ និងបានបោះជំហានយ៉ាងវែងក្នុងការស្តាបនាសមិទ្ធផលជាច្រើនក្នុងកិច្ចដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច សំដៅដល់ការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាព និងបង្កើនប្រាក់ចំណូលរបស់ប្រជាជន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆតា ក្នុងការដាក់ចេញជាចក្ខុវិស័យក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងចំណូលខ្ពស់ត្រឹមឆ្នាំ ២០៥០។

ក្នុងឆ្នាំ ២០២០ គឺជារបត់ដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីទទួលរងនូវផលប៉ះពាល់ពីវិបត្តិសកលនៃការរីករាលដាលជម្ងឺកូវីដ-១៩ ដែលបានធ្វើឱ្យវិស័យមួយចំនួនមានការរាំងស្ទះ និងរារាំងដល់កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងដំណើរឆ្ពោះទៅកាន់ការសម្រេចបានចក្ខុវិស័យខាងលើ ជាពិសេសចក្ខុវិស័យឆ្នាំ ២០៣០ ដែលនឹងឈានមកដល់ក្នុងរយៈពេលដ៏ខ្លីខាងមុខ។ បន្ទាប់ពីទទួលបានជ័យជម្នះលើសមរភូមិនៃវិបត្តិជំងឺកូវីដ-១៩នេះ កម្ពុជាបន្តដំណើរលើមាគ៌ាស្តារ និងជម្រុញកំណើនឡើងវិញ ប៉ុន្តែកំណើនមិនទាន់ស្ថិតលើគន្លងសក្តានុពលនៅឡើយ ខណៈហានិភ័យ និងភាពមិនប្រាកដប្រជាទាំងក្នុងក្របខណ្ឌសកល តំបន់ និងក្នុងស្រុកនៅតែអាចមានលទ្ធភាពកើតឡើងខ្ពស់ ដែលនឹងធ្វើឱ្យចក្ខុវិស័យរបស់កម្ពុជាមិនអាចប្រែក្លាយជាតថភាពជាក់ស្តែងបាន។ ដោយហេតុនេះហើយទើបយើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទមួយ ដែលលើកឡើងស្តីអំពី **ឧបសគ្គ និងបញ្ហាប្រឈមក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០** យកមកធ្វើការសិក្សាស្រាវជ្រាវ។ ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមានគោលបំណងក្នុងការពង្រីកចំណេះដឹង និងស្វែងយល់បន្ថែមទៀតទៅលើឧបសគ្គដែលបាន និងកំពុងរារាំងពាំងដំណើរកម្ពុជាក្នុងការសម្រេចបានគោលដៅក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ ២០៣០ ខាងមុខនេះ ក៏ដូចជាបញ្ហាប្រឈមមួយចំនួនដែលអាចកើតឡើងនាពេលអនាគតដើម្បីងាយស្រួលកំណត់មុខសញ្ញានៃបញ្ហា និងស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា។

យើងខ្ញុំទាំងពីរនាក់ក៏សូមខន្តីអភ័យទោសនូវរាល់កំហុសខុសឆ្គងទាំងឡាយណា ដែលកើតចេញដោយអចេតនា និងរីករាយស្វាគមន៍ទទួលនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទៅលើអត្ថន័យ ឃ្លាឃ្លោង និងអក្ខរាវិរុទ្ធណាមួយ ដែលបានកើតឡើងនៅក្នុងកិច្ចការស្រាវជ្រាវនេះ។ យើងខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា បើទោះបីជាសារណានេះនៅមានចន្លោះខ្វះខាតយ៉ាងណាក្តី ក៏នៅតែអាចក្លាយទៅប្រភពនៃពុទ្ធិ និងជាឯកសារសម្រាប់ការសិក្សាស្រាវជ្រាវដល់កុលបុត្រកុលធីតាខ្មែរ អ្នកសិក្សាស្រាវជ្រាវ និងសិស្សនិស្សិតទាំងឡាយ ដែលមានបំណងចង់ស្វែងយល់ រៀនសូត្រ និងយកទៅប្រើប្រាស់ស្របតាមកម្មវត្ថុ និងតម្រូវការជាក់ស្តែងទៅលើប្រធានបទខាងលើ។ ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមអរគុណអ្នកទាំងអស់គ្នាសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃមកអានអត្ថបទសៀវភៅសារណានេះ។

# មាតិកា


បញ្ជីក្រាហ្វិក.....v

បញ្ជីតារាង.....vii

បញ្ជីអក្សរកាត់.....viii


## សេចក្តីផ្តើម


១. សារតានៃការសិក្សា.....១

២. កម្មវត្ថុនៃការស្រាវជ្រាវ.....២

៣. ចំណោទបញ្ហានៃការស្រាវជ្រាវ.....២

៤. វិសាលភាពនៃការស្រាវជ្រាវ.....៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ.....៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ.....៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៤


## ជំពូកទី ១

## ការរំលឹកទ្រឹស្តី


១.១. ទ្រឹស្តីជាមូលដ្ឋាននៃសេដ្ឋកិច្ច.....៦

១.១.១. និយមន័យសេដ្ឋកិច្ច.....៦

១.១.២. ក្របខណ្ឌមីក្រូសេដ្ឋកិច្ច.....៦

១.១.៣. ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច.....៧

១.១.៤. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច.....៧

១.១.៤.១. គោលនយោបាយរូបិយវត្ថុ.....៧

១.១.៤.២. គោលនយោបាយសារពើពន្ធ.....៨

១.១.៥. ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី.....៨

១.១.៦. ផលិតផលក្នុងស្រុកសរុប (GDP) ........ ៩
១.១.៧. ប្រាក់ចំណូលជាតិសរុប (GNI) ........ ១០
១.១.៨. វិធីសាស្រ្ត Atlas ........ ១០
១.២. ទ្រឹស្តីម៉ូដែលនៃសត្វក្ងានហោះ (Flying Geese Model) ........ ១០
១.៣. ទ្រឹស្តីម៉ូដែលនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ (Structural Change Model) ........ ១១
១.៤. សារតានៃការកំណត់ចំណាត់ថ្នាក់ប្រទេស ........ ១២
១.៤.១. មូលដ្ឋាននៃការចាត់ថ្នាក់ប្រទេស ........ ១២
១.៤.១.១. ការធ្វើចំណាត់ថ្នាក់ប្រទេសរបស់ធនាគារពិភពលោក ........ ១២
១.៤.១.២. ការធ្វើចំណាត់ថ្នាក់ប្រទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ........ ១៣
១.៤.១.៣. ការធ្វើចំណាត់ថ្នាក់ប្រទេសរបស់អង្គការសហប្រជាជាតិ ........ ១៣
១.៤.២. គោលការណ៏នៃការចាត់ថ្នាក់ប្រទេសរបស់ធនាគារពិភពលោក ........ ១៤
១.៤.២.១. ប្រទេសចំណូលកម្រិតទាប (Low Income Countries) ........ ១៤
១.៤.២.២. ប្រទេសចំណូលមធ្យមកម្រិតទាប (Lower-middle Income Countries) ........ ១៥
១.៤.២.៣. ចំណូលមធ្យមកម្រិតខ្ពស់ (Upper-middle Income Countries) ........ ១៥
១.៤.២.៤. ចំណូលកម្រិតខ្ពស់ (Upper Income Countries) ........ ១៦

## ជំពូកទី ២

## ស្ថានភាព និងចក្ខុវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា

២.១. លក្ខណៈទូទៅនៃសេដ្ឋកិច្ចកម្ពុជា ........ ១៧
២.១.១. ប្រវត្តិសេដ្ឋកិច្ចកម្ពុជា ........ ១៧
២.១.២. ប្រព័ន្ធសេដ្ឋកិច្ចកម្ពុជា ........ ១៨
២.១.៣. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា ........ ១៨
២.១.៤. ទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ ........ ២២

២.៣. ចក្ខុវិស័យសេដ្ឋកិច្ចកម្ពុជា ..... ២៤
២.៣.១. គោលការណ៍ក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០ ..... ២៤
២.៣.២. ឥទ្ធិពលនៃការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០ ..... ២៥
២.៣.២.១. អត្ថប្រយោជន៍ក្រោយពេលសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ ..... ២៥
២.៣.២.២. ការខាតបង់ក្រោយពេលសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ ..... ២៧
២.៣.៣. ផែនការក្នុងការសម្រេចឱ្យបានចក្ខុវិស័យឆ្នាំ ២០៣០ ..... ២៨
២.៣.៤. យុទ្ធសាស្ត្រក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០ ..... ២៩

## ជំពូកទី ៣

## ឧបសគ្គ និងបញ្ហាប្រឈមក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០

៣.១. ឧបសគ្គ និងបញ្ហាប្រឈមក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០ ..... ៣៣
៣.១.១. បញ្ហាសកល ..... ៣៣
៣.១.១.១. បញ្ហាជំងឺកូវីដ-១៩ ..... ៣៣
៣.១.១.២. សង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន ..... ៣៧
៣.១.១.៣. ភាពតានតឹងភូមិសាស្ត្រនយោបាយ ..... ៤២
៣.១.១.៤. ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល ..... ៥៨
៣.១.១.៥. ការប្រែប្រួលអាកាសធាតុ ..... ៦០
៣.១.១.៦. ការថមថយសេដ្ឋកិច្ចសកល ..... ៦៣
៣.១.២. ផលប៉ះពាល់នៃបញ្ហាសកលមកលើសេដ្ឋកិច្ចកម្ពុជា ..... ៦៦
៣.១.៣. បញ្ហាក្នុងស្រុក ..... ៦៧
៣.១.៣.១. ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ..... ៦៧
៣.១.៣.២. ថ្លៃដើមធុរកិច្ចនៅមានកម្រិតខ្ពស់ ..... ៦៨
៣.១.៣.៣. ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច ..... ៧៣

៣.១.៣.៤. បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញនៅមានកម្រិត....................................៧៤
៣.១.៣.៥. ភាពកម្សោយនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម........................................៧៦
៣.១.៤. បញ្ហាប្រឈមនាពេលអនាគត..........................................................................................៧៨
៣.១.៤.១. ការបែងចែកប្លុកសេដ្ឋកិច្ច និងពាណិជ្ជកម្ម ..............................................................៧៨
៣.១.៤.២. បរិវត្តកម្មឌីជីថល................................................................................................ ៨០
៣.១.៤.៣. ការប្រែប្រួលអាកាសធាតុ.........................................................................................៨១

# ជំពូកទី ៤

# ការវិភាគទិន្នន័យ និងបកស្រាយលទ្ធផល

៤.១. ការវិភាគទិន្នន័យ............................................................................................................ ៨៥
៤.២. ការបកស្រាយលទ្ធផលនៃការវិភាគ ..............................................................................................៨៧
៤.៣. ការព្យាករណ៍ទិន្នន័យលើចក្ខុវិស័យឆ្នាំ ២០៣០......................................................................... ៩០
៤.៤. ដំណោះស្រាយ.............................................................................................................. ៩១
**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**...........................................................................១០០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីក្រាហ្វិក


ក្រាហ្វិកទី១៖ បង្ហាញពីច្បាប់តម្រូវការ និងការផ្គត់ផ្គង់ ........ ៦

ក្រាហ្វិកទី២៖ បង្ហាញពីអត្រាកំណើនសេដ្ឋកិច្ចកម្ពុជាចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០២៣ ........ ១៩

ក្រាហ្វិកទី៣៖ ការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាតាមវិស័យផ្សេងៗ ........ ១៩

ក្រាហ្វិកទី៤ ៖ បង្ហាញពីទំហំពាណិជ្ជកម្មពិភពលោកចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០២១ ........ ៣៤

ក្រាហ្វិកទី៥៖ បង្ហាញពីលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសនៅទូទាំងពិភពលោក ........ ៣៥

ក្រាហ្វិកទី៦៖ បង្ហាញពីចំនួនភ្ញៀវទេសចរណ៍អន្តរជាតិគិតចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២១ ........ ៣៦

ក្រាហ្វិកទី៧៖ បង្ហាញពីបរិមាណនៃការនាំចេញស្រូវសាឡីចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៣ ........ ៣៩

ក្រាហ្វិកទី៨៖ បង្ហាញពីថ្លៃនៃស្រូវសាឡីចាប់ពីចុងឆ្នាំ ២០២០ ដល់ដើមឆ្នាំ ២០២៤ ........ ៣៩

ក្រាហ្វិកទី៩៖ បង្ហាញពីតម្លៃនៃថាមពលចាប់ពីចុងឆ្នាំ ២០២១ ដល់ដើមឆ្នាំ ២០២៤ ........ ៤០

ក្រាហ្វិកទី១០៖ អត្រាអតិផរណាសកល ចាប់ពីឆ្នាំ ២០១៩ ដល់ ឆ្នាំ២០២៤ ........ ៤១

ក្រាហ្វិកទី១១៖ បង្ហាញពីការនាំចេញ ICT សរុបក្នុងឆ្នាំ ២០១៨ ........ ៤៩

ក្រាហ្វិកទី១២៖ បង្ហាញពីផលិតកម្មយានយន្តសរុបក្នុងឆ្នាំ ២០១៨ ........ ៤៩

ក្រាហ្វិកទី១៣៖ កំណើន ផ.ស.ស. របស់ប៉ាឡេស្ទីនចាប់ពីត្រីមាសទី ៣ក្នុងឆ្នាំ ២០១៣ ដល់ឆ្នាំ ២០២៣..... ៥៥

ក្រាហ្វិកទី១៤ ៖ បង្ហាញពីអត្រាការប្រាក់ក្នុងប្រទេសអភិវឌ្ឍន៍ចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៤ ........ ៥៩

រូបភាព៖ បង្ហាញពីនិន្នាការនៃការប្រែប្រួលសីតុណ្ហភាពចាប់ពីឆ្នាំ ១៩០១ ដល់ឆ្នាំ ២០២៣ ........ ៦០

ក្រាហ្វិកទី១៥ ៖ បង្ហាញពីកម្រិតសីតុណ្ហភាពចាប់ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ២០២២ ........ ៦១

ក្រាហ្វិកទី១៦ ៖ បង្ហាញពីនិន្នាការកំណើនសេដ្ឋកិច្ចសកលចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៤ ........ ៦៤

ក្រាហ្វិកទី១៨៖ តម្លៃអគ្គិសនីសម្រាប់បំភ្លឺលំនៅដ្ឋាននៅតាមបណ្តាប្រទេសអាស៊ានឆ្នាំ ២០២៤ ........ ៦៩

ក្រាហ្វិកទី១៩៖ បង្ហាញពីការស្ទង់មតិរបស់សហគ្រាសក្នុងតំបន់នៅឆ្នាំ ២០២៣ ........ ៧០

ក្រាហ្វិកទី២០ ៖ បង្ហាញពីការស្ទង់មតិរបស់សហគ្រាសកម្ពុជាក្នុងឆ្នាំ ២០១៣, ២០១៦ និង ២០២៣........ ៧២

ក្រាហ្វិកទី២១ ៖ ការប្រៀបធៀបផលិតភាពកម្លាំងពលកម្មរបស់ប្រទេសមួយចំនួន ........ ៧៤

ក្រាហ្វិកទី២២ ៖ បង្ហាញពីកម្រិតជំនាញរបស់កម្លាំងពលកម្មក្នុងប្រទេសកម្ពុជា ........ ៧៥

ក្រាហ្វិកទី២៣៖ បង្ហាញពីចំណែកនៃGDP in PPP រវាងក្រុមប្រទេស BRICS និងលោកខាងលិច.............៧៩

# បញ្ជីតារាង

តារាងទី១ ៖ បង្ហាញពីសូចនាករសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៤ (ព្យាករណ៍) ........................ ២១

តារាងទី២៖ ទស្សនវិស័យសេដ្ឋកិច្ចតាមវិស័យឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៧ ............................................. ២៣

តារាងទី៣៖ គោលការណ៍ក្នុងការចាត់ថ្នាក់ប្រទេសរបស់ធនាគារពិភពលោកក្នុងឆ្នាំ ២០២៣-២០២៤ ......... ២៥

តារាងទី៤ ៖ បង្ហាញពីទំហំ GDP, FDI, Export និង Import ក្នុងប្រទេសកម្ពុជា....................................... ៨៥

# បញ្ជីអក្សរកាត់

- BRI៖ Belt and Road Initiative គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ
- FAO៖ Food and Agriculture Organization អង្គការចំណីអាហារ និងកសិកម្ម
- FDI៖ Foreign Direct Investment ការវិនិយោគផ្ទាល់ពីបរទេស
- GDP៖ Gross Domestic Product ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)
- GDP per capita៖ ផលិតផលក្នុងស្រុកសរុបក្នុងពលរដ្ឋម្នាក់
- GNI៖ Gross National Income ចំណូលជាតិសរុប (ច.ជ.ស.)
- GNI per capita៖ ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់
- HDI៖ Human Development Index សន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស
- ICT ៖ Information and communication technology goods ទំនិញបច្ចេកវិជ្ជាព័ត៌មាន និងទំនាក់ទំនង
- IMF៖ International Monetary Fund មូលនិធិរូបិយវត្ថុអន្តរជាតិ
- IPEF៖ Indo-Pacific Economic Framework ក្របខណ្ឌសេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិច
- NATO៖ North Atlantic Treaty Organization អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង
- QUAD៖ Quadrilateral Security Dialogue បក្សសម្ព័ន្ធចតុភាគី
- RCEP៖ Regional Comprehensive Economic Partnership ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់
- SDGS៖ Sustainable Development Goals គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- SMEs៖ សហគ្រាសធុនតូច និងមធ្យម
- TFO៖ ការិយាល័យទទួលបន្ទុកកិច្ចសម្រួលពាណិជ្ជកម្ម
- UNDP៖ United Nations Developing program កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ
- WB៖ World Bank ធនាគារពិភពលោក
- WTO៖ World Trade Organization អង្គការពាណិជ្ជកម្មអន្តរជាតិ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. សាវតានៃការសិក្សា

ក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងមកនេះ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចដ៏រឹងមាំប្រកបដោយចីរភាពក្នុងអត្រាជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ ដែលនាំឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥ ដោយមានទំហំផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) កើនឡើងប្រមាណ ១០ ដង ពីទំហំទឹកប្រាក់ ៣,១១ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ ១៩៩៨ ដល់ប្រមាណ ២៩,៦០ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ ២០២២។ ជាមួយគ្នានេះ ផ.ស.ស. សម្រាប់មនុស្សម្នាក់បានកើនឡើងរហូតដល់ ៧ ដង ពីរង្វង់ ២៥៣ ដុល្លារអាមេរិកក្នុងឆ្នាំ ១៩៩៨ ដល់ ១ ៧៨៤ ដុល្លារអាមេរិកក្នុងឆ្នាំ ២០២២ ហើយអត្រាភាពក្រីក្រធ្លាក់ចុះនៅក្រោម ១០% នៅមុនវិបត្តិជំងឺកូវីដ-១៩ និងគម្លាតវិសមភាពសង្គមកាន់តែរួមតូច ក្នុងនោះដែរ រចនាសម្ព័ន្ធសេដ្ឋកិច្ចបានផ្លាស់ប្តូរពីសេដ្ឋកិច្ចពឹងផ្អែកជាចម្បងលើកសិកម្មប្រពៃណីទៅជាសេដ្ឋកិច្ចពឹងលើឧស្សាហកម្ម និងសេវាកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ជាងមុន។

ជាមួយនឹងកំណើនខ្ពស់ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច កម្ពុជាបានដាក់ចេញនូវមហិច្ឆតារបស់ខ្លួននៅក្នុងដំណើរអភិវឌ្ឍន៍វែងឆ្ងាយគឺការប្រែក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០។[1] ដើម្បីសម្រេចបានចក្ខុវិស័យខាងលើ រាជរដ្ឋាភិបាលនីតិកាលទី៧ បានដាក់ចេញនូវ *"**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១**"* ក្នុងគោលដៅកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការបន្តដំណើរឈានទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ដោយក្នុងនោះរាជរដ្ឋាភិបាលបានកំណត់គោលដៅយុទ្ធសាស្ត្រធានាឱ្យបានកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយភាពធន់នឹងវិបត្តិនានាតាមរយៈការជម្រុញសន្ទុះនៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដើម្បីបង្កើតចន្ទល់ថ្មីនៃកំណើនសេដ្ឋកិច្ច ការលើកកម្ពស់ភាពប្រកួតប្រជែង និងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប ធានាស្ថិរភាពអត្រាប្តូរប្រាក់ ខិតខំបង្កើនទុនបម្រុងជាប្រចាំ និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមបញ្ចូលទាំងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព។[2] ប៉ុន្តែចាប់តាំងពីឆ្នាំ ២០២០មក កម្ពុជាក៏ដូចជាប្រទេសផ្សេងទៀតទូទាំងពិភពលោក បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩ ដែលជាវិបត្តិសុខភាពសកលដ៏កាចសាហាវបំផុត ដែលនាំឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមាន ៣,១% ក្នុងឆ្នាំ ២០២០។ យ៉ាងណាមិញ កម្ពុជាបានយកឈ្នះលើសមរភូមិនៃវិបត្តិជំងឺកូវីដ-១៩ នេះ ដែលឈានទៅរកការបើកប្រទេសឡើងវិញនាចុងឆ្នាំ ២០២១ ជាមួយនឹងកំណើនយឺតត្រឹម ៣,០% មុននឹងងើបឡើងយ៉ាងឆាប់រហ័សដោយសម្រេចបានកំណើនសេដ្ឋកិច្ច ៥.២% ក្នុងឆ្នាំ២០២២និងបន្តកើនឡើងបន្ថែមក្នុងអត្រាប្រមាណ ៥.៦% ក្នុងឆ្នាំ ២០២៣។ ទន្ទឹមនឹងនេះ បើតាមការព្យាករណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[1] អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស, *"សុន្ទរកថារបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ថ្លែងក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣," វិច្ឆិកា ២៣, ២០២៣,* https://pressocm.gov.kh/archives/89000

[2] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១*, ២០២៣, ទំព័រទី៣០

ក្នុងឆ្នាំ ២០២៤ កម្ពុជានឹងមានកំណើនសេដ្ឋកិច្ចប្រហែល ៦.៦%។[3] ទោះជាយ៉ាងនេះក្តី តាមរយៈតួលេខនៃអត្រាកំណើនចាប់ពីឆ្នាំ ២០២០ ដល់ ឆ្នាំ ២០២៤ ខាងលើនេះ កម្ពុជាហាក់នៅមានភាពស្រពិចស្រពិលក្នុងការសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ ដោយហេតុថាអត្រាកំណើនទាំងនោះស្ថិតក្នុងកម្រិតទាបនៅឡើយ បើធៀបនឹងអត្រាកំណើនមុនវិបត្តិជំងឺកូវីដ-១៩។

## ២. កម្មវត្ថុនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើកម្មវត្ថុមួយចំនួនរួមមាន៖

- សិក្សាស្វែងយល់អំពីម៉ូដែលនៃការអភិវឌ្ឍ និងការធ្វើចំណាត់ថ្នាក់ប្រទេសរបស់អង្គការ ស្ថាប័នសំខាន់ៗ
- សិក្សាស្វែងយល់អំពីស្ថានភាព និងចក្ខុវិស័យសេដ្ឋកិច្ចកម្ពុជា
- សិក្សាស្វែងយល់អំពីឧបសគ្គ និងបញ្ហាប្រឈម ដែលកម្ពុជាជួបប្រទះ
- ការវិភាគទិន្នន័យតាមម៉ូដែល និងការព្យាករណ៍ទៅលើលទ្ធភាពសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០
- សិក្សាស្វែងយល់អំពីដំណោះស្រាយ និងការត្រៀមខ្លួនទុកជាមុន។

## ៣. ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ សេដ្ឋកិច្ចកម្ពុជាកំពុងងើបឡើងវិញ និងត្រឡប់ទៅរកភាពប្រក្រតីក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ ទោះជាយ៉ាងនេះក្តី កម្ពុជា ក៏ដូចជាបណ្តាប្រទេសផ្សេងទៀតលើសកលលោកកំពុងត្រូវបានហ៊ុមព័ទ្ធទៅដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ពីកត្តាខាងក្រៅធំៗ ដែលជានិន្នាការសកលរួមមាន ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងពាណិជ្ជកម្ម ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ ការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន សង្គ្រាមអ៊ីស្រាអែល-ហាម៉ាស និងការប្រែប្រួលអាកាសធាតុជាដើម និងបញ្ហាប្រឈមជារចនាសម្ព័ន្ធផ្ទៃក្នុងប្រទេសមួយចំនួនទៀត។ ហានិភ័យ និងបញ្ហាប្រឈមទាំងនេះបាននឹងកំពុងបង្កផលប៉ះពាល់មកលើពាណិជ្ជកម្មអន្តរជាតិ និងលំហូរនៃការវិនិយោគមកកម្ពុជា ដែលអាចរារាំងដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាអាចប៉ះទង្គិចដល់គន្លងនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។[4]

អាស្រ័យដូចបានរៀបរាប់ខាងលើ វាមានភាពចាំបាច់ណាស់ក្នុងការសិក្សាស្វែងយល់បន្ថែមអំពីឧបសគ្គ និងបញ្ហាដែលកម្ពុជាបានជួបប្រទះ និងប្រឈមនាពេលខាងមុខ ដែលរារាំងពាំងដំណើរកម្ពុជាក្នុងការឈានទៅសម្រេចគោលដៅឆ្នាំ ២០៣០ ដោយវាជាមធ្យោបាយមួយក្នុងការឈានទៅរកដំណោះស្រាយ ក៏ដូចជាការដាក់ចេញផែនការយុទ្ធសាស្ត្រជាបន្តបន្ទាប់ទៀត។ ហេតុដូចនេះហើយទើបមានប្រធានបទមួយបានលើកឡើងថា **“តើប្រទេសកម្ពុជាជួបប្រទះនូវឧបសគ្គ និងបញ្ហាប្រឈមអ្វីខ្លះក្នុងការសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០?”**

---

[3] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ថវិកាសង្ខេបឆ្នាំ ២០២៣*, ២០២២, ក្នុងជំពូកទី២ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច

[4] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ថវិកាសង្ខេបឆ្នាំ ២០២៤*, ២០២៣, ទំព័រទី២-៣

## ៤. វិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងរបាយការណ៍កិច្ចការស្រាវជ្រាវនេះ យើងនឹងធ្វើការសិក្សាជាលម្អិតអំពីបញ្ហាក្នុង និងក្រៅប្រទេស ដែលកម្ពុជាបានជួបប្រទះ និងប្រឈមនាពេលអនាគត ដែលផ្តោតទៅលើការសិក្សាក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច កម្ពុជាចាប់ពីសម័យសង្គមរាស្ត្រនិយម រហូតដល់ឆ្នាំ ២០២៤។ ជាមួយគ្នានេះដែរ យើងនឹងប្រើប្រាស់នូវអត្ថបទ ព័ត៌មាន និងឯកសារមួយចំនួនរបស់បណ្តាអង្គការ ស្ថាប័នកំពូលៗជុំវិញពិភពលោក ដែលមានដូចជាស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) អង្គការសហប្រជាជាតិ (UNDP) និងធនាគារពិភពលោក (World Bank) ជាដើម សម្រាប់ធ្វើការស្រាវជ្រាវក្នុងប្រធានបទ ហើយជាពិសេសក្នុងនោះដែរ យើងនឹងលើកយកនូវឯកសារសំខាន់ៗមួយចំនួននៃគោលនយោបាយរបស់រាជរដ្ឋាភិបាលមកធ្វើជាគោលគំនិតឱ្យស្របទៅតាមចក្ខុវិស័យរបស់ប្រទេសកម្ពុជា។ លើសពីនេះទៅទៀត យើងខ្ញុំក៏បានរួមបញ្ចូលការវិភាគម៉ូដែល ដោយប្រើប្រាស់ទិន្នន័យពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០២២ និងការព្យាករណ៍សេដ្ឋកិច្ចទៅថ្ងៃអនាគត។ ជាមួយគ្នានេះដែរ យើងបានលើកយកនូវដំណោះស្រាយ និងយុទ្ធសាស្ត្រមួយចំនួនរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងផ្តល់ជាអនុសាសន៍ដើម្បីឆ្លើយតបនូវចក្ខុវិស័យខាងលើផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

បន្ទាប់ពីបានសិក្សាអំពីប្រធានបទនេះ យើងនឹងបានស្វែងយល់កាន់តែច្បាស់អំពីការបែងចែក និងការធ្វើចំណាត់ថ្នាក់ប្រទេសរបស់អង្គការ និងដៃគូអភិវឌ្ឍន៍សេដ្ឋកិច្ចសំខាន់ៗទៅតាមលក្ខន្តិកៈ និងឋានានុក្រម ដើម្បីប្រើប្រាស់ក្នុងគោលលបំណងផ្សេងៗគ្នា។ ម្យ៉ាងវិញទៀត យើងនឹងយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាពីអតីតកាល បច្ចុប្បន្ន និងការព្យាករណ៍និន្នាការសេដ្ឋកិច្ចកម្ពុជានាពេលខាងមុខ ជាពិសេស ឧបសគ្គដែលកម្ពុជាបាន និងកំពុងជួបប្រទះ ក៏ដូចជាបញ្ហាប្រឈមដែលអាចនឹងកើតឡើងនាពេលខាងមុខក្នុងមាគ៌ាឆ្ពោះទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ដែលជាចក្ខុវិស័យដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជាក្នុងដំណើរលើកកម្ពស់ជីវភាព និងបង្កើនប្រាក់ចំណូលប្រជាជនកម្ពុជា។ ក្នុងនោះដែរ ការសិក្សាស្រាវជ្រាវនេះក៏បានរួមបញ្ចូលដំណោះស្រាយ និងផែនការយុទ្ធសាស្ត្រផ្សេងៗរបស់រាជរដ្ឋាភិបាលក្នុងការជម្រុញចក្ខុវិស័យខាងលើឱ្យសម្រេចបានទៅដោយរលូនតាមការគ្រោងទុក។ ឯកសារនេះក៏អាចក្លាយជាឧត្តមប្រយោជន៍មួយយ៉ាងប្រសើរសម្រាប់សង្គមជាតិ ជាពិសេសចូលរួមផ្សព្វផ្សាយជាសារដាស់តឿន ពញ្ញាក់ស្មារតីដល់យុវជនយុវនារីខ្មែរទាំងអស់ក្នុងការអភិវឌ្ឍខ្លួន បង្កើនចំណេះជំនាញបន្ថែមក្នុងនាមជាចលករដ៏សំខាន់ក្នុងដំណើរជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជា។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះក៏អាចក្លាយជាប្រភពព័ត៌មាន និងឯកសារយោងចម្បងមួយដល់អ្នកស្រាវជ្រាវយកទៅប្រើប្រាស់ និងធ្វើជាមូលដ្ឋានក្នុងការសិក្សាអំពីបញ្ហា និងដំណោះស្រាយនេះបន្ថែមទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសិក្សាអំពីប្រធានបទទាក់ទងនឹងឧបសគ្គ និងបញ្ហាប្រឈមក្នុងការសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ ឱ្យកាន់តែក្បោះក្បាយ និងស៊ីជម្រៅ យើងបានប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវតាមបែបវិធីសាស្ត្រគុណវិស័យ (Qualitative Method) ដោយបានលើកយកនូវទ្រឹស្តីពាក់ព័ន្ធ គំរូសេដ្ឋកិច្ច និងគោលការណ៍មួយចំនួនមកធ្វើជាអំណះអំណាងក្នុងការសិក្សា ហើយជាពិសេសបានបង្ហាញពីសន្ទរកថា និងខ្លឹមសារនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ព្រមទាំងបានដកស្រង់ចេញពីអត្ថបទព័ត៌មានជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងឧបសគ្គ បញ្ហាប្រឈម និងដំណោះស្រាយ។

ក្រៅពីវិធីសាស្ត្រនេះ ការសិក្សាស្រាវជ្រាវក៏បានបញ្ចូល និងបំពេញបន្ថែមនូវវិធីសាស្ត្របរិមាណវិស័យ (Quantitative Method) ដោយបានប្រើប្រាស់នូវប្រភពទិន្នន័យទី២ (Secondary Data) ក្នុងការពិពណ៌នាពីទិន្នន័យ និងក្រាហ្វិកក្នុង និងក្រៅប្រទេស ឱ្យស្របទៅតាមទិដ្ឋភាពជាក់ស្តែងក្នុងចំណុចនីមួយៗដើម្បីជាទឡ្ហីករណ៍ក្នុងការគាំទ្រដល់ការស្រាវជ្រាវ។ ជាមួយគ្នានេះ យើងក៏បានជ្រើសរើសបង្កើតនូវម៉ូដែលមួយក្នុងការសិក្សា និងវិភាគពីទំនាក់ទំនងនៃអថេរមួយចំនួនតាមរយៈការវិភាគតាមបែប Multiple Regression Linear ហើយបានភ្ជាប់ជាមួយនឹងការបកស្រាយលទ្ធផលនៃការវិភាគនោះផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងរបាយការណ៍នៃការសិក្សានៃប្រធានបទខាងលើនេះបានបែងចែកជា ៦ ផ្នែកធំៗ ដោយផ្នែកដំបូងនៃប្រធានបទគឺជា សេចក្តីផ្តើម ដែលនៅក្នុងផ្នែកនេះនឹងបង្ហាញពីសារៈតានៃការសិក្សា កម្មវត្ថុ ចំណោទបញ្ហាសារៈសំខាន់ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

- **ជំពូកទី១ ការរំលឹកទ្រឹស្តីទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច**

ក្នុងជំពូកដំបូងនេះ យើងនឹងធ្វើការរំលឹកឡើងវិញនូវទ្រឹស្តីដែលពាក់ព័ន្ធជុំវិញនឹងនិយមន័យសេដ្ឋកិច្ច ក្របខណ្ឌមីក្រូសេដ្ឋកិច្ច ម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយរូបិយវត្ថុ គោលនយោបាយសារពើពន្ធ ផលិតផលក្នុងស្រុកសរុប (GDP) ប្រាក់ចំណូលជាតិសរុប (GNI) ទ្រឹស្តីម៉ូដែលសត្វក្ងានហោះ ទ្រឹស្តីម៉ូដែលនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ សារៈតានៃការធ្វើចំណាត់ថ្នាក់ប្រទេស មូលដ្ឋាននៃការចាត់ថ្នាក់ប្រទេសរបស់ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងអង្គការUNICEF និងគោលការណ៍នៃការចាត់ថ្នាក់ប្រទេសរបស់ធនាគារពិភពលោក។

- **ជំពូកទី២ ស្ថានភាព និងចក្ខុវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា**

ក្នុងជំពូកទី២ យើងនឹងសិក្សាអំពីប្រវត្តិសេដ្ឋកិច្ចកម្ពុជាចាប់តាំងពីការទទួលបានឯករាជ្យពីបារាំងក្នុងឆ្នាំ ១៩៤៩ ដំណាក់កាលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ការផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ច ការផ្លាស់ប្តូររចនាសម្ព័ន្ធ និង

ការវិវត្តឧស្សាហូបនីយកម្មរបស់កម្ពុជាតាមម៉ូដែលសត្វក្ងានហោះ ស្ថានភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន និងនាពេលអនាគត ក៏ដូចជាចក្ខុវិស័យនានាក្នុងសេដ្ឋកិច្ចកម្ពុជាផងដែរ។

- **ជំពូកទី៣ ឧបសគ្គ និងបញ្ហាប្រឈមក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០**

ការសិក្សានឹងផ្តោតទៅលើឧបសគ្គ និងបញ្ហាប្រឈមដែលកើតមានទាំងក្នុង និងក្រៅប្រទេសដែលយាយីមកកាន់សេដ្ឋកិច្ចកម្ពុជា រារាំងដំណើរក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងភ្ជាប់មកជាមួយនឹងដំណោះស្រាយមួយចំនួន ដែលអាចប្រើប្រាស់បានដើម្បីទប់ទល់បញ្ហានាពេលបច្ចុប្បន្ន និងបង្ការបញ្ហាប្រឈមនាពេលខាងមុខ។

- **ជំពូកទី៤ ការវិភាគ និងបកស្រាយទិន្នន័យ**

នៅក្នុងជំពូកចុងក្រោយនេះនឹងបង្ហាញពីការសិក្សាទំនាក់ទំនងរវាងអថេរមួយចំនួន ដែលមានភាពជាប់ពាក់ព័ន្ធគ្នាជាមួយនឹងការជម្រុញនូវកំណើនសេដ្ឋកិច្ចកម្ពុជា ដោយផ្សារភ្ជាប់នឹងការវិភាគទិន្នន័យ និងបកស្រាយលទ្ធផលនៃមេគុណអថេរនីមួយៗ ដែលទទួលបានក្រោយការធ្វើវិភាគ។ ជាមួយគ្នានេះ យើងក៏បានធ្វើការព្យាករណ៍ទៅលើលទ្ធភាពសម្រេចបាននៃចក្ខុវិស័យឆ្នាំ ២០៣០ របស់កម្ពុជាផងដែរ។ លើសពីនេះទៅទៀត យើងក៏បានដាក់បញ្ចូល និងបង្ហាញនូវដំណោះស្រាយក្នុងការឆ្លើយតបទៅនឹងឧបសគ្គ និងបញ្ហាប្រឈមមួយចំនួន ដែលកម្ពុជាជួបប្រទះនាពេលបច្ចុប្បន្ន និងអនាគត។

នៅក្នុងផ្នែកចុងបញ្ចប់នៃរបាយការណ៍សិក្សានេះ ការសិក្សាស្រាវជ្រាវនឹងផ្តល់ជាសេចក្តីសន្និដ្ឋាន ដោយធ្វើការសំយោគ និងបូកបញ្ចូលគោលគំនិតរួមចុងក្រោយមួយទៅលើប្រធាន ដែលបានសិក្សា និងវិភាគ ហើយជាពិសេសថែមទាំងបានផ្សារភ្ជាប់ជាមួយនឹងការផ្តល់អនុសាសន៍តាមរយៈការផ្តល់ជាមតិយោបល់ និងការយល់ឃើញទៅលើឧបសគ្គ និងបញ្ហាប្រឈមនានាក្នុងគោលដៅឆ្លើយតបទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវ។

# ជំពូកទី ១
# ការរំលឹកទ្រឹស្តី

# ជំពូកទី ១
# ការរំលឹកទ្រឹស្តី

## ១.១. ទ្រឹស្តីជាមូលដ្ឋាននៃសេដ្ឋកិច្ច

### ១.១.១. និយមន័យសេដ្ឋកិច្ច

និយមន័យសេដ្ឋកិច្ចមានច្រើនខុសៗគ្នាអាស្រ័យទៅតាមការលើកឡើងរបស់សេដ្ឋវិទូផ្សេងៗ ដែលជារួមអត្ថន័យទូទៅនៃសេដ្ឋកិច្ច ដែលមានមនុស្សជាច្រើនបានប្រើប្រាស់វាក្នុងការពន្យល់ និងបកស្រាយទៅលើការគ្រប់គ្រង និងការបែងចែកធនធានកម្រ ដែលធ្វើឡើង និងសម្រេចចិត្តដោយបុគ្គល អាជីវកម្ម និងរដ្ឋាភិបាលក្នុងការផលិតជាទំនិញ និងសេវាកម្មដើម្បីបំពេញចំណង់គ្មានព្រំដែនរបស់មនុស្ស ជាពិសេសប្រើប្រាស់ និងចែកចាយធនធានទាំងនោះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។[5]

### ១.១.២. ក្របខណ្ឌមីក្រូសេដ្ឋកិច្ច

មីក្រូសេដ្ឋកិច្ច (Microeconomics) ជាផ្នែកមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលសិក្សាអំពីឥរិយាបថរបស់បុគ្គល ក្រុមហ៊ុន ឬស្ថាប័នដែលពាក់ព័ន្ធទៅនឹងជម្រើស និងការសម្រេចចិត្តក្នុងការឆ្លើយតបនឹងថ្លៃទំនិញ និងតម្រូវការក្នុងទីផ្សារ ហើយវាក៏ពិនិត្យពីរបៀប ដែលអង្គភាពទាំងនោះធ្វើអន្តរកម្មនៅក្នុងទីផ្សារដើម្បីបែងចែកធនធាន និងចែកចាយទំនិញ និងសេវាកម្ម ដោយគោលគំនិតជាមូលដ្ឋានទាក់ទងផ្ទាល់នឹងច្បាប់តម្រូវការ-ផ្គត់ផ្គង់ ដែលពាក់ព័ន្ធជាមួយនឹងការកំណត់តម្លៃផលិតផល ថ្លៃដើមកត្តាផលិតកម្ម ប្រាក់ចំណេញ ការប្រកួតប្រជែងលើទីផ្សារ និងរចនាសម្ព័ន្ធទីផ្សារ។

**ក្រាហ្វិកទី១៖ បង្ហាញពីច្បាប់តម្រូវការ និងការផ្គត់ផ្គង់**




(រូបភាពទី ១)




(រូបភាពទី ២)

ប្រភព៖ Economicshelp[6]

[5] Mamidi Long, *Macroeconomics First Edition,* (ភ្នំពេញ, ២០២០)

[6] Tejvan Pettinger, "Diagrams for Supply and Demand," 2019, https://www.economicshelp.org/blog/1811/markets/diagrams-for-supply-and-demand/

តាមរយៈក្រាហ្វិកនៃរូបភាពទី ១ ខាងលើ វាបានបកស្រាយថា នៅពេលដែលខ្សែកោងតម្រូវការ $D_1$ រំកិលទៅខាងស្តាំដល់ខ្សែកោងតម្រូវការ $D_2$ នោះបង្ហាញពីបរិមាណតម្រូវការលើទំនិញ និងសេវាកម្មកើនឡើងនៅក្នុងទីផ្សារ ស្របពេលដែលខ្សែកោងផ្គត់ផ្គង់ $S_1$ ផ្លាស់ប្តូរទៅខាងឆ្វេងដល់ខ្សែកោងផ្គត់ផ្គង់ $S_2$ នោះវាក៏បង្ហាញពីបរិមាណផ្គត់ផ្គង់ថយចុះផងដែរ ដោយការប្រែប្រួលនៃខ្សែកោងទាំងពីរនេះនឹងធ្វើឱ្យតម្លៃទំនិញ និងសេវាកម្មនៅក្នុងទីផ្សារកើនឡើងពីថ្លៃ $P_1$ ទៅថ្លៃ $P_2$ ហើយវាក៏បាននាំឱ្យបរិមាណនៅក្នុងទីផ្សារថយចុះពីបរិមាណ $Q_1$ មក បរិមាណ$Q_2$ ។ ផ្ទុយទៅវិញ បើមើលក្នុងរូបភាពទី ២ នៅពេលដែលខ្សែកោងតម្រូវការ $D_1$ រំកិលទៅខាងឆ្វេងដល់ខ្សែកោងតម្រូវការ $D_2$ ខណៈខ្សែកោងផ្គត់ផ្គង់ $S_1$ ផ្លាស់ប្តូរទៅខាងស្តាំដល់ខ្សែកោងផ្គត់ផ្គង់ $S_2$ នោះវានឹងនាំឱ្យថ្លៃនៅលើទីផ្សារធ្លាក់ចុះពីថ្លៃ $P_1$ មកថ្លៃ $P_2$ ហើយបរិមាណនៅក្នុងទីផ្សារកើនឡើងពីបរិមាណ $Q_1$ ទៅ $Q_2$។

### ១.១.៣. ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច

ម៉ាក្រូសេដ្ឋកិច្ច (Macroeconomics) ក៏ជាសាខាមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលសិក្សាអំពីដំណើរការឥរិយាបថនៃប្រព័ន្ធសេដ្ឋកិច្ចជាតិទាំងមូល ដោយផ្តោតទៅលើចំណូលជាតិ កម្រិតថ្លៃទូទៅ ទីផ្សារការងារ និងប្រព័ន្ធរូបិយវត្ថុ។ វិសាលភាពក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច គឺពាក់ព័ន្ធនឹងរចនាសម្ព័ន្ធសេដ្ឋកិច្ច បញ្ហារួមរបស់សេដ្ឋកិច្ច និងការដាក់ចេញនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយក្នុងនោះគ្របដណ្តប់លើបញ្ហាអតិផរណា និកម្មភាព តម្រូវការរួម ការផ្គត់ផ្គង់រួម ការធ្វើពាណិជ្ជកម្មអន្តរជាតិ និងវដ្តសេដ្ឋកិច្ច។ នៅក្នុងក្របខណ្ឌនេះ វាមានវិសាលភាពធំក្នុងការគ្រប់គ្រង និងដោះស្រាយបញ្ហាប្រឈមនានាលើសេដ្ឋកិច្ចជាតិឱ្យមានប្រសិទ្ធភាពប្រកបដោយនិរន្តរភាព និងចីរភាព។[7]

### ១.១.៤. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

#### ១.១.៤.១. គោលនយោបាយរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុគឺសំដៅដល់ដំណើរការ ដែលធនាគារកណ្តាលរបស់ប្រទេសមួយប្រើប្រាស់និងដាក់ចេញនូវគោលនយោបាយ ដើម្បីគ្រប់គ្រងការផ្គត់ផ្គង់លុយនៅក្នុងទីផ្សារទាំងមូលក្នុងគោលបំណងគ្រប់គ្រងកម្រិតអត្រាអតិផរណា និងអត្រាការប្រាក់ក្នុងទិសដៅរក្សាស្ថិរភាពថ្លៃ បង្កើតឱកាសការងារ និងជម្រុញកំណើនសេដ្ឋកិច្ចជាតិ។ ធនាគារកណ្តាលមានតួនាទីក្នុងការកំណត់អត្រាការប្រាក់ (Interest Rate) កែសម្រួលទុនបម្រុងកាតព្វកិច្ច (Reserve Requirements) និងធ្វើប្រតិបត្តិការទីផ្សារបើកចំហរ (Open Market-Operations) នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ ជាទូទៅ ការដាក់ចេញនូវគោលនយោបាយរូបិយវត្ថុមានពីរប្រភេទគឺ៖

- គោលនយោបាយរូបិយវត្ថុពង្រីក (Expansionary Monetary Policy)៖ សំដៅលើការបង្កើនបរិមាណផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងទីផ្សារ។ វាបានប្រើដោយធនាគារកណ្តាលដើម្បីចៀសវាងវិបត្តិសេដ្ឋកិច្ច និងគ្រប់គ្រងភាពគ្មានការងារធ្វើ។ ធនាគារផ្តល់នូវប្រាក់កម្ចីកាន់តែមានតម្លៃសមរម្យ និងកំណត់អត្រាការ-

[7] Mamidi Long, *Macroeconomics First Edition,* (ភ្នំពេញ, ២០២០)

ប្រាក់ទាប ហើយអាជីវកម្មអាចខ្ចីប្រាក់បន្ថែមបានច្រើនដើម្បីចំណាយលើបុគ្គលិក ពង្រីកការចំណាយ និងទិញសម្ភារៈផ្សេងៗ។

- គោលនយោបាយរូបិយវត្ថុបង្រួម (Contractionary Monetary Policy) ៖ សំដៅលើការបន្ថយបរិមាណការផ្គត់ផ្គង់រូបិយវត្ថុ។ វាបានប្រើដោយធនាគារកណ្តាលដើម្បីគ្រប់គ្រងអតិផរណា។ គោលនយោបាយនេះ កំណត់បរិមាណរូបិយវត្ថុដែលអាចខ្ចីដោយធនាគារដើម្បីគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ។ ជាលទ្ធផលធនាគារផ្តល់នូវប្រាក់កម្ចីកាន់តែថ្លៃជាងមុន ដោយគិតអត្រាការប្រាក់កាន់តែខ្ពស់ជាង។ នេះអាចត្រូវបានធ្វើដោយការបង្កើនអត្រាការប្រាក់លើការលក់ មូលបត្របំណុលរដ្ឋាភិបាល ឬបង្កើនទុនបម្រុងកាតព្វកិច្ច។ គោលនយោបាយនេះប្រើនៅពេលរដ្ឋាភិបាលចង់គ្រប់គ្រងកម្រិតអតិផរណា។[8]

#### ១.១.៤.២. គោលនយោបាយសារពើពន្ធ

គោលនយោបាយសារពើពន្ធ គឺជាការប្រើប្រាស់ចំណាយ និងការប្រមូលចំណូលពន្ធរបស់រដ្ឋាភិបាលនៃប្រទេសមួយ ដែលមានឥទ្ធិពលលើសេដ្ឋកិច្ចជាតិ។ ជាធម្មតា រដ្ឋាភិបាលប្រើប្រាស់គោលនយោបាយសារពើពន្ធនេះ ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងចីរភាពព្រមទាំងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។ គោលនយោបាយនេះមានប្រភពចេញពីទ្រឹស្តីសេដ្ឋកិច្ច Keynesian ដែលក្នុងនោះលោក Keynes បានបង្ហាញថា រដ្ឋាភិបាលអាចមានឥទ្ធិពលទៅលើកម្រិតផលិតភាពរបស់សេដ្ឋកិច្ចជាតិតាមរយៈការបង្កើន ឬបន្ថយអត្រាពន្ធ និងការចំណាយសាធារណៈ។ រដ្ឋាភិបាលធ្វើការគ្រប់គ្រងគោលនយោបាយនេះតាមរយៈវិសាលភាព ឬសមាសភាពនៃការចំណាយ និងការផ្លាស់ប្តូរកម្រិត ឬប្រភេទនៃពន្ធក្នុងគោលដៅដោះស្រាយនូវបញ្ហាផ្សេងៗនៅក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ជាពិសេសធ្វើឱ្យមានតុល្យភាពថវិកាជាតិដើម្បីជម្រុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។[9]

### ១.១.៥. ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី

ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី គឺជាប្រព័ន្ធសេដ្ឋកិច្ចដែលធនធានសេដ្ឋកិច្ច ឬកត្តាផលិតកម្មមួយភាគធំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភ្នាក់ងារឯកជនមាននីតិបុគ្គល និងរូបវន្តបុគ្គល ។ ចំពោះយន្តការគ្រប់គ្រង និងសម្របសម្រួលក្នុងសេដ្ឋកិច្ច គឺអាស្រ័យទៅនឹងយន្តការទីផ្សារ។ មានន័យថារាល់ការសម្រេចចិត្តសំខាន់ៗរបស់ភ្នាក់ងារឯកជនក្នុងសេដ្ឋកិច្ច ដូចជាត្រូវផលិតអ្វី? ផលិតយ៉ាងដូចម្តេច ? និង ផលិតសំរាប់អ្នកណា ? ត្រូវបានកំណត់តាមរយៈទីផ្សារក្រោមឥទ្ធិពលនៃកម្លាំងពីរគឺកម្លាំងផ្គត់ផ្គង់ និងកម្លាំងតម្រូវការ។ រដ្ឋមានតួនាទីសម្របសម្រួល

---

[8] *Senghong Thun, «តើគោលនយោបាយរូបិយវត្ថុជាអ្វី?,» Tmey Tmey News, តុលា ១២, ២០២៣,* https://thmeythmey.com/?page=detail&id=130758

[9] Leslie Kramer, *"Fiscal Policy," Investopedia,* August 29, 2023, https://www.investopedia.com/insights/what-is-fiscal-policy/

យន្តការទីផ្សារមួយចំនួនក្នុងប្រព័ន្ធសេដ្ឋកិច្ចនេះ ចំណែកឯអ្នកប្រើប្រាស់មានសិទ្ធិនៅក្នុងការចំណាយលុយរបស់ពួកគេទៅតាមបំណងរៀងខ្លួន ដោយអាចប្រើប្រាស់លុយរបស់គេដើម្បីទិញលក់ទំនិញ និងសេវាកម្ម ទៅតាមតម្រូវការ។ អ្នកផលិតធ្វើការសម្រេចចិត្តថាតើទ្រព្យ ឬសេវាកម្មអ្វី ដែលពួកគេត្រូវផលិត ផ្គត់ផ្គង់ទៅឱ្យទីផ្សារដើម្បីទទួលបានទិន្នផលច្រើនបំផុតតាមដែលអាចធ្វើបាន។

### ១.១.៦. ផលិតផលក្នុងស្រុកសរុប (GDP)

ផលិតផលក្នុងស្រុកសរុប ឬ Gross Domestic Product គឺជាតម្លៃដែលមានទម្រង់ជារូបិយវត្ថុនៃផលបូកតម្លៃទំនិញ ឬសេវាសម្រេច ដែលផលិតបាននៅក្នុងប្រទេសមួយនៅក្នុងកំឡុងពេលជាក់លាក់ណាមួយ។ គួរបញ្ជាក់ដែរថា ចំនួននេះគឺរាប់បញ្ចូលទាំងផលិតផល ដែលក្រុមហ៊ុនបរទេស ដែលមករកស៊ីនៅក្នុងប្រទេសនោះបានផលិតផងដែរ។ GDP ត្រូវបានគេបែកចែកជាពីរគឺ Real GDP ដោយគណនាប្រើថ្លៃទំនិញនៅឆ្នាំគោលដែលបានកំណត់។ ចំណែក Nominal GDP គឺប្រើថ្លៃទីផ្សារបច្ចុប្បន្នមកគណនា។

ជាទូទៅ គេអាចរកចំនួនផលិតផលក្នុងស្រុកនេះបាន តាមរយៈការគណនារកការចំណាយសរុប ដូចជាការចំណាយប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់ ការចំណាយលើការវិនិយោគ ការចំណាយរបស់រដ្ឋាភិបាល និងការនាំចេញសុទ្ធជាដើម។[10]

❖ រូបមន្តគណនារកផលិតផលក្នុងស្រុកសរុបៈ

$$GDP = C + I + G + (X - M)$$

ដែល GDP ជាផលិតផលក្នុងស្រុកសរុប, C ជាការប្រើប្រាស់, I ជាការវិនិយោគ,

G ជាការចំណាយរបស់រដ្ឋាភិបាល, X ជាទំហំនាំចេញ, M ជាទំហំនាំចូល

❖ រូបមន្តគណនាអត្រាកំណើនសេដ្ឋកិច្ចៈ

$$GDP\ Growth\ Rate = \frac{GDP_{(t+1)} - GDP_t}{GDP_t} \times 100$$

ដែល GDP Growth Rate: ជាអត្រាកំណើនផលិតផលក្នុងស្រុកសរុប

$GDP_t$: ជាផលិតផលក្នុងស្រុកសរុបនៅខណៈពេល t

$GDP_{(t+1)}$: ជាផលិតផលក្នុងស្រុកសរុបនៅខណៈពេល t+1

[10] Jason Fernando, *"Gross Domestic Product," Investopedia,* June 03, 2024, Gross Domestic Product (GDP) Formula and How to Use It (investopedia.com)

### ១.១.៧. ប្រាក់ចំណូលជាតិសរុប (GNI)

ចំណូលជាតិសរុបគឺជាសូចនាករដែលប្រើប្រាស់សម្រាប់វាស់ស្ទង់ពីចំណូល ដែលផលិតបានពីប្រភពជាតិសរុប វាមានលក្ខណៈជាកូនកាត់រវាង GDP និង GNP ព្រោះ GNI មានគោលបំណងចម្បងមួយសម្រាប់វាស់ស្ទង់ពីកម្រិតជីវភាពរបស់ប្រជាជននៃប្រទេសមួយបានច្បាស់និងពិតប្រាកដជាង GDP និង GNP ។ GNI រាប់បញ្ចូលចំណូលរបស់ប្រជាជនដែលទៅធ្វើការនៅក្រៅប្រទេសនិងផ្ញើលុយចូលស្រុកវិញ រាប់បញ្ចូលចំណូលរបស់ជនបរទេស ដែលចំណាយក្នុងស្រុកព្រោះគេគិតថាបើជនបរទេសចំណាយក្នុងស្រុកនឹងក្លាយជាចំណូលរបស់ប្រជាជនម្ចាស់ប្រទេស និង ចំណូលដែលប្រជាជនក្នុងប្រទេសរកបានក្នុងស្រុក។[11]

❖ រូបមន្តគណនាប្រាក់ចំណូលជាតិសរុប៖

GNI = GDP + (ចំណូលប្រភពជាតិពីក្រៅប្រទេសផ្ញើចូលស្រុក - ចំណូលជនបរទេសដែលរកបានក្នុងស្រុកផ្ញើចេញទៅក្រៅវិញ)

❖ រូបមន្តគណនាប្រាក់ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់៖

$$\text{GNI per Capita} = \frac{GNI}{\text{ចំនួនប្រជាជនសរុប}}$$

### ១.១.៨. វិធីសាស្ត្រ Atlas

វិធីសាស្ត្រ Atlas គឺជាវិធីមួយដើម្បីបំប្លែងប្រាក់ចំណូលជាតិសរុប (GNI) របស់ប្រទេសមួយពីរូបិយប័ណ្ណក្នុងស្រុករបស់ខ្លួនទៅជាដុល្លារអាមេរិក។ វិធីសាស្ត្រ Atlas ត្រូវបានប្រើដើម្បី៖

- ប្រៀបធៀបទំហំសេដ្ឋកិច្ចនៃប្រទេសផ្សេងៗគ្នា
- ចាត់ថ្នាក់ប្រទេសទៅជាក្រុមចំណូល (ទាប កណ្តាល ខ្ពស់)
- កំណត់សិទ្ធិទទួលបានប្រាក់កម្ចីពីស្ថាប័នអន្តរជាតិ។[12]

## ១.២. ទ្រឹស្តីម៉ូដែលនៃសត្វក្ងានហោះ (Flying Geese Model)

Flying Geese Model ឬម៉ូដែលសត្វក្ងានហោះ គឺជាគំរូនៃការអភិវឌ្ឍសេដ្ឋកិច្ច ដែលពន្យល់ពីរបៀបឧស្សាហូបនីយកម្ម និងកំណើនសេដ្ឋកិច្ចរីករាលដាលពាសពេញប្រទេស ដែលត្រូវបានបង្កើតឡើងដោយសេដ្ឋវិទូជប៉ុន Kaname Akamatsu ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០។ ម៉ូដែលនេះមានគោលគំនិតសំខាន់ៗដូចជា៖

- ឧស្សាហូបនីយកម្មតាមលំដាប់លំដោយ៖ គំរូនេះ ពិពណ៌នាអំពីគំរូដែលការអភិវឌ្ឍឧស្សាហកម្មកើតឡើងតាមលំដាប់លំដោយនៅទូទាំងប្រទេស ដែលការអភិវឌ្ឍនេះចាប់ផ្តើមជាមួយនឹងប្រទេសឈានមុខ

---

[11] CamboFinance, *"ភាពខុសគ្នានៃ GDP, GNI និង GNP,"* Facebook, ឧសភា ០៦, ២០២១

[12] *"What is the World Bank Atlas method?," World Bank, n.d,* [What is the World Bank Atlas method? – World Bank Data Help Desk]

គេមួយ (សត្វក្ងាននាំមុខ) ហើយត្រូវបានបន្តដោយប្រទេសផ្សេងទៀត (ក្ងានហោះតាម) ដែលចម្លងពីដំណើរការឧស្សាហូបនីយកម្ម បច្ចេកវិទ្យា ជំនាញ និងដើមទុនជាហូរហែរបន្តបន្ទាប់គ្នា។

- ដំណាក់កាលទាំងបីនៃការអភិវឌ្ឍន៍ឧស្សាហកម្ម៖
  - ដំណាក់កាលឧស្សាហូបនីយកម្មជំនួសការនាំចូល៖ ប្រទេសនេះចាប់ផ្តើមនាំចូលទំនិញមូលធនដើម្បីធ្វើការផលិតទំនិញប្រើប្រាស់ដែលធ្លាប់នាំចូលកន្លងមក សម្រាប់ផ្គត់ផ្គង់នៅក្នុងស្រុក។
  - ដំណាក់កាលឧស្សាហូបនីយកម្មសម្តៅដល់ការនាំចេញ៖ ប្រទេសនេះឈានទៅដល់ការផលិតដើម្បីធ្វើការនាំចេញទៅក្រៅប្រទេស និងចាប់ផ្តើមវិនិយោគទៅលើ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធអប់រំ និងបច្ចេកវិទ្យា ដើម្បីបង្កើនភាពប្រកួតប្រជែងនៅក្នុងទីផ្សារ។
  - ដំណាក់កាលនាំចេញ៖ ប្រទេសនេះចាប់ផ្តើមពង្រីកខ្សែចង្វាក់ផលិតកម្ម ដោយផ្តោតទៅលើទំនិញដែលមានតម្លៃបន្ថែមខ្ពស់ដល់កំណើនសេដ្ឋកិច្ច និងចាប់យកបច្ចេកវិទ្យាថ្មីៗ គាំទ្រដល់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ។[13] (យោងតាមឧបសម្ព័ន្ធទី១)

## ១.៣. ទ្រឹស្តីម៉ូដែលនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ (Structural Change Model)

គំរូនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ (Structural Change Model) គឺជាទ្រឹស្តីសេដ្ឋកិច្ចពន្យល់អំពីរបៀបដែលសេដ្ឋកិច្ចផ្លាស់ប្តូរតាមពេលវេលា ជាពិសេសនៅពេលដែលពួកគេអភិវឌ្ឍពីស្ថានភាពចំណូលទាបទៅជាស្ថានភាពចំណូលខ្ពស់។ គំរូនេះផ្តោតលើការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចនៃប្រទេសមួយ ជាធម្មតាពាក់ព័ន្ធនឹងការផ្លាស់ប្តូសក្តានុពលនៃវិស័យផ្សេងៗគ្នា ដូចជាកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម នៅពេលដែលប្រទេសមួយរីកចម្រើននាំឱ្យមានការកើនឡើងនៃផលិតភាពសេដ្ឋកិច្ច និងកម្រិតប្រាក់ចំណូល។ សេដ្ឋវិទូប្រើប្រាស់គំរូនេះ ដើម្បីវិភាគពីប្រវត្តិសេដ្ឋកិច្ចរបស់ប្រទេស និងព្យាករណ៍និន្នាការអភិវឌ្ឍនាពេលអនាគត និងគាំទ្រដល់ការសម្រេចចិត្តលើគោលនយោបាយឧស្សាហកម្ម កំណែទម្រង់ទីផ្សារការងារ និងការអប់រំ។ គំរូនេះច្រើនតែភ្ជាប់ទៅនឹងដំណាក់កាលនៃកំណើនសេដ្ឋកិច្ច ដែលប្រទេសនីមួយៗឆ្លងកាត់ដំណាក់កាលផ្សេងៗគ្នាពីការផ្តោតលើវិស័យកសិកម្ម រហូតដល់ឧស្សាហូបនីយកម្ម និងបន្តផ្លាស់ទៅវិស័យសេវាកម្ម។

- **កសិកម្មទៅកាន់ឧស្សាហកម្ម៖** ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ធនធាន និងកម្លាំងពលកម្មភាគច្រើនរបស់ប្រទេសមួយត្រូវបានប្រើប្រាស់ក្នុងវិស័យកសិកម្ម។ នៅពេលសេដ្ឋកិច្ចរីកចម្រើន មូលធនទាំងនោះផ្លាស់ប្តូរបន្តិចម្តងៗពីវិស័យកសិកម្មទៅជាសកម្មភាពផលិតកម្ម និងឧស្សាហកម្ម។
- **ឧស្សាហកម្មទៅសេវាកម្ម៖** ពេលដែលវិស័យឧស្សាហកម្មមានភាពចាស់ទុំ វាមានការផ្លាស់ប្តូរធនធានបន្ថែមទៀតពីវិស័យផលិតកម្មទៅវិស័យសេវាកម្ម ដែលនាំទៅសេដ្ឋកិច្ចជឿនលឿន។[14]

---

[13] Venkatachalam Anbuomozhi and Xianin Yao, *The Case of Flying Geese Model,* (ADB, October, 2017)

[14] John Stephen Agbenyo, *The Structural Change Theory,* (Faculty of Social Science, January, 2020)

## ១.៤. សាវតានៃការកំណត់ចំណាត់ថ្នាក់ប្រទេស

ចំណាត់ថ្នាក់ប្រទេសសំដៅលើការចាត់ថ្នាក់ប្រទេស ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យផ្សេងៗដូចជា ដំណើរការសកម្មភាពសេដ្ឋកិច្ច កម្រិតប្រាក់ចំណូល ស្ថានភាពអភិវឌ្ឍន៍ និងតំបន់ភូមិសាស្ត្រ។ ស្ថាប័នអន្តរជាតិ ដូចជា ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងអង្គការសហប្រជាជាតិ បានចាត់ថ្នាក់ប្រទេសទៅជា ប្រភេទផ្សេងៗគ្នា ដោយប្រើប្រាស់ចំណាត់ថ្នាក់ទាំងនេះដើម្បីវិភាគនិន្នាការសកល ស្ថានភាពសង្គមសេដ្ឋកិច្ច ការបែងចែកធនធានអំណោយជំនួយផ្សេងៗប្រៀបធៀបសេដ្ឋកិច្ចនៅទូទាំងតំបន់ និងក្រុមចំណូលផ្សេងៗគ្នា។ ការចាត់ថ្នាក់ទាំងនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ស្ថាប័នអន្តរជាតិ ដើម្បីផ្តល់ការណែនាំក្នុងការបង្កើត គោលនយោបាយ ជួយសម្រួលដល់ការគាំទ្រ និងអន្តរាគមន៍អន្តរជាតិឱ្យស្របទៅនឹងតម្រូវការជាក់លាក់របស់ ប្រទេសដែលកំពុងប្រឈមមុខនឹងបញ្ហា លើកកម្ពស់លទ្ធផលអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងសមធម៌។ ចំណាត់ថ្នាក់ទាំងនេះ ក៏អាចឆ្លុះបញ្ចាំងពីការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសមួយពីសម័យកាលមួយ ទៅសម័យកាលមួយផងដែរ។

### ១.៤.១. មូលដ្ឋាននៃការចាត់ថ្នាក់ប្រទេស

#### ១.៤.១.១. ការធ្វើចំណាត់ថ្នាក់ប្រទេសរបស់ធនាគារពិភពលោក

ធនាគារពិភពលោក គឺជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលផ្តល់ប្រាក់កម្ចី និងជំនួយដល់រដ្ឋាភិបាលនៃ ប្រទេសដែលមានចំណូលទាប និងមធ្យម ដែលមានតម្រូវការយកទៅប្រើប្រាស់ក្នុងគោលបំណងបន្តគម្រោង អភិវឌ្ឍន៍នានារបស់ខ្លួន និងចំណាយទៅលើការកសាងមូលធន។

គោលដៅចម្បងរបស់ធនាគារពិភពលោក គឺដើម្បីកាត់បន្ថយភាពក្រីក្រ ដោយគាំទ្រគម្រោងដែលនឹងធ្វើ ឱ្យប្រសើរឡើងនូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាពរស់នៅ។ ស្ថាប័ននេះផ្តល់មូលនិធិដល់ គម្រោងជាច្រើនដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការកែលម្អការអប់រំ និងសេវាសុខភាព និងការលើកកម្ពស់ គោលនយោបាយសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

ធនាគារពិភពលោកចាត់ថ្នាក់ប្រទេសនីមួយដោយផ្អែកលើកម្រិតប្រាក់ចំណូលជាចម្បង ដោយប្រើ ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់ (GNI per Capita) ជារង្វាស់។ ចំណាត់ថ្នាក់របស់ប្រទេសនីមួយៗត្រូវបាន ធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំនៅថ្ងៃទី០១ ខែកក្កដា ដោយការពិនិត្យទៅលើទិន្នន័យចុងក្រោយបំផុតស្តីពី ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់គិតជាដុល្លារតម្លៃបច្ចុប្បន្ន (ដោយប្រើអត្រាប្តូរប្រាក់តាមវិធី Atlas របស់ ធនាគារពិភពលោក) នៃឆ្នាំមុន និងសូចនាករសេដ្ឋកិច្ចផ្សេងៗទៀត។ ធនាគារពិភពលោកបានបែងចែកប្រទេស ជាបួនក្រុមចំណូលធំៗរួមមាន៖

- ប្រទេសដែលមានចំណូលទាប (Lower Income Countries)
- ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប (Lower-middle Income Countries)

- ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ (Upper-middle Income Countries)
- ប្រទេសដែលមានចំណូលខ្ពស់ (High Income Countires)។[15]

### ១.៤.១.២. ការធ្វើចំណាត់ថ្នាក់ប្រទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

មូលនិធិរូបិយវត្ថុអន្តរជាតិ គឺជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៤៤ ក្នុងគោលបំណងធានាស្ថិរភាពនៃប្រព័ន្ធរូបិយវត្ថុអន្តរជាតិ ដែលជាប្រព័ន្ធទូទាត់អន្តរជាតិ និងជាប្រព័ន្ធអត្រាប្តូរប្រាក់ ប្រើប្រាស់ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចពិភពលោក និងស្ថិរភាពហិរញ្ញវត្ថុ លើកទឹកចិត្តពាណិជ្ជកម្មអន្តរជាតិ និងកាត់បន្ថយភាពក្រីក្រនៅជុំវិញពិភពលោក។ មូលនិធិរូបិយវត្ថុអន្តរជាតិប្រើប្រាស់សូចនាករមួយចំនួនសម្រាប់ចាត់ថ្នាក់ដូចជា៖

- សូចនាករសេដ្ឋកិច្ច៖ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ អត្រាកំណើន GDP កម្រិតឧស្សាហូបនីយកម្ម ការបើកចំហពាណិជ្ជកម្ម។ល។
- កត្តាស្ថាប័ន៖ អភិបាលកិច្ច កម្រិតអំពើពុករលួយ នីតិរដ្ឋ ការអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុ។ល។
- សូចនាករសង្គម៖ កម្រិតអប់រំ សូចនាករសុខភាព អត្រាភាពក្រីក្រ។ល។

ការចាត់ថ្នាក់នេះជួយក្នុងការយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ច និងសក្តានុពលនៃប្រទេសផ្សេងៗគ្នា ការណែនាំអំពីគោលនយោបាយ និងការសម្រេចចិត្តវិនិយោគ។ វាក៏មានប្រយោជន៍ផងដែរសម្រាប់គោលបំណងវិភាគ និងការបង្កើតគោលនយោបាយ។ ចំណាត់ថ្នាក់ចម្បងគឺ៖

- ក្រុមសេដ្ឋកិច្ចកម្រិតខ្ពស់ Advanced Economies
- ក្រុមទីផ្សារ ដែលកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ Emerging Market and Developing Economies (EMDEs)
- ប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានចំណូលទាប Low-income Developing Countries (LIDCs)។[16]

### ១.៤.១.៣. ការធ្វើចំណាត់ថ្នាក់ប្រទេសរបស់អង្គការសហប្រជាជាតិ

កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិគឺជាបណ្តាញអភិវឌ្ឍន៍សកល ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៦៥ មានគោលដៅចម្បងដើម្បីលុបបំបាត់ភាពក្រីក្រ កាត់បន្ថយវិសមភាព កសាងភាពធន់ និងជម្រុញការអភិវឌ្ឍ។ អង្គការនេះ សហការជាមួយប្រទេសជាច្រើននៅលើពិភពលោក ដោយផ្តល់អ្នកជំនាញសម្រាប់ការ

[15] Eric Metreau et al., *"World Bank Country Classifications,"* World Bank, July 01, 2024 World Bank country classifications by income level for 2024-2025

[16] Lynge Nielsen and Catherine Pattillo, *Classifications of Countires on Their Level of Development,* (IMF, February, 2011)

បណ្តុះបណ្តាល និងផ្តល់ជំនួយឥតសំណងដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ក្នុងប្រទេសជាសមាជិក ហើយក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជ្រោមជ្រែងឱ្យប្រទេសទាំងអស់នោះសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។

កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ចាត់ថ្នាក់ប្រទេសជាចម្បងដោយផ្អែកលើសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស (HDI) ជាសូចនាករ។ HDI ធ្វើការវាស់វែង និងបែងចែកចំណាត់ថ្នាក់ផ្អែកលើមូលដ្ឋានសំខាន់ៗចំនួនបីគឺ អាយុសង្ឃឹមរស់ ការអប់រំ ស្តង់ដារនៃការរស់នៅ។ ដោយផ្អែកលើមូលដ្ឋានទាំង ប្រទេសត្រូវបានចាត់ថ្នាក់ជាបួនប្រភេទរួមមាន៖

- ការអភិវឌ្ឍន៍មនុស្សខ្ពស់ណាស់ (Very High Human Development)
- ការអភិវឌ្ឍន៍មនុស្សខ្ពស់ (High Human Development)
- ការអភិវឌ្ឍន៍មនុស្សមធ្យម (Medium Human Development)
- ការអភិវឌ្ឍន៍មនុស្សទាប (Low Human Development)។[17]

### ១.៤.២. គោលការណ៍នៃការចាត់ថ្នាក់ប្រទេសរបស់ធនាគារពិភពលោក

#### ១.៤.២.១. ប្រទេសចំណូលកម្រិតទាប (Lower Income Countries)

សម្រាប់ឆ្នាំសារពើពន្ធបច្ចុប្បន្ន សេដ្ឋកិច្ចដែលមានចំណូលទាបត្រូវបានកំណត់ថាជាអ្នកដែលមានប្រាក់ចំណូលជាតិក្នុងពលរដ្ឋម្នាក់ ស្មើ ឬតិចជាង ១ ១៤៥ ដុល្លារអាមេរិក។ ជាទូទៅ ប្រទេសដែលទទួលបានចំណាត់ថ្នាក់ប្រភេទនេះត្រូវបានគេកំណត់លក្ខណៈដូចជា៖

- **កត្តាសេដ្ឋកិច្ច៖** ជាប្រទេសដែលពឹងផ្អែកភាគច្រើនទៅលើវិស័យកសិកម្ម និងទំនិញមូលដ្ឋាន ជាមួយនឹងភាពមានកម្រិតនៃឧស្សាហកម្ម។
- **កត្តានយោបាយ៖** ហានិភ័យខ្ពស់នៃការកើតជម្លោះ អស្ថិរភាពនយោបាយ អំពើពុករលួយកើតឡើងច្រើន សមត្ថភាពរបស់រដ្ឋាភិបាលមានកម្រិតក្នុងការផ្តល់សេវាសាធារណៈ និងអនុវត្តច្បាប់។
- **កត្តាសង្គម៖** ការអប់រំមានកម្រិតទាប ប្រជាជនខ្វះការយល់ដឹង លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាពមានកម្រិត អត្រាគ្មានការងារធ្វើខ្ពស់ កង្វះស្បៀងអាហារ អត្រាភាពក្រីក្រខ្ពស់ និងមានអត្រាវិសមភាពសង្គមខ្ពស់
- **ហេដ្ឋារចនាសម្ព័ន្ធ៖** ហេដ្ឋារចនាសម្ព័ន្ធ ការដឹកជញ្ជូន និងមធ្យោបាយធ្វើដំណើរជួបការលំបាក ប្រភពថាមពលមានកំណត់ ប្រព័ន្ធទូរគមនាគមន៍ដំណើរការមិនល្អ។

[17] "*What is the criteria of UNDP to classify countires,*" EduRev, n.d, What is the criteria of UNDP to classify countries - EduRev Class 10 Question

### ១.៤.២.២. ប្រទេសចំណូលមធ្យមកម្រិតទាប (Lower-middle income Countries)

សេដ្ឋកិច្ចដែលមានចំណូលមធ្យមកម្រិតទាប គឺជាប្រទេសដែលមានប្រាក់ចំណូលជាតិសរុបក្នុងមនុស្សម្នាក់ចន្លោះពី ១ ១៤៦ ទៅ ៤ ៥១៥ ដុល្លារអាមេរិក។ ជាធម្មតា ប្រទេសទាំងនេះស្ថិតក្នុងដំណាក់កាលអន្តរកាលដោយផ្លាស់ប្តូរពីស្ថានភាពចំណូលទាប ប៉ុន្តែមិនទាន់សម្រេចបាននូវកម្រិតប្រាក់ចំណូល និងកម្រិតជីវភាពដូចបណ្តាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ ឬប្រទេសដែលមានចំណូលខ្ពស់នៅឡើយ។ លក្ខណៈសំខាន់ៗនៃប្រទេសដែលមានចំណូលមធ្យមកម្រិតទាបមានដូចជា៖

- **កត្តាសេដ្ឋកិច្ច៖** មានសេដ្ឋកិច្ចកំពុងរីកចម្រើន ប៉ុន្តែនៅតែប្រឈមមុខនឹងបញ្ហាសំខាន់ៗ និងភាគច្រើនជាប្រទេសដែលផ្លាស់ប្តូរពីការពឹងផ្អែកលើវិស័យកសិកម្មទៅកាន់វិស័យឧស្សាហកម្ម និងសេវាកម្ម។
- **កត្តានយោបាយ៖** អនុវត្តកំណែទម្រង់អភិបាលកិច្ច កាត់បន្ថយអំពើពុករលួយ កាត់បន្ថយភាពក្រីក្រ និងទាក់ទាញការវិនិយោគពីបរទេស ប៉ុន្តែងាយរងផលប៉ះពាល់ពីវិបត្តិផ្សេងៗ
- **កត្តាសង្គម៖** លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាពត្រូវបានកែលម្អជាបន្តបន្ទាប់ ប៉ុន្តែជារឿយៗនៅតែប្រឈមមុខនឹងបញ្ហាគុណភាព និងការប្រើប្រាស់សេវាទាំងនោះមានកម្រិត។
- **ហេដ្ឋារចនាសម្ព័ន្ធ៖** មានការវិនិយោគសំខាន់ៗនៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែនៅតែអាចប្រឈមមុខនឹងឱនភាពក្នុងវិស័យដូចជា ការដឹកជញ្ជូន ថាមពល និងទំនាក់ទំនង។

### ១.៤.២.៣. ចំណូលមធ្យមកម្រិតខ្ពស់ (Upper-middle Income Countries)

សេដ្ឋកិច្ចដែលមានចំណូលមធ្យមកម្រិតខ្ពស់គឺជាប្រទេសដែលមានប្រាក់ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់ចន្លោះពី ៤ ៥១៦ ទៅ ១៤ ០០៥ ដុល្លារអាមេរិក។ ប្រទេសទាំងនេះត្រូវបានកំណត់ដោយការអភិវឌ្ឍសេដ្ឋកិច្ចជឿនលឿនជាងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ប៉ុន្តែមិនទាន់ឈានដល់កម្រិតចំណូលខ្ពស់នៅឡើយ។ ជាទូទៅ ប្រទេសដែលទទួលបានចំណាត់ថ្នាក់ប្រភេទនេះត្រូវបានគេកំណត់លក្ខណៈដូចជា៖

- **កត្តាសេដ្ឋកិច្ច៖** ជាប្រទេសមានផលិតភាពសេដ្ឋកិច្ចខ្ពស់ ពោរពេញដោយភាពចម្រុះនៃវិស័យឧស្សាហកម្ម សេវាកម្ម និងកសិកម្ម ដោយមានការចូលរួមចំណែកយ៉ាងសំខាន់ពីបច្ចេកវិទ្យាដ៏រីកចម្រើន ការវិនិយោគនវានុវត្តន៍ និងការស្រាវជ្រាវទៅលើវិស័យនានា។
- **កត្តានយោបាយ៖** បរិយាកាសនយោបាយមានស្ថិរភាពជាងមុន និងរចនាសម្ព័ន្ធអភិបាលកិច្ចកាន់តែប្រសើរ បើប្រៀបធៀបទៅនឹងប្រទេសដែលមានចំណូលទាប
- **កត្តាសង្គម៖** ឆ្លុះបញ្ចាំងពីស្តង់ដាររស់នៅ ជាមួយនឹងការទទួលបានការអប់រំ និងការថែទាំសុខភាពកាន់តែប្រសើរឡើងដែលនាំឱ្យអាយុសង្ឃឹមរស់បានយូរ ប៉ុន្តែបញ្ហាវិសមភាពនៅតែកើតមាន និងជួបប្រទះនូវផលប៉ះពាល់ទៅលើបរិស្ថានមួយចំនួន

- **ហេដ្ឋារចនាសម្ព័ន្ធ៖** ហេដ្ឋារចនាសម្ព័ន្ធដ៏សម្បូរបែបត្រូវបានអភិវឌ្ឍន៍ដើម្បីជម្រុញដល់កំណើនសេដ្ឋកិច្ចបន្ថែមទៀតដូចជា បណ្តាញដឹកជញ្ជូន ប្រភពថាមពល និងបណ្តាញទូរគមនាគម៍ ជាពិសេសការរីកចម្រើនផ្នែកនគរូបនីយកម្មគួរឱ្យកត់សម្គាល់។

### ១.៤.២.៤. ចំណូលកម្រិតខ្ពស់ ( Upper Income Countries )

សេដ្ឋកិច្ចដែលមានប្រាក់ចំណូលខ្ពស់ សម្តៅដល់ប្រទេសដែលមាន GNI ក្នុងមនុស្សម្នាក់ចាប់ពី ១៤ ០០៦ ដុល្លារអាមេរិក ឬច្រើនជាងនេះ។ ប្រទេសទាំងនេះជាធម្មតាបង្ហាញពីការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តភាព ធន់នឹងវិបត្តិ ស្តង់ដាររស់នៅខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធរឹងមាំ និងសេវាកម្មសង្គមដែលមានការអភិវឌ្ឍន៍យ៉ាងល្អ។ លក្ខណៈសម្គាល់សំខាន់ៗនៃប្រទេសដែលមានចំណូលខ្ពស់៖

- **កត្តាសេដ្ឋកិច្ច៖** ឆ្លុះបញ្ចាំងពីប្រទេសដែលមានសេដ្ឋកិច្ច និងកម្រិតប្រាក់ចំណូលខ្ពស់បំផុតបើធៀបទៅនឹងក្រុមប្រទេសបីដទៃ ដោយវិស័យឧស្សាហកម្ម និងសេវាកម្មមានដំណើរការយ៉ាងរឹងមាំ ជាមួយនឹងការរួមចំណែកយ៉ាងសំខាន់ពីវិស័យហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការផលិតដែលមានតម្លៃបន្ថែមខ្ពស់។
- **កត្តានយោបាយ៖** រចនាសម្ព័ន្ធអភិបាលកិច្ចរឹងមាំ ស្ថិរភាពនយោបាយ និងប្រព័ន្ធច្បាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់
- **កត្តាសង្គម៖** ប្រព័ន្ធអប់រំ និងការថែទាំសុខភាពដ៏ល្អ ដោយមានអត្រាចុះឈ្មោះចូលរៀនខ្ពស់ក្នុងការអប់រំ និងសេវាថែទាំសុខភាពដ៏ទូលំទូលាយ នាំឱ្យអាយុសង្ឃឹមរស់ខ្ពស់ ទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ និងលក្ខខណ្ឌរស់នៅដ៏ប្រសើរ
- **ហេដ្ឋារចនាសម្ព័ន្ធ៖** ហេដ្ឋារចនាសម្ព័ន្ធជឿនលឿន បណ្តាញដឹកជញ្ជូន ដែលត្រូវបានអភិវឌ្ឍយ៉ាងល្អ ការផ្គត់ផ្គង់ថាមពល ប្រព័ន្ធទំនាក់ទំនង និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា។[18]

[18] Eric Metreau et al., *"World Bank Country Classifications,"* World Bank, July 01, 2024 [World Bank country classifications by income level for 2024-2025]

# ជំពូកទី ២

# ស្ថានភាព និង

# ចក្ខុវិស័យសេដ្ឋកិច្ចរបស់

# ប្រទេសកម្ពុជា

# ជំពូកទី ២
# ស្ថានភាព និងចក្ខុវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា

## ២.១. លក្ខណៈទូទៅនៃសេដ្ឋកិច្ចកម្ពុជា

### ២.១.១. ប្រវត្តិសេដ្ឋកិច្ចកម្ពុជា

ក្រោយពីទទួលបានឯករាជ្យពេញលេញពីរបបអាណានិគមបារាំង កម្ពុជាបានឆ្ពោះទៅរករបបថ្មីមួយទៀតគឺរបបសង្គមរាស្ត្រនិយមក្រោមការដឹកនាំរបស់ **ព្រះបាទសម្តេច នរោត្តម សីហនុ** ដែលជាបិតាឯករាជ្យជាតិ ដោយព្រះអង្គបានប្រកាន់យកនយោបាយអព្យាក្រឹត្យ ដែលធ្វើឱ្យកម្ពុជារីកចម្រើនស្ទើរតែគ្រប់វិស័យ ប៉ុន្តែដោយសារឥទ្ធិពលសង្គ្រាមត្រជាក់រវាងមហាអំណាចសេរី និងលោកកម្មុយនីស បានរុញច្រានកម្ពុជាឱ្យចូលបន្តិចម្តងៗក្នុងអណ្តាតភ្លើងនៃសង្គ្រាម ដែលកំពុងឆាបឆេះនៅឧបទ្វីបឥណ្ឌូចិនមុននឹងឈានទៅដល់រដ្ឋប្រហារដោយលោក លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ជាបន្តបន្ទាប់ កម្ពុជាបានឆ្លងកាត់ភ្នក់ភ្លើង សង្គ្រាមដ៏សែនរន្ធត់ អំពើហិង្សា ជាពិសេសប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងអន្លង់អន្ធការនៃរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ ដែលជាសម័យកាលដ៏ខ្មៅងងឹតបំផុតក្នុងប្រវត្តិសាស្ត្រ ដោយរស់នៅក្នុងស្ថានភាពឯកោអស់រយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ។

ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ គឺជាទិវាប្រវត្តិសាស្ត្រ ដែលមាតុភូមិកម្ពុជាត្រូវបានរំដោះចេញផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាប់បដិសន្ធិឡើង។ ប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងអស់ពីកម្លាំងកាយចិត្ត ដើម្បីស្តារកសាងប្រទេសជាតិឡើងវិញទៅលើគ្រប់វិស័យ និងរៀបចំខឿនសេដ្ឋកិច្ចថ្មីដោយចាប់ផ្តើមពីបាតដៃទទេ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីដំណោះស្រាយនយោបាយគ្រប់ជ្រុងជ្រោយនៃវិបត្តិកម្ពុជានៅសន្និសិទអន្តរជាតិទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានឈានទៅដល់ការចុះហត្ថលេខាលើសន្ធិសញ្ញាទីក្រុងប៉ារីសតាមរយៈការបោះឆ្នោតជាសកល ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ ១៩៩៣។

ក្រោយពីទទួលបាននូវសុខសន្តិភាពពេញលេញ នៅចុងឆ្នាំ ១៩៩៨ រហូតដល់បច្ចុប្បន្ន កម្ពុជាបានប្រែក្លាយពីប្រទេសដែលប្រកបដោយកលិយុគ សង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សរ៍ វាលពិឃាដ និងចម្ការមីន ដែលគ្រប់គ្នាភ័យខ្លាចទៅជាប្រទេសដែលមានសុខសន្តិភាព សុវត្ថិភាព ស្ថិរភាព ការបង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ នីតិរដ្ឋ និងជាតំបន់ទេសចរណ៍លំដាប់សកលប្រកបដោយប្រជាប្រិយភាព និងស្វាមញញឹមពីទេសចរជាតិ និងអន្តរជាតិរាប់លាននាក់ក្នុងមួយឆ្នាំៗ។ កម្ពុជាបានប្រែមុខមាត់ទាំងស្រុង ដោយទទួលបានការសោទរយ៉ាងខ្លាំងក្លាពីសំណាក់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដែលពីមុនធ្លាប់ជាប្រទេសទទួលរងការហ៊ុមព័ទ្ធ និងឯកាទាំងខាងនយោបាយការទូត និងសេដ្ឋកិច្ច។ បច្ចុប្បន្ននេះ កម្ពុជាបានក្លាយជាប្រទេសដែលបានដឹកនាំសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្នុងឋានៈជាប្រធានប្តូរវេនប្រកបដោយជោគជ័យចំនួន ៣ លើក និងបានក្លាយជា

សមាជិកស្ថាបនិកនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដ៏ធំជាងគេបង្អស់ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ពោលគឺកិច្ចព្រមព្រៀងភាពជាគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP)។ ការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជាបានចែកចាយជាបីដំណាក់កាលខុសៗគ្នារួមមាន ដំណាក់កាលស្តារ និងនីតិសម្បទាក្នុងឆ្នាំ ១៩៨៩-១៩៩៨ ដំណាក់កាលស្ថាបនាឡើងវិញក្នុងឆ្នាំ ១៩៩៩-២០០៣ និងដំណាក់កាលហក់ឡើងនៃសេដ្ឋកិច្ចឆ្នាំ ២០០៤-២០០៨។[19]

### ២.១.២. ប្រព័ន្ធសេដ្ឋកិច្ចកម្ពុជា

ចាប់តាំងពីឆ្នាំ ១៩៨៩ កម្ពុជាបានអនុវត្តការកែទម្រង់ជាច្រើន ដែលផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារជាផ្លូវការដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។ ទាំងអស់នេះរួមបញ្ចូលទាំងការអនុវត្តកម្មសិទ្ធិឯកជនទៅលើទ្រព្យសម្បត្តិ សេរីភាវូបនីយកម្មថ្លៃ និងពាណិជ្ជកម្ម ការធ្វើឱ្យរូបិយប័ណ្ណអាចដោះដូរបាន ការបើកទូលាយទីផ្សារក្នុងស្រុកដល់ធុរកិច្ចឯកជន ការធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនរដ្ឋ ការលុបបំបាត់ភាពផ្តាច់មុខក្នុងឧស្សាហកម្ម និងសេវាកម្ម និងកំណែទម្រង់បទដ្ឋានគណនេយ្យ ប្រព័ន្ធពន្ធដារ ប្រព័ន្ធច្បាប់ និងវិស័យហិរញ្ញវត្ថុដើម្បីលើកកម្ពស់ពាណិជ្ជកម្មឱ្យស្មើភាព ដែលកត្តាទាំងនេះផ្តល់ភាពងាយស្រួលដល់វិនិយោគិនហើយទាញដល់ធុរជន ដែលមានបំណងនាំចេញទំនិញ និងសេវាកម្មដែលមានសក្តានុពលទៅកាន់ទីផ្សារអាស៊ានដៃគូសហភាពអឺរ៉ុប និងដៃគូពាណិជ្ជកម្មផ្សេងទៀតដែលកម្ពុជាទទួលបានការអនុគ្រោះពាណិជ្ជកម្ម។

### ២.១.៣. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

គិតមកត្រឹមឆ្នាំ ២០១៥ សេដ្ឋកិច្ចកម្ពុជានៅបន្តកំណើនយ៉ាងរឹងមាំ និងជឿជាក់ក្នុងរយៈពេលខ្លី និងមធ្យម។ នៅឆ្នាំ ២០១៥ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងសម្រេចបានក្នុងរង្វង់ ៧ %។ កំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះបានធ្វើឱ្យផលិតផលក្នុងស្រុកកម្ពុជា (ផ.ស.ស.) តាមថ្លៃបច្ចុប្បន្ន មានចំនួន ៧៤ ៤៤៤ ពាន់លានរៀល ដែលស្មើនឹងប្រមាណជា ១៨ ៣៨១ លានដុល្លារអាមេរិក ។ ប្រការនេះធ្វើឱ្យប្រាក់ចំណូលសម្រាប់មនុស្សម្នាក់រំពឹងថានឹងទទួលបាន ១ ២២៥ ដុល្លារអាមេរិក ដោយនេះមានន័យថា កម្ពុជាកំពុងបោះជំហានពីសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រ គឺការឆ្លងពីឋានៈប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបជាផ្លូវការ ក្នុងឆ្នាំ២០១៥ ព្រមទាំងត្រូវបានចាត់ទុកថាជា "ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី" ក្នុងឆ្នាំ២០១៦។[20] កំណើនដ៏គួរឱ្យស្ញប់ស្ញែងនេះ បានបង្កើតការងារជាច្រើនដល់ប្រជាពលរដ្ឋទូទាំងប្រទេស ដែលឆ្លុះបញ្ចាំងតាមរយៈតួលេខរបស់ធនាគារ ពិភពលោកដែលបានបង្ហាញថា ភាពគ្មានការងារធ្វើនៅប្រទេសកម្ពុជាស្ថិតក្នុងអត្រា 0,៣% និងភាពក្រីក្រតោកយ៉ាកត្រូវបានលុបបំបាត់ចោលទាំងស្រុងក្នុងឆ្នាំ២០១៧។ រាជរដ្ឋាភិបាលនីតិកាលទី៥នេះបានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតា ដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០។

---

[19] ហង់ ជួនណារ៉ុន, *សេដ្ឋកិច្ចនៃប្រទេសកម្ពុជា,* (ភ្នំពេញ, ២០១៥)

[20] Ibid., ទំព័រទី5

**ក្រាហ្វិកទី២៖ បង្ហាញពីអត្រាកំណើនសេដ្ឋកិច្ចកម្ពុជាចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០២៣**




ប្រភព៖ ធនាគារពិភពលោក

ក្នុងវិស័យសេដ្ឋកិច្ច កម្ពុជាសម្រេចបាននូវសមិទ្ធផលយ៉ាងធំធេង។ សេដ្ឋកិច្ចកម្ពុជាបានប្រែក្លាយពីសេដ្ឋកិច្ចប្រពៃណី ដែលផ្អែកលើវិស័យកសិកម្មដែលមានផលិតភាពទាប និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចតិចតួចជាចម្បងទៅជាសេដ្ឋកិច្ចទំនើប ដែលវិស័យឧស្សាហកម្ម និងសេវាកម្មដើរតួនាទីឈានមុខ។ បើគិតចាប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២១ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងផលិតផលសរុបក្នុងស្រុក (GDP) មានការធ្លាក់ចុះជាង ១២% ពោលគឺពី ៣៥% ក្នុងឆ្នាំ ២០១១ មកត្រឹម ២៣% ក្នុងឆ្នាំ ២០២១ ជាពិសេសកម្លាំងពលកម្មដែលចូលរួមក្នុងវិស័យកសិកម្មក៏មានការថយចុះជាង ២០% ដែរ ពោលធ្លាក់ចុះពី ៥៦% ក្នុងឆ្នាំ ២០១១ មកកាន់ ៣៦% ក្នុងឆ្នាំ ២០២១។

**ក្រាហ្វិកទី៣៖ ការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាតាមវិស័យផ្សេងៗ**




ប្រភព៖ Cambodia Economics Update Nov 2023[21]

21 *Cambodia Economics Updated,* World Bank Report, Nov 2023

ប្រទេសកម្ពុជាបានផ្លាស់ប្តូរឆ្ពោះទៅរកឧស្សាហូបនីយកម្ម ជាពិសេសក្នុងវិស័យកាត់ដេរ និងវាយនភ័ណ្ឌ ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ GDP និងការងារ ដែលជម្រុញដោយការវិនិយោគផ្ទាល់ពីបរទេស (FDI) និងបានរួមបញ្ចូលទៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ពិភពលោក។ វិស័យសំណង់ក៏មានការរីកដុះដាលផងដែរ ដែលជម្រុញដោយតម្រូវការក្នុងស្រុក និងការវិនិយោគពីបណ្តាប្រទេសនានា ជាពិសេសប្រទេសចិន។ វិស័យសេវាកម្មនៅកម្ពុជារួមមានទេសចរណ៍ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុក៏មានការរីកចម្រើនយ៉ាងឆាប់រហ័ស ជាពិសេស វិស័យទេសចរណ៍បានក្លាយជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ច ដោយបានទាក់ទាញភ្ញៀវទេសចររាប់លាននាក់ក្នុងមួយឆ្នាំៗ ដែលការវិវត្តិនេះបានឆ្លុះបញ្ចាំងពីគំរូនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ ដែលសេដ្ឋកិច្ចផ្លាស់ប្តូរពីកសិកម្មទៅជាឧស្សាហកម្ម និងបន្ទាប់មកទៅកាន់សេវាកម្ម ហើយការប្រែប្រួលនេះវាស្របទៅនឹងទ្រឹស្តីម៉ូដែលនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ។

នៅក្នុងបរិបទនៃប្រទេសកម្ពុជា គំរូសត្វក្ងានហោះ (The Flying Geese's Model) អាចត្រូវបានអនុវត្តដើម្បីយល់ពីដំណើរការវិវត្តនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាត្រូវចាត់តាំងជាប្រទេស "អ្នកដើរតាម" ដែលមានន័យថា ប្រទេសនេះកំពុងធ្វើឧស្សាហកម្មនៅពីក្រោយដៃគូក្នុងតំបន់ ហើយអាចទទួលបានអត្ថប្រយោជន៍ពីការសាយភាយនៃបច្ចេកវិទ្យា ការវិនិយោគ និងការអនុវត្តអាជីវកម្ម បន្ទាប់ពីប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនដូចជាប្រទេសជប៉ុន កូរ៉េខាងត្បូង និងក្រោយមកទៀតគឺប្រទេសថៃ និងវៀតណាម។ ដោយសារប្រាក់ឈ្នួល និងថ្លៃដើមផលិតកម្មកើនឡើងនៅក្នុងប្រទេសជឿនលឿន សកម្មភាពផលិតកម្មដែលមានតម្លៃទាប ជាពិសេសក្នុងវិស័យកាត់ដេរ និងវាយនភណ្ឌ បានផ្លាស់ប្តូរមកកម្ពុជា។ ការធ្វើសមាហរណកម្មរបស់កម្ពុជាទៅក្នុងខ្សែសង្វាក់តម្លៃសកល ជាពិសេសតាមរយៈឧស្សាហកម្មកាត់ដេរ គឺជាឧទាហរណ៍នៃគំរូសត្វក្ងានហោះ ដោយប្រទេសនេះបានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) យ៉ាងសំខាន់ក្នុងការផលិត ដែលកំពុងជួយប្រទេសនេះឱ្យផ្លាស់ប្តូរបន្តិចម្តងៗពីការតម្លើងមូលដ្ឋាន និងការផលិតទៅជាទម្រង់ផលិតកម្មទំនើបជាងមុន។ ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានអាស្រ័យទៅនឹងយុទ្ធសាស្ត្រសេដ្ឋកិច្ចរបស់មេដឹកនាំក្នុងតំបន់ ដូចជាប្រទេសចិន និងវៀតណាម ដែលប្រទេសអភិវឌ្ឍន៍តិចតួចពឹងផ្អែកលើប្រទេសដែលមានការអភិវឌ្ឍន៍ច្រើនសម្រាប់ការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា និងការទទួលបានទីផ្សារ។ ដើម្បីបន្តទទួលបានអត្ថប្រយោជន៍ពីគំរូនេះ កម្ពុជាចាំបាច់ត្រូវធ្វើពិពិធកម្មទៅក្នុងឧស្សាហកម្ម និងសេវាកម្មដែលមានតម្លៃបន្ថែមខ្ពស់ដូចជា គ្រឿងអេឡិចត្រូនិក គ្រឿងបន្លាស់រថយន្ត និងទេសចរណ៍ ស្រដៀងទៅនឹងរបៀបដែលប្រទេសអាស៊ីអាគ្នេយ៍ផ្សេងទៀតបានវិវត្តន៍ទៅតាមពេលវេលាកន្លងមក។

របត់ដ៏សំខាន់ក្នុងដំណើរអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជាបានកើតឡើងក្នុងឆ្នាំ ២០២០-២០២១ គឺក្នុងកំឡុងពេលនៃវិបត្តិជំងឺរាតត្បាតជាសកលកូវីដ-១៩ ដែលកម្ពុជា ក៏ដូចជាបណ្តាប្រទេសនានា កំពុងរងផលប៉ះពាល់ជាពិសេសមកលើការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ការប្រកបអាជីវកម្ម ការងារ និងការរស់នៅរបស់ប្រជាជន។ ជាក់ស្តែងក្រោយពីរងការប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមាន ៣,១% ក្នុងឆ្នាំ ២០២០ ហើយ

សេដ្ឋកិច្ចរបស់កម្ពុជាអាចស្តារសេដ្ឋកិច្ចឱ្យមានកំណើនឡើងវិញពោលគឺកើនឡើងទាបត្រឹម ៣% នៅឆ្នាំ ២០២១ និងបន្តកើនឡើង ៥,២% នៅឆ្នាំ ២០២២។

ជាមួយនឹងការអនុវត្តកម្មវិធីគោលនយោបាយ វិធានការគន្លឹះ និងវិធានការកែទម្រង់មុតស្រួចនានា ដែលត្រូវបានដាក់ចេញកន្លងមក និងវិធានការបុរេសកម្មផ្សេងៗ កម្ពុជារំពឹងថានឹងសម្រេចបានកំណើនសេដ្ឋកិច្ច ក្នុងអត្រា ៥,៦% នៅឆ្នាំ ២០២៣ និងបន្តដើបកាន់តែលឿនក្នុងអត្រា ៦,៦% នៅឆ្នាំ ២០២៤ ដែលកំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះបានធ្វើឱ្យ ផ.ស.ស. ថ្លៃបច្ចុប្បន្នស្ថិតក្នុងរង្វង់ ១៤២ ៩៥៧ ប៊ីលានរៀល សមមូលនឹងប្រមាណ ៣៥ ១៦៨ លានដុល្លារអាមេរិក ស្របពេលដែល ផ.ស.ស. ក្នុងមនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ២ ០៧១ ដុល្លារអាមេរិក បើប្រៀបធៀបនឹង ១ ៩១៧ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០២៣ ចំណែកឯអត្រាប្តូរប្រាក់រៀលគឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ ៤ ០៦៥ រៀល ក្នុងមួយដុល្លារអាមេរិកក្នុងឆ្នាំ ២០២៤ ឱនភាពគណនីចរន្ត (រួមបញ្ចូលឋង្វៃ) ត្រូវបានព្យាករថានឹងរួមតូចបន្តិចមកត្រឹម ៩,៦% នៃ ផ.ស.ស. ដោយសារការរំពឹងទុកលើការបន្តកើនឡើងនូវការនាំចេញ និងចំណូលពីវិស័យទេសចរណ៍។ ទុនបម្រុងអន្តរជាតិសរុប ត្រូវបានរំពឹងថានឹងកើនឡើងដល់ ២១ ២៨៥ លានដុល្លារអាមេរិក និងធានាការនាំចូលបាន ៦ ខែ។

**តារាងទី១ ៖ បង្ហាញពីសូចនាករសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ (ព្យាករណ៍)**

| សូចនាករសេដ្ឋកិច្ច | ២០២២ | ២០២៣<br>ប៉ាន់ស្មាន | ២០២៤<br>ព្យាករណ៍ |
|---|---|---|---|
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | 12 989 | 130 805 | 142 957 |
| កំណើននៃ ផ.ស.ស. តាមថ្លៃថេរ (%) | 5,2 | 5,6 | 6,6 |
| ផ.ស.ស. សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | 1 784 | 1 917 | 2 071 |
| អតិផរណា (អត្រាមធ្យមប្រចាំឆ្នាំ) | 5,3 | 2,5 | 2,5 |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | 4 090 | 4 065 | 4 065 |
| សមតុល្យគណនីចរន្ត (% នៃ ផ.ស.ស.) | -25,6 | -10,7 | -9,6 |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | 17 805 | 19 437 | 21 285 |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | 6,1 | 6,9 | 6,6 |

*ប្រភព៖ ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា សម្រាប់ឆ្នាំ ២០២២ និងការប៉ាន់ស្មានឆ្នាំ ២០២៣ និងការព្យាករឆ្នាំ ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខែ ឧសភា ឆ្នាំ ២០២៣*

កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានទ្រទ្រង់ដោយវិស័យចន្ទល់ដែលជាឆ្អឹងកងសេដ្ឋកិច្ចសំខាន់ចំនួនបីរួមមានៈ

- វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើងក្នុងរង្វង់ ៨,៥% ក្នុងឆ្នាំ ២០២៤ ពីប្រមាណ ៥,០% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកការងើបឡើងវិញនៃអនុវិស័យកាត់ដេរ ស្របពេលដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅបន្តរក្សាបានកំណើនរឹងមាំ ខណៈដែលអនុវិស័យសំណង់នៅបន្តមានកំណើនទាប។
- វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងបន្តនិន្នាការល្អ ក្នុងអត្រាកំណើន ៦,៩% ក្នុងឆ្នាំ ២០២៤ ពីមូលដ្ឋានល្អក្នុងរង្វង់ ៨,១% ក្នុងឆ្នាំ ២០២៣ ដោយសារការបន្តងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ជាពិសេសអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ដែលក៏នឹងមានផលជះជាវិជ្ជមានដល់វិស័យ-អនុវិស័យគាំទ្រផ្សេងៗទៀតរួមមាន អនុវិស័យលក់ដុំ-រាយ និងអនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ខណៈអនុវិស័យអចលនទ្រព្យរំពឹងថាបន្តសម្រេចបានកំណើនទាបជាងនិន្នាការធម្មតា។
- វិស័យកសិកម្ម រំពឹងថានឹងបន្តសម្រេចបានកំណើនល្អ ក្នុងរង្វង់ ១,១% ក្នុងឆ្នាំ ២០២៤ ធៀបនឹង ០,៩% ក្នុងឆ្នាំ ២០២៣ ដោយសារការបន្តនិន្នាការល្អនៃអនុវិស័យដំណាំ និងការបន្តងើបឡើងវិញនៃអនុវិស័យនេសាទ ខណៈដែលអនុវិស័យចិញ្ចឹមសត្វនៅបន្តមានស្ថិរភាព។[22]

### ២.១.៤. ទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧

ក្នុងរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថាស្ថិតក្នុងអត្រាជាមធ្យម ៦,៥% ក្នុងនោះឆ្នាំ ២០២៥ ព្យាករថាមានកំណើន ៦,៣% ក្រោមការរំពឹងទុកនៃនិន្នាការល្អនៃតម្រូវការសកល និងកំណើនទំនុកចិត្តវិនិយោគិនបរទេស ស្របពេលដែលលក្ខខណ្ឌហិរញ្ញវត្ថុសកលអាចប្រសើរឡើង។ ទន្ទឹមនេះ ការពង្រឹងការអនុវត្ត "**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១**" និងឆន្ទៈក្នុងការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចរបស់រាជរដ្ឋាភិបាលនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហារចនាសម្ព័ន្ធ ដែលមានភាពប្រទាក់ក្រឡា សំដៅជម្រុញកំណើនសេដ្ឋកិច្ច តាមរយៈការកសាងមូលធនមនុស្ស ពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច បង្កើនផលិតភាពផលិតកម្ម ជម្រុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទដោយបូកបញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល ក្នុងការឈានទៅបង្កើត និងចាប់យកវិស័យកំណើនថ្មីដោយផ្អែកលើជំនាញ បច្ចេកវិទ្យា និងនវានុវត្តន៍។

- វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ៨,៩% សម្រាប់រយៈពេលមធ្យម ២០២៥-២០២៧ ក្នុងនោះឆ្នាំ ២០២៥ ព្យាករថាមានកំណើន ៨,៦% គាំទ្រ ដោយការរក្សាបានតុល្យភាពនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈ អនុវិស័យសំណង់នៅបន្តមានកំណើនទាបជាងនិន្នាការធម្មតា (មុនវិបត្តិជំងឺកូវីដ-១៩) ។

[22] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ថវិកាសង្ខេបឆ្នាំ ២០២៤,* ២០២៣

- វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ៥,៧% ប្រហាក់ប្រហែលគ្នាទៅនឹងនិន្នាការធម្មតា សម្រាប់រយៈពេលមធ្យម ២០២៥-២០២៧ ក្នុងនោះឆ្នាំ ២០២៥ ព្យាករថាមានកំណើន ៥,៦% ដោយសារការបន្តរក្សាបានចលនការនៃអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ និងសេវាកម្មទេសចរណ៍គាំទ្រផ្សេងទៀត ខណៈដែលអនុវិស័យ អចលនទ្រព្យនៅបន្តមានកំណើនទាប។
- វិស័យកសិកម្ម ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ១,២% ប្រហាក់ប្រហែលនិន្នាការកន្លងទៅ សម្រាប់រយៈពេលមធ្យម ក្នុងនោះឆ្នាំ ២០២៥ ព្យាករថាមានកំណើន ១,១% ដោយសារការរំពឹងទុកនូវកំណើនល្អនៃអនុវិស័យដំណាំ និងចិញ្ចឹមសត្វ និងការងើបសន្សឹមៗ នៃអនុវិស័យនេសាទ។

ក្នុងរយៈពេលមធ្យមខាងមុខ (២០២៥-២០២៧) អត្រាអតិផរណាត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,៥% ដោយសារការរក្សាបាននូវចលនការសេដ្ឋកិច្ចក្នុងស្រុក និងប្រក្រតីភាពនៃស្ថានភាព និងថ្លៃទំនិញអន្តរជាតិ ស្របពេលដែលអត្រាប្តូរប្រាក់ផ្លូវការរំពឹងថារក្សាបានក្នុងរង្វង់ជាមធ្យម ៤ ០៦០ រៀល/ដុល្លារអាមេរិក។ បើទោះបីជាការព្យាករថាកំណើនសេដ្ឋកិច្ចសកលនឹងងើបឡើងវិញក្តី ការចាកចេញរបស់កម្ពុជាពីឋានៈប្រទេសដែលមានការអភិវឌ្ឍតិចតួចទៅជាប្រទេសកំពុងអភិវឌ្ឍនឹងនាំមកនូវបញ្ហាប្រឈមមួយចំនួនសម្រាប់សេដ្ឋកិច្ចកម្ពុជារួមមានៈ ការថយចុះនៃថវិកាជំនួយ និងភាពអនុគ្រោះខាងពាណិជ្ជកម្ម, ការថមថយលំហូរទុនវិនិយោគពីបរទេស, មូលដ្ឋានសេដ្ឋកិច្ចចង្អៀត និងល្បឿនពិពិធកម្មសេដ្ឋកិច្ចយឺត, ថ្លៃដើមធុរកិច្ចនៅខ្ពស់, ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកមានកម្រិត, ការសម្របសម្រួលស្ថាប័ន ពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច, បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ, ផលិតភាព សេដ្ឋកិច្ចទាប, និងភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម"។[23]

**តារាងទី២៖ ទស្សនវិស័យសេដ្ឋកិច្ចតាមវិស័យឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៧**

| កំណើន (%) | 2019 | 2020 | 2021 | 2022 | 2023ប. | 2024ព្យ. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|---|---|---|---|
| ផ.ស.ស. | 7.9 | -3.6 | 3.1 | 5.1 | 5.0 | 6.0 | 6.3 | 6.5 | 6.7 |
| វិស័យកសិកម្ម | -0.4 | 0.6 | 1.5 | 0.6 | 0.9 | 0.7 | 1.1 | 1.2 | 1.3 |
| ដំណាំ | 0.6 | 0.9 | 2.2 | 1.1 | 1.3 | 1.6 | 1.6 | 1.7 | 1.8 |
| នេសាទ | -2.6 | 0.9 | 2.3 | 1.2 | 0.9 | -2.0 | 0.3 | 0.5 | 0.6 |
| ចិញ្ចឹមសត្វ | -1.5 | 0.7 | -1.0 | -1.3 | 0.1 | 0.2 | 0.3 | 0.4 | 0.5 |
| វិស័យឧស្សាហកម្ម | 13.0 | -2.2 | 8.4 | 8.2 | 4.3 | 7.9 | 8.6 | 9.1 | 9.5 |
| កាត់ដេរ | 12.9 | -7.7 | 15.9 | 11.3 | -3.5 | 7.5 | 9.4 | 9.1 | 8.8 |
| សំណង់ | 18.7 | -7.6 | -8.0 | 0.9 | 0.7 | 1.1 | 2.5 | 4.0 | 5.8 |
| ផលិតកម្មម្ហូបអាហារ | 7.8 | 3.4 | 4.2 | 7.6 | 7.3 | 7.7 | 7.5 | 6.7 | 6.5 |
| ផលិតកម្មភេសជ្ជៈ និងថ្នាំជក់ | 7.7 | 4.4 | 7.9 | 5.6 | 6.8 | 7.7 | 8.4 | 8.9 | 9.4 |
| កម្មន្តសាលមិនមែនកាត់ដេរ | 8.4 | 11.9 | 16.8 | 10.3 | 17.0 | 13.0 | 11.7 | 11.7 | 11.7 |
| សេវាកម្ម | 6.6 | -6.7 | -1.8 | 3.6 | 7.2 | 5.8 | 5.6 | 5.9 | 5.8 |
| បដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ | 5.5 | -34.2 | -39.5 | 22.0 | 47.5 | 12.6 | 8.4 | 7.3 | 5.1 |
| លក់ដុំ-រាយ | 5.7 | -6.3 | 2.5 | 4.5 | 4.0 | 5.3 | 5.9 | 6.1 | 6.3 |
| ដឹកជញ្ជូន និងស្តុក | 8.4 | -2.7 | 3.8 | 4.7 | 4.7 | 5.2 | 5.8 | 6.2 | 6.6 |
| បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ | 9.8 | 11.5 | 12.0 | 9.0 | 9.0 | 8.0 | 7.5 | 7.5 | 7.5 |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 7.9 | 4.3 | 3.2 | -1.0 | -4.0 | 0.1 | 1.5 | 2.8 | 4.2 |
| អចលនទ្រព្យ | 8.7 | -8.3 | -8.5 | 0.5 | 0.0 | 1.2 | 2.8 | 3.7 | 4.9 |
| អតិផរណា | 1.8 | 2.9 | 2.9 | 5.3 | 2.1 | 2.7 | 2.5 | 2.5 | 2.5 |
| អត្រាប្តូរប្រាក់ | 4,052 | 4,077 | 4,068 | 4,087 | 4,110 | 4,083 | 4 069 | 4 056 | 4 054 |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ២០១៩-២០២២ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៣-២០២៧)

[23] រាជរដ្ឋាភិបាលកម្ពុជា, *ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧*, ២០២៤

## ២.៣. ចក្ខុវិស័យសេដ្ឋកិច្ចកម្ពុជា

### ២.៣.១. គោលការណ៍ក្នុងការសម្រេចចក្ខុវិស័យឆ្នាំ២០៣០

ប្រទេសកម្ពុជាបានសម្រេចកំណើនសេដ្ឋកិច្ចដ៏រឹងមាំប្រកបដោយចីរភាពក្នុងអត្រាជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំសម្រាប់រយៈពេលជាង ២ ទស្សវត្សរ៍កន្លងមក ដែលនេះធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុត។ កំណើនដ៏ខ្ពស់នេះ បានធ្វើឱ្យកម្ពុជាចាកចេញពីឋានៈជាប្រទេសក្រីក្រ និងបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ ២០១៥ កន្លងទៅ។ តាមរយៈកំណើនខ្ពស់ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ប្រទេសកម្ពុជាបានដាក់ចេញនូវមហិច្ឆតារបស់ខ្លួន ដែលបានកំណត់នូវចក្ខុវិស័យនៅក្នុងដំណើរអភិវឌ្ឍន៍វែងឆ្ងាយគឺការប្រែក្លាយទៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ ២០៥០។ យ៉ាងណាមិញ ដើម្បីសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ ក្នុងការប្រែក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ទាមទារឱ្យកម្ពុជាបំពេញនូវលក្ខខណ្ឌមួយចំនួន ទៅតាមគោលការណ៍របស់ធនាគារពិភពលោកដែលជាដៃគូរអភិវឌ្ឍន៍ ក៏ដូចជាអ្នកកំណត់ចំណាត់ថ្នាក់នៃចក្ខុវិស័យខាងលើ។

ការកំណត់គោលការណ៍នៃការចាត់ថ្នាក់ប្រទេសគឺអាស្រ័យទៅតាមបណ្តាអង្គការ និងស្ថាប័នកំពូលៗដែលបានកំណត់នូវគោលការណ៍ខុសៗគ្នាតាមរយៈការពិនិត្យ និងវាយតម្លៃទៅតាមបរិបទសង្គម-សេដ្ឋកិច្ចជាក់ស្តែង។ តួយ៉ាង ដើម្បីអាចប្រែក្លាយពីប្រទេសប្រាក់ចំណូលមធ្យមកម្រិតទាបទៅជាប្រទេសប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ ធនាគារពិភពលោកបានកំណត់គោលការណ៍ក្នុងការចាត់ថ្នាក់ប្រទេសនីមួយៗដោយផ្អែកលើចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់ (GNI per Capita)។ ប្រទេសដែលមានប្រាក់ចំណូលមធ្យម (MICs) ត្រូវបានកំណត់ថាជាប្រទេសដែលមានប្រាក់ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់ ចន្លោះពី ១ ១៣៦ ទៅ ១៣ ៨៤៥ ដុល្លារក្នុងមនុស្សម្នាក់។ ដោយក្នុងនោះ ធនាគារពិភពលោកបានធ្វើការបែងចែកប្រទេសចំណូលមធ្យមជា ២កម្រិតគឺប្រទេសចំណូលមធ្យមកម្រិតទាបត្រូវមានប្រាក់ចំណូលជាតិសរុប ចន្លោះពី ១ ១៤៦ ទៅ ៤ ៥១៥ ដុល្លារក្នុងមនុស្សម្នាក់ និងប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រូវមានប្រាក់ចំណូលជាតិសរុប ចន្លោះពី ៤ ៤៦៦ ទៅ ១៤ ០០៥ ដុល្លារក្នុងមនុស្សម្នាក់។

តាមរយៈនៃគោលការណ៍របស់ធនាគារពិភពលោក ដើម្បីឱ្យប្រទេសកម្ពុជាសម្រេចបានចក្ខុវិស័យក្នុងការប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ កម្ពុជាត្រូវមានប្រាក់ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់ ៤,៥១៥ ដុល្លារ។[24]

---

[24] Eric Metreau et al., *"World Bank Country Classifications,"* World Bank, July 01, 2024 [World Bank country classifications by income level for 2024-2025]

**តារាងទី៣៖ គោលការណ៍ក្នុងការចាត់ថ្នាក់ប្រទេសរបស់ធនាគារពិភពលោកក្នុងឆ្នាំ ២០២៣ និង២០២៤**

| | Low Income | Lower-middle Income | Upper-middle Income | High Income |
|---|---|---|---|---|
| July 1, 2024 – for FY25 (new) | ≤ 1,145 | 1,146 - 4,515 | 4,516 - 14,005 | > 14,005 |
| July 1, 2023 – for FY24 (previous) | ≤ 1,135 | 1,136 - 4,465 | 4,466 - 13,845 | > 13,845 |

Source: World Bank Group • Figures in United States Dollar (US$)

WORLD BANK GROUP

### ២.៣.២. ឥទ្ធិពលនៃការសម្រេចចក្ខុវិស័យឆ្នាំ២០៣០

ប្រទេសទាំងអស់នៅលើសកលលោកសុទ្ធសឹងតែមានចក្ខុវិស័យក្នុងការប្រែក្លាយប្រទេសរបស់ខ្លួនទៅជាប្រទេសអភិវឌ្ឍន៍ដែលមានសេដ្ឋកិច្ចល្អប្រសើរ ជីវភាពប្រជាជនធូរធារពោរពេញទៅដោយសុខុមាលភាពជាអតិបរមា ប៉ុន្តែគ្រប់គ្នាត្រូវតែទទួលស្គាល់ថារាល់ការអភិវឌ្ឍទាំងអស់នាំមកជាមួយទាំងផលវិជ្ជមាន និងអវិជ្ជមានដោយផលទាំងពីរនេះតែងតែដើរទន្ទឹមគ្នា ដូច្នេះការថ្លឹងថ្លែងឱ្យបានត្រឹមត្រូវពីផលជះមកលើសង្គមជាតិ ដោយធានាថានឹងទទួលបានអត្ថប្រយោជន៍ច្រើនជាងការខាតបង់គឺជារឿងចាំបាច់។

#### ២.៣.២.១. អត្ថប្រយោជន៍ក្រោយពេលសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០

ការផ្លាស់ប្តូរពីប្រទេសដែលមានចំណូលទាបទៅមធ្យមកម្រិតខ្ពស់គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ដែលអាចសម្គាល់បានតាមរយៈកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ការផ្លាស់ប្តូរចំណាត់ថ្នាក់នេះក៏នឹងនាំមកនូវអត្ថប្រយោជន៍សំខាន់ៗមួយចំនួនសម្រាប់កម្ពុជារួមមាន៖

- **កម្រិតជីវភាពកាន់តែប្រសើរឡើង៖** ការប្រែប្រួលឋានៈខាងលើគឺជាសូចនាករដ៏សំខាន់ ដែលបង្ហាញអំពីការកើនឡើងនូវប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាជន។ ប្រាក់ចំណូលកាន់តែខ្ពស់នាំទៅរកការទទួលបានការថែទាំសុខភាពពេញលេញ ការអប់រំយ៉ាងទូលំទូលាយ លំនៅដ្ឋានសមរម្យ និងអាចមានលទ្ធភាពប្រើប្រាស់ទំនិញ និងសេវាកម្មសំខាន់ៗផ្សេងទៀតទៅតាមតម្រូវការរបស់ខ្លួនបានយ៉ាងងាយស្រួលប្រកបដោយគុណភាព និងធ្វើឱ្យស្តង់ដារការរស់នៅរបស់ប្រជាជននឹងកាន់តែល្អប្រសើរពោរពេញទៅដោយសុខុមាលភាពសង្គម។
- **ការរីកចម្រើននៃវិស័យសាធារណៈ៖** ការសម្រេចបានចក្ខុវិស័យនេះ ក៏នឹងនាំមកនូវការកែលម្អ និងអភិវឌ្ឍន៍នូវហេដ្ឋារចនាសម្ព័ន្ធដ៏ច្រើនសម្បូរបែបរួមមាន ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ សំណង់អគារសាលារៀន និងមន្ទីរពេទ្យជាដើម ដែលនឹងជួយសម្រួលដល់ការធ្វើដំណើរបានរហ័សជាងមុន ជួយផ្សារភ្ជាប់តំបន់ដាច់ស្រយាលទៅនឹងទីប្រជុំជនដើម្បីកាត់បន្ថយគម្លាតទីក្រុង និងជនបទ ហើយជាពិសេសអនុញ្ញាតឱ្យប្រជាជនអាចប្រើប្រាស់សេវាសាធារណៈបានយ៉ាងទូលំទូលាយប្រកបដោយសមភាព។

- **វិស័យអប់រំកាន់តែប្រសើរ៖** ពលរដ្ឋកម្ពុជានឹងទទួលបាននូវការអប់រំកាន់តែមានប្រសិទ្ធភាព តាមរយៈការពង្រឹងប្រព័ន្ធអប់រំ ការលើកទឹកចិត្ត ការប្រកួតប្រជែងសមត្ថភាពនានា និងផ្តល់ការបំពាក់បំប៉នជំនាញបច្ចេកទេសស្របទៅតាមតម្រូវការទីផ្សារការងារ ដែលជាកត្តាអាទិភាពគន្លឹះសម្រាប់បណ្តុះឱ្យមាននូវធនធានមនុស្សប្រកបដោយសក្តានុពល ដោយអាចជម្រុញដល់ការអភិវឌ្ឍមូលធនមនុស្សឱ្យមានចំណេះ ជំនាញពេញលេញ និងច្បាស់លាស់ដើម្បីជាឱកាសសម្រាប់ពលរដ្ឋកម្ពុជាមានលទ្ធភាពទទួលបានការងារគ្រប់ៗគ្នា ហើយក៏ជាមូលដ្ឋានក្នុងការធានា និងពង្រឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនបន្ថែមទៀតប្រកបដោយនិរន្តរភាព និងចីរភាព។
- **កាត់បន្ថយភាពក្រីក្រ៖** កំណើនសេដ្ឋកិច្ចខ្ពស់អាចជួយដឹកនាំប្រជាជនចេញពីភាពក្រីក្រ តាមរយៈការបង្កើតឱកាសការងារ កំណើនកម្មករជំនាញ ជម្រុញដល់ការប្រកបរបរលក់ដូររកស៊ី ដែលកាត់បន្ថយភាពមិនស្មើគ្នា គម្លាតសង្គម និងជាពិសេសការចំណាកស្រុកទៅធ្វើពលករនៅក្រៅប្រទេស។
- **សេដ្ឋកិច្ចរឹងមាំ៖** ប្រទេសមួយមានប្រជាជនវណ្ណៈកណ្តាលកាន់តែច្រើន ការចំណាយរបស់អ្នកប្រើប្រាស់ក៏កាន់តែកើនឡើង អាជីវកម្មក្នុងស្រុកក៏មានស្ថានភាពល្អប្រសើរដែលជម្រុញដល់តម្រូវការ និងការផ្គត់ផ្គង់ឱ្យមានលក្ខណៈសម្បូរបែបនៅក្នុងទីផ្សារ ដែលសុទ្ធសឹងតែជាកត្តារុញច្រានកំណើនសេដ្ឋកិច្ចរបស់ប្រទេស ស្តែងចេញតាមរយៈការប្រមូលពន្ធផ្សេងៗ ជាពិសេសពន្ធដារ ដែលឈានទៅរកការឧបត្ថម្ភធនទៅលើវិស័យនានា និងសុវត្ថិភាពសង្គម។
- **ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស៖** សេដ្ឋកិច្ចរីកចម្រើន បរិយាកាសធុរកិច្ចល្អនឹងទាក់ទាញដល់អ្នកវិនិយោគបរទេសមកបណ្តាក់ទុនបន្ថែម ដែលនាំមកនូវសកលភាវូបនីយកម្មពាណិជ្ជកម្ម ការផ្ទេរបច្ចេកវិទ្យា ការចែករំលែកចំណេះដឹង ការបង្កើតឱកាសការងារដល់ពលរដ្ឋកម្ពុជា និងផលវិជ្ជមានជាច្រើនទៀតមកកាន់សង្គមជាតិទាំងមូល។
- **លើកកម្ពស់មុខមាត់លើឆាកអន្តរជាតិ៖** ការទទួលបានងារជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ជួយបង្កើនឥទ្ធិពលកាន់តែខ្លាំង ស្មើមុខស្មើមាត់នៅលើឆាកអន្តរជាតិ បង្កភាពងាយស្រួលក្នុងការចរចារចុះកិច្ចព្រមព្រៀង ការបង្កើនភាពស្និទ្ធស្នាលជាមួយបណ្តាសម្ព័ន្ធមិត្ត ទំនាក់ទំនងនយោបាយការបរទេស និងជម្រុញល្បឿនពាណិជ្ជកម្មអន្តរជាតិ ជាពិសេសអាចចូលរួមយ៉ាងសកម្មនៅក្នុងអភិបាលកិច្ចសកល។
- **សេដ្ឋកិច្ចចម្រុះ៖** ជារឿយៗការផ្លាស់ប្តូរទៅកាន់ស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់ពាក់ព័ន្ធនឹងការផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចចម្រុះជាងមុន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ចទៅលើគ្រប់វិស័យ ដោយកាត់បន្ថយការពឹងផ្អែកលើវិស័យមួយចំនួន និងបង្ការហានិភ័យពីការជាប់គាំងក្នុងវិស័យណាមួយ។

### ២.៣.២.២. ការខាតបង់ក្រោយពេលសម្រេចបានចក្ខុវិស័យឆ្នាំ២០៣០

ការសម្រេចបានឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់មិនមែនសុទ្ធតែទទួលបានអត្ថប្រយោជន៍ និងផ្តល់ផលចំណេញទាំងអស់នោះទេ វាក៏នឹងនាំមកនូវផលខាតបង់មួយចំនួន ដែលកម្ពុជាចាំបាច់ត្រូវត្រៀមខ្លួនឆ្លើយតបឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ ផលខាតបង់ទាំងនោះមានដូចខាងក្រោមៈ

- **វិសមភាពប្រាក់ចំណូលៈ** កំណើនសេដ្ឋកិច្ចឆាប់រហ័សអាចធ្វើឱ្យមានវិសមភាពប្រាក់ចំណូល និងគម្លាតវណ្ណៈសង្គមកាន់តែធ្ងន់ធ្ងរ ប្រសិនបើមិនមានវិធានការគាំទ្រដល់អ្នកមានប្រាក់ចំណូលទាប និងមិនបានគ្រប់គ្រងដោយប្រុងប្រយ័ត្នទៅលើបញ្ហាមួយចំនួនដូចជាការជំនួសកម្លាំងពលកម្ម ដោយប្រើបច្ចេកវិទ្យាមនុស្សយន្ត ឬបញ្ញាសិប្បនិមិត្តជាដើម។
- **អន្ទាក់ចំណូលមធ្យមៈ** គឺជាកាលៈទេសៈ ដែលប្រទេសមួយសម្រេចបានកម្រិតប្រាក់ចំណូលមធ្យម ប៉ុន្តែជួបប្រទះនឹងអត្រាកំណើនយឺត និងស្ថិតក្នុងស្ថានភាពជាប់គាំង (Steady State) មិនអាចឈានទៅដល់កម្រិតចំណូលខ្ពស់បាន ដោយសារកត្តាមួយចំនួនដូចជាកត្តាកង្វះនវានុវត្តន៍ អភិបាលកិច្ចទន់ខ្សោយ ភាពតានតឹងក្នុងសង្គម គម្លាតនៃការអប់រំ ភាពមានកំណត់នៃមូលធន និងការពឹងផ្អែកពេកទៅលើការវិនិយោគពីបរទេសជាដើម។
- **បញ្ហាប្រឈមផ្នែកបរិស្ថានៈ** ការបង្កើនសកម្មភាពសេដ្ឋកិច្ចអាចនាំឱ្យមានការរិចរិល និងប៉ះពាល់ដល់បរិស្ថាន តាមរយៈការកាប់បំផ្លាញធនធានធម្មជាតិ ការប្រើប្រាស់ធនធានលើសកំណត់ ការបំពុលបរិស្ថាន ការប្រែប្រួលអាកាសធាតុ ប្រសិនបើមិនមានការអនុវត្តន៍ប្រកបដោយនិរន្តរភាព។
- **ភាពចលាចលក្នុងសង្គមៈ** ពេលខ្លះការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងសង្គម អាចនាំឱ្យមានភាពតានតឹង និងចលាចលក្នុងសង្គមដោយហេតុថា ផលប្រយោជន៍អាចទទួលបានសម្រាប់តែប្រជាជនមួយក្រុមតូចជាពិសេសអ្នកវិនិយោគ ឬអ្នកមាន បើធៀបទៅនឹងបុគ្គលិកធម្មតាដែលអាចនាំឱ្យគម្លាតសង្គមកាន់តែខ្លាំង។
- **ការពឹងផ្អែកលើសេដ្ឋកិច្ចសកលៈ** បណ្តាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ច្រើនតែប្រឈមមុខនឹងហានិភ័យនៃការប្រែប្រួលសេដ្ឋកិច្ចពិភពលោក ដោយសារការពឹងផ្អែកទៅលើប្រភពខាងក្រៅដូចជាប្រព័ន្ធខ្សែចង្វាក់ផលិតកម្មសកល ទីផ្សារបរទេស លំហូរសាច់ប្រាក់ពីបរទេស និងការផ្ទេរចំណេះដឹង ឬបច្ចេកវិទ្យាពីបរទេស ដោយមិនខិតខំស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយខ្លួនឯង។
- **ការបាត់បង់ជំនួយៈ** ជាធម្មតាការផ្លាស់ប្តូរទៅស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់អាចនាំឱ្យមានការថយចុះនៃជំនួយបរទេស និងការឧបត្ថម្ភធនផ្សេងៗពីដៃគូរអភិវឌ្ឍន៍ អង្គការ ឬម្ចាស់ជំនួយនានា ដោយហេតុថាការផ្តល់ជូនទាំងនោះធ្វើឡើងតាមរយៈស្ថានភាពសង្គម-សេដ្ឋកិច្ចប្រទេសនានា ដោយជាទូទៅប្រទេសកាន់តែលំបាកមានតម្រូវការច្រើន ខ្វះខាតធនធាន មានអាទិភាពខ្ពស់ក្នុងការទទួលជំនួយកាន់តែច្រើន។ កាលណា ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ គេរំពឹងថានឹងមានសេដ្ឋកិច្ច

អភិវឌ្ឍន៍ ទីផ្សារហិរញ្ញវត្ថុកាន់តែច្រើន និងមានដៃគូសហការជាយុទ្ធសាស្ត្រក្នុងវិស័យការបរទេស ពាណិជ្ជកម្ម។ ម្យ៉ាងទៀត បញ្ហាអត្រាការប្រាក់កើនឡើងខ្ពស់ជាងមុនក៏អាចលេចចេញមក ដោយហេតុថាម្ចាស់បំណុលយល់ឃើញថាអ្នកខ្ចីមានលទ្ធភាពខ្ពស់ជាងមុនក្នុងការសងត្រឡប់មកវិញ។

សរុបជារួមមក គុណសម្បត្តិ និងគុណវិបត្តិជាក់លាក់អាចប្រែប្រួល ដោយវាអាស្រ័យទៅលើកាលៈទេសៈជាក់ស្តែងរបស់ប្រទេស រួមទាំងធនធានធម្មជាតិ អភិបាលកិច្ច និងរចនាសម្ព័ន្ធសង្គមរបស់ប្រទេសនីមួយៗ។ ដើម្បីឆ្លើយតបទៅនឹងផលខាតបង់ទាំងនេះ គឺទាមទារឱ្យមានគោលនយោបាយច្បាស់លាស់ និងវិធានការគាំទ្រយ៉ាងមានប្រសិទ្ធភាពក្នុងការជម្រុញឱ្យដំណើរការក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ប្រកបដោយនិរន្តរភាព និងចីរភាព ជាពិសេសនៅក្រោយពេលសម្រេចបានចក្ខុវិស័យនោះ ដើម្បីធានាថាកម្ពុជានឹងទទួលបានផលប៉ះពាល់តិចតួចបំផុតប្រកបដោយនិរន្តរភាព និងចីរភាព។

### ២.៣.៣. ផែនការក្នុងការសម្រេចឱ្យបានចក្ខុវិស័យឆ្នាំ ២០៣០

នៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ និងដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រ ក៏ដូចជាផែនការមួយចំនួនសម្រាប់ជម្រុញឱ្យមាននូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពដើម្បីធានា និងរក្សាគោលជំហរក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យឆ្នាំ ២០៣០ និងឆ្ពោះទៅបំពេញមហិច្ឆតាក្នុងការកែប្រែប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ ២០៥០។ ក្នុងន័យនេះ នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ បានរំលេចនូវគោលដៅមួយចំនួនរួមមាន៖

- ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយភាពធន់នឹងវិបត្តិនានា តាមរយៈការជម្រុញសន្ទុះនៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដើម្បីបង្កើតចន្ទល់ថ្មីៗនៃកំណើន ការលើកកម្ពស់ភាពប្រកួតប្រជែង និងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយគ្រប់គ្រងអត្រាអតិផរណាឱ្យស្ថិតក្នុងអត្រាទាប ធានាស្ថិរភាពអត្រាប្តូរប្រាក់ ខិតខំបង្កើនទុនបម្រុងជាប្រចាំ និង ពង្រឹងការគ្រប់គ្រង់ហិរញ្ញវត្ថុសាធារណៈ រួមបញ្ចូលទាំងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង់ទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព
- បង្កើតការងារឱ្យបានកាន់តែច្រើនទាំងបរិមាណ និងគុណភាពជូនដល់ប្រជាជនកម្ពុជា ជាពិសេសសម្រាប់យុវជនតាមរយៈការពង្រឹងគុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញទាំងជំនាញរឹង និងជំនាញទន់ឱ្យស្របទៅនឹងតម្រូវការក្នុងទីផ្សារការងារ ការផ្តល់ព័ត៌មានឱ្យបានទូលំទូលាយអំពីទីផ្សារការងារ ការកែលម្អលក្ខខណ្ឌការងារប្រកបដោយផាសុកភាព ការលើកកម្ពស់ផលិតភាព ការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និងធុរកិច្ច និងការជម្រុញ និងទាក់ទាញការវិនិយោគទាំងការវិនិយោគក្នុងស្រុក និងការវិនិយោគផ្ទាល់ពីបរទេស
- សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រក្នុងអត្រាទាបជាង ១០% និងបន្តខិតខំកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមាតាមរយៈវិធានការបង្រួមវិសមភាពសេដ្ឋកិច្ចការអភិវឌ្ឍ

និងការកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្ដុំ និងសង្គតិភាព ការកាត់បន្ថយបន្ទុកជីវភាពប្រជាជន និងការផ្ដល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងបរិយាបន្ន

- ❖ បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជន និងបន្តកិច្ចប្រឹងប្រែងលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងពាណិជ្ជកម្ម
- ❖ ធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដោយធ្វើបរមភាវូបនីយកម្ម (Optimization) ផលលាភប្រជាសាស្ត្រ និងពង្រឹងភាពធន់នៃប្រជាសាស្ត្រ លើកកម្ពស់សមភាពយេនឌ័រ គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព បង្កើនហិរញ្ញប្បទានចីរភាព និងបៃតងនៅក្នុងបណ្ដុំកម្ចីសរុបដើម្បីបង្កើនលំហូរហិរញ្ញវត្ថុឆ្ពោះទៅរកការវិនិយោគបៃតង និងសេដ្ឋកិច្ចបៃតង ជម្រុញការវិនិយោគសាធារណៈ ដែលមានភាពធន់នឹងអាកាសធាតុ និងមានការបញ្ជ្រាបកាបូនទាប និងធានាចីរភាពបរិស្ថានព្រមទាំងត្រៀមខ្លួនជាស្រេចដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។[25]

## ២.៣.៤. យុទ្ធសាស្ត្រក្នុងការសម្រេចចក្ខុវិស័យឆ្នាំ២០៣០

ក្នុងបរិការណ៍ក្រោយការរាតត្បាតនៃជំងឺកូវីដ១៩ និងការប្រែប្រួលយ៉ាងឆាប់រហ័សនៃភូមិសាស្ត្រនយោបាយសកល កម្ពុជាមានភាពចាំបាច់ក្នុងការងើបឈរឡើង និងពង្រឹងខ្លួនឱ្យបានមាំមួនដើម្បីស្ដារសង្គម-សេដ្ឋកិច្ចឡើងវិញក្រោយពីមានការខាតបង់ពីវិបត្តិជំងឺកូវីដ១៩ និងវិបត្តិសកលផ្សេងៗទៀត។ ក្នុងនោះ រាជរដ្ឋាភិបាលបានគិតគូរយ៉ាងម៉ត់ចត់ ដោយផ្ដោតលើការសម្រេចឱ្យបាននូវគោលដៅរយៈពេលវែងនៃការកសាងជាតិ និងប្រកាន់យកនូវអភិក្រមនៃការអនុវត្តជាដំណាក់កាលៗ ដោយពង្រីកវិសាលភាព សម្រិតសម្រាំង ធ្វើអាទិភាវូបនីយកម្មនៃកោណអាទិភាពឡើងវិញ ព្រមទាំងកែលម្អគោលនយោបាយ និងយន្តការអនុវត្តទៅតាមការប្រែប្រួលនៃបរិការណ៍ជាតិ និងអន្តរជាតិ និងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ ដោយត្រូវរក្សាជានិច្ចនូវរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នា និងត្រូវអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចឱ្យមាននិរន្តរភាព និងចីរភាព។

ក្នុងន័យនេះ ដោយឈរលើស្មារតី « រក្សាសមិទ្ធផលចាស់ បង្កើតសមិទ្ធផលថ្មី » និង « គិតគូរជាសកល និងអនុវត្តតាមបរិការណ៍ក្នុងប្រទេស (Think Globally and Act Locally) » រាជរដ្ឋាភិបាលនីតិកាលទី៧ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត ព្រមទាំងកំណត់យកនូវអាទិភាពគន្លឹះចំនួន ៥គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដែលត្រូវបានឆ្លុះបញ្ចាំងជាចម្បងតាមរយៈបញ្ចកោណយុទ្ធសាស្ត្រទាំង ៥ នៅក្នុងរចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រទាំងមូល។ យុទ្ធសាស្ត្របញ្ចកោណ ប្រកាន់យកទស្សនវិស័យវែងឆ្ងាយ ដោយកំណត់ទិសដៅអាទិភាព និងអនុវត្តន៍ជា ៥ ដំណាក់កាលសម្រាប់ឈានឆ្ពោះទៅសម្រេចចក្ខុវិស័យឆ្នាំ ២០៣០ ក៏ដូចជាចក្ខុវិស័យឆ្នាំ

[25] រាជរដ្ឋាភិបាលកម្ពុជា, *ឯកសារយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១, ២០២៣,* ទំព័រ៣០-៣១

២០៥០ ដែលឈរលើបេសកកម្មជាប្រវត្តិសាស្ត្រចម្បងពីរ៖ (ទី១). ថែរក្សា និងថែបំប៉នសុខសន្តិភាព ដែលសម្រេចបានមកដោយលំបាកជាមួយនឹងការលះបង់មិនអាចកាត់ថ្លៃបាន និងពូនជ្រំចលនការនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជារួម និង(ទី២). កសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជម្រុញសន្ទុះនៃការអភិវឌ្ឍប្រទេសជាតិឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។

ដើម្បីបង្កើនសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះ ដើម្បីបន្តដំណើរជាមួយនឹងការកសាងភាពធន់រឹងមាំ ក្នុងការឆ្លងកាត់បង្គោលចរនៃការសម្រេចឱ្យបាននូវចក្ខុវិស័យសេដ្ឋកិច្ចធំៗទាំងពីរខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតលើអាទិភាពគន្លឹះ និងដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណចំនួន ៥ រួមមាន៖

❖ **បញ្ចកោណទី ១ : ការអភិវឌ្ឍមូលធនមនុស្ស**

ការអភិវឌ្ឍមូលធនមនុស្សគឺជាទ្រព្យសកម្មជាតិដ៏រឹងមាំសម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច លើកកម្ពស់តម្លៃវប្បធម៌ និងបង្កើតគំនិតថ្មីៗ សំដៅធានាចីរភាពកំណើនរយៈពេលវែង និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ការណ៍នេះបង្ហាញថា ការវិនិយោគក្នុងការអភិវឌ្ឍមូលធនមនុស្សមានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានផ្តោតលើអាទិភាពមុំចំនួន៥ដើម្បីអភិវឌ្ឍន៍មូលធនមនុស្សឱ្យមានចំណេះជំនាញខ្ពស់៖

- ➢ មុំទី១ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ➢ មុំទី២ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស
- ➢ មុំទី៣ ការលើកកម្ពស់សុខភាព និង សុខុមាលភាព ប្រជាជន
- ➢ មុំទី៤ ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង
- ➢ មុំទី៥ ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអរិយធម៌ខ្ពស់ប្រកបដោយសីលធម៌, សមធម៌ និងបរិយាបន្ន។

❖ **បញ្ចកោណទី ២ : ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាពប្រកួតប្រជែង**

ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង គឺជាមូលដ្ឋាននៃការគាំទ្រកំណើនប្រកបដោយចីរភាព និងភាពធន់ ក្នុងរយៈពេលមធ្យម និងវែង តាមរយៈការពង្រីកមូលដ្ឋានផលិតកម្ម ការបង្កើនតម្លៃបន្ថែម ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និងផ្គត់ផ្គង់សកល ព្រមទាំងការទាក់ទាញ និងការជម្រុញវិនិយោគក្នុងឧស្សាហកម្មថ្មីៗ ដែលកំពុងលេចឡើង។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាពមុំចំនួន៥គឺ៖

- ➢ មុំទី១ ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច
- ➢ មុំទី២ ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទីក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល
- ➢ មុំទី៣ ការកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ

- មុំទី៤ ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញ នៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួន ឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និង តំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក (Free-TradeZone)
- មុំទី៥ ការនវានុវត្តយន្តការហិរញ្ញប្បទាន និង ផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ។

❖ **បញ្ហកោណទី ៣ : ការអភិវឌ្ឍវិស័យឯកជន និង ការងារ**

ការអភិវឌ្ឍវិស័យឯកជន និងការងារគឺជារបៀបវារៈគោលនយោបាយសំខាន់សម្រាប់ជម្រុញកំណើននៅក្នុងបរិការណ៍នៃដំណើរការបរិវត្តកម្មសង្គម-សេដ្ឋកិច្ចកម្ពុជានាបច្ចុប្បន្ន និងសម្រាប់រយៈពេល២៥ឆ្នាំខាងមុខ។ រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើន និងជាដៃគូសំខាន់បំផុតក្នុងការបង្កើតការងារ ការបង្កើតគំនិតច្នៃប្រឌិត និងនវានុវត្ត ការលើកកម្ពស់ផលិតភាព និងការពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារតំបន់ និងសកល។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាពមុំចំនួន៥គឺ៖

- មុំទី១ ការអភិវឌ្ឍទីផ្សារការងារ
- មុំទី២ ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- មុំទី៣ ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន
- មុំទី៤ ការពង្រឹងការប្រកួតប្រជែង
- មុំទី៥ ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

❖ **បញ្ហកោណទី ៤ : ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន**

ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្នគឺជាអភិក្រមរួម និងជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មសង្គម-សេដ្ឋកិច្ច ដើម្បីធានាឱ្យសង្គមទាំងមូលអាចត្រៀមខ្លួនបានល្អក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមចម្រុះ និងភាពមិនប្រាកដប្រជានៃសកលភាវូបនីយកម្ម ចីរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាពមុំចំនួន៥ដែលមានដូចជា៖

- មុំទី១ ការធ្វើបរមភាវូបនីយកម្មផលលាភប្រជាសាស្ត្រ, ការពង្រឹង ភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ
- មុំទី២ ការគ្រប់គ្រង ធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និង ទេសចរណ៍ ប្រកបដោយចីរភាព
- មុំទី៣ ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ
- មុំទី៤ ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម
- មុំទី៥ ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង ។

❖ **បញ្ហកោណទី ៥ : ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល**

រាជរដ្ឋាភិបាល បានចាត់ទុកបច្ចេកវិទ្យាឌីជីថលជាកាតាលីករថ្មីដ៏មានសារៈសំខាន់ដែលមានសក្តានុពល និងកាលានុវត្តភាពក្នុងការជម្រុញកំណើនផលិតភាពសេដ្ឋកិច្ច និងសង្គម ក៏ដូចជាប្រសិទ្ធភាពនៃការងាររដ្ឋបាល។ ក្នុងទិសដៅនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ សេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និង គោលនយោបាយ រដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ។

ក្រៅពីនេះ រាជរដ្ឋាភិបាលក៏ផ្តោតលើអាទិភាពមុំចំនួន៥ផងដែររួមាន៖

- មុំទី១ ការកសាងរដ្ឋាភិបាលឌីជីថល និង ពលរដ្ឋឌីជីថល
- មុំទី២ ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តឌីជីថល
- មុំទី៣ ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល
- មុំទី៤ ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល
- មុំទី៥ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។ (យោងតាមឧបសម្ព័ន្ធទី២)

រាជរដ្ឋាភិបាលមិនត្រឹមតែដាក់ចេញនូវយុទ្ធសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែបានដាក់ចេញនូវកម្មវិធីយន្តការកែទម្រង់ និងវិធានការដាក់ស្តែងជាបន្តបន្ទាប់ដូចជា “ កម្មវិធីគោលនយោបាយអាទិភាព ៦ ” ក្នុងនោះ កម្មវិធីចំនួន ៥ ត្រូវបានប្រកាស និងដាក់ឱ្យចាប់ផ្តើមអនុវត្តន៍រួចហើយរួមមាន៖ (ទី១). យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ (ទី២). ការពង្រីកវិសាលភាពមូលនិធិសមធម៌សុខាភិបាលដល់គ្រួសារងាយរងហានិភ័យ និង(ទី៣). ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងងាយរងហានិភ័យនៅទូទាំងប្រទេស ជាមួយនឹងការពង្រីកវិសាលភាពរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដល់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុករបស់សមាជិក ប.ស.ស. ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត (ទី៤). កម្មវិធីហិរញ្ញប្បទានសំដៅលើកស្ទួយផលិតផលកសិកម្ម រកទីផ្សារជូនកសិករ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ និង(ទី៥). ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស និងការរៀបចំឱ្យមានសហគមន៍កសិកម្មបែបថ្មី។

ក្នុងចំណោម “ វិធានការគន្លឹះ ៥ ” ដែលមានចរិតជាការកែទម្រង់ស្ថាប័ន រាជរដ្ឋាភិបាលបានសម្រេចរៀបចំនូវគណៈកម្មាធិការជាតិ ៣ រួមមាន (១). គណៈកម្មាធិការជាតិជម្រុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ (២). គណៈកម្មាធិការជាតិជម្រុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ (៣). គណៈ-កម្មាធិការជាតិជម្រុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល។ បន្ថែមលើនេះ រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផងដែរដើម្បីសម្របសម្រួលដោយសន្តិវិធីក្នុងប្រព័ន្ធយុត្តិធម៌។[26]

[26] រាជរដ្ឋាភិបាលកម្ពុជា, *ឯកសារយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១, ២០២៣,*

# ជំពូកទី ៣

# ឧបសគ្គ និងបញ្ហាប្រឈម ក្នុងការសម្រេចចក្ខុវិស័យ ឆ្នាំ ២០៣០

# ជំពូកទី៣

# ឧបសគ្គ និងបញ្ហាប្រឈមក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០

## ៣.១. ឧបសគ្គ និងបញ្ហាប្រឈមក្នុងការសម្រេចចក្ខុវិស័យឆ្នាំ ២០៣០

### ៣.១.១. បញ្ហាសកល

#### ៣.១.១.១. បញ្ហាជំងឺកូវីដ-១៩

កំឡុងចុងឆ្នាំ២០១៩ ប្រទេសទាំងអស់នៅលើពិភពលោកបានជួបប្រទះនឹងជំងឺរាតត្បាតជាសកល ដែលបានប្រែក្លាយជាវិបត្តិសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរបំផុតមួយក្នុងយុគសម័យទំនើប ដោយបានគម្រាមកំហែងដល់អាយុជីវិតប្រជាជននៅលើសកលលោក។ ជំងឺដ៏កាចសាហាវនេះជាវីរុសថ្មីមួយដែលទើបតែរកឃើញនៅខែវិច្ឆិកា ឆ្នាំ២០១៩ និងមានប្រភពដំបូងមកពីទីក្រុង អ៊ូហាន (Wuhan) ប្រទេសចិន ដោយត្រូវបានគេហៅឈ្មោះជំងឺនេះថាជាជំងឺកូវីដ-១៩ (Covid-19) ឬឈ្មោះម្យ៉ាងទៀតគឺមេរោគវីរុសកូរ៉ូណា (Coronavirus)។ ជម្ងឺកូវីដ-១៩ ឬវីរុសកូរ៉ូណានេះត្រូវបានចម្លងតាមរយៈការប៉ះពាល់ផ្ទាល់ទៅនឹងដំណក់ទឹកតូចៗ ដែលចេញពីប្រព័ន្ធផ្លូវដង្ហើមរបស់អ្នកដែលបានឆ្លងវីរុសតាមរយៈការក្អក និងកណ្តាស់ និងការប៉ះផ្ទាល់ទៅលើផ្ទៃនានាដែលមានវីរុសនោះ។ វីរុសកូវីដ-១៩នេះអាចរស់នៅផ្ទៃខាងក្រៅបានជាច្រើនម៉ោង ហើយវាឆ្លងទៅមនុស្សគ្រប់វ័យបានទាំងអស់ថែមទាំងមានគ្រោះថ្នាក់ដល់អាយុជីវិតទៀតផង ជាពិសេសនោះគឺមនុស្សវ័យចំណាស់ដែលមានជំងឺប្រចាំកាយតែម្តង។ ជំងឺនេះបានបន្តរីករាលដាលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតយ៉ាងឆាប់រហ័ស ដោយបានធ្វើឱ្យបណ្តាប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោកប្រឈមនឹងបញ្ហាសុខភាពសាធារណៈយ៉ាងធ្ងន់ធ្ងរ។ ត្ចយ៉ាង បើគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២០ ចំនួនអ្នកឆ្លងមេរោគកូវីដ-១៩ មានជិត ៦០លាននាក់ និងមានអ្នកបាត់បង់ជីវិតច្រើនជាង ១,៤លាននាក់ នេះបើយោងតាមការវាស់វែងស្ថិតិកូវីដ-១៩ពិភពលោក។ ការណ៍នេះសបញ្ជាក់ឱ្យឃើញថាជំងឺកូវីដ-១៩ជាជំងឺរាតត្បាតដ៏កាចសាហាវបំផុតមួយរបស់ពិភពលោក ហើយជាព្រឹត្តិការណ៍សោកនាដកម្មសកល ដែលពិភពលោកខកខានជួបប្រទះជាយូរណាស់មកហើយ។ ជាមួយស្ថានភាពដ៏លំបាកនេះ នៅក្នុងដំណាក់កាលដំបូងនៃការប្រយុទ្ធប្រឆាំងនឹងជំងឺនេះ បណ្តាប្រទេសជាច្រើនបានសម្រេចជ្រើសរើសនូវវិធានការរឹតត្បិតការធ្វើដំណើរ ព្រមទាំងដាក់ចេញនូវវិធានការសុខាភិបាល និងវិធានការរដ្ឋបាលផ្សេងទៀត រួមទាំងការបិទប្រទេសដោយផ្នែកៗតាមតំបន់ដែលមានការឆ្លងខ្លាំង ឬបិទប្រទេសទាំងស្រុងជាច្រើនលើកច្រើនសារ ដើម្បីគ្រប់គ្រងស្ថានការណ៍ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺដ៏កាចសាហាវនេះ។

ក្នុងន័យនេះបណ្តាប្រទេសជាច្រើន ដែលមានអ្នកវិទ្យាសាស្ត្រជំនាញខាងវេជ្ជសាស្ត្របានខិតខំរិះរកនូវមធ្យោបាយសុខាភិបាល ដោយបានស្រាវជ្រាវរកឃើញ និងផលិតនូវវ៉ាក់សាំងកូវីដ-១៩ ដើម្បីជាជំនួយក្នុងការជម្រុញដល់ការគ្រប់គ្រងការឆ្លងមេរោគវីរុសកូរ៉ូណាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ តាមរយៈនៃវិធានការរដ្ឋបាល

វិធានការសុខាភិបាល និងវិធានដទៃផ្សេងទៀត គួបផ្សំនឹងការបញ្ច្រាបការចាក់វ៉ាក់សាំងការពារជូនដល់ប្រជាពលរដ្ឋនៅលើសកលបានធ្វើឱ្យមានភាពស៊ាំនឹងជំងឺ ហើយវាក៏បាននាំឱ្យស្ថានភាពនៃការចម្លងមេរោគកូវីដ-១៩ បានធូរស្បើយជាងមុន។ ដូចនេះ វិធានការខាងលើនេះពិតជាបានជួយកាត់បន្ថយនូវអត្រាអ្នកឆ្លង និងអ្នកស្លាប់ពីជំងឺកូវីដ-១៩ឱ្យស្ថិតក្នុងអត្រាទាប និងបានជួយឱ្យបណ្តាប្រទេសទាំងអស់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងស្ថានការណ៍នៃការឆ្លងមេរោគដ៏កាចសាហាវនេះ។

បើទោះបីជាប្រទេសជាច្រើនអាចគ្រប់គ្រងការឆ្លងបានក៏ពិតមែន ប៉ុន្តែតាមរយៈការដាក់ចេញនូវវិធានការទាំងអស់នោះ បាននាំឱ្យបង្កជាផលអវិជ្ជមានដល់សេដ្ឋកិច្ចសកលទាំងមូល ដោយក្នុងនោះវាបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ខ្សែសង្វាក់ផ្គត់ផ្គង់សកល រំហូរពាណិជ្ជកម្មសកល ការវិនិយោគសកល និងវិស័យទេសចរណ៍ ជាពិសេសវិស័យសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត។ ត្វយ៉ាងការបិទខ្ទប់តាមតំបន់ ឬតាមប្រទេសផ្សេងៗបានធ្វើឱ្យរោងចក្រ និងសហគ្រាសជាច្រើននៅលើសកលលោកមិនមានដំណើរការផលិតកម្ម ដោយបានកាត់បន្ថយ ឬបញ្ឈប់កត្តាផលិតកម្មរបស់ខ្លួនក្នុងគោលដៅទប់ស្កាត់ការចម្លងមេរោគ ដោយការបិទនេះគឺដោយសារតែនៅក្នុងរោងចក្រ ឬសហគ្រាសតែងតែមានមនុស្សច្រើនប្រមូលផ្តុំគ្នាធ្វើការក្នុងដំណើរការផលិតកម្ម ដែលវាងាយនឹងចម្លងមេរោគ និងអាចឱ្យស្ថានភាពកាន់តែគ្រោះថ្នាក់ថែមទៀតផង។ តាមរយៈនៃការបិទខ្ទប់នេះបានបង្កជាបញ្ហាក្នុងការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់សកល ដែលនាំឱ្យការផ្គត់ផ្គង់ទំនិញមានសភាពខ្វះខាត និងបានបន្តប៉ះពាល់ដល់រំហូរពាណិជ្ជកម្មសកល ដោយធ្វើឱ្យសកម្មភាពពាណិជ្ជកម្មមានការធ្លាក់ចុះយ៉ាងច្រើន។ បើតាមទិន្នន័យពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) បានបង្ហាញថានៅដើមឆ្នាំ២០១៩ ទំហំពាណិជ្ជកម្មសកលមានប្រមាណ ៦,០០០ប៊ីលានដុល្លារសហរដ្ឋអាមេរិក ខណៈពេលដែលមានជំងឺកូវីដ-១៩កើតឡើងនៅចុងឆ្នាំ ២០១៩ ទំហំពាណិជ្ជកម្មសកលបានថយចុះរហូតដល់ក្នុងចំនួនប្រហែល ៤ ៦០០ប៊ីលានដុល្លារសហរដ្ឋអាមេរិក (យោងតាមក្រាហ្វិកទី៤)។ នេះសបញ្ជាក់ឱ្យឃើញថាជំងឺរាតត្បាតសកលបានកាត់បន្ថយទំហំពាណិជ្ជកម្មរហូតដល់ ១ ៤០០ប៊ីលានដុល្លារសហរដ្ឋអាមេរិកដែលជាតួលេខមួយដ៏ច្រើនក្នុងយុគសម័យទំនើប។[27]

**ក្រាហ្វិកទី៤ ៖ បង្ហាញពីទំហំពាណិជ្ជកម្មពិភពលោកចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០២១**




*Source*: Authors' calculations, based on WTO trade data (https://data.wto.org).
*Note*: The figure displays the evolution of non-seasonally adjusted quarterly world trade volume for countries that reported both merchandise and commercial services trade flows.

[27] " *World Trade Report 2021,*" WTO Org, 2021, https://www.wto.org/english/res_e/booksp_e/wtr21_e/01_c_wtr21_e.pdf

លើសពីនេះទៀត ការដាក់ចេញវិធានការបិទខ្ទប់តាមតំបន់ ឬតាមប្រទេសក៏បានធ្វើឱ្យការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅទូទាំងសកលធ្លាក់ចុះផងដែរ ព្រោះនៅក្នុងកាលៈទេសៈក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតនេះ រដ្ឋាភិបាលនៃប្រទេសនីមួយៗបានដាក់កំហិត និងហាមឃាត់រាល់សកម្មភាពដែលប្រមូលផ្តុំទៅដោយមនុស្សច្រើន ដែលនាំឱ្យអាជីវកម្មជាច្រើនបានផ្អាកបណ្តោះអាសន្ន និងបានបាត់បង់នូវប្រាក់ចំណេញ ដោយវាជាហានិភ័យចម្បងមួយសម្រាប់វិនិយោគគិនក្នុងការបណ្តាក់ទុន។ ជាក់ស្តែង បើតាមរយៈទិន្នន័យនៃអង្គការសហប្រជាជាតិបានឱ្យដឹងថា ការវិនិយោគផ្ទាល់ពីបរទេសនៅទូទាំងពិភពលោកបានថយចុះពីចំនួនទឹកប្រាក់ ១,៤៨១ប៊ីលានដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ ២០១៩ មកនៅត្រឹម ៩៦៣ប៊ីលានដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ ២០២០ ដែលមានអត្រាកំណើនអវិជ្ជមាន៣៥%។

**ក្រាហ្វិកទី៥៖ បង្ហាញពីរំហូរនៃការវិនិយោគផ្ទាល់ពីបរទេសនៅទូទាំងពិភពលោកពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២១**




*Source:* UNCTAD calculations, based on data from the UNCTAD foreign direct investment and multinational enterprises database.

ម្យ៉ាងទៀត នៅកំឡុងពេលដែលសភាពការណ៍ជំងឺរាតត្បាតមិនទាន់អាចគ្រប់គ្រងបាន វិធានការរឹតត្បិតការធ្វើដំណើរពីតំបន់មួយទៅតំបន់មួយ និងពីប្រទេសមួយទៅប្រទេសមួយត្រូវបានដាក់ចេញឱ្យអនុវត្តន៍នៅតាមបណ្តាប្រទេសដែលមានចំនួនករណីមនុស្សឆ្លងច្រើន គួបផ្សំនឹងប្រជាពលរដ្ឋមិនហ៊ានចាកចេញពីទីតាំងរបស់ខ្លួន និងការដាក់ធ្វើចត្តាឡីស័កទៀតសោត វាក៏បានធ្វើឱ្យសកម្មភាពវិស័យទេសចរណ៍នៅលើសកលលោកធ្លាក់ចុះយ៉ាងខ្លាំងផងដែរ។ ក្នុងនោះ បើយោងតាមទិន្នន័យរបស់អង្គការសហប្រជាជាតិខាងក្រោម ក្រាហ្វិកបានបង្ហាញថា ចំនួនភ្ញៀវទេសចរណ៍សកលបានថយចុះយ៉ាងគំហុកពីចំនួនភ្ញៀវប្រហែលជាមធ្យម ១២៥ លាននាក់នៅឆ្នាំ ២០១៩ មកនៅត្រឹមចំនួនភ្ញៀវជាមធ្យមប្រមាណ ២៥ លាននាក់នៅឆ្នាំ ២០២០ ដោយមានអត្រាថយចុះ

ជាង ៨០%។ លើសពីនេះទៀត បើប្រៀបធៀបរវាងឆ្នាំ ២០១៩ និង ២០២០ ក្នុងកំឡុងខែមីនា ដល់ខែឧសភា ចំនួនភ្ញៀវទេសចរណ៍បានថយចុះស្ទើរតែ ១០០% ទៅហើយ ដោយមានភ្ញៀវទេសចរណ៍តិចតួចប៉ុណ្ណោះ។[28]

**ក្រាហ្វិកទី៦៖ បង្ហាញពីចំនួនភ្ញៀវទេសចរណ៍អន្តរជាតិគិតចាប់ពីឆ្នាំ ២០១៩ ដល់២០២១**




ប្រភព៖ ការគណនារបស់ UNCTAD

សរុបជារួម ការរីករាលដាលនៃជំងឺកូវីដ-១៩នៅលើសកលលោកបានបង្កជាបច្ច័យអវិជ្ជមានដល់សេដ្ឋកិច្ចសកលទាំងមូល ដោយតាមរយៈទិន្នន័យដែលបានបង្ហាញនៅខាងលើ វាបង្ហាញពីការធ្លាក់ចុះនូវសកម្មភាពសេដ្ឋកិច្ចសកលយ៉ាងគំហុក ដែលវិស័យទាំងអស់ហ្នឹងសុទ្ធសឹងតែជាចរន្តសរសៃឈាមសេដ្ឋកិច្ចដ៏សំខាន់ក្នុងការជម្រុញនូវកំណើនសេដ្ឋកិច្ចសកល។ នៅពេលដែលវិស័យទាំងនោះមានភាពជាប់គាំង និងមិនមានសកម្មភាពសេដ្ឋកិច្ចវាបានបង្កផលប៉ះពាល់ដល់អាជីវកម្ម ភាពមានការងារធ្វើ និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋសកល។ ដោយក្នុងនោះ ការរាតត្បាតនៃជំងឺកូវីដ-១៩បានដាក់សម្ពាធ និងកាត់បន្ថយអត្រាកំណើនសេដ្ឋកិច្ចសកលដល់អត្រាកំណើនអវិជ្ជមាន ៣.៤% នៅឆ្នាំ២០២០ បើតាមរយៈតួលេខរបស់ស្ថាប័នស្ថិតិ(Statista)។ ជាងនេះទៅទៀត ជំងឺរាតត្បាតនេះបានប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពសាធារណៈសកលទាំងមូល ដោយក្នុងនោះបានគម្រាមកំហែងដល់អាយុជីវិត និងស្មារតីរបស់ពលរដ្ឋ ដែលធ្វើឱ្យបាត់បង់នូវសុខុមាលភាពសង្គម។ បើមើល

[28] *"Impact of the Covid-19 Pandemic on Trade and Development,"* UNCTAD, 2022, https://unctad.org/system/files/official-document/osg2022d1_en.pdf

ទាំងវិបត្តិសេដ្ឋកិច្ច និងវិបត្តិសង្គម ការកើតមាននូវជំងឺ និងមេរោគរាតត្បាតសកលនេះបានបង្កជាបញ្ហាដល់សង្គម និងក្លាយជាឧបសគ្គរារាំងដល់កំណើនសេដ្ឋកិច្ចសកល ដែលទាមទារឱ្យប្រទេសនីមួយៗត្រូវយកចិត្តទុកដាក់ និងត្រូវរិះរកនូវមធ្យោបាយ ឬវិធានការនានាដើម្បីការពារអាយុជីវិត និងធ្វើឱ្យជីវភាពរបស់ពលរដ្ឋសកលមានជីវៈភាពល្អប្រសើរជាងមុន។ លុះមកដល់ចុងឆ្នាំ ២០២១ ការគ្រប់គ្រង និងការទប់ទល់ជាមួយនឹងជំងឺកូវីដ-១៩ មានវឌ្ឍនភាពល្អប្រសើរច្រើនជាងមុន ជាពិសេសវ៉ាក់សាំងជាច្រើនប្រភេទត្រូវបានអភិវឌ្ឍន៍ និងផលិតឡើងដើម្បីបង្អើនភាពស៊ាំនឹងជំងឺនៅជុំវិញពិភពលោក។ ដោយរហូតមកដល់ឆ្នាំ២០២៤នេះ ស្ថានភាពនៃជំងឺកូវីដ-១៩ មានភាពធូរស្រាលជាខ្លាំង និងមានកម្រិតហានិភ័យទាប ដែលផ្តល់ឱកាសដល់ការលើកលែងនូវវិធានការរឹតត្បិតការធ្វើដំណើរ វិធានការបិទខ្ទប់ វិធានការសុខាភិបាល និងវិធានការរដ្ឋបាលផ្សេងៗទៀត ដោយជាលក្ខណៈអំណោយផលដល់ការរុញច្រានសេដ្ឋកិច្ចសកលឱ្យមានកំណើនវិញ។ ក៏ប៉ុន្តែ បើទោះបីជាសភាពការណ៍មានលក្ខណៈធូរស្បើយក៏ពិតមែន តែការកើតមានជំងឺរាតត្បាតនេះបានបង្កជាផលវិបាកមួយសម្រាប់ការកសាងសង្គម និងជម្រុញសេដ្ឋកិច្ចសកលឱ្យមានស្ថិរភាព និងនិរន្តរភាពឱ្យដូចពីពេលមុនបានទេ ព្រោះបន្ទាប់ពីមានជំងឺរាតត្បាតកើតឡើង និន្នាការសង្គម និងសកម្មភាពសេដ្ឋកិច្ចមួយចំនួនត្រូវបានផ្លាស់ប្តូរទាំងស្រុង ដែលតម្រូវឱ្យសកលលោករៀនរស់នៅក្នុងបរិបទថ្មីមួយផ្សេងទៀត ដោយក្នុងនោះបណ្តាប្រទេសនីមួយត្រូវប្រឈមមុខនឹងឧបសគ្គជាច្រើនបន្ថែមទៀតក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។

### ៣.១.១.២. សង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន

ភាពតានតឹងរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែនមានជាយូរយារណាស់មកហើយ។ ដោយក្នុងនោះ ការលុកលុយយ៉ាងសម្ងាត់ពីសំណាក់កងទ័ពរុស្ស៊ីនៅតំបន់គ្រីមេ (Crimea) បានធ្វើឱ្យប្រទេសអ៊ុយក្រែនបាត់បង់ឧបទ្វីបគ្រីមេចេញពីដែនដីរបស់ខ្លួន ហើយប្រទេសរុស្ស៊ីបានកាន់កាប់ និងដាក់បញ្ចូលតំបន់គ្រីមេឱ្យស្ថិតក្នុងឧបសម្ព័ន្ធរុស្ស៊ីនៅខែកុម្ភៈ ឆ្នាំ២០១៤។ ជម្លោះរវាងប្រទេសទាំងពីរត្រូវបានបន្តវាយប្រហារដល់តំបន់ដុនបាស (Donbass) ស្ថិតនៅភាគខាងកើតនៃប្រទេសអ៊ុយក្រែនដោយកងទ័ពរុស្ស៊ី និងក្រុមឧទ្ទាមប្រយុទ្ធជាមួយនឹង កងទ័ពអ៊ុយក្រែនអស់រយៈពេលជាច្រើនឆ្នាំ។ លុះមកដល់ឆ្នាំ២០២១ ភាពតានតឹងនៃប្រទេសទាំងពីរកាន់តែកើនឡើងកម្ដៅខ្លាំងនៅពេលប្រធានាធិបតីអ៊ុយក្រែនបានស្នើសុំចូលជាសមាជិករបស់អង្គការ NATO ដែលធ្វើឱ្យប្រធានាធិបតីរុស្ស៊ីផ្ទុះកំហឹងជាខ្លាំង ហើយរុស្ស៊ីបានចាប់ផ្ដើមដាក់កងទ័ពនៅជិតព្រំដែនប្រទេសអ៊ុយក្រែន។ ចាប់ពីពេលនោះមកជម្លោះរុស្ស៊ី-អ៊ុយក្រែនបានបង្កជាភាពតានតឹងកាន់តែខ្លាំងឡើងៗ ដោយនៅខែកុម្ភៈ ឆ្នាំ ២០២២ រុស្ស៊ីបានចាប់ផ្ដើមបើកប្រតិបត្តិការយោធាពិសេសធ្វើការលុកលុយពាសពេញផ្ទៃប្រទេស ហើយចាប់ផ្ដើមកាន់កាប់បានតំបន់មួយចំនួនក្នុងដែនដីប្រទេសអ៊ុយក្រែន។ ការឈ្លានពានលើទឹកដីប្រទេសអ៊ុយក្រែនបានបង្កឱ្យកើតឡើងនូវសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែននៅដើមឆ្នាំ ២០២២ រហូតមកដល់ពេលបច្ចុប្បន្ននេះ។[29]

[29] Michael Ray, *"Russia-Ukraine War,"* Britannica, Sep 01,2024, https://www.britannica.com/event/2022-Russian-invasion-of-Ukraine

បញ្ហាសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែនបានបន្សល់ទុកនូវផលវិបាកយ៉ាងធ្ងន់ធ្ងរ ដែលមិនត្រឹមតែប៉ះពាល់ដល់សង្គម-សេដ្ឋកិច្ចរបស់ប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែនតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជះឥទ្ធិពលដល់សង្គម-សេដ្ឋកិច្ចលើពិភពលោកទាំងមូលទៀតផង។ តួយ៉ាង ប្រទេសអ៊ុយក្រែនជាដែនដីក្នុងចំណោមកន្លែងស្តុក និងផ្គត់ផ្គង់ស្រូវសាឡីដ៏ធំបំផុតមួយរបស់ពិភពលោក ឬក៏ជាប្រទេសដែលមានដីសម្បូរបែប និងអាកាសធាតុអំណោយផលដល់ការផលិតស្រូវសាឡី និងគ្រាប់ធញ្ញជាតិ។ ការឈ្លានពានរបស់រុស្ស៊ីបានដាក់សម្ពាធយ៉ាងខ្លាំងដល់ខ្សែសង្វាក់ផលិតកម្ម និងការនាំចេញស្បៀងអាហាររបស់អ៊ុយក្រែន។[30] ការផ្គត់ផ្គង់ស្បៀងអាហារពីអ៊ុយក្រែនទៅកាន់បណ្តាប្រទេសផ្សេងទៀតបានជួបការលំបាកដោយសារសង្គ្រាមបានធ្វើឱ្យរាំងស្ទះដល់ខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្ម និងការដឹកជញ្ជូនស្បៀងអាហាររបស់អ៊ុយក្រែន ដោយនាំឱ្យផលិតភាពនៃកត្តាផលិតកម្មស្រូវសាឡីបានធ្លាក់ចុះ ដែលធ្វើឱ្យការនាំចេញថយចុះពីបរិមាណប្រហែល ៧.៧ លានតោននៅត្រីមាសទី ១ មកសល់ត្រឹមបរិមាណ ៥.៩ លានតោននៅត្រីមាសទី ៣ ក្នុងឆ្នាំ ២០២២ (យោងតាមក្រាហ្វិកទី៧)។ ចំណែកឯប្រទេសរុស្ស៊ីវិញក៏ជាប្រទេសដែលផ្គត់ផ្គង់ស្រូវសាឡី និងប្រភពថាមពលច្រើនបំផុតមួយរបស់ពិភពលោកផងដែរ។ នៅពេលសង្គ្រាមបានផ្ទុះឡើង សហគមន៍អន្តរជាតិ ដែលក្នុងនោះមានសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និងបណ្តាប្រទេសមួយចំនួនផ្សេងទៀតបានថ្កោលទោសពីការឈ្លានពានរបស់ប្រទេសរុស្ស៊ីទៅលើប្រទេសអ៊ុយក្រែន និងបានដាក់នូវទណ្ឌកម្មសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងន់ទៅដល់ប្រទេសរុស្ស៊ីក្នុងការរឹតបន្តឹងលើវិស័យពាណិជ្ជកម្ម ហិរញ្ញវត្ថុ បច្ចេកវិទ្យា ទំនិញប្រើប្រាស់ ឧស្សាហកម្ម និងការដឹកជញ្ជូនពីប្រទេសរុស្ស៊ីចូលទៅក្នុងសហគមន៍អន្តរជាតិ។ ការថ្កោលទោស និងការដាក់ទណ្ឌកម្មសេដ្ឋកិច្ចនេះបានធ្វើឱ្យប្រទេសរុស្ស៊ីមានភាពលំបាក ឬមិនអាចផ្គត់ផ្គង់ និងនាំចេញស្រូវសាឡីទៅកាន់ទីផ្សារនៅប្រទេសទាំងនោះបានទេ។ ដូចនេះ ប្រទេសរុស្ស៊ីបានបាត់បង់ចំណែកទីផ្សារក្នុងការនាំចេញស្រូវសាឡីមួយចំនួន ដែលនាំឱ្យបរិមាណនៃការនាំចេញស្រូវសាឡីធ្លាក់ចុះក្នុងបរិមាណពី ៧ លានតោន នៅត្រីមាសទី១ ដល់ បរិមាណ ៥.៨ លានតោន នៅត្រីមាសទី ៣ ក្នុងឆ្នាំ ២០២២ ។

[30] ឆន ឌីណា, “ *តើសង្គ្រាមរុស្ស៊ីអ៊ុយក្រែនធ្វើឱ្យភាពក្រីក្រ និងថ្លៃទំនិញសកលកើនឡើងរបៀបណា?,*” rfi, ធ្នូ ១២, ២០២២, https://www.rfi.fr/km/

### ក្រាហ្វិកទី៧៖ បង្ហាញពីបរិមាណនៃការនាំចេញស្រូវសាឡីចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៣




ប្រភព៖ ធនាគារពិភពលោក

តាមរយៈទិន្នន័យចាប់ពីត្រីមាសទី ១ ដល់ត្រីមាសទី ៣ ក្នុងឆ្នាំ ២០២២ ការផ្គត់ផ្គង់ស្រូវសាឡីពីប្រទេសរុស្ស៊ី និងអ៊ុយក្រែនទៅកាន់ទីផ្សារពិភពលោកមានបរិមាណថយចុះ ២.២ លានតោន ស្របពេលតម្រូវការស្រូវសាឡីនៅតែបន្តកើនឡើង។ ការណ៍នេះ បានបណ្តាលឱ្យថ្លៃស្រូវសាឡីកើនឡើងខ្ពស់ពីតម្លៃប្រហែល ១,០៥០ ដុល្លារក្នុងមួយប៊ូសែល ទៅតម្លៃប្រមាណ ១,១៨០ ដុល្លារក្នុងមួយប៊ូសែល (USD/BU)។

### ក្រាហ្វិកទី៨៖ បង្ហាញពីថ្លៃនៃស្រូវសាឡីចាប់ពីចុងឆ្នាំ ២០២០ ដល់ដើមឆ្នាំ ២០២៤




ប្រភព៖ TradingEconomics

លើសពីនេះទៅទៀត ការដាក់ទណ្ឌកម្មរបស់សហគមន៍អន្តរជាតិ ជាពិសេសសហរដ្ឋអាមេរិកមិនត្រឹមតែប៉ះពាល់ដល់ខ្សែសង្វាក់ផ្គត់ផ្គង់ស្រូវសាឡីរបស់រុស្សីតែប៉ុណ្ណោះទេ វាថែមទាំងផ្តល់នូវឥទ្ធិពលអវិជ្ជមានដល់វិស័យជាច្រើនរបស់រុស្សី ជាពិសេសការផ្គត់ផ្គង់ប្រភពថាមពល។ គួររម្លឹកផងដែរថា ប្រទេសរុស្សីក៏ជាប្រទេសដែលស្តុក និងផលិតប្រភពថាមពលធំជាងគេមួយរបស់ពិភពលោក។ នៅពេលបណ្តាប្រទេសទាំងនោះបានដាក់បម្រាមហាមឃាត់លើការនាំចូល ឬដឹកជញ្ជូនប្រេងឆៅ និងផលិតផលគីមីឥន្ធនៈពីរុស្សី វាបានធ្វើឱ្យបរិមាណនៃការផ្គត់ផ្គង់ប្រភពថាមពលនៅលើទីផ្សារសកលធ្លាក់ចុះក្នុងបរិមាណមួយ ដែលបានរុញឱ្យថ្លៃថាមពលកើនឡើងផងដែរ។

តាមរយៈទិន្នន័យនៃតម្លៃថាមពលខាងក្រោម យើងឃើញថា កំឡុងពេលបើកការឈ្លានពានរបស់រុស្សីនៅចម្លោះដើមឆ្នាំ ដល់ចុងឆ្នាំ២០២២ តម្លៃនៃប្រភេទថាមពលមួយចំនួនបានកើនឡើងក្នុងថ្លៃរួមមាន៖

- ថ្លៃឧស្ម័នធម្មជាតិបានកើនឡើងពីតម្លៃប្រហែល ៥ ទៅជិត ១០ដុល្លារក្នុងមួយលានឯកតាកម្តៅ (dollar per million British units) ដែលនេះវាបានកើនឡើងក្នុងអត្រាទ្វេដង។
- តម្លៃប្រេងឆៅមានការកើនឡើងពីតម្លៃប្រហែលជិត ១០០ ដុល្លារក្នុងមួយបារ៉ែល (dollar per barrel) ទៅតម្លៃប្រមាណ ១១០ ដុល្លារក្នុងមួយបារ៉ែល។
- ថ្លៃថាមពលអគ្គិសនីបានកើនឡើងពីថ្លៃប្រហែល ១៥០ ទៅថ្លៃខ្ពស់បំផុតប្រមាណ ៦០០ យូរ៉ូក្នុងមួយមេហ្គាវ៉ាត់ម៉ោង (euro per megawatt hour) ដែលវាជាតួលេខនៃការកើនឡើងថ្លៃដ៏ខ្ពស់មួយ។

**ក្រាហ្វិកទី៩៖ បង្ហាញពីតម្លៃនៃថាមពលចាប់ពីចុងឆ្នាំ២០២១ ដល់ដើមឆ្នាំ២០២៤**




ប្រភព៖ គេហទំព័រ Financial TImes

សរុបជារួម នៅក្នុងស្ថានភាពនៃវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនបានធ្វើឱ្យពិភពលោកបាត់បង់ចំណែកដ៏ធំសម្រាប់ផលិតភាពនៃកត្តាផលិតកម្មស្រូវសាឡី និងប្រភពថាមពលទៅកាន់ទីផ្សារសកលព្រោះទាំងប្រទេសអ៊ុយក្រែន និងប្រទេសរុស្ស៊ីគឺសុទ្ធតែជាប្រទេសដែលមានចំណែកដ៏សំខាន់ក្នុងការផ្គត់ផ្គង់ស្បៀងអាហារ និងប្រភពថាមពលទៅកាន់ទីផ្សារពិភពលោក ដែលការផ្គត់ផ្គង់នេះពិតជាមានសារៈសំខាន់ណាស់នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋសកល ជាពិសេសពលរដ្ឋរបស់បណ្តាប្រទេសនៅក្នុងសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ដោយវាជាប់ទាក់ទងដោយផ្ទាល់ដល់សុវត្ថិភាពស្បៀងអាហារ និងការដឹកជញ្ជូន។ នៅពេលបរិមាណផ្គត់ផ្គង់ទំនិញទាំងនោះមិនអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងបានទេ នោះវាក៏បានរុញច្រានឱ្យថ្លៃទំនិញ និងសេវាកម្មកើនឡើងផងដែរ។ ការណ៍នេះ បានធ្វើឱ្យពិភពលោកកំពុងប្រឈមមុខនឹងវិបត្តិស្បៀងអាហារសកល និងបញ្ហាអត្រាអតិផរណាខ្ពស់ ដែលវាអាចនាំឱ្យអត្រានៃភាពក្រីក្រ និងបទល្មើសឧក្រិដ្ឋកម្មកើនឡើង មានវិសមភាពសង្គម និងសុខុមាលភាពសង្គមធ្លាក់ចុះ ដោយបញ្ហាទាំងអស់នេះនឹងធ្វើឱ្យរារាំងដល់ការអភិវឌ្ឍប្រទេស និងនាំឱ្យសង្គម-សេដ្ឋកិច្ចសកលគ្មានស្ថិរភាព។[31]

**ក្រាហ្វិកទី១០៖ អត្រាអតិផរណាសកល ចាប់ពីឆ្នាំ ២០១៩ ដល់ ឆ្នាំ២០២៤**




ប្រភព៖ Statista 2024

[31] Einar H. Dyvik, *"Annual inflation rate for consumer prices worldwide,"* Statista, July 04, 2024, https://www.statista.com/statistics/1325670/inflation-rate-continent/

### ៣.១.១.៣. ភាពតានតឹងភូមិសាស្ត្រនយោបាយ

កត្តាភូមិសាស្ត្រនយោបាយដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមពង្រឹងអំណាច និងឥទ្ធិពលរបស់ប្រទេសមួយ ឬក្រុមប្រទេស ដោយវាអាស្រ័យទៅលើចំណងមិត្តភាពជាមួយប្រទេសផ្សេងៗក្នុងទិដ្ឋភាពនយោបាយអន្តរជាតិ និងកិច្ចសហប្រតិបត្តិការ។ ជាទូទៅ ប្រទេសមហាអំណាចធំៗមានការប្រកួតប្រជែងគ្នាក្នុងការទាញយកផលចំណេញពីទិដ្ឋភាពភូមិសាស្ត្រនយោបាយសម្រាប់ពង្រឹង ឬរក្សានូវអំណាច និងពង្រីកឥទ្ធិពលរបស់ខ្លួនក្នុងគោលដៅគ្រប់គ្រងទៅតាមតំបន់ភូមិសាស្ត្រផ្សេងៗ និងការស្វះស្វែងរកធនធានបន្ថែមទៀត ដើម្បីឱ្យទទួលជាផលប្រយោជន៍ទាំងផ្នែកភូមិសាស្ត្រ និងផ្នែកសេដ្ឋកិច្ចសម្រាប់ជម្រុញឱ្យប្រទេសមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងចីរភាព។ ទោះជាយ៉ាងណាក៏ដោយ ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយគឺទាមទារឱ្យមាននូវការផ្តល់ផលប្រយោជន៍ជារួមឱ្យគ្នាទៅវិញទៅមកក្នុងគោលដៅរួបរួម និងសាមគ្គីគ្នាដើម្បីអភិវឌ្ឍន៍ប្រជាជាតិឱ្យមានភាពរីកចម្រើន ដោយមិនអាចគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនតែម្ខាងនោះទេ។ ជាការពិត នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កត្តាភូមិសាស្ត្រនយោបាយបាននឹងកំពុងជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ការប្រកួតប្រជែងអំណាចនយោបាយអន្តរជាតិទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រតំបន់ និងសេដ្ឋកិច្ច។ ក្នុងពេលជាមួយគ្នានេះ កត្តាភូមិសាស្ត្រនយោបាយនៅលើសកលលោកកំពុងតែមានភាពប្រែប្រួល ឬផ្លាស់ប្តូរស្ទើរតែទាំងស្រុង ដោយមាននិន្នាការវិវត្តន៍ទៅរកប្រព័ន្ធអន្តរជាតិមួយដែលមានលក្ខណៈសកល និងពហុប៉ូលដោយតំបន់ ឬប្រទេសនីមួយៗអាចទាញយកផលប្រយោជន៍ គុណតម្លៃ និងរបៀបវារៈរៀងៗខ្លួន ហើយប្រទេសទាំងនោះក៏អាចមានសិទ្ធិក្នុងការសហការណ៍រួមគ្នាក្រោមឥទ្ធិពលរបស់ប្រទេសណាមួយ ឬក៏អាចប្រកួតប្រជែងគ្នាទៅតាមបណ្តុំនៃប្រទេស។[32] ជាក់ស្តែង នៅក្នុងឆ្នាំ២០២៤នេះ ភូមិសាស្ត្រនយោបាយនៅជុំវិញពិភពលោកកំពុងតែមានភាពតានតឹងកាន់តែខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារតែមានការប្រកួតប្រជែងអំណាចនយោបាយ និងពាណិជ្ជកម្មរវាងប្រទេសជាច្រើន ជាពិសេសប្រទេសមហាអំណាចធំៗ ដែលវាបង្កឱ្យលេចឡើងនូវបញ្ហាជាបន្តបន្ទាប់ ដោយនាំឱ្យជះឥទ្ធិពលដល់កិច្ចសហប្រតិបត្តិការ និងសណ្តាប់ធ្នាប់សកល ជាពិសេសបង្កជាផលវិបាក និងឧបសគ្គរាំងស្ទះដល់ការជម្រុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមរបស់ប្រទេសនានាលើសកលលោក។ ទំនាក់ទំនងការទូត និងការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងបណ្តាប្រទេសមួយចំនួនកំពុងតែមានការកើនឡើងកម្តៅជាខ្លាំង និងមានការបែងចែកអំណាចគ្នា ដែលក្នុងនោះបានបង្ហាញឱ្យឃើញនៅក្នុងបញ្ហាអសន្តិសុខ និងជម្លោះភូមិសាស្ត្រនយោបាយមួយចំនួនដូចខាងក្រោម៖

#### ក. ភាពតានតឹងរវាងសហរដ្ឋអាមេរិក និងចិន

ក្រោយពីការបញ្ចប់សង្គ្រាមលោកលើកទី២ និងសង្គ្រាមត្រជាក់រួចមក សហរដ្ឋអាមេរិកបានក្លាយជាប្រទេសមហាអំណាចទីមួយដែលមានអំណាច និងឥទ្ធិពលខ្លាំងជាងគេបំផុតនៅក្នុងពិភពលោក ដោយប្រទេស

[32] សន ស៊ុនលី, *"ផ្លូវយល់ពីពិភពលោកពហុប៉ូល,"* , AMS Economy, August 31, 2023, https://economy.ams.com.kh/economic/news/understanding-the-world-with-multipolar-system/

នេះមានអំណាចផ្នែកយោធា ទំនាក់ទំនងការទូត និងសេដ្ឋកិច្ចស្ថិតក្នុងលំដាប់ថ្នាក់លេខមួយ ដែលមិនមានប្រទេសណាជាដៃគូប្រកួតប្រជែង ឬដាក់គំនាបមកលើប្រទេសរបស់ខ្លួនបាននោះទេ។ ប៉ុន្តែអ្វីៗក៏បានប្រែប្រួលនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារតែមានដំណើរស្ទុះឡើងយ៉ាងឆាប់រហ័សនៃការលូតលាស់ស្ទើរតែគ្រប់វិស័យនៅក្នុងប្រទេសចិន ជាពិសេសវិស័យពាណិជ្ជកម្ម ដែលបានរុញច្រានឱ្យសេដ្ឋកិច្ចចិនមានកំណើនខ្ពស់ប្រកបដោយនិរន្តភាព និងមានភាពធន់ ហើយបានផ្តល់ឱកាសឱ្យប្រទេសនេះមានលទ្ធភាពអាចក្លាយជាដៃគូប្រកួតប្រជែងមហាអំណាចសេដ្ឋកិច្ចជាមួយសហរដ្ឋអាមេរិក។

មិនតែប៉ុណ្ណោះ ប្រទេសចិនក៏ជាប្រទេសមួយដែលមានឥទ្ធិពលទៅលើកត្តាភូមិសាស្ត្រនយោបាយ និងទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសផ្សេងៗទៀតផងដែរ បន្ទាប់ពីសហរដ្ឋអាមេរិក។ តាមរយៈនៃការរីកចម្រើនយ៉ាងលឿនដ៏គួរឱ្យកត់សម្គាល់របស់ប្រទេសចិនទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច វាបានធ្វើឱ្យសហរដ្ឋអាមេរិកមានភាពភ្ញាក់ផ្អើល និងមើលឃើញពីសក្តានុពលរបស់ចិនក្នុងការប្រជែងជាប្រទេសមហាអំណាចជាមួយខ្លួន ហើយបានបង្កជាក្តីព្រួយបារម្ភ និងទុក្ខកង្វល់សម្រាប់សហរដ្ឋអាមេរិកក្នុងការរក្សានូវឋានៈជាប្រទេសមហាអំណាចទីមួយនៅក្នុងសកលលោក។

ការណ៍នេះ បាននាំឱ្យសហរដ្ឋអាមេរិកបានដាក់ចេញនូវគោលនយោបាយមួយចំនួនដើម្បីកាត់បន្ថយ និងរារាំងកំណើនសេដ្ឋកិច្ចចិនកុំឱ្យមានអត្រាកំណើនខ្ពស់ពេក ជាពិសេសទប់ស្កាត់ និងកាត់បន្ថយការមានឥទ្ធិពលភូមិសាស្ត្រនយោបាយអន្តរជាតិរបស់ប្រទេសចិន។ ដោយចាប់ពីពេលនោះមក ភាពតានតឹងនៃប្រទេសទាំងពីរកាន់តែកើនឡើង និងមានលក្ខណៈស្មុគស្មាញជាខ្លាំង ដែលគិតមកដល់ឆ្នាំ២០២៤នេះ សហរដ្ឋអាមេរិក និងប្រទេសចិនបាននឹងកំពុងតែមានភាពប្រកួតប្រជែងគ្នាខ្លាំងលើទិដ្ឋភាពពាណិជ្ជកម្ម និងភូមិសាស្ត្រនយោបាយ ដោយក្នុងនោះបង្កឱ្យកើតមាននូវបញ្ហាមួយចំនួនដូចជា៖

❖ **សង្គ្រាមពាណិជ្ជកម្ម**

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយមកនេះ ប្រទេសចិនបានក្លាយជាប្រទេសមហាអំណាចសេដ្ឋកិច្ចមួយនៅក្នុងពិភពលោកបន្ទាប់ពីសហរដ្ឋអាមេរិក។ ក្នុងនាមសហរដ្ឋអាមេរិកជាមហាអំណាចសេដ្ឋកិច្ចលេខមួយលើលោក សហរដ្ឋអាមេរិកមិនទុកឱ្យសេដ្ឋកិច្ចចិនមានកំណើនខ្ពស់ៗជារៀងរាល់ឆ្នាំនោះទេ ដោយត្រូវធ្វើយ៉ាងណាទប់ស្កាត់ និងកាត់បន្ថយអត្រាកំណើនសេដ្ឋកិច្ចចិន។ ក្នុងន័យនេះ ដើម្បីរារាំងកំណើនសេដ្ឋកិច្ចចិនកុំឱ្យមានអត្រាកំណើនខ្ពស់ពេក សហរដ្ឋអាមេរិកបានដាក់នូវចេញនូវការអនុវត្តគោលនយោបាយពាណិជ្ជកម្ម ដោយបានតម្លើងនូវអត្រាពន្ធគយយ៉ាងខ្ពស់ទៅលើផលិតផល និងទំនិញនាំចេញរបស់ប្រទេសចិនចូលមកក្នុងប្រទេសខ្លួន។ បើតាមរយៈទិន្នន័យរបស់ស្ថាប័នមូលដ្ឋានពន្ធ (TFO) នៅក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ រដ្ឋាភិបាលអាមេរិកកំណត់អត្រាពន្ធក្នុងអត្រាអតិបរមា ២៥%នៃទំនិញនាំចេញរបស់ប្រទេសចិន ដោយគិតជាទឹកប្រាក់ប្រមាណជិត ៩០ ប៊ីលានដុល្លារសហរដ្ឋអាមេរិក ដែលជាចំនួននៃការបង្កើនអត្រាពន្ធខ្ពស់បំផុតមិនធ្លាប់មាននៅក្នុងរយៈពេល

១ទសវត្សន៍ចុងក្រោយនេះ។ ក្នុងន័យនេះ វានឹងធ្វើឱ្យទំនិញរបស់ចិនឡើងថ្លៃ ហើយពិបាកក្នុងការប្រកួតប្រជែងក្នុងទីផ្សារអាមេរិក បន្ទាប់មកធ្វើឱ្យវិនិយោគិនដែលបោះទុនលើវិស័យផលិតកម្ម និងក្រុមហ៊ុនមួយចំនួនដែលមានទីតាំងផលិតនៅប្រទេសចិនបានផ្លាស់ប្តូរទិសដៅទៅបើករោងចក្រថ្មីនៅប្រទេសផ្សេងទៀត ដើម្បីគេចវេសពីរបាំងពន្ធគយដ៏ខ្ពស់របស់សហរដ្ឋអាមេរិក។ ការធ្វើនូវគោលនយោបាយពាណិជ្ជកម្មបែបនេះ នឹងធ្វើឱ្យវិស័យផលិតកម្មដែលជាចន្ទុលសេដ្ឋកិច្ចសំខាន់មួយរបស់ចិនបានថមថយនូវការវិនិយោគ និងកាត់បន្ថយទំហំនាំចេញដោយនាំឱ្យរារាំងដល់កំណើនសេដ្ឋកិច្ចចិនឱ្យមានអត្រាទាបជាងមុន។ គួរបញ្ជាក់ផងដែរថា ទីផ្សារអាមេរិកមានទំហំធំជាងគេ ស្របពេលសេដ្ឋកិច្ចចិនពឹងផ្អែកមួយផ្នែកធំលើការនាំចេញទំនិញ ដូចនេះនៅពេលដែលប្រទេសចិនបានបាត់បង់ចំណែកទីផ្សារនៅក្នុងទីផ្សារអាមេរិក វាបានបង្កជាបច្ច័យអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចចិនជាខ្លាំង។ បន្ទាប់ពីមានការដាក់នូវរបាំងពន្ធគយយ៉ាងតឹងរឹងលើផលិតផលនាំចេញរបស់ប្រទេសចិន ភាគីប្រទេសចិនក៏បានតបតទៅវិញ ដោយបានតម្លើងអត្រាពន្ធគយលើទំនិញនាំចូលពីសហរដ្ឋអាមេរិកផងដែរ ដោយក្នុងនោះរដ្ឋាភិបាលចិនក៏បានអនុម័តនូវអត្រាពន្ធ ២៥% លើផលិតផល ១០៦មុខនៃទំនិញរបស់អាមេរិក នេះបើយោងតាមរបាយការណ៍របស់ក្រសួងហិរញ្ញវត្ថុរបស់ចិននៅក្នុងឆ្នាំ ២០១៨។

ដូច្នេះ នៅពេលសហរដ្ឋអាមេរិក និងប្រទេសចិនដាក់អនុវត្តន៍នូវរបាំងពាណិជ្ជកម្ម ដោយបានតម្លើងអត្រាពន្ធគយក្នុងកម្រិតខ្ពស់ វាបានផ្តល់ផលជាអវិជ្ជមានដល់ប្រទេសទាំងពីរក្នុងការប្រឈមមុខនឹងបញ្ហាថ្លៃដើមខ្ពស់សម្រាប់នាំចេញ ការធ្លាក់ចុះទុនវិនិយោគ ប្រជាជនបាត់បង់ការងារធ្វើ និងទំនាក់ទំនងពាណិជ្ជកម្មមានទំហំទាបជាងមុន។ លើសពីនេះទៅទៀត សង្គ្រាមពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ចទាំងពីរនេះ ក៏បាននាំឱ្យជះឥទ្ធិពលដល់ទិដ្ឋភាពសេដ្ឋកិច្ចសកលទាំងមូលផងដែរ ដោយវាធ្វើឱ្យខ្សែសង្វាក់ផ្គត់ផ្គង់សកលមានភាពរអាក់រអួលដោយសារការផ្លាស់ប្តូរទីតាំង ឬផ្អាកដំណើរការបណ្តោះអាសន្នរបស់អ្នកវិនិយោគ។ ស្របពេលជាមួយគ្នានេះ សង្គ្រាមពាណិជ្ជកម្មរវាងប្រទេសកំពូលៗទាំងពីរក៏បានធ្វើឱ្យមានការប្រែប្រួលលើទីផ្សារហិរញ្ញវត្ថុដែលប៉ះពាល់ដល់តម្លៃភាគហ៊ុន និងបង្កើននូវហានិភ័យខ្ពស់ជាងមុន។ មិនត្រឹមតែប៉ុណ្ណោះ ការបង្កជម្លោះនេះបានឆ្លុះបញ្ចាំងពីការប្រកួតប្រជែងយ៉ាងបើកចំហពីសំណាក់ប្រទេសមហាអំណាចទាំងពីរ ដែលនាំឱ្យពិភពលោកបន្តកើតមាននូវភាពមិនប្រាកដប្រជា និងការបែងចែកភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចកាន់តែមានគម្លាតធំជាមុន ដោយបង្កជាឧបសគ្គ និងបញ្ហាប្រឈមដល់ការរារាំងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសកល។

### ❖ ភូមិសាស្ត្រនយោបាយ

នៅពេលដែលសេដ្ឋកិច្ចប្រទេសចិនមានដំណើរការអភិវឌ្ឍលើគ្រប់វិស័យ និងមានកំណើនគួរឱ្យកត់សម្គាល់ ស្ថានភាពនេះបានធ្វើឱ្យប្រទេសចិនជាប្រទេសមហាអំណាចសេដ្ឋកិច្ចដ៏មានឥទ្ធិពល ដោយមានទម្ងន់ខាងភូមិសាស្ត្រនយោបាយ ទំនាក់ទំនងការទូត និងយោធា ដែលអាចមានសមត្ថភាពក្នុងការប្រកួតប្រជែងទៅលើកត្តាភូមិសាស្ត្រនយោបាយជាមួយសហរដ្ឋអាមេរិក ស្របពេលសហរដ្ឋអាមេរិកអាមេរិកជាប់ផុងក្នុងសង្គ្រាមនៅអាហ្វហ្គានីស្ថាន អ៊ីរ៉ាក់ និងក្នុងប្រទេសមួយចំនួនទៀត ក្នុងនាមប្រឆាំងភេរវកម្ម ឬការពារលទ្ធិប្រជាធិបតេយ្យ។

ការងើបឡើងនៃឥទ្ធិពលនយោបាយអន្តរជាតិរបស់ប្រទេសចិនបានបង្កទៅជាការប្រឈមជាយុទ្ធសាស្ត្រដ៏ធំបំផុតសម្រាប់សហរដ្ឋអាមេរិក។ ទំនាក់ទំនងកាន់តែលំបាកឡើងរវាងសហរដ្ឋអាមេរិក និងប្រទេសចិន ដែលជះឥទ្ធិពលសំខាន់បំផុតលើដំណើរនៃប្រព័ន្ធអភិបាលកិច្ច និងសណ្តាប់ធ្នាប់សកល។ ការប្រកួតប្រជែងនេះបានស្តែងឡើងតាមរូបភាពចម្រុះ និងតាមការដាក់ចេញនូវគំនិតផ្តួចផ្តើមជាច្រើន ដែលជាការតបតគ្នាមិនដាច់។ ដោយឆ្លើយតបនឹងការងើបឡើងនៃអំណាច និងឥទ្ធិពលរបស់ចិន ចាប់តាំងពីប្រទេសនេះបានដាក់ចេញនូវគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវ (BRI) នៅឆ្នាំ ២០១៣ មក សហរដ្ឋអាមេរិកក៏បានដាក់ចេញនូវយុទ្ធសាស្ត្រ និងពង្រឹងភូមិសាស្ត្រនយោបាយនៅក្នុង និងក្រៅតំបន់ ដោយបានចងសម្ព័ន្ធមិត្ត និងធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាច្រើន ដោយបានដាក់ចេញនូវយុទ្ធសាស្ត្រ ឥណ្ឌូ-ប៉ាស៊ីហ្វិក សេរី និងបើកចំហរ (បន្ទាប់ពីនយោបាយងាកមករកអាស៊ី-Pivot to Asia របស់លោក Obama) ដែលយុទ្ធសាស្ត្រនេះត្រូវដាស់ និងពង្រឹងឡើងវិញនូវសម្ព័ន្ធភាពរបស់ខ្លួននៅអឺរ៉ុប និងនៅអាស៊ី ព្រមទាំងកសាងឡើងនូវអង្គការភូមិសាស្ត្រនយោបាយ ដើម្បីហ៊ុំព័ទ្ធប្រទេសចិន តួយ៉ាងមានដូចជាកិច្ចសន្ទនាសន្តិសុខចតុភាគី (QUAD) កិច្ចព្រមព្រៀងសន្តិសុខត្រីភាគី (AUKUS) និង ក្របខណ្ឌសេដ្ឋកិច្ចឥណ្ឌូ-ប៉ាស៊ីហ្វិក (IPEF) ជាដើម។ "យុទ្ធសាស្ត្រសន្តិសុខជាតិ" របស់សហរដ្ឋអាមេរិកដែលចេញផ្សាយនាខែតុលា ឆ្នាំ២០២២ បានបង្ហាញយ៉ាងជាក់ច្បាស់ពីការប្តេជ្ញារបស់អាមេរិកក្នុងការទប់ទល់នឹងឥទ្ធិពលរបស់ចិន ដោយយកការប្រកួតប្រជែងភូមិសាស្ត្រនយោបាយជាមួយចិនជាអាទិភាពដំបូង។[33] ក្នុងនោះ សហរដ្ឋអាមេរិកក៏បានដាក់ចេញនូវយុទ្ធសាស្ត្រ និងពង្រឹងភូមិសាស្ត្រនយោបាយនៅក្នុង និងក្រៅតំបន់ដោយបានចងសម្ព័ន្ធមិត្ត និងធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាច្រើននៅជុំវិញសកលលោក ដើម្បីកាត់បន្ថយឥទ្ធិពលភូមិសាស្ត្រនយោបាយរបស់ប្រទេសចិន ក្នុងគោលដៅធានាឱ្យរក្សាបាននូវឋានៈជាប្រទេសមហាអំណាចទីមួយលើពិភពលោក និងរៀបចំសណ្តាប់ធ្នាប់សកលឱ្យស្ថិតនៅក្រោមឥទ្ធិពលភូមិសាស្ត្ររបស់ខ្លួន។ ដើម្បីឱ្យការចងជាសម្ព័ន្ធមិត្តជាមួយបណ្តាប្រទេសមួយចំនួន ដែលមានទីតាំងភូមិសាស្ត្រអំណោយផលក្រោមលក្ខណៈជាភូមិសាស្ត្រនយោបាយ និងពាណិជ្ជកម្មប្រព្រឹត្តិទៅដោយរលូន សហរដ្ឋអាមេរិកបានផ្តល់ផលប្រយោជន៍ និងជួយជ្រោមជ្រែងដល់ប្រទេសជាដៃគូឱ្យមានការអភិវឌ្ឍទាំងនៅក្នុងសេដ្ឋកិច្ច និងសង្គម។ តួយ៉ាង នៅក្នុងឆ្នាំ២០២៤នេះ សហរដ្ឋអាមេរិកបានពង្រឹង និងពង្រីកការនូវចងសម្ព័ន្ធមិត្ត ដោយធ្វើកិច្ចសហប្រតិបត្តិការ និងផ្តល់កិច្ចគាំទ្រដល់ប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ី ដើម្បីទប់ទល់ឥទ្ធិពលទំនាក់ទំនងនយោបាយអន្តរជាតិរបស់ប្រទេសចិន ដែលក្នុងនោះសហរដ្ឋអាមេរិកបានចូលរួមគាំទ្រ និងពង្រឹងនូវភូមិសាស្ត្រនយោបាយនៅតំបន់អាស៊ីក្នុងបញ្ហាមួយចំនួនដូចជា៖

[33] ក្រសួងការបរទេស, " *សុន្ទរកថាឯកឧត្តម ប្រាក់ សុខុន ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២២ និងទិសដៅឆ្នាំ ២០២៣,* " *មីនា ០១, ២០២៣,* https://www.mfaic.gov.kh/files/uploads/ZD3W70V2Z7W0/28022023_DPM_opening_speech_for_the_AC_2023_FINAL.pdf

- **បញ្ហាកោះតៃវ៉ាន់**

នៅក្នុងជម្លោះរវាងប្រទេសចិន និងតៃវ៉ាន់ សហរដ្ឋអាមេរិកបានចូលលូកដៃ និងជួយការពារដែនដីតៃវ៉ាន់ក្នុងការទាមទារឯករាជ្យពីប្រទេសចិន។ មូលហេតុដែលសហរដ្ឋអាមេរិកគាំទ្រដល់តៃវ៉ាន់គឺដោយសារកោះតៃវ៉ាន់មានភូមិសាស្ត្រដ៏សំខាន់មួយនៅក្នុងប្រជុំកោះ ដែលសហរដ្ឋអាមេរិកពឹងផ្អែកដើម្បីទប់ស្កាត់ឥទ្ធិពលចិន និងការពារផ្លូវពាណិជ្ជកម្ម។ តៃវ៉ាន់បានក្លាយជាអ្នកផ្គត់ផ្គង់សំខាន់នៃឧបករណ៍អេឡិចត្រូនិក និងទំនិញបច្ចេកវិទ្យាខ្ពស់ផ្សេងទៀតក្រោមការគាំទ្រពីសហរដ្ឋអាមេរិក។ តៃវ៉ាន់គឺជាដៃគូពាណិជ្ជកម្មធំទី ១១ របស់អាមេរិក និងទី ២២ របស់ពិភពលោក និងជាដៃគូទំនាក់ទំនងដ៏សំខាន់នៅក្នុងសង្វាក់ផ្គត់ផ្គង់សម្រាប់តំបន់ Silicon Valley ខណៈជាដៃគូសន្តិសុខដ៏សំខាន់ក្នុងការសម្រេចបាននូវគោលដៅរួមរបស់តៃវ៉ាន់និងអាមេរិកនៃឥណ្ឌូប៉ាស៊ីហ្វិកសេរី និងបើកចំហ។ តៃវ៉ាន់ក៏ជាចំណុចកណ្ដាលនៃភូមិសាស្ត្រនយោបាយរបស់អាមេរិកនៅតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ សារៈប្រយោជន៍ទាំងសេដ្ឋកិច្ច និងភូមិសាស្ត្រនៃកោះតៃវ៉ាន់បានដាស់តឿនសហរដ្ឋអាមេរិកក្នុងការបន្តប្រកាន់ជំហរពង្រឹងសម្ព័ន្ធភាពរបស់ខ្លួននឹងតៃវ៉ាន់ ដែលជាដែនកោះប្រជាធិបតេយ្យមួយនៅពេលមានការប្រឈមមុខណាមួយពីការឈ្លានពានរបស់ចិននៅក្នុងតំបន់។ ភាពចាំបាច់របស់សេដ្ឋកិច្ចតៃវ៉ាន់នៅតែអាចសំខាន់ ចំពោះពាណិជ្ជកម្មអាមេរិកនៅក្នុងតំបន់ តែអ្វីដែលយើងមិនអាចប្រកែកបាននោះគឺវាផ្តល់នូវចំណុចប្រឆាំងផ្នែកនយោបាយដ៏ល្អបំផុតទៅកាន់ប្រទេសចិន។ ជារួម សហរដ្ឋអាមេរិកតែងតែចាត់ទុកតៃវ៉ាន់ជាទ្រព្យសម្បត្តិយុទ្ធសាស្ត្រដ៏សំខាន់ដែលមិនត្រូវអនុញ្ញាតឱ្យធ្លាក់ក្រោមការគ្រប់គ្រងរបស់ប្រទេសចិន និងជាចំណុចមូលដ្ឋានសម្រាប់ប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងឥទ្ធិពលប្រទេសចិននៅអាស៊ី ហើយអ្វីដែលជាគោលដៅរបស់អាមេរិកគឺការបញ្ច្រាបលទ្ធិប្រជាធិបតេយ្យ និងធ្វើឱ្យអាស៊ីទុកចិត្តពីឥទ្ធិពលរបស់ខ្លួនក្នុងតំបន់នោះ។[34]

គួររម្លឹកផងដែរថា ភាពតានតឹងរវាងប្រទេសចិននិងកោះតៃវ៉ាន់គឺជាបញ្ហាមួយដែលបានអូសបន្លាយតាំងតែពីជាង៧០ឆ្នាំមុនមកម្ល៉េះ។ កោះតៃវ៉ាន់ជាកោះមួយស្ថិតនៅជិតបំផុតទៅនឹងដែនដីគោករបស់ប្រទេសចិន ដែលខណ្ឌចែកដោយច្រកសមុទ្រ ហើយមានទីតាំងនៅភាគខាងត្បូងឆៀងខាងកើតនៃប្រទេសចិន។ គិតត្រឹមឆ្នាំ ២០២៤ កោះមួយនេះមានប្រជាជនជាង ២៤លាននាក់ និងមានរបបនយោបាយដឹកនាំប្រទេសច្បាស់លាស់ ហើយកោះតៃវ៉ាន់ជាដែនដីមួយ ដែលបានប្រកាសផ្តាច់ចេញ ពីចិនអស់រយៈពេលជាង ៧០ឆ្នាំមកហើយ ប៉ុន្តែនៅមិនទាន់ទទួលបានឯករាជ្យពីប្រទេសចិននៅឡើយ ហើយប្រទេសចិនក៏នឹងមិនអាចឱ្យតៃវ៉ាន់ក្លាយជារដ្ឋឯករាជ្យបាននោះដែរព្រោះតៃវ៉ាន់មានសារៈសំខាន់បំផុតសម្រាប់ប្រទេសចិនទាំងខាងចំណាងប្រវត្តិសាស្ត្រ និងខាងផ្នែកភូមិសាស្ត្រនយោបាយ។

មួយរយៈកាលចុងក្រោយនេះ ស្ថានភាពរវាងភាគីទាំងពីរបានប្រែប្រួលទៅជារបត់នយោបាយថ្មីមួយទៀត ដោយសារតែដែនដីតៃវ៉ាន់បានពង្រីកខ្លួនឱ្យក្លាយទៅជាដែនដីមួយដែលមានសេដ្ឋកិច្ចរីកចម្រើនក្រោមការ

[34] ចាំង ស៊ីណាន និងហ៊ុន សំរិទ្ធកេតិស័ក្ក, *"ហេតុអ្វីបានជាតៃវ៉ាន់សំខាន់សម្រាប់អាមេរិក?,"* គ្រាប់ពូជកម្ពុជា, កញ្ញា ១៣, ២០២១, https://www.theseedcambodia.com/article/7706/

ជួយជ្រោមជ្រែង និងគាំទ្រយ៉ាងពេញទំហឹងពីសហរដ្ឋអាមេរិក ដែលជាដៃគូប្រជែងខាងភូមិសាស្ត្រនយោបាយ និងគូជម្លោះពាណិជ្ជកម្មរបស់ប្រទេសចិន។ ជាក់ស្តែង នៅក្នុងឆ្នាំ២០២៤ ស្ថានភាពជុំវិញបញ្ហារវាងប្រទេសចិន និងដែនដីតៃវ៉ាន់មានភាពតានតឹងកាន់តែខ្លាំងឡើងៗគួរឱ្យកត់សម្គាល់ ដែលជាហេតុធ្វើឱ្យមានការព្រួយបារម្ភពីប្រទេសជិតខាង ក៏ដូចជាប្រទេសមួយចំនួនក្នុងតំបន់ ដោយសភាពការណ៍បច្ចុប្បន្នអាចឈានទៅដល់ការប្រឈមមុខដាក់គ្នាខាងយោធារវាងប្រទេសចិននិងកោះតៃវ៉ាន់ ដែលស្ថានការណ៍ដ៏តានតឹងនេះបណ្តាលមកពីមូលហេតុមួយចំនួនដូចជាគណបក្សកាន់អំណាចរបស់តៃវ៉ាន់នៅតែប្រកាន់ជំហរប្រកាសឯករាជ្យ ដែលប៉ះពាល់ដល់គោលនយោបាយចិនតែមួយ និងការជួយគាំទ្រ និងសហការណ៍ពីសំណាក់ដៃគូប្រកួតប្រជែងសហរដ្ឋអាមេរិកដោយបានលក់គ្រឿងសព្វាវុធមកឱ្យកោះតៃវ៉ាន់ ជាពិសេសប្រធានសភាអាមេរិកបានធ្វើដំណើរទស្សនៈកិច្ចមកកាន់កោះតៃវ៉ាន់ក្នុងគោលដៅបង្ហាញពីការជួយការពារ និងពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស្អិតរមួតបន្ថែមទៀត ដែលនេះ ប្រទេសចិនយល់ថាជាការគាំទ្រកោះតៃវ៉ាន់យ៉ាងបើកចំហក្នុងការប្រកាសទាមទារឯករាជ្យចេញពីប្រទេសចិន។ ក្នុងចំណោមមូលហេតុទាំងនោះមានបុព្វហេតុមួយដែលនាំឱ្យប្រទេសចិនកាន់តែកើនឡើងកម្តៅខ្លាំងគឺបន្ទាប់ពីមានដំណើរទស្សនកិច្ចរបស់ប្រធានសភាអាមេរិកនៅកោះតៃវ៉ាន់ ប្រទេសចិនក៏បានធ្វើសមយុទ្ធយោធាបាញ់គ្រាប់ពិតទ្រង់ទ្រាយធំនៅក្នុងច្រកសមុទ្រតៃវ៉ាន់ និងនៅជុំវិញកោះតៃវ៉ាន់ដូចជាការធ្វើសមយុទ្ធកងទ័ពជើងគោក ជើងទឹក និងផ្លូវអាកាស និងការដាក់ទណ្ឌកម្មលើមន្ត្រីកំពូលៗរបស់កោះតៃវ៉ាន់ និងបានបិទផ្លូវនាវាចរណ៍ និងផ្លូវអាកាសនៅក្នុងតំបន់ច្រកសមុទ្រកោះតៃវ៉ាន់ថែមទៀតផង ដែលធ្វើឱ្យធ្វើឱ្យប៉ះពាល់ដល់លំហូរពាណិជកម្ម។ ភ្លាមៗ ទីផ្សារភាគហ៊ុនរបស់ក្រុមហ៊ុនដឹកជញ្ជូនតៃវ៉ាន់បានធ្លាក់ចុះជាង ១% ហើយខាតតម្លៃអស់ ៤,៦%នៃតម្លៃភាគហ៊ុន។ ក្រុមហ៊ុនដឹកជញ្ជូនខ្លះបានបង្វែរគោលដៅទៅរកការចុះចតនៅសមុទ្ររបស់ហ្វីលីពីនវិញ។ ចំពោះការដឹកជញ្ជូនតាមផ្លូវអាកាសវិញ ដោយសារតែសមយុទ្ធរបស់ចិន ក៏បានធ្វើឱ្យជើងហោះហើរយន្តហោះប្រមាណ ៤០០ ត្រូវបិទសម្រាប់ការហោះហើរ ជាមួយចិន រីឯជើងហោះហើរតៃវ៉ាន់ និងអន្តរជាតិវិញគឺមានចំនួន ១៨ ក៏ត្រូវរងផលប៉ះពាល់ផងដែរ។[35]

ជាការឆ្លើយតបទៅនឹងការធ្វើសមយុទ្ធយោធារបស់ប្រទេសចិន រដ្ឋាភិបាលកោះតៃវ៉ាន់ក៏ចង់បង្ហាញពីសមត្ថភាពនិងភាពរឹងមាំនៃវិស័យការពារជាតិទៅកាន់ចិនផងដែរ។ ជាក់ស្តែង កោះតៃវ៉ាន់បានចាប់ផ្តើមទិញសព្វាវុធ យន្តហោះចម្បាំង នាវាចម្បាំង និងនាវាមុជទឹកទំនើបៗជាច្រើនពីសហរដ្ឋអាមេរិក និងបានធ្វើសមយុទ្ធយោធាបាញ់កាំភ្លើងធំ ដោយធ្វើឱ្យដូចទៅនឹងស្ថានការណ៍ទប់ទល់នឹងការប្រឆាំង និងការវាយប្រហារណាមួយពីកងទ័ពចិនយ៉ាងដូច្នោះដែរ។ បន្ថែមលើស្ថានភាពតានតឹងនៅច្រកសមុទ្រតៃវ៉ាន់ កិច្ចគាំទ្រយ៉ាងពេញទំហឹងពីសហរដ្ឋអាមេរិក ដែលថាក្នុងករណីកោះតៃវ៉ាន់ត្រូវបានប្រទេសចិនឈ្លានពាន សហរដ្ឋអាមេរិកនឹងចូល

[35] តាំង សុខជី និងទន់ លីណាសុផាឬទ្ធិ, *"ការកើនឡើងភាពតានតឹងបច្ចុប្បន្នជុំវិញបញ្ហាកោះតៃវ៉ាន់,"* Asian Vision Institute, សីហា ២៩, ២០២២, https://www.asianvision.org/archives/15442

អន្តរាគមន៍ជួយភ្លាមៗ។ ការអះអាងនេះ កាន់តែធ្វើឱ្យស្ថានភាពកាន់តែក្ដៅថែមទៀត និងក៏ជាការលើកទឹកចិត្តដល់រដ្ឋាភិបាលតៃវ៉ាន់កាន់តែមានឆន្ទៈបន្ថែមទៀតក្នុងការប្រឆាំងនឹងប្រទេសចិន។

ជារួម ការព្រមាន និងតបតដោយការធ្វើសមយុទ្ធយោធា និងការដាក់ទណ្ឌកម្មរវាងប្រទេសចិន និងតៃវ៉ាន់ ជាពិសេសការមានកិច្ចគាំទ្រពីសហរដ្ឋអាមេរិកបាននាំឱ្យមាននូវផលអវិជ្ជមានដល់ប្រទេសដែលមានជម្លោះជាមួយគ្នា ហើយជាពិសេសប៉ះពាល់ដល់សេដ្ឋកិច្ចសកលទាំងមូលតែម្តងព្រោះទាំងប្រទេសចិន និងកោះតៃវ៉ាន់ ពិតជាមាន សារៈសំខាន់ ខ្លាំង ចំពោះ ខ្សែសង្វាក់ផ្គត់ផ្គង់ទំនិញសកល និងគ្រឿងបង្គុំអេឡិចត្រូនិចសកលពីសំណាក់កោះតៃវ៉ាន់ ដែលវាពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាផ្ទាល់ក្នុងការផ្គត់ផ្គង់គ្រឿងបង្គុំបច្ចេកវិទ្យានៅទីផ្សារសកល ដោយវាជាធាតុផ្សំដែលមិនអាចខ្វះបាន ឬអាចចាត់ទុកជាបេះដូងរបស់ឧបករណ៍អេឡិចត្រូនិចទាំងអស់ ហើយក្នុងសតវត្សទី២១នេះគឺពឹងផ្អែកទៅលើបច្ចេកវិទ្យា និងឧបករណ៍អេឡិចត្រូនិចខ្លាំងមែនទែនក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចពិភពលោក។[36] តួយ៉ាង ក្នុងរយៈពេលកន្លងមក តៃវ៉ាន់ផលិតបាន ៩២% នៃបន្ទះសៀគ្វីតក្កវិជ្ជាទំនើបបំផុតរបស់ពិភពលោក (នៅទំហំថ្នាំងតិចជាង ១០ ណាណូម៉ែត្រ) ក៏ដូចជាមួយភាគបីទៅពាក់កណ្ដាលនៃទិន្នផលសកលសម្រាប់បន្ទះឈីបដែលមិនសូវពេញនិយម។ តាមការប៉ាន់ស្មានមួយចំនួន បន្ទះឈីបឈានមុខគេរបស់តៃវ៉ាន់ រោងចក្រ TSMC ផលិត ៣៥% នៃ microcontrollers របស់យានយន្តក្នុងពិភពលោក និង ៧០% នៃបន្ទះឈីបទូរស័ព្ទឆ្លាតវៃរបស់ពិភពលោក។ លើសពីនេះ វាក៏គ្របដណ្ដប់លើការផលិតបន្ទះឈីបសម្រាប់អង្គភាពដំណើរការក្រាហ្វិកកម្រិតខ្ពស់នៅក្នុងកំព្យូទ័រ និងម៉ាស៊ីនមេ។ ក្នុងន័យនេះ នៅពេលដែលមានការបិទចរាចរណ៍ដឹកជញ្ជូន និងការដាក់កំហិតផ្សេងៗពីប្រទេសចិន វានឹងធ្វើឱ្យការនាំចេញបន្ទះឈីបទៅផ្គត់ផ្គង់ផលិតកម្មផ្សេងៗលើសកលលោកមានភាពខ្វះខាត ដែលប៉ះពាល់ដល់ក្រុមហ៊ុនមួយចំនួន ជាពិសេសក្រុមហ៊ុនផលិតបច្ចេកវិទ្យាផ្ទាល់ និងក្រុមហ៊ុនផលិតឡានត្រូវការផ្អាករោងចក្ររបស់ខ្លួនឯងព្រោះតែខ្វះខាតបន្ទះឈីបតូចមួយ។ ឧទាហរណ៍ដូចជាក្រុមហ៊ុន GM បានបាត់បង់ប្រាក់ចំណូលយ៉ាងហោចណាស់ ២ ពាន់លានដុល្លារក្នុងមួយឆ្នាំ ព្រោះខ្វះខាតគ្រឿងបង្គុំបន្ទះឈីបសម្រាប់បំពាក់ក្នុងរថយន្ត។ ជាងនេះទៅទៀត ភាពអាក់អួលនៃការផ្គត់ផ្គង់បន្ទះឈីបក៏បាននាំប៉ះពាល់ដល់ខ្សែសង្វាក់តម្លៃសកលសម្រាប់ឧបករណ៍អេឡិចត្រូនិចទាំងនេះរាប់បញ្ចូលទាំងផលិតផលទូរស័ព្ទ គ្រឿងអេឡិចត្រូនិចផ្សេងៗគ្រឿងបន្លាស់រថយន្ត និងយានជំនិះធំៗទូទាំងពិភពលោកដូចជាប្រទេសចិន សហរដ្ឋអាមេរិក ជប៉ុន ឬអាល្លឺម៉ង់។ ក្នុងកំឡុងពេលកង្វះខាតគ្រឿងបង្គុំអេឡិចត្រូនិចដូចជាបន្ទះឈីបនៅឆ្នាំ២០២១ ការផលិតរថយន្តដឹកអ្នកដំណើរជាមធ្យមនៅអឺរ៉ុបបានធ្លាក់ចុះប្រហែល ១៣% ដោយការផលិតរបស់អាល្លឺម៉ង់ធ្លាក់ចុះជិត ២០% និងផលិតកម្មអ៊ីតាលីជាង ២៥%។ ផលខាតបង់ទាំងអស់នេះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ចន្ទុលសេដ្ឋកិច្ចសំខាន់ៗរបស់ពិភពលោក ដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចសកលមានអត្រាកំណើនទាបជាងមុន។ មិនតែប៉ុណ្ណោះ ប្រទេសចិនឯនេះវិញ ក៏ទទួលរងផលប៉ះពាល់មួយចំនួនផងដែរពី

[36] ហោង ច័ន្ទសម្បត្តិ និងទន់ លីណាសុជាឫទ្ធិ, "*កង្វះខាតជាសកល Semiconductor និងផលប៉ះពាល់លើឧស្សាហកម្មបច្ចេកវិទ្យា,*" Asian Vision Institute, តុលា ១៣, ២០២១ https://www.asianvision.org/archives/12238

កង្វះគ្រឿងបង្គុំអេឡិចត្រូនិច តួយ៉ាងស្ថានភាពសេដ្ឋកិច្ចក្នុងប្រទេសចិនជួបផលវិបាកនៅពេលមានការរំខានដល់ខ្សែសង្វាក់តម្លៃគ្រឿងបង្គុំអេឡិចត្រូនិចសកល។ ប្រទេសចិនគឺជាប្រទេសនាំចេញទំនិញ ICT ដ៏ធំបំផុតរបស់ពិភពលោក ក៏ដូចជាមជ្ឈមណ្ឌលផលិតកម្មពិភពលោកលំដាប់លេខមួយសម្រាប់ទំនិញរថយន្តនៅក្នុងឆ្នាំ ២០១៨ បើយោងតាមក្រាហ្វិកទី ១១ និង ១២ ខាងក្រោមនេះ។

**ក្រាហ្វិកទី១១៖ បង្ហាញពីការនាំចេញ ICT សរុបក្នុងឆ្នាំ២០១៨**




ប្រភព៖ UNCTAD, OECD

**ក្រាហ្វិកទី១២៖ បង្ហាញពីផលិតកម្មយានយន្តសរុបក្នុងឆ្នាំ២០១៨**




ប្រភព៖ UNCTAD, OECD

ក្នុងន័យនេះ នៅពេលមានកង្វះគ្រឿងបង្គុំអេឡិចត្រូនិចសកល បានធ្វើឱ្យទីផ្សារនាំចេញ និងផលិតកម្មយានយន្តរបស់ប្រទេសចិនធ្លាក់ចុះ ដែលវាប៉ះពាល់ដល់រំហូរពាណិជ្ជកម្ម និងកត្តាផលិតកម្ម ដោយនាំឱ្យរាំងស្ទះដល់ការជម្រុញកំណើនសេដ្ឋកិច្ចចិន ហើយវាបន្តប៉ះពាល់សេដ្ឋកិច្ចសកលផងដែរ។ ក្រៅពីភាពខ្វះខាតនៃគ្រឿងបង្គុំអេឡិចត្រូនិចសកល ពាណិជ្ជកម្មរវាងចិន និងពិភពលោកនឹងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្នុងការរំខានដល់ហិរញ្ញវត្ថុពាណិជ្ជកម្មសកល។ ជារៀងរាល់ឆ្នាំ ធនាគារផ្តល់ហិរញ្ញប្បទានពី ៦.៥ ទៅ ៨ ពាន់ពាន់លានដុល្លារ ដើម្បីជួយអ្នកនាំចូល និងអ្នកនាំចេញ ដោយសម្រួលពាណិជ្ជកម្មនៅកំឡុងពេលទំនិញកំពុងត្រូវបានដឹកជញ្ជូន។ ហិរញ្ញវត្ថុរយៈពេលខ្លីនេះគាំទ្រដល់ចំនួនមួយភាគបីនៃរំហូរពាណិជ្ជកម្ម។ នៅក្នុងព្រឹត្តិការណ៍នៃជម្លោះរវាងចិន និងតៃវ៉ាន់ វិនិយោគិនសកលនឹងដកថយពីសកម្មភាពផ្តល់ប្រាក់កម្ចី ដោយកាត់បន្ថយលទ្ធភាពទទួលបានហិរញ្ញវត្ថុពាណិជ្ជកម្ម ព្រោះការផ្តល់ហិរញ្ញប្បទានប្រឈមនឹងហានិភ័យជាច្រើននៅក្នុងស្ថានការណ៍ដ៏មិនប្រាកដប្រជានេះ។ ក្នុងកំឡុងពេលមានភាពតានតឹង ការធ្លាក់ចុះនៃទំហំហិរញ្ញប្បទានពាណិជ្ជកម្មត្រូវបានប៉ាន់ប្រមាណថាមានការថយចុះស្ទើរតែមួយភាគប្រាំនៃទំហំពាណិជ្ជកម្មសកល។ រវាងវិបត្តិសាច់ប្រាក់ងាយស្រួលសកល និងការគម្រាមកំហែងនៃទណ្ឌកម្ម ហិរញ្ញវត្ថុពាណិជ្ជកម្មជាមួយប្រទេសចិនទំនងជានឹងកាន់តែខ្វះខាត និងរំខានដល់ទំហំពាណិជ្ជកម្មក្នុងទឹកប្រាក់ជាង ២៧ ពាន់លានដុល្លាររវាងប្រទេសចិន និងពិភពលោកទាំងមូល។ លើសពីនេះ វិនិយោគិនក្នុងស្រុក និងសកលលោកស្ទើរតែនឹងស្វែងរកការផ្ទេរប្រាក់ចេញពីប្រទេសចិន ដោយធ្វើឱ្យអត្រាប្តូរប្រាក់របស់ចិនកាន់តែតានតឹងដល់កម្រិតខ្ពស់មួយ។ ការរំខានសំខាន់ៗផ្សេងទៀតចំពោះសកម្មភាពសេដ្ឋកិច្ចពិភពលោកនៅក្នុងជម្លោះតៃវ៉ាន់ អ្នកវិនិយោគបរទេសទំនងជាហ៊ានបោះបង់ការកាន់កាប់មូលបត្ររបស់ចិន។ គិតត្រឹមខែមិថុនា ឆ្នាំ២០២២ វិនិយោគិនបរទេសកាន់កាប់ជាងមួយពាន់ពាន់លានដុល្លារនៅក្នុងមូលបត្របំណុល និងភាគហ៊ុនរបស់ចិន ហើយគិតត្រឹមខែកញ្ញា ឆ្នាំ ២០២២ មានទំហំជាង ៧៧៥ ពាន់លានដុល្លារប៉ុណ្ណោះនៅក្នុងភាគហ៊ុនចិន។ ក្នុងករណីមានជម្លោះ អ្នកវិនិយោគនឹងលក់មូលបត្រចិន ដើម្បីកាត់បន្ថយការប្រឈមមុខនឹងទណ្ឌកម្មហិរញ្ញវត្ថុ ដែលអាចនឹងកើតមាន និងហានិភ័យសេដ្ឋកិច្ចកាន់តែខ្ពស់។

ជម្លោះមួយនេះ ក៏ទំនងជាមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការវិនិយោគ និងសកម្មភាពផ្តល់ប្រាក់កម្ចីក្រៅប្រទេសរបស់ចិនផងដែរ។ ក្នុងនោះ ប្រទេសចិនទំនងជានឹងផ្អាកសកម្មភាពវិនិយោគផ្ទាល់នៅក្រៅប្រទេស ការផ្តល់កម្ចី និងជំនួយនានា។ ប្រទេសដែលពឹងផ្អែកលើការបង្វិលសង និងការផ្តល់ប្រាក់កម្ចីរបស់ចិនដូចជាស្រីលង្កា ប៉ាគីស្ថាន និងឡាវ នឹងត្រូវរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត។ ជម្លោះតៃវ៉ាន់ក៏នឹងប៉ះពាល់ដល់ការវិនិយោគផ្ទាល់របស់តៃវ៉ាន់ផងដែរ។ តៃវ៉ាន់វិនិយោគប្រហែល ១៨ ពាន់លានដុល្លារក្នុងមួយឆ្នាំនៅបរទេស ហើយជនបរទេសចម្រុះជាតិសាសន៍ ដែលបានវិនិយោគក្នុងទឹកដីតៃវ៉ាន់បានធ្វើដកដើមទុនយកទៅប្រទេសខ្លួនវិញប្រហែល ២២ ពាន់លានដុល្លារនៅឆ្នាំ ២០២១។ ជម្លោះអាចធ្វើឱ្យរំហូរទាំងនេះ និងទ្រព្យសម្បត្តិបរទេសនៅក្នុងតៃវ៉ាន់ រួមទាំងការវិនិយោគផ្ទាល់ចំនួន ១២៧ ពាន់លានដុល្លារ ប្រឈមនឹងហានិភ័យ។

សរុបជារួម ជម្លោះរវាងប្រទេសចិន និងកោះតៃវ៉ាន់ពិតជាបានផ្តល់ជាឥទ្ធិពលអវិជ្ជមានដល់ការផ្គត់ផ្គង់គ្រឿងបង្គុំអេឡិចត្រូនិច ទំនិញ និងយានយន្តសម្រាប់នាំចេញទៅទីផ្សារសកល ដែលគម្រាមកំហែងដល់ខ្សែសង្វាក់ផ្គត់ផ្គង់ទំនិញ និងតម្លៃសកល។ កង្វះខាតគ្រឿងបង្គុំអេឡិចត្រូនិចបានធ្វើឱ្យបង្អាក់ និងរាំងស្ទះដំណើរការផលិតកម្មសកល ដែលនាំឱ្យប៉ះពាល់ដល់វិស័យពាណិជ្ជកម្មសកល ជាពិសេសវាបន្តឱ្យការវិនិយោគធ្លាក់ចុះ ការលក់មូលបត្រ ភាគហ៊ុនជួបប្រទះ និងប្រឈមនឹងហានិភ័យខ្ពស់។ កត្តាជាបច្ច័យអវិជ្ជមានទាំងអស់នេះនឹងនាំឱ្យបណ្តាប្រទេសជុំវិញពិភពលោកប្រឈមមុខនឹងហានិភ័យនៃវិបត្តិពាណិជ្ជកម្មសកល វិបត្តិហិរញ្ញវត្ថុ ការកើនឡើងអតិផរណា ភាពអត់ការងារធ្វើ និងកង្វះខាតធាតុចូលទៅក្នុងវិស័យឧស្សាហកម្មសកល ដោយបញ្ហាទាំងអស់នេះនឹងបង្កឱ្យមាននូវវិបត្តិសេដ្ឋកិច្ចសកល។[37]

- **បញ្ហាជម្លោះសមុទ្រចិនខាងត្បូង**

សមុទ្រចិនខាងត្បូងគឺជាតំបន់ដែនទឹកដែលមានសក្តានុពលខ្លាំងទាំងសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ ហើយក៏ជាទីតាំងស្នូលមួយរបស់ពិភពលោកក្នុងការដឹកជញ្ជូន និងចរាចរណ៍ទំនិញអន្តរជាតិ ដោយបានគ្របដណ្តប់ទំហំមួយភាគបីនៃការដឹកជញ្ជូន និងចរាចរណ៍ទំនិញទូទាំងសកលលោក។ លើសពីនេះ សមុទ្រចិនខាងត្បូងជាតំបន់ដែលសម្បូរទៅដោយធនធានធម្មជាតិមានតម្លៃដ៏សម្បើម ព្រមទាំងអាចផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើនមហាសាល។ សម្បត្តិធម្មជាតិសំខាន់ៗទាំងនោះរួមមានដូចជាប្រេង ឧស្ម័នធម្មជាតិ ធនធាននេសាទ រួមជាមួយជីវចម្រុះជាច្រើនប្រភេទទៀតផង។ ចំពោះសក្តានុពលភូមិសាស្ត្រនយោបាយវិញ ទីតាំងសមុទ្រចិនខាងត្បូងនេះគឺជាច្រកផ្លូវដ៏ល្អឥតខ្ចោះសម្រាប់ពាណិជ្ជកម្មពិភពលោក និងជាទីតាំងពិសេសដែលអាចធ្វើសមយុទ្ធយោធា ឬបើកការវាយប្រហារទៅកាន់ប្រទេសនានានៅក្នុងតំបន់នេះផងដែរ។ ដោយសារតែមានផលប្រយោជន៍សំខាន់ៗជាច្រើនហើយទើបបណ្តាលឱ្យប្រទេស ដែលនៅជុំវិញសមុទ្រចិនខាងត្បូងរួមមានប្រទេសចិន វៀតណាម ម៉ាឡេស៊ី ហ្វីលីពីន និងព្រុយណេបានព្យាយាមបង្កើតឱ្យមានទីតាំងឈរជើងនៅតាមដែនទឹករបស់ពួកគេរៀងៗខ្លួនដើម្បីក្រសោបយកផលប្រយោជន៍ពីតំបន់ដ៏អំណោយផលមួយនេះ។ ទន្ទឹមនឹងការបង្កើតទីតាំងឈរជើង ប្រទេសទាំងអស់បានសម្រេចអនុវត្តន៍ច្បាប់របស់អង្គការសហប្រជាជាតិ ដែលបានលើកឡើងថា ដែនសមុទ្ររបស់ប្រទេសមួយមានចម្ងាយលាតសន្ធឹង ៣៧០ គីឡូម៉ែត្រ ពីច្រាំងសមុទ្ររបស់ខ្លួន ហើយប្រទេសគ្រប់ភាគីទាំងអស់បានកំណត់យកកម្រិត ៣៧០ គីឡូម៉ែត្រដើម្បីលាតសន្ធឹងកំណត់យកដែនទឹករបស់ខ្លួន។ ប៉ុន្តែក្នុងចំណោមប្រទេសទាំងនោះប្រទេសចិនកំពុងតែបង្ហាញជំហរក្នុងការវាតទីខ្លាំងក្លាជាងគេ នៅក្នុងតំបន់ហើយចង់គ្រប់គ្រងដែនទឹកនៅសមុទ្រចិនខាងត្បូងស្ទើរទាំងស្រុង ដើម្បីពង្រីកអំណាចគ្រប់គ្រងផ្លូវពាណិជ្ជកម្ម កាន់កាប់ទីតាំងភូមិសាស្ត្រនយោបាយ និងប្រមូលយកធនធានធម្មជាតិ។ ការទាមទាររបស់ចិនទៅលើសមុទ្រចិនខាងត្បូងនេះ បានបណ្តាលឱ្យប្រទេសមហាអំណាចធំៗនៅលើពិភពលោកដូចជាសហរដ្ឋអាមេរិក សហភាព

[37] Charlie Vest et al., *"The Global Economic Disruptions from a Taiwan Conflict,"* Rhodium Group, December 14, 2022 https://rhg.com/research/taiwan-economic-disruptions/

អឺរ៉ុប និងអូស្ត្រាលីជាដើម បានបង្ហាញគោលគំនិតមិនគាំទ្រសកម្មភាពរបស់ប្រទេសចិនជាដាច់ខាតព្រោះនៅពេលដែលប្រទេសចិនកាន់កាប់សមុទ្រចិនខាងត្បូងពេញលេញ នោះនឹងអាចគម្រាមកំហែងទាំងផ្នែកពាណិជ្ជកម្មដឹកជញ្ជូន និងវិស័យយោធាដល់ពិភពលោកបាន។ រីឯប្រទេសតូចៗដែលមានវត្តមាននៅជុំវិញតំបន់សមុទ្រចិនខាងត្បូងតែងតែមានការជំទាស់ និងភាពចម្រូងចម្រាស់ផ្នែកការទូតឥតឈប់ឈរជាមួយប្រទេសចិន។ បើតាមរយៈផែនទីនៃតំបន់ជុំវិញសមុទ្រចិនខាងត្បូង បានបង្ហាញពីមហិច្ឆតាចង់បានដែនទឹកពីសំណាក់ក្រុមប្រទេសដែលស្ថិតនៅជុំវិញសមុទ្រនេះ ដោយក្នុងនោះភាគីចិនបានទាមទារនៅលើបន្ទាត់ក្រហម ដែលបន្ទាត់នោះស្ទើរតែទាមទារគ្រប់គ្រងសមុទ្រចិនខាងត្បូងទាំងមូល។ ចំណែក ប្រទេសវៀតណាមគឺទាមទារលើផ្នែកទាំងស្រុងនៃប្រជុំកោះ Paracel និង ផ្នែកខ្លះនៃប្រជុំកោះ Spratly នៃដែនសមុទ្រនេះ (ស្ថិតលើបន្ទាត់ពណ៌បៃតង)។ រីឯ ប្រទេសព្រុយណេចង់គ្រប់គ្រងក្នុងទំហំដែនទឹកមួយភាគតូចក្បែរប្រជុំកោះ Spratly (ស្ថិតលើបន្ទាត់ពណ៌លឿង) ខណៈប្រទេសម៉ាឡេស៊ីទាមទារកោះតូចៗមួយចំនួន ដែលស្ថិតក្នុងប្រជុំកោះ Spratly និង ផ្នែកផ្សេងទៀតនៃសមុទ្រចិនខាងត្បូង (ស្ថិតលើបន្ទាត់ពណ៌ស្វាយ)។ ចំណែកប្រទេសហ្វីលីពីនបានទាមទារប្រជុំ កោះ Spratly ទាំងមូល និងតំបន់ផ្សេងទៀត (ស្ថិតលើបន្ទាត់ពណ៌ទឹកក្រូច)។ តាមការចង់បាននូវទំហំដែនទឹកពីគ្រប់សមាសភាគី និងការបែងចែកតំបន់មិនមានមូលដ្ឋានច្បាស់លាស់ បានបង្កទៅជាជម្លោះរវាងប្រទេសទាំងនោះនៅជុំវិញសមុទ្រចិនខាងត្បូង ដោយភាពតានតឹងក្នុងភូមិសាស្ត្រនយោបាយនេះគឺជាបញ្ហាដ៏ស្មុគស្មាញមួយព្រោះតំបន់ខ្លះ ភាគីជម្លោះបានទាមទារលើតំបន់ជាន់គ្នារហូតដល់៣ទៅ៤ភាគីពាក់ព័ន្ធ។ តួយ៉ាង តំបន់ប្រជុំកោះ Spratly ត្រូវបានទាមទារដោយប្រទេសវៀតណាម ហ្វីលីពីន និងចិន ខណៈផ្នែកខ្លះទៀតនៃសមុទ្រចិនខាងត្បូងទាមទារដល់ទៅ៤ភាគីឯណោះ។ ក្រៅពីភាគីដែលមានជម្លោះជាមួយប្រទេសចិន ក៏មានតួអង្គខាងក្រៅ ដែលបានលូកដៃចូលទៅក្នុងបញ្ហាសមុទ្រចិនខាងត្បូងនេះ ដោយក្នុងនោះមានប្រទេសជប៉ុន ឥណ្ឌា និងអូស្ត្រាលី ជាពិសេសប្រទេសមហាអំណាចសហរដ្ឋអាមេរិកតែម្ដង ដែលសុទ្ធសឹងតែជាប្រទេសមានសមត្ថភាពខ្លាំងទាំងសេដ្ឋកិច្ច ការទូត និងយោធា។ ការឈានចូលក្នុងជម្លោះនេះ គឺដោយសារការចង់ធានាឱ្យបានស្ថិរភាព និងសន្តិសុខតំបន់ ព្រមទាំងការធ្វើនាវាចរាចរណ៍ដោយសេរី និងមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសណាមួយឡើយ។ ក៏ប៉ុន្តែ នៅពីក្រោយហេតុផលទាំងអស់នេះ គឺមានវត្ថុបំណងផ្សេងផងដែរ ក្នុងនោះមានមហិច្ឆតានយោបាយ និងសេដ្ឋកិច្ច។ ចំពោះទិដ្ឋភាពនយោបាយគឺការបង្កើតឱ្យមានសម្ព័ន្ធមិត្តយោធាហ៊ុមព័ទ្ធចិន រារាំងចិនកុំឱ្យកសាងមូលដ្ឋានទ័ពក្នុងដែនទឹក និងការគាបសង្កត់ចិនតាមផ្លូវច្បាប់អន្តរជាតិ។ ចំពោះគោលគំនិតសេដ្ឋកិច្ចវិញ គឺប្រទេសមហាអំណាចទាំងអស់នោះ ដែលដឹកនាំដោយសហរដ្ឋអាមេរិកមានគោលដៅចង់បង្អាក់ ឬធ្វើឱ្យសេដ្ឋកិច្ចចិនចុះខ្សោយ តាមរយៈការកៀងគរសម្ព័ន្ធមិត្តរបស់ខ្លួនបន្តគាបសង្កត់សេដ្ឋកិច្ចចិន ដោយដាក់ទណ្ឌកម្មលើក្រុមហ៊ុនចិនក្នុងការមិនលក់វត្ថុធាតុដើមទៅចិន ការតម្លើងពន្ធគយ និងការធ្វើការស៊ើបអង្កេតទៅលើសមត្ថភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចិនដែលពាក់ព័ន្ធនឹងការលាងលុយខ្មៅ ឬកាត់បន្ថយការធ្វើពាណិជ្ជកម្មជាមួយក្រុមហ៊ុនចិនតែម្ដង។ ស្របពេលជាមួយគ្នានេះដែរ សហរដ្ឋអាមេរិកក៏ទទួលបានផលប្រយោជន៍សេដ្ឋកិច្ចមួយទៀត គឺការលក់សព្វាវុធទៅឱ្យប្រទេសមួយចំនួនក្នុងតំបន់អាស៊ាន ដែលស្ថិតនៅជុំវិញសមុទ្រចិនខាងត្បូង។ តួយ៉ាងប្រទេស ហ្វីលីពីនបាន

ទិញយន្តហោះចម្បាំងបន្ថែម F-16 ចំនួន ១២ គ្រឿងបន្ថែម និងមីស៊ីលជាច្រើនទៀតក្នុងតម្លៃ ២.៥៣ពាន់លានដុល្លារសហរដ្ឋអាមេរិក ដើម្បីការពារនឹងការគម្រាមគំហែងរបស់ប្រទេសចិន។ ចំណែកឯប្រទេសម៉ាឡេស៊ីវិញ បានដាក់ចេញគោលនយោបាយទំនើបកម្មកងទ័ពអាកាសរបស់ខ្លួន បន្ទាប់ពីមានការឈ្លានពានដែនអាកាសពីយន្តហោះចិនជារឿយៗ។ នៅក្នុងជម្លោះនេះ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ សហរដ្ឋអាមេរិកនឹងឈរជាមួយសម្ព័ន្ធមិត្តអាស៊ីអាគ្នេយ៍ ធ្វើកិច្ចសហប្រតិបត្តិការ និងជួយជាកិច្ចគាំទ្រដល់បណ្តាប្រទេសមួយចំនួននៅសមុទ្រចិនខាងត្បូងដូចជាប្រទេសហ្វីលីពីន ម៉ាឡេស៊ីព្រុយណេ និងថ្មីៗក្នុងឆ្នាំ២០២៤នេះ សហរដ្ឋអាមេរិកបានងាកទៅរកការចងសម្ព័ន្ធជាមួយប្រទេសវៀតណាម ដែលកាលពីពេលមុនធ្លាប់តែជាសត្រូវនឹងគ្នា។ ក្នុងន័យនេះ វាបង្ហាញឱ្យឃើញថា សហរដ្ឋអាមេរិកបានប្រឹងប្រែងជួយការពារ និងរក្សាឱ្យតំបន់សមុទ្រចិនខាងត្បូងមានស្ថិរភាព និងសុវត្ថិភាព ដោយមិនអាចធ្លាក់ចូលទៅកណ្តាប់ដៃរបស់ប្រទេសចិនទាំងអស់នោះទេ។ ការដែលសហរដ្ឋអាមេរិកបង្ហាញជំហរយ៉ាងរឹងមាំ ក្នុងការជ្រៀតជ្រែកចូលក្នុងជម្លោះសមុទ្រចិនខាងត្បូងនេះគឺដើម្បី ការពារសមុទ្រចិនខាងត្បូង និងទប់ស្កាត់សកម្មភាពមួយចំនួនរបស់ប្រទេសចិន។ នៅពេលមានភាពតានតឹង និងការបង្កជម្លោះរវាងភាគីពាក់ព័ន្ធ ជាពិសេសភាគីដែលជាប្រទេសមហាអំណាចសហរដ្ឋអាមេរិក ដោយការធ្វើសមយុទ្ធយោធា ការដាក់ទណ្ឌកម្មមួយចំនួន និងភាពរអាក់រអួលនៃសេវាដឹកជញ្ជូន បានធ្វើឱ្យជះឥទ្ធិពលដល់សុខសុវត្ថិភាព និងសេដ្ឋកិច្ចសកលទាំងមូលផងដែរ ។ ជាការពិត ការចូលរួមពីប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ាន និងប្រទេសមហាអំណាចក្នុងជម្លោះដែនទឹកនៅសមុទ្រចិនខាងត្បូងនឹងបង្កជាផលប៉ះពាល់ដល់ស្ថិរភាពក្នុងតំបន់ និងដល់សក្តានុពលភូមិសាស្ត្រនយោបាយសកល។ មិនតែប៉ុណ្ណោះ សមុទ្រចិនខាងត្បូងគឺជាផ្លូវពាណិជ្ជកម្មផ្លូវសមុទ្រដ៏សំខាន់មួយដែលមានទឹកប្រាក់ប្រហែល ៣.៤ ពាន់ពាន់លានដុល្លារ ដែលត្រូវបានជួញដូរជារៀងរាល់ឆ្នាំ។ ការរំខានដោយសារជម្លោះទឹកដី ឬសកម្មភាពយោធាអាចប៉ះពាល់ដល់ការដឹកជញ្ជូនទំនិញ និងរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់សកល ដែលនាំឱ្យតម្លៃទំនិញសកលឡើងថ្លៃ និងប៉ះពាល់ដល់លំហូរពាណិជ្ជកម្មពិភពលោក។ ម្យ៉ាងទៀត នៅក្នុងជម្លោះនេះ ក៏មានលេចឡើងនូវបញ្ហាការប្រកួតប្រជែងធនធានប្រេង និងឧស្ម័ន្ធធម្មជាតិ ដែលនាំឱ្យមានភាពអណាធិបតេយ្យក្នុងការកេងប្រវ័ញ្ចធនធានធម្មជាតិ ដោយបញ្ហានេះនឹងជះឥទ្ធិពលទៅលើសេដ្ឋកិច្ចសកល និងនាំឱ្យមានការបំផ្លិចបំផ្លាញបរិស្ថាន ឬប្រព័ន្ធអេកូឡូស៊ីដែលប៉ះពាល់ដល់ជីវៈចម្រុះ និងជលផលក្នុងស្រុកផងដែរ។

### ខ. ជម្លោះរវាងអ៊ីស្រាអែល និងហាម៉ាស

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៣ ក្រុមចលនាហាម៉ាសដែលជាសកម្មប្រយុទ្ធរបស់ប្រទេសប៉ាឡេស្ទីនបានឈ្លានពានចូលទៅក្នុងទឹកដីអ៊ីស្រាអែលតាមរយៈការចូលក្នុងសហគមន៍នៅព្រំដែនហ្គាហ្សា និងអ៊ីស្រាអែលដោយបានវាយបំផ្លាញរបាំងសម្រាប់ខណ្ឌចែកដែនដីទាំងពីរ ជាពិសេសបានបាញ់គ្រាប់រ៉ុក្កែតជាច្រើនពាន់គ្រាប់ទៅក្នុងដែនដីនៃប្រទេសអ៊ីស្រាអែល។[38] បន្ទាប់ពីអ៊ីស្រាអែលបានទទួលរងការវាយប្រហារយ៉ាងធ្ងន់ធ្ងរពីក្រុម

[38] *"តើសង្គ្រាមអ៊ីស្រាអែល និងហាម៉ាសនឹងបញ្ឈប់ទៅវិញដោយវិធីណា?,"* សារព័ត៌មានថ្មីៗ, តុលា ១១, ២០២៣

សកម្មប្រយុទ្ធហាម៉ាស់ ភាគីអ៊ីស្រាអែលបានប្រកាសដាក់ប្រទេសក្នុងស្ថានភាពសង្គ្រាម និងបានបញ្ជាឱ្យកងទ័ពរបស់ខ្លួនបើកប្រតិបត្តិការវាយប្រហារទៅលើតំបន់ហ្កាហ្សា ដើម្បីឆ្លើយតបទៅនឹងការឈ្លានពានពីសំណាក់ក្រុមហាម៉ាស់ ដោយបានវាយប្រហារវិញដោយប្រើយន្តហោះចម្បាំងរថក្រោះ និងកាំភ្លើងធំបង្ក្រាបទៅលើប្រជាជនប៉ាឡេស្ទីនដោយមិនរើសមុខ។ ជម្លោះរវាងប្រទេសទាំងពីរនេះបានបន្ត និងអូសបន្លាយរហូតមកដល់ពេលបច្ចុប្បន្ននេះ ដែលបានបង្កជាផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជីវិតមនុស្ស អសន្តិសុខនយោបាយ និងសង្គមជាពិសេសទទួលរងនូវវិបត្តិសេដ្ឋកិច្ច។[39]

គួររម្លឹកផងដែរថា ជម្លោះរវាងអ៊ីស្រាអែល-ប៉ាឡេស្ទីនមិនមែនទើបតែកើតឡើងនៅរយៈពេលថ្មីៗនេះទេ គឺជម្លោះនេះមានឫសគល់ និងបានចាប់ផ្តើមនៅចុងសតវត្សទី ១៩ និងដើមសតវត្សទី ២០ ជាមួយនឹងកំណើតនៃចលនាជាតិនិយមសំខាន់ៗក្នុងចំណោមពួកជ្វីហ្វ(អ៊ីស្រាអែល) និងក្នុងចំណោមពួកអារ៉ាប់(ប៉ាឡេស្ទីន) ដែលពួកគេទាំងពីរមានបំណងឆ្ពោះទៅរកការទទួលបានអធិបតេយ្យភាព សម្រាប់ប្រជាជនរបស់ពួកគេរៀងៗខ្លួននៅតំបន់មជ្ឈិមបូព៌ា។ ទោះបីជាអ៊ីស្រាអែល និងប៉ាឡេស្ទីន បានចុះកិច្ចព្រមព្រៀងជាមួយគ្នាក៏ដោយ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ភាគីក្រុមជ្រុលនិយមរបស់អ៊ីស្រាអែលមិនយល់ព្រមឱ្យរដ្ឋាភិបាលអ៊ីស្រាអែលបញ្ឈប់ការកាន់កាប់ដែនដីប្រទេសប៉ាឡេស្ទីន ហើយពួកជ្រុលនិយមទាំងនោះក៏មិនយល់ព្រមដកខ្លួនចេញពីដែនដីប៉ាឡេស្ទីនដែលខ្លួនបានកាន់កាប់នោះដែរ។ ចំណែកឯខាងភាគីប៉ាឡេស្ទីនវិញ ពួកជ្រុលនិយមហាម៉ាស់ និងជីហាតអ៊ីស្លាមីត ដែលមិនព្រមទទួលស្គាល់កិច្ចព្រមព្រៀងនោះ បានបន្តប្តេជ្ញាតាំងចិត្តថានឹងធ្វើការកម្ទេចអ៊ីស្រាអែលជាក់ជាមិនខាន។ ហេតុផលទាំងអស់នេះគឺសុទ្ធសឹងជាបុព្វហេតុ ដែលធ្វើឱ្យពួកជ្រុលនិយមហាម៉ាស់បន្តធ្វើភេរវកម្ម និងឈ្លានពានមកលើភាគីអ៊ីស្រាអែល។ បើតាមរយៈជម្លោះចុងក្រោយនៅចុងឆ្នាំ២០២៣ ភាគីអ៊ីស្រាអែលបានប្រើអំពើឃោរឃៅមកលើប្រជាជនប៉ាឡេស្ទីន ដែលគម្រាមកំហែងដល់អាយុជីវិតពលរដ្ឋប៉ាឡេស្ទីន ដោយនេះជាមូលហេតុ និងដើមចមឱ្យក្រុមសកម្មជនហាម៉ាស់បើកការវាយប្រហារសារជាថ្មីនៅលើទឹកដីអ៊ីស្រាអែល។

គិតមកត្រឹមដើមឆមាសទី ២ ក្នុងឆ្នាំ ២០២៤ ជម្លោះបានផ្ទុះឡើង ជម្លោះហាម៉ាស់ និងអ៊ីស្រាអែលមិនទាន់មានសញ្ញាណបញ្ចប់នៅឡើយ បើទោះបីជាមានការបាត់បង់អាយុជីវិតយ៉ាងធ្ងន់ធ្ងរពីភាគីទាំងពីរ និងវិបត្តិមនុស្សធម៌ដែលកាន់តែមានហានិភ័យពីមួយថ្ងៃទៅមួយថ្ងៃក៏ដោយ។ នៅពាក់កណ្តាលខែធ្នូ ឆ្នាំ ២០២៣ តួលេខនានារបស់អង្គការសហប្រជាជាតិ ទីភ្នាក់ងារសុខាភិបាលតំបន់ហ្កាហ្សា ក៏ដូចជាអាជ្ញាធរអ៊ីស្រាអែលបានឱ្យដឹងថាមនុស្សប្រមាណ ២ ម៉ឺននាក់បានស្លាប់ ក្នុងនោះមានជនជាតិប៉ាឡេស្ទីនជាង ១៨ ៥០០ នាក់ (រួមទាំងកងកម្លាំងហាម៉ាស និងជនស៊ីវិល) ព្រមទាំងជនស៊ីវិល និងកងទ័ពអ៊ីស្រាអែលជាង ១ ៤០០នាក់។

[39] ឈាង បុប្ផា, *"អ៊ីស្រាអែលប្រកាសសង្គ្រាមក្រោយការវាយប្រហារទ្រង់ទ្រាយមិនធ្លាប់មានរបស់ក្រុមហាម៉ាស,"* rfi, តុលា ០៧, ២០២៣ https://www.rfi.fr/km

ទាំងនេះគឺជាតួលេខខាតបង់ដ៏ធ្ងន់ធ្ងរបំផុតចំពោះភាគីទាំងអ៊ីស្រាអែល និងប៉ាឡេស្ទីនចាប់តាំងពីចុងទសវត្សន៍ទី ១៩ មក។ ជម្លោះនេះបានធ្វើឱ្យសេដ្ឋកិច្ចនៃប្រទេសទាំងពីរទទួលរងការខាតបង់ជាច្រើន ជាពិសេសសេដ្ឋកិច្ចក្នុងប្រទេសប៉ាឡេស្ទីនដែលស្ថិតនៅក្នុងស្ថានភាពជាប់គាំងព្រោះពលរដ្ឋប៉ាឡេស្ទីនខិតខំព្យាយាមរត់គេច និងស្វះស្វែងរកទីសុវត្ថិភាពដើម្បីធានាឱ្យទទួលបានការរស់រានមានជីវិតពីការវាយប្រហាររបស់អ៊ីស្រាអែល ដែលនាំឱ្យមិនមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេស។ ជម្លោះនេះបានធ្វើឱ្យសេដ្ឋកិច្ចនៃប្រទេសទាំងពីរទទួលរងការខាតបង់ជាច្រើន ជាពិសេសសេដ្ឋកិច្ចក្នុងប្រទេសប៉ាឡេស្ទីនដែលស្ថិតនៅក្នុងស្ថានភាពជាប់គាំងព្រោះពលរដ្ឋប៉ាឡេស្ទីនខិតខំព្យាយាមរត់គេច និងស្វះស្វែងរកទីសុវត្ថិភាពដើម្បីធានាឱ្យទទួលបានការរស់រានមានជីវិតពីការវាយប្រហាររបស់អ៊ីស្រាអែល ដែលនាំឱ្យមិនមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេស។ ជាក់ស្តែង បើតាមរយៈក្រាហ្វិកខាងក្រោម នៅពេលដែលមានជម្លោះ និងសង្គ្រាមបានកើតឡើងនៅក្នុងតំបន់ហ្គាហ្សា វាបានធ្វើឱ្យកំណើនផលិតផលក្នុងស្រុកសរុប (GDP) របស់ប៉ាឡេស្ទីនមានអត្រាប្រែប្រួលថយចុះយ៉ាងគំហុក ដោយក្នុងកំឡុងពេលឆ្នាំ ២០១៤ កំណើនសេដ្ឋកិច្ចប៉ាឡេស្ទីនមានអត្រាកំណើនអវិជ្ជមាន ៣៧.៩៨% ជាពិសេសជម្លោះថ្មីៗនេះ ដែលទើបតែចាប់ផ្តើមក្នុងឆ្នាំ ២០២៣ បានរុញច្រានឱ្យសេដ្ឋកិច្ចប៉ាឡេស្ទីនធ្លាក់ចុះក្នុងអត្រាកំណើនអវិជ្ជមានរហូតដល់ ៨៦.៣៧%។ ការថយចុះដ៏សន្ធឹកសន្ធាប់នៃកំណើនសេដ្ឋកិច្ចនេះបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ពលរដ្ឋប៉ាឡេស្ទីន ក៏ដូចជាបំផ្លិចបំផ្លាញដល់ខឿនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។

**ក្រាហ្វិកទី១៣៖ កំណើន ផ.ស.ស. របស់ប៉ាឡេស្ទីនចាប់ពីត្រីមាសទី ៣ ក្នុងឆ្នាំ ២០១៣ ដល់ឆ្នាំ ២០២៣**




ប្រភព៖ ស្ថិតិរបស់ការិយាល័យកណ្តាលប៉ាឡេស្ទីន (PCBS)

រីឯសេដ្ឋកិច្ចប្រទេសអ៊ីស្រាអែលវិញមិនសូវជាប៉ះពាល់ខ្លាំងនោះទេ ដោយសារតែមានជំនួយ និងការការពារពីសហរដ្ឋអាមេរិកក្នុងនាមជាប្រទេសសម្ព័ន្ធមិត្តប្រវត្តិសាស្ត្រ ដែលបានផ្តល់នូវកិច្ចគាំទ្រវិស័យយោធា និងថវិកាជាច្រើនដល់ប្រទេសខ្លួន។ ការចេញមុខគាំទ្រពីសំណាក់ប្រទេសមហាអំណាចនេះគឺដោយសារសហរដ្ឋអាមេរិកមានទំនាក់ទំនងសេដ្ឋកិច្ច និងទទួលបានផលចំណេញពីតំណក់ប្រេងរបស់អ៊ីស្រាអែលស្របពេលដែលទីផ្សារផ្គត់ផ្គង់ថាមពលសកលមានភាពខ្វះខាត ជាពិសេសសហរដ្ឋអាមេរិកចង់រៀបសណ្តាប់ធ្នាប់ និងពង្រឹងភូមិសាស្ត្រនយោបាយនៅតំបន់មជ្ឈិមបូព៌ាឱ្យមានរបៀបរៀបរយ និងស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។ ជាមួយគ្នានេះ ជម្លោះរវាងអ៊ីស្រាអែល និងក្រុមហាម៉ាសគឺមានការពាក់ព័ន្ធទៅដល់ភូមិសាស្ត្រនយោបាយ ទីតាំងយុទ្ធសាស្ត្រ សាសនា ពូជសាសន៍ ឧត្តមភាពរបស់ពួកមហាអំណាច និងតំណក់ប្រេងកាត។[40]

ការណ៍នេះ នៅក្នុងស្ថានភាពដ៏តានតឹងរវាងជម្លោះអ៊ីស្រាអែល និងក្រុមហាម៉ាស បាននាំឱ្យពិភពលោកទទួលរងឥទ្ធិពលអវិជ្ជមាន ដែលបានផ្តល់ផលប៉ះពាល់ដល់ស្ថិរភាពនយោបាយ សង្គម និងសេដ្ឋកិច្ចសកលទាំងមូល។ តួយ៉ាង នៅពេលមានជម្លោះកាន់តែខ្លាំងឡើងរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីនបានធ្វើឱ្យទំនាក់ទំនងរវាងបណ្តាប្រទេសមួយចំនួននៅតំបន់មជ្ឈិមបូព៌ាមានភាពរង្គោះរង្គើ និងអាចបង្កជាចលាចលក្នុងតំបន់ ដែលនាំឱ្យមានការរាំងស្ទះដល់ការផ្គត់ផ្គង់ប្រេងចូលទៅក្នុងទីផ្សារសកលព្រោះតំបន់មជ្ឈិមបូព៌ាជាតំបន់មួយ ដែលមានចំណែកក្នុងការផ្គត់ផ្គង់ប្រេងជិតមួយភាគបីនៃការផ្គត់ផ្គង់ប្រេងសរុបរបស់ពិភពលោក។ ក្នុងន័យនេះ នៅពេលដែលការផ្គត់ផ្គត់មានភាពរអាក់រអួល នោះបានធ្វើឱ្យការនាំចេញប្រេងទៅទីផ្សារសកលធ្លាក់ចុះមួយចំណែកធំ ដែលនាំឱ្យតម្លៃប្រេងកើនឡើង ដោយវាបានបង្កជាផលវិបាកដល់សកម្មភាពសេដ្ឋកិច្ចសកល ជាពិសេសប៉ះពាល់ខ្លាំងដល់វិស័យដឹកជញ្ជូន ដោយធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចមានកំណើនទាប និងមិនមាននិរន្តរភាព។ លើសពីនេះទៅទៀត ជម្លោះនេះក៏បានធ្វើឱ្យទីផ្សារហ៊ុនសកលងាយរងនឹងហានិភ័យដោយសារភាពមិនប្រាកដប្រជានៃស្ថានភាពនយោបាយ និងសេដ្ឋកិច្ច ជាពិសេសការវិនិយោគថយចុះដោយសារការតម្លើងអត្រាការប្រាក់ដើម្បីទប់ទល់នឹងការកើនឡើងនៃអត្រាអតិផរណា។ មិនតែប៉ុណ្ណោះភាពតានតឹងនៃជម្លោះនេះ ក៏បានធ្វើឱ្យបណ្តាប្រទេសធំៗកំពុងប្រឈមមុខដាក់គ្នាពាក់ព័ន្ធនឹងការប្រកួតប្រជែងទីតាំងភូមិសាស្ត្រនយោបាយ ដែលនាំឱ្យមាននិន្នាការបែងចែកប្លុកភូមិសាស្ត្រ និងពាណិជ្ជកម្ម។

### គ. ភាពតានតឹងនៅតំបន់សមុទ្រក្រហម

ចាប់តាំងពីជម្លោះរវាងអ៊ីស្រាអែល និងក្រុមហាម៉ាសបានផ្ទុះឡើងមក ការរាលដាលនៃជម្លោះនេះបានបង្កឱ្យមាននូវអស្ថិរភាព និងអសន្តិសុខនៅក្នុងតំបន់មជ្ឈិមបូព៌ា ជាពិសេសនៅតាមសមុទ្រក្រហម ដែលជាផ្លូវទឹក ដ៏សំខាន់សម្រាប់តភ្ជាប់ពីមហាសមុទ្រឥណ្ឌាទៅសមុទ្រមេឌីទែរ៉ាណេតាមរយៈព្រែកជីកស៊ុយអេ ដោយកំពុងសម្រួលដល់លំហូរពាណិជ្ជកម្មពីអឺរ៉ុបទៅកាន់អាស៊ី។ ជាក់ស្តែង ភាពអសន្តិសុខនៅតំបន់សមុទ្រក្រហម

[40] ប៊ុន, *"ដើមហេតុនៃសង្គ្រាមរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន,"* The Other Truth, ធ្នូ ២៩, ២០២៣
https://theothertruth.info/history-of-the-israeli-palestinian-conflict/

កំពុងតែក្លាយជាប្រធានបទដ៏ក្ដៅគគុកមួយ ដែលបានគម្រាមកំហែងដល់ចរាចរណ៍នាវាដឹកទំនិញធ្វើដំណើរឆ្លងកាត់ ស្របពេលតំបន់សមុទ្រក្រហមគឺជាផ្លូវទឹកដ៏សំខាន់មួយដែលចាំបាច់សម្រាប់សេរីភាពនាវាចរណ៍ និងជាច្រករបៀងសមុទ្រដ៏សំខាន់មួយដែលសម្រួលពាណិជ្ជកម្មអន្តរជាតិក្នុងការដឹកជញ្ជូនទំនិញ និងថាមពល ជាពិសេសជាខ្សែផ្លូវទឹកមានចម្ងាយខ្លី ដែលនាវាប្រើរយៈពេលតិចក្នុងការដឹកជញ្ជូនរំហូរពាណិជ្ជកម្មពីទ្វីបអឺរ៉ុបទៅទ្វីបអាស៊ី ដោយវាបានធ្វើឱ្យថ្លៃដឹកជញ្ជូនមានតម្លៃទាប និងនាំឱ្យការចំណាយថ្លៃដើមផលិតកម្មទាបផងដែរ។ ទោះបីជាយ៉ាងណា តាមរយៈស្ថានការណ៍វិវត្តន៍ចុងក្រោយនៅក្នុងបរិបទជម្លោះនៅហ្គាហ្សា សន្តិសុខនៅតំបន់សមុទ្រក្រហមក៏កំពុងតែបង្កឱ្យមានភាពតានតឹងកាន់តែខ្លាំងឡើង ដោយសារក្រុមឧទ្ទាមហ៊ូទីនៅប្រទេសយេម៉ែនបានវាយប្រហារជាច្រើនលើកទៅលើដែនសមុទ្រ ដោយបានបាញ់មីស៊ីល គ្រាប់រ៉ុកែត ដ្រូនអត្តឃាត ព្រមទាំងបានប្លន់យកនាវាដឹកទំនិញ និងបានប្រកាសគម្រាមថានឹងវាយប្រហារលើកប៉ាល់ដឹកទំនិញអន្តរជាតិដែលបើកឆ្លងកាត់ច្រកសមុទ្របាបអ៊ែលម៉ាន់ដេប (Bab al-Mandeb) កៀកនឹងឆ្នេរនៃប្រទេសយេម៉ែនដើម្បីជាការឆ្លើយតបទៅនឹងការទម្លាក់គ្រាប់បែករបស់អ៊ីស្រាអែលទៅលើតំបន់ហ្គាហ្សានៅក្នុងប្រទេសប៉ាឡេស្ទីន។ នៅក្នុងស្ថានការណ៍ដ៏តានតឹងនេះ បាននឹងកំពុងបង្ខំឱ្យក្រុមហ៊ុនដឹកជញ្ជូនប្ដូរការធ្វើចរាចរណ៍នាវាទៅតាមបណ្ដោយផ្លូវទឹកផ្សេង ពោលគឺងាកទៅប្រើផ្លូវវៀងឆ្ងាយដែលប្រើរយៈពេលវែង និងចំណាយក្នុងការដឹកជញ្ជូនកាន់តែខ្ពស់ជាងមុន។ បើតាមអ្នកជំនាញពាណិជ្ជកម្មរបស់សភាពាណិជ្ជកម្មអង់គ្លេសបាននិយាយថា កុងតឺន័រប្រហែល ៥ សែនគ្រឿង ត្រូវបានឆ្លងកាត់ព្រែកជីកស៊ុយអេក្នុងខែវិច្ឆិកា ប៉ុន្តែវាបានធ្លាក់ចុះ ៦០ ភាគរយមកនៅត្រឹម ២ សែនគ្រឿង ប៉ុណ្ណោះក្នុងខែធ្នូ ឆ្នាំ ២០២៣។ មិនត្រឹមតែប៉ុណ្ណោះ វាបានបង្កើនការចំណាយដោយកុងតឺន័រមានតម្លៃ ១ ៥០០ ដុល្លារក្នុងខែវិច្ឆិកា កើនឡើងដល់ ៤ ០០០ ដុល្លារក្នុងខែធ្នូ ឆ្នាំ ២០២៣។

ដូចនេះ ភាពតានតឹងនៅតំបន់សមុទ្រក្រហមបានជះជាបច្ច័យអវិជ្ជមានជាច្រើនដល់ពិភពលោកទាំងលើទិដ្ឋភាពភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ដោយក្នុងនោះវាបានធ្វើឱ្យរំខានដល់ផ្លូវដឹកជញ្ជូនសំខាន់ៗរបស់ពិភពលោក និងបង្កភាពយឺតយ៉ាវក្នុងបណ្ដាញផ្គត់ផ្គង់សកល ដែលរុញច្រានឱ្យថ្លៃទំនិញ និងសេវាកម្មនៅលើសកលមានតម្លៃខ្ពស់ ដោយវាជាសម្ពាធក្នុងការបង្កើនអត្រាអតិផរណាសកលបន្ថែមទៀត ជាពិសេសប៉ះពាល់យ៉ាងខ្លាំងដល់រំហូរពាណិជ្ជកម្មសកល ដែលនាំឱ្យការធ្វើពាណិជ្ជកម្មតាមបណ្ដាប្រទេសនានាជួបផលវិបាក និងធ្លាក់ចុះនៃការដោះដូរពាណិជ្ជកម្មសកល។ ជាងនេះទៅទៀត វាក៏បានបន្តឱ្យប៉ះពាល់ដល់ការវិនិយោគព្រោះថ្លៃដើមមានតម្លៃខ្ពស់ និងមានហានិភ័យខ្ពស់ក្នុងការវិនិយោគ ដែលធ្វើឱ្យវិនិយោគិនយកដើមទុនរបស់ខ្លួនទុកសន្សំជំនួសឱ្យការបណ្ដាក់ទុននៅតាមបណ្ដាវិស័យ ដោយនេះវាបាននាំឱ្យការវិនិយោគធ្លាក់ចុះ និងនាំឱ្យមានការថយចុះនៃកំណើនសេដ្ឋកិច្ចសកល។ តាមរយៈនៃឥទ្ធិពលអវិជ្ជមានទាំងអស់នេះ បានធ្វើឱ្យសេដ្ឋកិច្ចពិភពលោកជួបប្រទះនឹងវិបត្តិជាច្រើន ដែលនាំឱ្យប្រទេសនានាបាត់បង់នូវស្ថិរភាពសេដ្ឋកិច្ច និងមានកំណើនថមថយដែលរាំងស្ទះដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ភាពតានតឹងនេះមិនត្រឹមតែប៉ះពាល់ដល់សេដ្ឋកិច្ច

សកលនោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យភូមិសាស្ត្រនយោបាយសកលមានភាពមិនប្រកដប្រជា ដោយមានទំនោរបែងចែកភូមិសាស្ត្រទៅជាពហុប៉ូលក្រោមការចង្អុលបង្ហាញពីប្រទេសមហាអំណាចផ្សេងៗគ្នា។[41]

### ៣.១.១.៤. ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល

នៅកំឡុងដើមឆ្នាំ២០២២ ប្រទេសរុស្សីបានចាប់ផ្តើមធ្វើការឈ្លានពានទៅលើទឹកដីនៃប្រទេសអ៊ុយក្រែន ដែលធ្វើឱ្យសហរដ្ឋអាមេរិក និងបណ្តាប្រទេសលោកខាងលិចបានថ្កោលទោសប្រទេសរុស្សីជាខ្លាំង និងបានដាក់នូវទណ្ឌកម្ម សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងន់ទៅដល់ប្រទេសរុស្សីក្នុងការរឹតបន្តឹង និងដាក់ហាមឃាត់លើការនាំចូល ឬដឹកជញ្ជូនប្រេងឆៅ និងផលិតផលគីមីឥន្ធនៈពីប្រទេសរុស្សីចូលទៅក្នុងប្រទេសបស្ចិមលោកទាំងនោះ។ តាមរយៈការដាក់ទណ្ឌកម្មសេដ្ឋកិច្ចនេះ បានធ្វើឱ្យការផ្គត់ផ្គង់ថាមពលនៅលើសកលលោកមានភាពខ្វះខាតដែលមិនអាចបំពេញនូវតម្រូវការទីផ្សារបាន ដែលនាំឱ្យថ្លៃថាមពលមានការកើនឡើងយ៉ាងខ្លាំង ហើយវាក៏ធ្វើឱ្យតម្លៃនៃការដឹកជញ្ជូនមានតម្លៃខ្ពស់ ដោយវាបានប៉ះពាល់ដល់ថ្លៃដើមផលិតកម្ម និងនាំឱ្យថ្លៃទំនិញ និងសេវាកម្មកើនឡើងដែលបង្កឱ្យមានកំណើនអត្រាអតិផរណាខ្ពស់នៅតាមប្រទេសនានាលើពិភពលោក។ នៅក្នុងស្ថានភាពបែបនេះ ធានាគារកណ្តាលនៃបណ្តាប្រទេសធំៗជាច្រើន ជាពិសេសសហរដ្ឋអាមេរិកបានរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ដោយបានតម្លើងអត្រាការប្រាក់គោលក្នុងគោលដៅទប់ទល់ និងកាត់បន្ថយអត្រាអតិផរណាឱ្យនៅកម្រិតទាប។ ជាក់ស្តែង ចាប់ពី ត្រីមាសទី២ ក្នុងឆ្នាំ២០២២ ធនាគារកណ្តាលអាមេរិកបានដាក់ចេញនូវវិធានការរឹតបន្តឹងគោលនយោបាយ រូបិយវត្ថុដោយបានតម្លើងអត្រាការប្រាក់គោលរបស់ខ្លួនដើម្បីទប់ស្កាត់ពីការហក់ឡើងយ៉ាងខ្ពស់នៃអត្រាអតិផរណាដោយមានអត្រា ៩.១% ដែលជាអត្រាដែលមិនធ្លាប់មានក្នុងរយៈពេល៤០ឆ្នាំកន្លងមកនេះ។ តួលេខដ៏ខ្ពស់នៃអត្រាអតិផរណានេះគឺបណ្តាលមកពីបញ្ហាសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលធ្វើឱ្យថ្លៃដើមផលិតកម្មកើនឡើង ស្របពេលជាមួយនឹងការកើនឡើងយ៉ាងខ្លាំងនៃតម្រូវការទំនិញ និងសេវាកម្មរបស់ពលរដ្ឋអាមេរិកបន្ទាប់ពីមានភាពធូរស្រាលនៃជំងឺកូវីដ១៩។ ខណៈពេលជាមួយគ្នានេះក៏មានកង្វះខាតនៃការផ្គត់ផ្គត់ទំនិញ និងសេវាកម្មទាំងនៅក្នុង និងក្រៅប្រទេស ដែលធ្វើឱ្យខ្សែសង្វាក់ផលិតកម្មមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផលិតនូវទំនិញ និងសេវាកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់បានទាន់ពេលវេលា ដោយការណ៍នេះបានធ្វើឱ្យមានការកើនឡើងកាន់តែខ្លាំងនូវថ្លៃទំនិញ និងសេវាកម្មនៅក្នុងទីផ្សារ(ច្បាប់តម្រូវការ-ផ្គត់ផ្គង់) ហើយវាក៏បានធ្វើឱ្យតម្លៃនៃរូបិយវត្ថុអាមេរិកធ្លាក់ចុះផងដែរ។ លើសពីនេះទៅទៀតបើមើលតាមរយៈក្រាហ្វិកខាងក្រោម ធនាគារគណ្តាលនៅក្នុងប្រទេសមហាអំណាចធំៗបានតម្លើងនូវអត្រាការប្រាក់របស់ខ្លួនដើម្បីទប់ស្កាត់នឹងបញ្ហាអតិផរណា។ ក្នុងនោះ ធនគារកណ្តាលអាមេរិកបានតម្លើងអត្រាការប្រាក់ក្នុងអត្រាចាប់ពី ០.១៣% នៅឆ្នាំ ២០២១ រហូតដល់អត្រាការប្រាក់ ៥.៣៨% ក្នុងឆ្នាំ ២០២៣ ដែលជាតួលេខ

[41] យឿន ពុធធីតា, "*ការវាយប្រហារនៅសមុទ្រក្រហមអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក,*" AMS Economy, មករា ១៦, ២០២៤ https://economy.ams.com.kh/economic/news/the-red-sea-crisis-could-seriously-affect-global-economic-recovery/

កើនយ៉ាងច្រើនគួរឲ្យកត់សម្គាល់។ ចំណែកឯ ប្រទេសនៅក្នុងសហភាពអឺរ៉ុបវិញ ធនាគារកណ្តាលនៃប្រទេសទាំងនេះបានរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ដែលបានតម្លើងអត្រាការប្រាក់ក្នុងអត្រា ៤.៥% ក្នុងឆ្នាំ ២០២៣ ហើយបានបន្តព្យាករណ៍នៅឆ្នាំ ២០២៤ នូវអត្រា ៣.៧៥%។

**ក្រាហ្វិកទី១៤ ៖ បង្ហាញពីអត្រាការប្រាក់ក្នុងប្រទេសអភិវឌ្ឍន៍ចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៤**




ប្រភព៖ Statista 2024

ការតម្លើងនូវអត្រាការប្រាក់នេះ នឹងធ្វើឱ្យពលរដ្ឋយកថវិកាមួយចំណែករបស់ខ្លួនទៅវិនិយោគនៅក្នុងប្រព័ន្ធធនាគារដោយធ្វើការដាក់សន្សំដើម្បីទទួលបានការប្រាក់បន្ថែម ដែលធ្វើឱ្យរូបិយប័ណ្ណនៅក្នុងទីផ្សារថយចុះ។ ជាមួយគ្នានេះ ពួកគេនឹងកាត់បន្ថយការចំណាយទៅលើទំនិញ និងសេវាកម្មឱ្យនៅតិចជាងមុន ដែលវាអាចកាត់បន្ថយនូវតម្រូវការទំនិញ និងសេវាកម្មរបស់អ្នកប្រើប្រាស់នៅក្នុងទីផ្សារ។ នៅពេលតម្រូវការទំនិញថយចុះ វាក៏បានធ្វើឱ្យថ្លៃទំនិញ និងសេវាកម្មថយចុះផងដែរ ដែលអាចរារាំង និងកាត់បន្ថយអត្រាអតិផរណាឱ្យស្ថិតក្នុងកម្រិតទាប។ ជាពិសេស ការតម្លើងអត្រាការប្រាក់នឹងធ្វើឱ្យអ្នកវិនិយោគបង្វែរដើមទុនវិនិយោគពីខាងក្នុង និងក្រៅប្រទេសចូលមកដាក់សន្សំឬវិនិយោគនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុវិញដើម្បីទទួលបានផលចំណេញខ្ពស់ និងមានហានិភ័យទាបជាងការវិនិយោគទៅលើវិស័យដទៃ។ បើទោះបីជាយ៉ាងណាក៏ដោយ ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុបានជះឥទ្ធិពលដោយផ្ទាល់ និងដោយប្រយោលដល់ប្រទេសដទៃផ្សេងទៀតក្នុងការប្រឈមមុខនឹងបញ្ហាជាច្រើនដូចជា ការថយចុះនៃទំហំវិនិយោគ ការធ្លាក់ចុះរំហូរមូលធន តម្រូវការទំនិញពីទីផ្សារបរទេសមានការថយចុះ និងតម្លៃរូបិយប័ណ្ណក្នុងស្រុកធ្លាក់ថ្លៃផងដែរ។

### ៣.១.១.៥. ការប្រែប្រួលអាកាសធាតុ

ចាប់តាំងពីមានការកកើតឡើងនូវបដិវត្តន៍ឧស្សាហកម្មនៅចន្លោះសតវត្សទី ១៧ និង ១៨ មក មនុស្សចាប់ផ្ដើមចេះប្រើប្រាស់ធនធានធម្មជាតិដើម្បីបម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដោយពេលនោះមនុស្សបានជីកយកធ្យូងថ្ម ដុតប្រេងឥន្ធនៈផូស៊ីល និងយកធនធានធម្មជាតិសំខាន់ផ្សេងទៀតយកទៅកែច្នៃ និងប្រើប្រាស់ជាវត្ថុធាតុដើម ឬឧបករណ៍ផ្សេងៗសម្រាប់បង្កើតនូវរបស់របរប្រើប្រាស់ប្រចាំថ្ងៃ ជាពិសេសបំពេញតម្រូវការឥតព្រំដែនរបស់មនុស្ស។ ការវិវត្តន៍នៃបដិវត្តន៍ឧស្សាហកម្មកាន់តែរីកចម្រើនបន្តទៅមុខរហូតមកដល់សម័យកាលសតវត្សទី២១ ដែលជាពេលកំពុងអនុវត្តន៍នូវបដិវត្តន៍ឧស្សាហកម្មទី៤សម្រាប់ជម្រុញ និងបង្កើននូវសមត្ថភាពកត្តាផលិតកម្មនៅក្នុងវិស័យឧស្សាហកម្មដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់មនុស្ស ខណៈពេលដែលធនធានធម្មជាតិសំខាន់ៗ ប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធជីវៈចម្រុះបាននឹងកំពុងត្រូវរងគ្រោះ និងបាត់បង់ដោយសារតែការបញ្ចេញឧស្ម័នកាបូនិច (ឧស្ម័នពុល) និងការប្រើប្រាស់នូវធនធានទាំងនោះជារៀងរាល់ថ្ងៃ ដែលបណ្ដាលឱ្យស្រទាប់ផែនដីងាយរងគ្រោះ និងបំផ្លាញដល់គម្របធម្មជាតិយ៉ាងធ្ងន់ធ្ងរ។ ការណ៍នេះ បានធ្វើឱ្យកើតមានឡើងនូវការប្រែប្រួលអាកាសធាតុនៅលើភពផែនដីមានកម្រិតខ្ពស់ និងស្ថិតក្នុងល្បឿនលឿនហួសពីលក្ខណៈធម្មជាតិដែលបង្កឱ្យមានបម្រែបម្រួលខ្លាំងនៃលក្ខខណ្ឌធម្មជាតិ និងអាកាសធាតុ។ ការផ្លាស់ប្ដូរនេះបានធ្វើឱ្យសីតុណ្ហភាពមធ្យមនៃភពផែនដីមានការប្រែប្រួលចុះ ឡើងយ៉ាងឆាប់រហ័ស និងកើតមានជាញឹកញាប់នូវគ្រោះទឹកជំនន់ ការឡើងកម្ពស់ទឹកនីវ៉ូសមុទ្រ ខ្យល់ព្យុះ ការធ្លាក់ផ្ទាំងទឹកកកធំៗ បន្ទុះភ្នំភ្លើង គ្រោះរញ្ជួយដី រលកកម្ដៅ ភ្លើងឆេះព្រៃ គ្រោះរាំងស្ងួតជាដើម។

**រូបភាព៖ បង្ហាញពីនិន្នាការនៃការប្រែប្រួលសីតុណ្ហភាពចាប់ពីឆ្នាំ១៩០១ ដល់២០២៣**




ប្រភព៖ ទិន្នន័យ NCEI

ជាទូទៅ ភាគច្រើននៃការប្រែប្រួលអាកាសធាតុគឺកើតឡើងដោយសារសកម្មភាពមនុស្សតាមរយៈការបំផ្លាញឃ្លាំងផ្ទុកកាបូន ការកាប់បំផ្លាញព្រៃឈើ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសផែនដី។ ក្នុងនោះឥទ្ធិពលនៃកំណើនឧស្ម័នផ្ទះកញ្ចក់អាចធ្វើឱ្យកម្ដៅព្រះអាទិត្យអាចចាំងចូលតាមកញ្ចក់ ក៏ប៉ុន្តែកញ្ចក់នេះអាចទប់កម្ដៅមិនឱ្យភាយចេញទៅក្រៅវិញ ទើបធ្វើឱ្យសីតុណ្ហភាពក្នុងផ្ទះកញ្ចក់មានកម្រិតខ្ពស់ ហើយបើសិនជាស្រទាប់ឧស្ម័ននេះកើនឡើង ទប់កម្ដៅបានច្រើន វាក៏ធ្វើឱ្យសីតុណ្ហភាពកើនឡើង ដែលបង្កឱ្យមានរលកកម្ដៅនៅលើផែនដីកាន់តែខ្លាំង។ ជាក់ស្ដែង ការកើនឡើងនៃប្រេកង់ អាំងតង់ស៊ីតេ និងរយៈពេលនៃរលកកម្ដៅនឹងបង្កើនសម្ពាធក្ដៅទៅក្នុងបរិយាកាស បង្កើតឱ្យមានករណីភ្លើងឆេះព្រៃនៅលើសកលលោក គុណភាពខ្យល់កាន់តែអាក្រក់ទៅៗ ដែលផ្ដល់ហានិភ័យកាន់តែខ្ពស់ដល់សុខភាពមនុស្ស និងប្រព័ន្ធអេកូឡូស៊ី ហើយវាក៏នាំឱ្យមានគ្រោះរាំងស្ងួតផងដែរ។ តួយ៉ាង យោងតាមទីភ្នាក់ងារអង្គការសហប្រជាជាតិសម្រាប់ចំណីអាហារ និងកសិកម្ម (FAO) បានឱ្យដឹងថា មនុស្សប្រមាណ ៧៨៣លាននាក់ ឬច្រើនជាង ៩% នៃប្រជាជនពិភពលោក បានទទួលរងគ្រោះទុរភិក្សដ៏រ៉ាំរ៉ៃកាលពីឆ្នាំ២០២៣ ការប្រែប្រួលអាកាសធាតុគឺជាកត្តាមួយដ៏សំខាន់នៃវិបត្តិគ្រោះទុរភិក្ស | RVA (rvasia.org) ។ លើសពីនេះទៅទៀត បើតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិបានបង្ហាញថា ការកើនឡើងកម្ដៅបានផ្ដល់ហានិភ័យខ្ពស់ដល់សុខភាពរបស់ពលករ ដែលកម្លាំងពលកម្មជិត ៧១% ឬប្រហែលចំនួនប្រមាណ ២,៤០០លាននាក់ កំពុងធ្វើការក្រោមកម្ដៅដ៏ក្ដៅហួតហែង ដោយនេះបង្ហាញឱ្យឃើញពីការប្រឈមមុខនឹងជំងឺ និងគ្រោះថ្នាក់មួយចំនួនដល់ពលករទាំងនោះ ដែលមានដូចជាការទទួលរងពីពន្លឺកាំរស្មីអ៊ុលត្រា(UV) ខ្យល់ពុល និងការងាយឆ្លងនឹងជំងឺអាសន្នរោគផ្សេងៗ ដោយធ្វើឱ្យសុខុមាលភាពរបស់ពលករថយចុះ បាត់បង់ចំណែកនៃប្រាក់ចំណូលរបស់ខ្លួន ខាតបង់ពេលវេលា និងអត្រានៃអាយុសង្ឃឹមរស់ទាប។ ផលប៉ះពាល់ទាំងអស់នេះមិនមែនត្រឹមតែផ្ដល់ផលវិបាកដល់ពលករប៉ុណ្ណោះទេ វាថែមទាំងប៉ះពាល់ដល់សេដ្ឋកិច្ច និងការរស់នៅរបស់ប្រជាជនទាំងអស់ ដែលទទួលរងក្រោមឥទ្ធិពលនៃការកើនឡើងកម្ដៅសកលនេះ។

**ក្រាហ្វិកទី១៥ ៖ បង្ហាញពីកម្រិតសីតុណ្ហភាពចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ២០២២**




ប្រភព៖ ស្នាក់កណ្ដាលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុក៏បណ្តាលឱ្យបាត់លំនឹងប្រព័ន្ធអេកូឡូស៊ី ដោយតំបន់ខ្លះគ្មានភ្លៀងសោះ ហេតុបង្កទៅជាគ្រោះរាំងស្ងួត ដែលបង្កជាឧបសគ្គដល់ការដាំដុះដំណាំកសិកម្ម។ តាមការសិក្សាមួយបានឱ្យដឹងថា គ្រោះរាំងស្ងួតបានលាតសន្ធឹងពាសពេញទ្វីបទាំងបីនៅរដូវក្តៅឆ្នាំ ២០២២។ គ្រោះខ្សត់ភ្លៀងនេះ បណ្តាលឱ្យសណ្ឋានដីមួយផ្នែកធំនៃទ្វីបអឺរ៉ុប សហរដ្ឋអាមេរិក និងប្រទេសចិនមានសភាពស្ងួត គ្មានសារធាតុទឹករឹងសោះកក្រោះ។ ការសិក្សាបន្តអះអាងទៀតថា គ្រោះរាំងស្ងួតបានកើនឡើងលើសពីធម្មតាប្រមាណ២០ដងដោយសារការបម្រែបម្រួលកាសធាតុ។ គ្រោះរាំងស្ងួតធ្វើឱ្យទន្លេធំៗគោក រាក់ឃើញតែដីបែកក្រហែង បំផ្លាញដំណាំបង្កជាភ្លើងឆេះព្រៃ គម្រាមកំហែងដល់ប្រភេទសត្វក្នុងទឹក និងនាំឱ្យបណ្តារដ្ឋមួយចំនួនចេញវិធានការរឹតបន្តឹងការប្រើប្រាស់ទឹកដោយប្រើសន្សំសំចៃ។ គ្រោះរាំងស្ងួត បានវាយប្រហារនៅសហរដ្ឋអាមេរិក និងប្រទេសលោកខាងលិចដែលជាប្រទេសធ្លាប់មានសីតុណ្ហភាពត្រជាក់។ ប្រទេសចិនក៏ទើបតែមានរដូវក្តៅដ៏ក្រៀមស្វិតបំផុតក្នុងរយៈពេល ៦០ ឆ្នាំ បណ្តាលឱ្យទន្លេយង់សេ( Yangtze )ដ៏ល្បីល្បាញរួមទទឹងទឹករហូតសល់ត្រឹមពាក់កណ្តាលតូចជាងផ្ទៃទន្លេពេលធម្មតា។ ចំណែកឯតំបន់ខ្លះទៀត មានភ្លៀងធ្លាក់ខ្លាំងក្នុងរយៈពេលយូរ ដែលបង្កទៅជាទឹកជំនន់ ជន់លិចដែលធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធ ទ្រព្យសម្បត្តិ ផ្ទះសម្បែង និងប៉ះពាល់ដល់អាយុជីវិតរបស់ពលរដ្ឋនៅតាមបណ្តាប្រទេសមួយចំនួន។ កាលពីឆ្នាំ២០២១ នៅភាគកណ្តាលក្នុងប្រទេសចិន ចំនួនជនរងគ្រោះស្លាប់នៅក្នុងគ្រោះទឹកជំនន់ដោយសារភ្លៀងធ្លាក់កើនឡើងយ៉ាងហោចដល់៥៧នាក់ និងបានបំផ្លាញ។ ចំណែកនៅក្នុងប្រទេសឥណ្ឌាស្ថិតតំបន់ភាគខាងលិច មានជនរងគ្រោះស្លាប់យ៉ាងហោចណាស់៦៧នាក់ដោយសារទឹកភ្លៀងបានធ្លាក់ឥតឈប់ ក្នុងរយៈពេលតែ២៤ម៉ោង កម្ពស់ទឹកភ្លៀងបានឡើងដល់ ២០០ មីល្លីម៉ែត្រ នៅតំបន់ឆ្នេរខាងលិច និងកន្លែងខ្លះដល់៥៩៤មីល្លីម៉ែត្រ។ ទឹកទន្លេ Vashishti នៃតំបន់ប៊ុមបេ បានជន់ជោរ ក្លាយជាទឹកជំនន់លិច តំបន់ជុំវិញ និងបង្កឱ្យមានការហូរបាក់ដី ដែលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធស្ពាន ផ្លូវថ្នល់ អគារ។ល។

តាមរយៈការប្រែប្រួលនៃលក្ខខណ្ឌធម្មជាតិ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យផ្សេងៗនៃសង្គមមានទំនាក់ទំនងគ្នាទៅវិញទៅមក។ គ្រោះរាំងស្ងួតអាចប៉ះពាល់ដល់ផលិតកម្មអាហារ និងសុខភាពមនុស្ស។ ទឹកជំនន់អាចនាំឱ្យមានការរីករាលដាលនៃជំងឺ និងការខូចខាតដល់ប្រព័ន្ធអេកូឡូស៊ី និងហេដ្ឋារចនាសម្ព័ន្ធ។ បញ្ហាសុខភាពមនុស្សអាចបង្កើនអត្រាមរណៈ ប៉ះពាល់ដល់លទ្ធភាពទទួលបានអាហារ និងកម្រិតផលិតភាពរបស់កម្មករ។ ផលប៉ះពាល់បម្រែបម្រួលអាកាសធាតុត្រូវបានបង្ហាញឱ្យឃើញនៅគ្រប់ទិដ្ឋភាពនៃពិភពលោកដែលយើងរស់នៅ។ បម្រែបម្រួលអាកាសធាតុ និងការកើនឡើងនៃព្រឹត្តិការណ៍អាកាសធាតុខ្លាំង គឺជាហេតុផលដែលនៅពីក្រោយការគម្រាមកំហែងសុខភាពសាធារណៈដ៏ធំបំផុតរបស់មនុស្សជាតិ ដែលវាកំពុងបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សតាមរយៈការបំពុលបរិយាកាស ជំងឺ ការផ្លាស់ទីលំនៅដោយបង្ខំ សម្ពាធលើសុខភាពផ្លូវចិត្ត និងការកើនឡើងនៃភាពអត់ឃ្លាន និងអាហាររូបត្ថម្ភមិនគ្រប់គ្រាន់។ ជារៀងរាល់ឆ្នាំ កត្តាបរិស្ថានបានឆក់យកជីវិតមនុស្សប្រហែល ១៣ លាននាក់។ ផលវិបាកនៃគ្រោះធម្មជាតិទាំងអស់នេះបានរំខានទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិក៏ដូចជាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅលើសកលលោក។ នៅពេលកើតមាននូវគ្រោះធម្មជាតិទឹកជំនន់ ខ្យល់ព្យុះ គ្រោះរញ្ជួយដី រលកកម្តៅខ្ពស់ ភ្លើងឆេះព្រៃ គ្រោះរាំងស្ងួត វាបានបំផ្លាញដល់

ដ្ឋានរចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន អគារ ផ្ទះសម្បែងប្រជាពលរដ្ឋ ជម្រកសត្វ និងរាំងស្ទះដល់ការអភិវឌ្ឍសង្គមជាតិ ជាពិសេសប៉ះពាល់ដល់ជីវិតមនុស្ស សត្វ និងរុក្ខជាតិនៅជុំវិញភពផែនដីទាំងមូល។ បណ្តាប្រទេសនីមួយៗលើពិភពលោកបានចាត់ទុកបញ្ហាការប្រែប្រួលអាកាសធាតុគឺជាចំណោទបញ្ហាចម្បងមួយ ដែលត្រូវរួមគ្នារិះរកនូវយុទ្ធសាស្ត្រ និងដោះស្រាយដើម្បីទប់ស្កាត់ រារាំង និងកាត់បន្ថយការកើតឡើងគ្រោះធម្មជាតិមកលើសង្គមជាតិឱ្យស្ថិតក្នុងកម្រិតអប្បបរមា។

### ៣.១.១.៦. ការថមថយសេដ្ឋកិច្ចសកល

កាលពីរយៈពេលពេលមុនឆ្នាំ២០១៨ ស្ថានភាពនៃសកលលោកស្ទើរតែមិនមានជួបនូវផលវិបាក និងឧបសគ្គរាំងដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនោះទេ ដែលនេះមានន័យថា សកលលោកមានដំណើររីកចម្រើនលូតលាស់ទៅមុខទាំងក្នុងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម ដែលបង្កជាលក្ខណៈវិជ្ជមានដល់ការបង្កើនសុខុមាលភាពនៃការរស់នៅរបស់ពលរដ្ឋសកល ដោយក្នុងនោះ បណ្តាប្រទេសជាច្រើនបានដាក់ចេញនូវយុទ្ធសាស្ត្រ គោលនយោបាយ និងយុទ្ធសាស្ត្រសេដ្ឋកិច្ចសម្រាប់ជម្រុញនូវការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសប្រទេសទាំងនោះបានពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅតំបន់ក្នុងគោលដៅពង្រីកនៃវិសាលភាពសម្រាប់ទំនាក់ទំនងការទូត និងការធ្វើពាណិជ្ជកម្មជាមួយគ្នា។[42]

ទោះបីជាយ៉ាងណាក៏ដោយ បើគិតក្នុងរយៈពេល ៧ ឆ្នាំចុងក្រោយ ដោយគិតចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៤ នេះ ស្ថានភាព និងរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចនៅជុំវិញពិភពលោកហាក់ដូចជាមាននិន្នាការប្រែប្រួល ឬផ្លាស់ប្តូរស្ទើរតែទាំងស្រុង ដោយក្នុងនោះស្ថានភាពនៃប្រទេសនានាលើសកលលោកបាននឹងកំពុងចាប់ផ្តើមលេចឡើង និងជួបប្រទះនូវបញ្ហាជាច្រើនពីទិដ្ឋភាពកត្តាភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច និងវិបត្តិជំងឺសកល ដែលបង្កជាបច្ច័យអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចសកល ហើយក៏ជាឧបសគ្គរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ ជាក់ស្តែង នៅក្នុងគ្រាដែលពិភពលោកប្រឈមនឹងបញ្ហាវិបត្តិសុខភាពសាធារណៈដោយសារជំងឺរាតត្បាតកូវីដ១៩ កំណើនសេដ្ឋកិច្ចសកលត្រូវបានធ្លាក់ចុះយ៉ាងខ្លាំងរហូតដល់អត្រាកំណើនអវិជ្ជមាន ២.៩% បើយោងតាមទិន្នន័យរបស់ធនាគារពិភពលោកនៅឆ្នាំ២០២០។ ក៏ប៉ុន្តែ បន្ទាប់ពីមានការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលជាមួយនឹងការបង្កើនការចាក់វ៉ាក់សាំងការពារពីការឆ្លងដល់ពលរដ្ឋសកល ក៏ដូចជាការសម្របខ្លួនទៅនឹងគន្លងនៃការរស់នៅក្នុងបរិបទថ្មីរបស់ប្រជាជនទូទាំងសកលលោក បានធ្វើឱ្យស្ថានភាពឆ្លងនៃជំងឺកូវីដ-១៩ក្នុងក្របខ័ណ្ឌសកលមានភាពស៊ាំក្នុងសហគមន៍កម្រិតខ្ពស់ ហើយនាំឱ្យស្ថានការណ៍នៃវិបត្តិសុខភាពសាធារណៈមានលក្ខណៈល្អប្រសើរ និងធូរស្បើយជាងមុន។ ការណ៍នេះត្រូវបានរំពឹងថា កំណើនសេដ្ឋកិច្ចសកលនឹងចាប់ផ្តើមងើបឡើង និងវិលទៅរកវិធីកំណើនខ្ពស់វិញ ដោយក្នុងកាលៈទេសៈនេះ វាឆ្លុះបញ្ចាំងពីនិន្នាការស្ទុះឡើងនៃតម្រូវការរបស់ពលរដ្ឋសកលសម្រាប់ការប្រើប្រាស់ទំនិញ និងសេវាកម្ម ស្របពេលជាមួយ

---

[42] Fivision, *"ទស្សនវិស័យសេដ្ឋកិច្ចឆ្នាំ ២០២៣"*, F.I Vision Capital, កុម្ភៈ ១៩, ២០២៣, https://fivisioncapital.com/news/

ការឈានទៅបើកប្រទេសជាបណ្តើរៗទៅតាមរោងចក្រផលិតកម្ម ទីកន្លែងទេសចរណ៍ និងប្រព័ន្ធមធ្យោបាយធ្វើដំណើរ។ល។ ការកើនឡើងនៃតម្រូវការសកលក៏បានធ្វើឱ្យមានរំហូរកាន់តែច្រើនលើពាណិជ្ជកម្មសកល និងជម្រុញការវិនិយោគសកលបន្ថែមទៀត ដែលសកម្មភាពស្ទួលសេដ្ឋកិច្ចទាំងនេះនឹងអាចនាំឱ្យសេដ្ឋកិច្ចសកលមានកំណើនវិជ្ជមានក្នុងអត្រាខ្ពស់ និងមានការអភិវឌ្ឍឡើងវិញក្រោយពីមានអត្រាកំណើនអវិជ្ជមាននៅកំឡុងពេលស្ថានភាពឆ្លងមេរោគបានរាតត្បាតពាសពេញសកល។ បើតាមរយៈទិន្នន័យរបស់ធនាគារពិភពលោកនៅឆ្នាំ២០២១ បន្ទាប់ពីជំងឺឆ្លងសកលបានធ្លាក់ចុះ និងដំណើរស្ទុះឡើងនៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងទីផ្សារសកល កំណើនសេដ្ឋកិច្ចសកលបានឈានទៅដល់កម្រិតកំណើនមួយខ្ពស់ ដែលមានអត្រាកំណើន ៦.៣%។ បើទោះបីជាមានសកម្មភាពសេដ្ឋកិច្ច និងកំណើនខ្ពស់ឡើងវិញក៏ពិតមែន ក៏ប៉ុន្តែនៅឆ្នាំបន្តបន្ទាប់មកទៀត កំណើនសេដ្ឋកិច្ចសកលនៅតែប្រឈម និងជួបប្រទះនឹងបញ្ហាថ្មីៗមួយចំនួន ដោយបង្កឱ្យសេដ្ឋកិច្ចសកលមានភាពមិនប្រាកដប្រជា និងមិនអាចរក្សាអត្រាកំណើនឱ្យស្ថិតក្នុងតួលេខខ្ពស់បាន ជាពិសេសមានអត្រាកំណើនថមថយទៀតផង។ តួយ៉ាង នៅក្នុងឆ្នាំ២០២២ កំណើនសេដ្ឋកិច្ចសកលមានអត្រា ៣.១% ដែលជាកំណើនថយចុះចំនួន ៣.២% បើធៀបនឹងឆ្នាំ២០២១។ រីឯ កំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២៣ មានអត្រាកំណើន ២.៧% ហើយប្រសិនបើយកតួលេខនេះធៀបជាមួយឆ្នាំ២០២២ កំណើនបានបន្តស្ថិតក្នុងអត្រាកំណើនថមថយដដែល ដោយកំណើនថយចុះក្នុងអត្រា ០.៥%។ បើតាមការព្យាករណ៍របស់ធនគារពិភពលោក កំណើនសេដ្ឋកិច្ចសកលនៅឆ្នាំ ២០២៤ នឹងបន្តមានកំណើនក្នុងអត្រាកំណើនទាបបន្ថែមទៀត ក្នុងរង្វង់តួលេខ ២.៦%។ តាមរយៈទិន្នន័យនៃកំណើនខាងលើ វាបង្ហាញឱ្យឃើញយ៉ាងជាក់ច្បាស់ថា ស្ថានភាពសេដ្ឋកិច្ចសកលបាននឹងកំពុងស្ថិតក្នុងភាពមិនប្រាកដប្រជា និងគ្មានស្ថិរភាពនោះទេ ដែលបង្កជាឧបសគ្គ និងផលវិបាកដល់ការអភិវឌ្ឍសង្គមជាតិទាំងមូល។[43]

**ក្រាហ្វិកទី១៦ ៖ បង្ហាញពីនិន្នាការកំណើនសេដ្ឋកិច្ចសកលចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៤**




ប្រភព៖ ការគណនារបស់ UNCTAD

[43] ក្រសួងព័ត៌មាន, , *"កំណើនសេដ្ឋកិច្ចសកល និងតំបន់នៅតែឈមនឹងភាពមិនប្រាកដប្រជាខ្ពស់,"* (ភ្នំពេញ, កញ្ញា ០៦, ២០២២, https://www.information.gov.kh/articles/85543

កំណើនសេដ្ឋកិច្ចសកលមានកំណើនទាប និងថមថយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះគឺបណ្តាលមកពីមូលហេតុចម្បងមួយចំនួន ដែលជាឧបសគ្គរាំងស្ទះដល់ការជម្រុញកំណើនសេដ្ឋកិច្ចសកលឱ្យមានកំណើនខ្ពស់។ ក្នុងនោះពិភពលោកកំពុងប្រឈមមុខនឹងវិបត្តិយ៉ាងច្រើនដំណាលគ្នា មិនថាវិបត្តិជំងឺសកល វិបត្តិសង្គ្រាម វិបត្តិភូមិសាស្ត្រនយោបាយ និងវិបត្តិផ្សេងៗទៀត ដោយបង្កជាបច្ច័យអវិជ្ជមានដល់សកម្មភាពសេដ្ឋកិច្ចសកល។ ជាក់ស្តែង បញ្ហាទាំងអស់នេះ បានធ្វើឱ្យកើតមាននូវអត្រាអតិផរណាខ្ពស់ដោយសារការកើនឡើងថ្លៃថាមពលប្រេង និងថ្លៃស្បៀងអាហារលើពិភពលោក ដែលបង្កផលប៉ះពាល់ដល់ប្រាក់ចំណូល និងជីវភាពរស់នៅរបស់ពលរដ្ឋសកល។ ដើម្បីអាចគ្រប់គ្រងកម្រិតអតិផរណាកុំឱ្យមានអត្រាខ្ពស់ពេក បណ្តាប្រទេសអភិវឌ្ឍន៍មួយចំនួនបានដាក់ចេញនូវការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ដោយបានតម្លើងអត្រាការប្រាក់គោលដល់កម្រិតអតិបរមា ដែលនាំឱ្យជះផលអវិជ្ជមានដល់រំហូរពាណិជ្ជកម្ម និងការវិនិយោគសកល។ គួរបញ្ជាក់ផងដែរថា នាពេលបច្ចុប្បន្ន កំណើនសេដ្ឋកិច្ចសកលពឹងផ្អែកខ្លាំងលើវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម ក្នុងន័យនេះ នៅពេលវិស័យទាំងពីរជួបនឹងបញ្ហា វាក៏បន្តប៉ះពាល់ដល់ការកើនឡើងនៃអត្រាអ្នកគ្មានការងារធ្វើ តម្រូវការសកលធ្លាក់ចុះ និងមានវិសមភាពប្រាក់ចំណូល ដោយនេះនឹងក្លាយជាឧបសគ្គរាំងដល់ការរុញច្រានអត្រាកំណើនសេដ្ឋកិច្ចសកលក្នុងរយៈពេលវែងផងដែរ។ នៅក្នុងកំឡុងពេលដែលសេដ្ឋកិច្ចសកលជួបនូវបញ្ហាជាច្រើន កម្រិតបំណុលសាធារណៈក៏មានអត្រាកើនឡើងខ្ពស់ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលនាំឱ្យការសងការប្រាក់ត្រឡប់ទៅវិញមានចំនួនច្រើនជាងមុន ដោយវាប៉ះពាល់ដល់ការបែងចែកចំណូលជាតិផងដែរ។

**ក្រាហ្វិកទី១៧៖ បង្ហាញពីបំណុលសាធារណៈរបស់សកលលោកចាប់ពីឆ្នាំ ១៩៥០ ដល់ឆ្នាំ ២០២២**




ប្រភព៖ IMF Database 2023

ប្រសិនបើមើលតាមទិដ្ឋភាពជាក់ស្តែង កំណើនសេដ្ឋកិច្ចថមថយបានកំពុងកើតមាននៅតាមបណ្តាប្រទេសជាច្រើននៅជុំវិញពិភពលោក ដោយក្នុងនោះកំណើនសេដ្ឋកិច្ចចិននឹងបន្តមានកម្រិតយឺតយ៉ាវ បើទោះបីក្រោយការបើកប្រទេសឡើងវិញក៏ដោយ ក៏កំណើនសេដ្ឋកិច្ចចិននៅតែត្រូវប្រឈមជាមួយស្ថានភាពដែលមានផលប៉ះពាល់ពីវិបត្តិអចលនទ្រព្យ ការធ្លាក់ចុះចំនួនប្រជាសាស្ត្រ និងការធ្លាក់ចុះផលិតភាព។ រីឯភាពតានតឹងកាន់តែខ្លាំងឡើងៗនៅកោះតៃវ៉ាន់ តំបន់មជ្ឈិមបូព៌ា និងសមុទ្រចិនខាងត្បូងបាននឹងកំពុងបង្កើននូវភាពអសន្តិសុខក្នុងសង្គម និងលើខ្សែសង្វាក់ផលិតកម្មសកល ដែលបង្កជាភាពរអាក់រអួលក្នុងការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម និងបានបង្កជាហានិភ័យខ្ពស់ដល់ការវិនិយោគ។ ម្យ៉ាងទៀត ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចទៅលើប្រទេសរុស្សីពីសំណាក់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប បានធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចសកលផងដែរព្រោះប្រទេសរុស្សីជាប្រទេសដែលមានចំណែកដ៏ធំសម្រាប់ការផ្គត់ផ្គង់នៅទីផ្សារសកល។ ចំពោះនៅតំបន់ចាយប្រាក់អឺរ៉ូ និងចក្រភពអង់គ្លេសប្រហែលជាស្ថិតក្នុងវិបត្តិសេដ្ឋកិច្ច ព្រោះថាប្រាក់ចំណូលរបស់ប្រជាជនត្រូវរងផលប៉ះពាល់ពីវិបត្តិឡើងថ្លៃថាមពល និងទំនិញទូទៅ។ ជាងនេះទៅទៀត ការប្រែប្រួលអាកាសធាតុក៏ជាកត្តាសំខាន់ក្នុងការបង្អាក់ដល់ការជម្រុញកំណើនសេដ្ឋកិច្ចផងដែរព្រោះគ្រោះធម្មជាតិបានបំផ្លាញជីវិតមនុស្ស ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន អាគារ និងផ្ទះរបស់ប្រជាពលរដ្ឋជារៀងរាល់ឆ្នាំ ដែលខាតបង់ទំហំទឹកប្រាក់ជាច្រើន ហើយត្រូវប្រើប្រាស់រយៈពេលយូរដើម្បីកសាងនូវហេដ្ឋារចនាសម្ព័ន្ធឡើងវិញ។ សរុបជារួម បើតាមរយៈបញ្ហាខាងលើទាំងអស់នេះ កំណើនសេដ្ឋកិច្ចនៅតែប្រឈមនឹងភាពមិនច្បាស់លាស់ និងមានហានិភ័យកាន់តែខ្ពស់ ដោយកើតឡើងជាបន្តបន្ទាប់នៃបញ្ហាអសន្តិសុខទាំងក្នុងទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច ដែលបង្កជាផលវិបាកដល់ការអភិវឌ្ឍប្រទេសជាតិ និងអាចនាំឱ្យពិភពលោកទាំងមូលងាយធ្លាក់ចូលក្នុងវិបត្តិសេដ្ឋកិច្ចសកល។

### ៣.១.២. ផលប៉ះពាល់នៃបញ្ហាសកលមកលើសេដ្ឋកិច្ចកម្ពុជា

ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ កម្ពុជាមានសេដ្ឋកិច្ចតូច ហើយបើកចំហ (Small Open Economy) និងមានការផ្សារភ្ជាប់កាន់តែខ្លាំងជាមួយសង្វាក់ផលិតកម្ម និងទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ហើយសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកខ្លាំងលើប្រភពខាងក្រៅសម្រាប់ជម្រុញនូវកំណើនសេដ្ឋកិច្ចជាតិ ដោយនៅក្នុងនោះរួមមាន វិស័យទេសចរណ៍ កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម និងសេវាកម្ម ដែលសុទ្ធសឹងជាវិស័យចន្ទល់នៃសេដ្ឋកិច្ចដ៏សំខាន់សម្រាប់ដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដែលបង្ហាញថាការប្រែប្រួលផ្សេងៗនៃនិន្នាការសកលលោក ក៏នឹងជះឥទ្ធិពលកមកាន់សេដ្ឋកិច្ចកម្ពុជាផងដែរ។[44] តាមរយៈនេះ បញ្ហាសកលដូចបានរៀបរាប់ខាងលើ បានជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចតាមវិស័យសំខាន់ៗរបស់កម្ពុជា ហើយភាពមិនប្រាកដប្រជាពីកត្តាខាងក្រៅទាំងអស់នេះនឹងធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាជួបប្រទះនឹងហានិភ័យ និងបង្កជាផលខាតបង់មកលើសេដ្ឋកិច្ចកម្ពុជាដោយផ្ទាល់ និងដោយប្រយោល ដែលក្នុងនោះសេដ្ឋកិច្ចកម្ពុជាបានទទួលរងនូវផលប៉ះពាល់មួយចំនួនដូចជា ថ្លៃដើមកត្តាផលិតកម្មខ្ពស់ ដែលបណ្តាលមកពីអត្រាអតិផរណានៅលើសកលទៅលើទំនិញ និងសេវាកម្មជាច្រើន ដោយវាបាននាំឱ្យថ្លៃដឹកជញ្ជូន និងវត្ថុធាតុដើមក្នុងស្រុកមានការកើន

[44] រាជរដ្ឋាភិបាលកម្ពុជា, *ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧*, ២០២៤

ឡើងជាងមុន ហើយវាក៏បានធ្វើឱ្យមានការចំណាយកាន់តែច្រើនទៅលើការផលិត និងការប្រើប្រាស់ ជាពិសេស វាបានបន្តប៉ះពាល់ដល់ចំណែកប្រាក់ចំណូលរបស់វិនិយោគិន និងអ្នកប្រើប្រាស់ក្នុងវិស័យផលិតកម្ម និងសេវាកម្ម។ លើសពីនេះទៅទៀត បញ្ហាអតិផរណានេះ ក៏បានធ្វើឱ្យតម្រូវការក្នុង និងក្រៅស្រុកមានការថយចុះផងដែរ ដោយនាំឱ្យកំណើននៃការនាំចេញ និងនាំចូលធ្លាក់ចុះដែលស្ថិតក្នុងអត្រាទាប។ មិនតែប៉ុណ្ណោះ វំហូរ វិនិយោគផ្ទាល់ពីបរទេសក៏បានធ្លាក់ចុះក្នុងអត្រាកំណើនទាប ព្រោះអ្នកវិនិយោគជាច្រើនបានផ្លាស់ប្តូរទៅជាការ វិនិយោគលើមូលបត្របំណុល ឬស្តុក ឬការដាក់សន្សំនៅក្នុងប្រព័ន្ធធនាគារដើម្បីទទួលបានអត្រាការប្រាក់ខ្ពស់ជាងមុន និងមានហានិភ័យទាបក្នុងការវិនិយោគ។ ក្រៅពីបញ្ហាអតិផរណា ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុនៅលើប្រទេសជឿនលឿនមួយចំនួន ក៏រួមចំណែកដល់ការបន្ទាបតម្លៃរូបិយប័ណ្ណប្រាក់រៀលផងដែរ ព្រោះកម្ពុជាជាប្រទេសប្រើប្រាស់ដុល្លារូបនីយកម្មច្រើន ដោយនៅពេលកម្រិតរូបិយវត្ថុបរទេសនៅក្នុងទីផ្សារមានបរិមាណតិច នោះវាធ្វើឱ្យតម្លៃរូបិយវត្ថុបរទេសកើនឡើង ដែលជាហេតុនាំឱ្យប្រាក់រៀលធ្លាក់ចុះ។ ជាងនេះទៅទៀត នៅពេលអត្រាការប្រាក់សកលកើនឡើង នោះវានាំឱ្យទំហំឥណទានមានទំនោរថមថយផងដែរព្រោះការសងការប្រាក់ និងប្រាក់ដើមត្រឡប់ទៅវិញមានកម្រិតខ្ពស់ជាងមុន។ ចំណែកឯទិដ្ឋភាពសន្តិសុខសកលវិញ នៅពេលមានភាពតានតឹងកាន់តែច្រើនឡើងរវាងប្រទេសមួយចំនួន វានឹងនាំឱ្យអ្នកទេសចរណ៍ជាតិ និងអន្តរជាតិកាត់បន្ថយការធ្វើដំណើរ សម្រាប់គោលដៅទេសចរណ៍មកកាន់ប្រទេសកម្ពុជា ដែលវាធ្វើឱ្យវិស័យទេសចរណ៍កម្ពុជាជួបផលវិបាកនៃការធ្លាក់ចុះចំនួនភ្ញៀវទេសចរណ៍។ សម្រាប់បញ្ហាការប្រែប្រួលអាកាសធាតុសកល បានបង្កជាបច្ច័យអវិជ្ជមានលើវិស័យកសិកម្ម និងដល់សុខភាពសាធារណៈរបស់ពលរដ្ឋកម្ពុជា។ ដូច្នេះ បញ្ហាសកលពិតជាបានផ្តល់ផលប៉ះពាល់ជាច្រើនដល់វិស័យសំខាន់ៗរបស់ចន្ទុលសេដ្ឋកិច្ចកម្ពុជា ដែលវាជារនាំងបង្អាក់ដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមរបស់ប្រទេសកម្ពុជា ជាពិសេសវាក្លាយជាឧបសគ្គរាំងស្ទះដល់ការសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០។

### ៣.១.៣. បញ្ហាក្នុងស្រុក

ទន្ទឹមនេះដែរ ក្រៅពីទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលពីឥទ្ធិពលខាងក្រៅ កម្ពុជាក៏ជួបប្រទះ និងប្រឈមទៅនឹងបញ្ហាជារចនាសម្ព័ន្ធខាងក្នុងមួយចំនួននៅក្នុងប្រទេស ដែលកំពុងយាយីរារាំងពាំងដំណើរកម្ពុជាក្នុងការប្រែក្លាយចក្ខុវិស័យឆ្នាំ ២០៣០ ឱ្យក្លាយទៅជាការពិត។

#### ៣.១.៣.១. ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច

ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង គឺជាចំណុចស្នូលអាទិភាពមួយដែលរដ្ឋាភិបាលត្រូវផ្តោតជាសំខាន់ ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យរបស់កម្ពុជាក្នុងដំណើរក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ក្នុងឆ្នាំ ២០៣០ មុននឹងក្លាយជាប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

ការធ្វើពិពិធកម្មសេដ្ឋកិច្ចសំដៅទៅលើដំណើរការនៃការពង្រីកមូលដ្ឋានសេដ្ឋកិច្ចដោយធ្វើការផ្លាស់ប្តូរឱ្យឆ្ងាយពីប្រភពប្រាក់ចំណូលតែមួយទៅកាន់ប្រភពជាច្រើនលើវិស័យនិងទីផ្សារជាច្រើន ដែលកំពុងរីកចម្រើន។ ការធ្វើពិពិធកម្មសេដ្ឋកិច្ចត្រូវបានអនុវត្តជាយុទ្ធសាស្ត្រមួយ ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍវិជ្ជមាន

ពោលគឺការពង្រីកសកម្មភាពសេដ្ឋកិច្ចឱ្យបានកាន់តែច្រើនឱ្យសម្បូរបែបក្នុងន័យធ្វើយ៉ាងដូចម្ដេចឱ្យមានកំណើនសេដ្ឋកិច្ចជានិរន្តរ៍ ដោយមិនគួរពឹងផ្អែកលើវិស័យសេដ្ឋកិច្ចដដែលៗនោះទេ។

ទោះបីជាកម្ពុជាបានងើបចេញពីវិបត្តិកូវីដ១៩ ជាមួយកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ក្ដី កំណើនសេដ្ឋកិច្ចប៉ុន្មានឆ្នាំចុងក្រោយនេះហាក់នូវមិនទាន់សម្រេចបានដូចអត្រាមុនវិបត្តិជម្ងឺរាតត្បាតពោលគឺក្នុងរង្វង់ ៧% ដែលទាមទារជាចាំបាច់ការធ្វើពិពិធកម្មសេដ្ឋកិច្ចបន្ថែមទៀត។ ការពឹងផ្អែកទៅលើផលិតផល ទីផ្សារ និងធនធានហិរញ្ញប្បទានដែលមានមូលដ្ឋានដ៏តូចចង្អៀតរបស់កម្ពុជា ហាក់មិនអាចធ្វើឱ្យកម្ពុជាមានជំហររឹងមាំសម្រាប់ទប់ទល់ទៅនឹងការអង្រួនដែលកើតមានចំពោះសេដ្ឋកិច្ច។[45]

ការធ្វើពិពិធកម្មសេដ្ឋកិច្ច ទាមទារនូវការបណ្ដុះបណ្ដាលជំនាញ ដែលមានលក្ខណៈពិសេស ទើបកម្ពុជាអាចប្រែក្លាយមូលដ្ឋាន ពីឧស្សាហកម្ម ផ្អែកលើអតិពលកម្ម ទៅជាឧស្សាហកម្មផ្អែកលើជំនាញ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។ កម្ពុជានៅជួបប្រទះបញ្ហានៃការថយចុះផលិតភាពដែលបណ្ដាលមកពីការផ្លាស់ប្ដូររចនាសម្ព័ន្ធយឺត ពោលកម្ពុជានៅតែពឹងផ្អែកលើឧស្សាហកម្មប្រើប្រាស់កម្មករជំនាញទាបដោយភាគច្រើនត្រូវការប្រើប្រាស់កម្លាំងខ្លាំងដូចជាវិស័យកាត់ដេរ និងកសិកម្មជាដើម ដែលសុទ្ធសឹងតែជាឧស្សាហកម្មមានកម្រិតមូលដ្ឋាន និងប្រើប្រាស់កម្លាំងពលកម្មគ្មានជំនាញ ឬមានជំនាញតិចតួច ដោយការចូលរួមនៃកត្តាផលិតភាពការងារនៅមានកម្រិតទាបនៅឡើយ។ ការណ៍នេះឆ្លុះបញ្ចាំងពីភាពមានកម្រិតនៃការបណ្ដុះបណ្ដាលជំនាញទាំងផ្នែករឹង និងផ្នែកទន់ដល់កម្មករ កម្មការិនី ដើម្បីយកទៅប្រើប្រាស់ក្នុងដំណើរធ្វើពិពិធកម្ម និងបង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច ពោលគឺមិនទាន់ត្រូវបានអភិវឌ្ឍឱ្យមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ផលិតទំនិញដែលមានតម្លៃបន្ថែមខ្ពស់។ ជារឿយៗឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់សំដៅដល់ឧស្សាហកម្មដែលមានទុន វិនិយោគខ្ពស់ ប្រើប្រាស់បច្ចេកវិទ្យាទំនើប កម្លាំងពលកម្មជំនាញមានឯកទេស និងពោរពេញទៅដោយការស្រាវជ្រាវ និងការអភិវឌ្ឍ(R&D) ដូចជាឧស្សាហកម្មធុនធ្ងន់ វិស្វកម្ម និងឧស្សាហកម្មនុយក្លេអ៊ែរជាដើម ដែលនាំមកនូវប្រាក់ចំណេញខ្ពស់ជួយបង្កើនខ្សែចង្វាក់តម្លៃ (Value Chain) ការប្រកួតប្រជែងជាសកល និងទទួលបានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តភាព។

### ៣.១.៣.២. ថ្លៃដើមធុរកិច្ចនៅមានកម្រិតខ្ពស់

បរិយាយធុរកិច្ចនៅកម្ពុជាហាក់នៅមិនទាន់បង្កភាពងាយស្រួលនៅឡើយ សម្រាប់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេសដោយសារកត្តាមួយចំនួនពាក់ព័ន្ធនឹងថ្លៃដើមមានកម្រិតខ្ពស់ ក្នុងការចាប់ផ្ដើមធុរកិច្ចរបស់ពួកគេដែលជាឧបសគ្គដល់សមត្ថភាពប្រកួតប្រជែងជាអន្តរជាតិ និងរារាំងដល់នវានុវត្តន៍ និងការងាកទៅរកសកម្មភាពសេដ្ឋកិច្ច មានតម្លៃបន្ថែមខ្ពស់ជាងបច្ចុប្បន្ន។ ការផ្គត់ផ្គង់ថាមពល ផ្នែកដឹកជញ្ជូន និងសមត្ថភាពឡូជីស្ទីក នៅតែជាបន្ទុកច្រើនលើចំណាយថ្លៃដើម។ ថ្លៃដើមខ្ពស់ ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា ចំណាយច្រើនជាងចំណេញលើវិស័យ

---

[45] ប៊ូ សាធឿន, *"ផលិតភាព, ពិពិធកម្ម និងការវិនិយោគក្នុងស្រុកជាកត្តាគន្លឹះសម្រាប់ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា,"* World Bank Group, មករា ៣១, ២០២២ https://www.worldbank.org/km/news/press-release/2022/01/31/productivity-diversification-domestic-investment-are-key-to-cambodia-s-economic-recovery

ឧស្សាហកម្ម និងសេវាកម្ម។ ជាក់ស្តែង បើតាមរបាយការណ៍ថ្នាក់ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនសេដ្ឋកិច្ចនៅកម្ពុជាឆ្នាំ ២០២២ ក៏បានបង្ហាញថា សរុបចំណូលពីការលក់ប្រចាំឆ្នាំរបស់ក្រុមហ៊ុន សហគ្រាសទាំងអស់នៅកម្ពុជាមានប្រមាណ៥០,៧ ប៊ីលានដុល្លារអាមេរិក ខណៈដែលការចំណាយប្រចាំឆ្នាំមានប្រមាណ ៣៨,៦ ប៊ីលានដុល្លារ ហើយនិងចំណេញជាមធ្យមប្រចាំឆ្នាំ មានចំនួនប្រមាណ ១២,១ ប៊ីលានដុល្លារអាមេរិក។ លទ្ធផលទិន្នន័យជំរឿននេះ បានបង្ហាញទៀតថា ការចំណាយប្រចាំឆ្នាំ មានភាគចំណែកប្រមាណ ៧៦% នៃចំណូលបានពីការលក់ប្រចាំឆ្នាំ ខណៈដែលចំណេញ និង ខាត មានត្រឹមចំនួនប្រមាណ ២៣% តែប៉ុណ្ណោះ។ ទោះបីជាក្នុងមួយឆ្នាំៗកម្ពុជាទទួលបានចំណូលច្រើនពីនាំចេញកសិផលច្រើនមុខទៅកាន់ទីផ្សារអន្តរជាតិ តែកម្ពុជានៅមានបញ្ហាប្រឈមសម្រាប់ខ្សែច្រវាក់ផលិតកម្ម ជាពិសេសតម្លៃនាំចេញកសិផលទាប តែថ្លៃដើមផលិតខ្ពស់។[46]

បញ្ហាតម្លៃអគ្គិសនី និង តម្លៃប្រេងឥន្ធនៈនៅតែជាកង្វល់របស់អ្នកវិនិយោគនានា ដោយហេតុថានៅមានកម្រិតថ្លៃខ្ពស់នៅឡើយបើធៀបនឹងប្រទេសក្នុងតំបន់។ ចំពោះតម្លៃអគ្គិសនីខ្ពស់ គឺដោយសារប្រទេសកម្ពុជា នៅជាប្រទេសនាំចូលអគ្គិសនីនៅឡើយ មិនទាន់មានសមត្ថភាពក្នុងការផលិតអគ្គិសនីសម្រាប់បំពេញតម្រូវការបានគ្រប់គ្រាន់ដោយខ្លួនឯងជាហេតុតម្រូវឱ្យកម្ពុជាត្រូវទិញភ្លើងបន្ថែមពីប្រទេសជិតខាង សម្រាប់ការផ្គត់ផ្គង់។ លោកស្រី Hannah Norton ប្រធានគ្រប់គ្រងផ្នែកទំនាក់ទំនងសាធារណៈឌីជីថលនៅក្រុមហ៊ុន Compare the-Market បានលើកឡើងថា តម្លៃអគ្គិសនីខ្ពស់បើធៀបនឹងបណ្តាប្រទេសផ្សេងទៀតអាចជាឧបសគ្គមួយដែលរួមចំណែកក្នុងការទាក់ទាញការវិនិយោគនៅក្នុងវិស័យផលិតកម្មផ្សេងៗរបស់កម្ពុជា។ ជាក់ស្តែង បើតាមការចុះផ្សាយរបស់គេហទំព័រ Energy Literacy របស់ហ្វីលីពីនបានបង្ហាញថា តម្លៃអគ្គិសនី សម្រាប់បំភ្លឺលំនៅដ្ឋាននៅបណ្តាប្រទេស អាស៊ាននាឆ្នាំ 2024 កម្ពុជាមានតម្លៃខ្ពស់ជាងគេទីបីនៅពីក្រោយប្រទេស សិង្ហបុរី និងហ្វីលីពីន។

**ក្រាហ្វិកទី១៨៖ តម្លៃអគ្គិសនីសម្រាប់បំភ្លឺលំនៅដ្ឋាននៅតាមបណ្តាប្រទេសអាស៊ាននាឆ្នាំ២០២៤**




ប្រភព៖ Energy Literacy PH

[46] ទូន សុផល, “ *ថ្លៃដើមខ្ពស់ ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា ចំណាយច្រើនជាងចំណេញលើវិស័យឧស្សាហកម្ម និងសេវាកម្ម,*” Kampucheatmey, មករា ០៣, ២០២៤, https://www.kampucheathmey.com/local-news/635642

បើធៀបនឹងឆ្នាំ ២០២០ តម្លៃអគ្គិសនីនៅប្រទេសក្នុងអាស៊ានភាគច្រើនបានកើនឡើង ហើយការកើនឡើងគួរឱ្យកត់សម្គាល់បំផុតត្រូវបានគេសង្កេតឃើញនៅប្រទេសសិង្ហបុរីកើនឡើង ៨០ភាគរយ កម្ពុជាកើនឡើង ៥០% និងហ្វីលីពីនកើនឡើង ៤០ ភាគរយ (Energy literacy) ដែលអត្រានេះនៅមានកម្រិតខ្ពស់ និងបង្ករភាពលំបាកដល់ការសម្រេចចិត្តរបស់វិនិយោគិនមុនមកធ្វើការវិនិយោគនៅកម្ពុជា។ លើសពីនេះ ភាពដែលអាចទុកចិត្តបានទៅលើអគ្គិសនីនៅកម្ពុជាក៏ជាកង្វល់ និងឧបសគ្គដល់បរិយាកាសធុរកិច្ចនៅកម្ពុជាផងដែរ។[47]

ជាក់ស្តែង បើតាមរយៈការស្ទង់មតិមួយរបស់ធនាគារពិភពលោកបានបង្ហាញថា ៤៣ ភាគរយនៃសហគ្រាសបានជួបប្រទះនឹងការដាច់ចរន្តអគ្គិសនី ដែលបញ្ហានៃការដាច់អគ្គិសនីជាញឹកញាប់នេះ នាំឱ្យថ្លៃចំណាយប្រចាំឆ្នាំក្នុងការធ្វើធុរកិច្ចនៅកម្ពុជា បានកើនឡើងពីត្រឹម ០.៣ ភាគរយនៃការលក់ក្នុងឆ្នាំ ២០១៣ ទៅ ១.១ ភាគរយក្នុងឆ្នាំ ២០២៣ ដែលការចំណាយនេះលើសពីប្រទេសឥណ្ឌូនេស៊ី វៀតណាម និងសិង្ហបុរី (យោងតាមក្រាហ្វិកទី១៩)។[48]

**ក្រាហ្វិកទី១៩៖ បង្ហាញពីការស្ទង់មតិរបស់សហគ្រាសក្នុងតំបន់នៅឆ្នាំ ២០២៣**




ប្រភព៖ ធនាគារពិភពលោក

[47] Energy Literacy PH, *"Asean Residential Electricity Rates 2024."* Facebook, March 27, 2024

[48] *Cambodia Economic Update,* World Bank, June, 2024, https://documents1.worldbank.org/curated/en

តម្លៃប្រេងឥន្ធនៈក៏ជាកម្មវត្ថុមួយសម្រាប់វិនិយោគិនពិចារណារមុននឹងមកបណ្តាក់ទុននៅកម្ពុជាផងដែរ ដោយហេតុថាវាជាកត្តាដែលទាក់ទងទៅដោយផ្ទាល់ទៅនឹងថ្លៃដឹកជញ្ជូន ដែលជាធាតុចូលមួយដ៏សំខាន់សម្រាប់ថ្លៃដើមធុរកិច្ច។ ជាក់ស្តែងបច្ចុប្បន្ន កម្ពុជានាំចូលផលិតផលប្រេងទាំងស្រុង ដែលនាំឱ្យមានអស្ថិរភាពតម្លៃ ដោយប្រភពនាំចូលភាគច្រើនគឺប្រទេសថៃ វៀតណាម និងសិង្ហបុរី និងបានចំណាយ ប្រាក់ជាង ២,១៧ ពាន់ លានដុល្លារ លើការនាំចូលប្រេងឥន្ធនៈ និង ប្រេងម៉ាស៊ូតសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក ជាពិសេសបើយោងតាមក្រសួងរ៉ែ និងថាមពលបានព្យាករថា តម្រូវការនៃការប្រើប្រាស់ប្រេងឥន្ធនៈនៅក្នុងប្រទេសកម្ពុជានឹងកើនឡើងដល់ ៤,៨ លានតោនត្រឹមឆ្នាំ ២០៣០ ដោយបានកើនឡើងពី ២,៨ លានតោន កាលពីឆ្នាំ ២០២០។[49]

ឧបសគ្គធំបំផុតទីបួនលើអាជីវកម្មនៅក្នុងការស្ទង់មតិសហគ្រាសឆ្នាំ ២០២៣ សម្រាប់ប្រទេសកម្ពុជា គឺការដឹកជញ្ជូន និងប្រព័ន្ធឡូជីស្ទីក ដែលមានការផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ បើគិតចាប់តាំងពីឆ្នាំ ២០១៦ ដោយវាមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនដូចជាការចំណាយខ្ពស់ និងសេចក្តីទុកចិត្តនៃដំណើរការដឹកជញ្ជូននៅកម្ពុជា។ លើសពីនេះ កម្ពុជាអាចនឹងប្រឈមលទ្ធភាពនៃកង្វះការប្រកួតប្រជែងទីផ្សារនាំចេញទំនិញទៅកាន់ទីផ្សារអន្តរជាតិ ប្រសិនបើតម្លៃដឹកជញ្ជូនតាមកំពង់ផែនៅតែរក្សាតម្លៃថ្លៃដដែល។ បញ្ហាដែលធ្វើឱ្យការដឹកជញ្ជូននៅតែមានតម្លៃខ្ពស់ដដែលនេះ គឺដោយសារតែ កង្វះហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យដឹកជញ្ជូន ជាក់ស្តែងកម្ពុជានៅមិនទាន់មានកំពង់ផែទឹកជ្រៅដែលអាចផ្តល់សមត្ថភាព និងវិសាលភាពធំចំពោះការចូលចតកប៉ាល់ដឹកទំនិញខ្នាតធំបាននៅឡើយទេ។ ផ្ទុយទៅវិញ រាល់ទំនិញដែលដឹកចេញពីប្រទេសកម្ពុជាគឺត្រូវធ្វើការផ្ទេរបញ្ជូនទៅតាមប្រទេសក្នុងតំបន់មួយចំនួន ដើម្បីបន្តដឹកជញ្ជូនទៅកាន់ប្រទេសទិសដៅចុងក្រោយ។ បន្ថែមពីនេះ បញ្ហាកង្វះទូកុងតឺន័រ និងការប្រើប្រាស់រថយន្តចាស់ៗ បញ្ហាកង្វះធនធានមនុស្ស បច្ចេកវិទ្យា និងការគ្រប់គ្រងមិនបានល្អក្នុងការដឹកទំនិញជញ្ជូនក្នុងស្រុក ក៏ជាធាតុផ្សំដែលធ្វើឡើងការដឹកជញ្ជូនទំនិញចេញពីកម្ពុជានៅមានតម្លៃថ្លៃផងដែរ។ យោងតាមការសិក្សារបស់ធនាគារពិភាពលោក បានបង្ហាញថា ថ្លៃឡូជីស្ទីកក្នុងប្រទេសកម្ពុជានៅមានកម្រិតខ្ពស់ និងមិនសូវមានស្ថិរភាព ដោយសារថ្លៃប្រតិបត្តិការ និងថ្លៃដឹកជញ្ជូនមានតម្លៃខ្ពស់ និងមានការបង់កម្រៃក្រៅផ្លូវការនៅឡើយ ព្រមទាំងបញ្ហាការតភ្ជាប់រវាងប្រភេទនៃការដឹកជញ្ជូនមួយទៅប្រភេទនៃការដឹកជញ្ជូនមួយទៀត។[50]

[49] ម៉ៃ គុណមករា, « *កម្ពុជាចំណាយជាង ២,១៧ ពាន់លានដុល្លារ លើការនាំចូលប្រេង,* » ភ្នំពេញប៉ុស្តិ៍, មករា ១៦, ២០២៤, https://www.postkhmer.com/business/2024-1-15-2012-257585

[50] ចេង ឆហួត, « *ថ្លៃឡូជីស្ទីកនៅកម្ពុជានៅតែខ្ពស់ និងមិនសូវមានស្ថិរភាពតម្រូវឲ្យមានការផ្លាស់ប្តូរមួយចំនួនទាំងក្នុងរយៈពេលខ្លី និងមធ្យម,* » CNC News, មិថុនា ០៦,២០២២, https://cnc.com.kh/detail/news/30960

**ក្រាហ្វិកទី២០ ៖ បង្ហាញពីការស្ទង់មតិរបស់សហគ្រាសកម្ពុជាក្នុងឆ្នាំ ២០១៣, ២០១៦ និង ២០២៣**




ប្រភព៖ ធនាគារពិភពលោក

ទោះបីជាវិស័យកម្មន្តសាលមានការរីកចម្រើនយ៉ាងណាក្តី ប៉ុន្តែកម្ពុជានៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់វត្ថុធាតុដើមពីក្នុងស្រុកនៅឡើយ ពោលគឺមិនទាន់មានការតភ្ជាប់បណ្តាញផ្គត់ផ្គង់វត្ថុធាតុដើមទៅនឹងឧស្សាហកម្មដែលបម្រើការនាំចេញ។ ជាក់ស្តែង កម្ពុជាបាននាំចូលមកវិញនូវវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ រថយន្ត ប្រេង គ្រឿងសំណង់ និងផលិតផលប្រើប្រាស់ប្រចាំថ្ងៃ ដែលភាគច្រើនមកពីប្រទេសចិន ថៃ វៀតណាម ជប៉ុន និងកូរ៉េខាងត្បូងជាដើម។ តាមការសិក្សារបស់ស្ថានទូតចិនប្រចាំនៅកម្ពុជាបានឱ្យដឹងកាលពីចុងខែកុម្ភៈថា វិស័យកាត់ដេរនៅកម្ពុជាបាននាំចូលនូវវត្ថុធាតុដើមប្រហែល ៦០ ភាគរយពីប្រទេសចិន។ កត្តាដែលជម្រុញឱ្យក្រុមហ៊ុនបរទេសទាំងនេះនាំចូលវត្ថុធាតុដើមពីបរទេសគឺ ដោយសារវត្ថុធាតុដើមទាំងនេះមិនមានផលិតនៅកម្ពុជា ជាពិសេសក្រុមហ៊ុនបរទេសទាំងនោះមិនចង់ចំណាយពេលស្វែងរកវត្ថុធាតុដើមក្នុងស្រុក ក៏ដូចជាក្រុមហ៊ុនក្នុងស្រុកពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការផលិត ផលិតផលឱ្យស្របតាមស្តង់ដារជាដើម ដែលបានធ្វើឱ្យកម្ពុជាបាត់បង់នូវភាពប្រកួតប្រជែងក្នុងការធ្វើទាក់ទាញការវិនិយោគ និងការធ្វើពាណិជ្ជកម្ម។ គួរឱ្យកត់សម្គាល់ផងដែរថា កាលពីខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅ ការដឹកជញ្ជូននូវគ្រឿងបង្គុំអេឡិចត្រូនិច និងវត្ថុធាតុដើមផ្សេងៗពីប្រទេសចិន ទៅកាន់រោងចក្រធំៗនៅក្រៅប្រទេសចិនបានជួបបញ្ហាកង្វះធាតុផ្សំ ដែលធ្វើឱ្យរាំងស្ទះដល់សង្វាក់ផលិតកម្មមិនអាចដំណើរការបាន ប៉ះពាល់យ៉ាងខ្លាំងដល់វិស័យឧស្សាហកម្មនៅកម្ពុជា ដែលនាំឱ្យរោងចក្រមួយចំនួនឈានទៅដល់ការបិទទ្វារថែមទៀតផង។

កាតព្វកិច្ចពន្ធនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្គាល់ជាញឹកញាប់ ដោយអាជីវកម្មមួយចំនួនថាជាឧបសគ្គដ៏ច្រើន ដែលប៉ះពាល់ដល់ប្រាក់ចំណេញ និងសមត្ថភាពហិរញ្ញវត្ថុរបស់អាជីវកម្មក្នុងការបន្តការវិនិយោគ និងការពង្រីក។ បើប្រៀបធៀបជាមួយដៃគូក្នុងតំបន់របស់ខ្លួន អត្រាពន្ធនៅកម្ពុជាមានបន្ទុកច្រើនជាង ដែលអាចធ្វើឱ្យអាជីវកម្មកម្ពុជាបាត់បងការប្រកួតប្រជែង ដែលពាក់ព័ន្ធជាពិសេសក្នុងការទាក់ទាញការវិនិយោគបរទេស ដែលក្រុមហ៊ុនអាចជ្រើសរើសទីតាំងដែលមានលក្ខខណ្ឌពន្ធអំណោយផលជាងនេះ។

#### ៣.១.៣.៣. ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច

ជាការពិត មួយចំណែកធំនៃកំណើនខ្ពស់របស់កម្ពុជាត្រូវបានទ្រទ្រង់ដោយពាណិជ្ជកម្ម។ ជាក់ស្តែង ការនាំចេញរបស់កម្ពុជាមានកំណើនជាមធ្យម ១៣,៣% ក្នុងចន្លោះឆ្នាំ ២០១៧ ដល់ឆ្នាំ ២០២៣ និង បានកើនឡើងដល់ទំហំ ២៣,៤៧ ប៊ីលានដុល្លារអាមេរិក ឬ ស្មើនឹង ៥៤,៧% នៃផលិតផលក្នុងស្រុកសរុប របស់កម្ពុជាក្នុងឆ្នាំ ២០២៣។ ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៤ និន្នាការនៃការនាំចេញនៅបន្តមានចលនាវិជ្ជមាន ក្នុងកំណើនប្រមាណ១៧,២%។[51]

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពក្នុងការទាក់ទាញការវិនិយោគពីបរទេស ដោយក្នុងនោះច្បាប់ស្តីពីការវិនិយោគរបស់កម្ពុជាផ្តល់ការលើកទឹកចិត្តពីការវិនិយោគផ្ទាល់ពីបរទេស (FDI) ជាច្រើនរួមមាន ផ្តល់សិទ្ធិក្នុងការក្លាយជាម្ចាស់ក្រុមហ៊ុន ១០០ ភាគរយក្នុងនាមជាជនបរទេស ការកាត់បន្ថយអត្រាពន្ធសាជីវកម្ម ការនាំចូលទំនិញមូលធនដោយមិនបង់ពន្ធ និងគ្មានការរឹតបន្តឹងលើការផ្ទេរដើមទុនទៅក្រៅប្រទេសជាដើម។ ទោះបីជាមានការលើកទឹកចិត្តទាំងនេះក៏ដោយ កម្ពុជាមិនទាន់អាចទាក់ទាញការវិនិយោគពីប្រភពខាងក្រៅបានច្រើនគួរឱ្យកត់សម្គាល់នៅឡើយ បើធៀបទៅនឹងប្រទេសជិតខាងក្នុងតំបន់។[52]

កង្វល់ដ៏សំខាន់មួយរបស់វិនិយោគិនគឺ នីតិវិធីនៃការស្នើសុំអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារតម្រូវនានាពាក់ព័ន្ធនឹងការនាំចេញ និងនាំចូលទំនិញ ដែលកន្លងមកពាណិជ្ជករត្រូវបំពេញបែបបទស្មុគស្មាញឆ្លងកាត់ក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងគ្នាជាច្រើនលើក ដែលនាំឱ្យខាតពេលវេលា និងចំណាយខ្ពស់។ តាមរយៈការស្ទាបស្ទង់មតិរបស់សហគ្រាសឆ្នាំ ២០២៣ ក្នុងក្រាហ្វិកទី ១៩ ធ្វើឡើងដោយធនាគារពិភពលោក បានបង្ហាញថា កម្ពុជាត្រូវការរយៈពេល ២៨ ថ្ងៃដើម្បីទទួលបានអាជ្ញាប័ណ្ណនាំចូល និង ៣០ ថ្ងៃដើម្បីទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការ បើប្រៀបធៀបទៅនឹងប្រទេសវៀតណាមប្រើរយៈពេល ១៣ ថ្ងៃ និង ៥ ថ្ងៃសម្រាប់ប្រទេសឥណ្ឌូនេស៊ី។ តាមរយៈការស្ទាបស្ទង់មតិសហគ្រាសឆ្នាំ ២០២៣ ដដែលក៏បានបង្ហាញថា នៅកម្ពុជាត្រូវការពេល ៨ ថ្ងៃ ដើម្បីរត់ការ និងបំពេញបែបបទការនាំចេញដោយផ្ទាល់តាមរយៈភ្នាក់ងារគយ និង ៩ ថ្ងៃត្រូវការដើម្បីការនាំចូល ធៀបនឹង ៤ ថ្ងៃ និង ៨ ថ្ងៃរៀងគ្នាទៅនឹងប្រទេសវៀតណាម។ ភាពស្មុគស្មាញទាំងនេះគឺជាកត្តាដែលធ្វើឱ្យក្រុមអ្នកវិនិយោគសម្លឹងមើលប្រទេសផ្សេងក្រៅពីកម្ពុជាព្រោះការផ្តល់លិខិតបទដ្ឋានគតិយុត្តមានការកកស្ទះ ប្រើរយៈពេលយូរ តម្លៃខ្ពស់ ដោយពិបាកក្នុងការប្រកួតប្រជែងជាមួយប្រទេសផ្សេង។

---

[51] "*Cambodia Economic Update*," World Bank, June, 2024, https://documents1.worldbank.org/curated/en/099060324061538453/pdf/P1773401c2325e0f81a05f159ec748e81f0.pdf

[52] ហ៊ុល រស្មី, "*របាយការណ៍សហរដ្ឋអាមេរិកស្តីពីបរិយាកាសវិនិយោគនៅកម្ពុជាមិនអំណោយផល ឆ្នាំ២០២៤*," VOA, កក្កដា ១៩, ២០២៤, https://khmer.voanews.com/amp/us-report-says-investment-climate-in-cambodia-not-benefitial-to-us-investors-due-to-corruption/7704777.html

### ៣.១.៣.៤. បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញនៅមានកម្រិត

**តាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដើម្បីសម្រេចបាននូវចក្ខុវិស័យឆ្នាំ ២០៥០ កម្ពុជាចាំបាច់ត្រូវមានមូលធនមនុស្ស ដែលពោរពេញដោយចំណេះដឹង សមត្ថភាពជំនាញ ព្រមទាំងប្រកបដោយគុណធម៌ សីលធម៌ និងសុខភាពមាំមួន ដើម្បីធានាបាននូវភាពប្រកួតប្រជែងលើឆាកអន្តរជាតិ ក៏ដូចជាសមត្ថភាពចូលរួមកសាងមូលដ្ឋានសង្គម សេដ្ឋកិច្ច និងឧស្សាហកម្មដែលផ្អែកលើចំណេះដឹង។

តាមការសិក្សារបស់ធនាគារពិភពលោក កង្វះពលកម្មជំនាញបានក្លាយជាឧបសគ្គសម្រាប់ក្រុមហ៊ុនក្នុងការផលិតផលិតផលនាំចេញ ដែលនាំឱ្យខ្សែចថ្នាក់ផលិតកម្មមានភាពយឺតយ៉ាវ និងធ្លាក់ចុះយ៉ាងខ្លាំងនៅរយៈពេលប្រាំឆ្នាំចុងក្រោយដោយមិនអាចផលិតបានតាមការចង់បានរបស់អ្នកវិនិយោគ។ បច្ចុប្បន្នកម្ពុជាជាប្រទេសមួយដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ក្នុងតំបន់ ប៉ុន្តែអ្វីជាក្តីកង្វល់ដែលយើងត្រូវយកចិត្តទុកដាក់នោះគឺកម្ពុជានៅតែខ្វះធនធានមនុស្សដែលមានជំនាញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារក្នុងសង្គម និងតំបន់។

បើយោងទៅតាមក្រាហ្វិកទី ២១ ខាងក្រោម ផលិតភាពការងាររបស់កម្ពុជាហាក់នៅយឺតជាងដៃគូប្រកួតប្រជែងក្នុងតំបន់មួយចំនួនដូចជាប្រទេសថៃ និងវៀតណាម ដោយជាក់ស្តែងកំណើនផលិតភាពរបស់កម្ពុជាមានការកើនឡើងតិចតួចបំផុតក្នុងចន្លោះឆ្នាំ ២០១១ ដល់ឆ្នាំ ២០២១។ នេះអាចបណ្តាលមកពីភាពមានកម្រិតនៃធនធានមនុស្សរបស់កម្ពុជាក្នុងការការកសាងមូលដ្ឋានសេដ្ឋកិច្ចកម្ពុជាតាមរយៈប្រើប្រាស់បច្ចេកវិទ្យា និងនវានុវត្តន៍។[53]

**ក្រាហ្វិកទី២១ ៖ ការប្រៀបធៀបផលិតភាពកម្លាំងពលកម្មរបស់ប្រទេសមួយចំនួន**




ប្រភព៖ Reproduced from Cambodian Economic Update, Nov 2023

[53] « *Cambodia Economic Update,*» World Bank, June, 2024,
https://documents1.worldbank.org/curated/en/099060324061538453/pdf/P1773401c2325e0f81a05f159ec748e81f0.pdf

បើយោងទៅតាមក្រាហ្វិកទី ២២ ខាងក្រោមនៅឆ្នាំ ២០១៩ និង ២០២០ មានកម្លាំងពលកម្មក្នុងប្រទេសកម្ពុជាតែប្រមាណ ៥% ប៉ុណ្ណោះដែលបានបញ្ចប់ថ្នាក់វិទ្យាល័យ និងប្រមាណត្រឹមតែ ១២% នៃកម្លាំងពលកម្មដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សា ដែលអត្រានេះសឹងតែគ្មានការប្រែប្រួលបើធៀបទៅនឹងឆ្នាំ ២០១៤។ អ្វីដែលគួរឱ្យកាន់តែព្រួយបារម្ភទៀតនោះ កម្ពុជានៅតែបន្តពឹងផ្អែកលើកម្លាំងពលកម្មមានកម្រិតជំនាញទាបដែលជាហានិភ័យនៃការអភិវឌ្ឍ និងវិបុលភាពសម្រាប់កម្ពុជានាពេលអនាគត។ ជាក់ស្តែងក្នុងឆ្នាំ ២០១៩ និង ២០២០ ការងារប្រមាណជាង ៩០% ត្រូវបានប្រព្រឹត្តទៅដោយបានប្រើប្រាស់កម្លាំងពលកម្មមានកម្រិតជំនាញទាប ឬការងារម្រិតមូលដ្ឋាន (Elementary Occupations) ដែលការងារ ៦% បានប្រើប្រាស់ពលកម្មកម្រិតជំនាញមធ្យម និងមានត្រឹមតែ ៥% ប៉ុណ្ណោះនៃការងារដែលមានបុគ្គលិកជំនាញខ្ពស់។

**ក្រាហ្វិកទី២២ ៖ បង្ហាញពីកម្រិតជំនាញរបស់កម្លាំងពលកម្មក្នុងប្រទេសកម្ពុជា**




ប្រភព៖ Reproduced from Cambodian Economic Update, Nov 2023

ការបណ្តុះបណ្តាលនូវជំនាញពិតប្រាកដសម្រាប់ពួកគេ គឺជារឿងចាំបាច់ដែលត្រូវធ្វើការបំផុសឡើង និងលើកស្ទួយពីរាជរដ្ឋាភិបាល ប៉ុន្តែសាលាដែលផ្តល់នូវជំនាញបំពាក់បំប៉នវិជ្ជាជីវៈគឺមិនទាន់មានច្រើននោះទេ។ គួរគូសបញ្ជាក់បន្ថែមទៀតថា បច្ចុប្បន្នមានក្រសួងស្ថាប័នចំនួន ២ គឺក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំពុងផ្តល់ការបណ្តុះបណ្តាលជំនាញទាំងផ្នែករឹង និងផ្នែកទន់ ក៏ប៉ុន្តែការបណ្តុះបណ្តាលនេះ ជារួម គឺផ្អែកលើការផ្គត់ផ្គង់ (Supply-Driven Skills) ពោលភាគច្រើនមានលក្ខណៈជាជំនាញពាក់ព័ន្ធនឹងចំណេះដឹងទូទៅ និងមិនទាន់ឆ្លើយតបបានទាំងស្រុងទៅនឹងតម្រូវការទីផ្សារ (Skills mismuch) ហើយគុណភាពនៃជំនាញទៀតសោត ក៏នៅមិនទាន់គ្រប់គ្រាន់នៅឡើយ (Quality mismuch)។ ប្រការនេះធ្វើឱ្យមានការខ្វះចន្លោះ ក្នុងការអភិវឌ្ឍជំនាញ ដែលជាបច្ច័យធ្វើឱ្យដំណើរការ នៃការធ្វើពិពិធកម្ម

ឧស្សាហកម្ម មានល្បឿនយឺត ធៀបនឹងគោលដៅ ដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កម្ពុជា ២០១៥-២០២៥។[54]

ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលបានជះឥទ្ធិពលអវិជ្ជមានជាច្រើនមកកាន់សង្គមជាតិទាំងមូល។ តួយ៉ាង រាជរដ្ឋាភិបាលកម្ពុជាប៉ាន់ស្មាន មានប្រជាពលរដ្ឋកម្ពុជាប្រមាណ ៣០ ភាគរយប៉ុណ្ណោះ ដែលមានជំនាញឌីជីថលបឋមក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការស្រាវជ្រាវអ៊ីនធឺណែត ទំនាក់ទំនង និងចែករំលែកព័ត៌មាន។ ទោះបីជាប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានខិតខំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឌីជីថលយ៉ាងណាក្តី ការប្រើប្រាស់ប្រព័ន្ធឌីជីថលលើវិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាហាក់នៅមានកម្រិត ហើយក្រុមហ៊ុនសហគ្រាសប្រមាណ ១.៣ ភាគរយប៉ុណ្ណោះបានប្រើប្រាស់ប្រព័ន្ធឌីជីថល ខណៈជាង ៩០ ភាគរយផ្សេងទៀតនៅមិនទាន់ប្រើពេញលេញនៅឡើយទេ ដែលអាចបណ្តាលមកពីកត្តាថ្លៃដើមខ្ពស់ កង្វះជំនាញក្នុងការប្រើប្រាស់ និងមានភាពលំបាកក្នុងការទទួលបានហិរញ្ញប្បទានជាដើម។

### ៣.១.៣.៥. ភាពកម្សោយនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម

បញ្ហាសុខភាព និងសុវត្ថិភាពរបស់កម្មករ និយោជិកគឺជាជារឿង ដែលរាជរដ្ឋាភិបាល និយោជក និងដៃគូពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តចាំបាច់។ ការធានាក្នុងការធ្វើឱ្យកន្លែងធ្វើការមានសុវត្ថិភាពគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់គ្រប់រោងចក្រ មិនត្រឹមតែដើម្បីធានាឲ្យមានការគោរពតាមច្បាប់ជាតិ និងបទដ្ឋានការងារអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីប្រាកដថាកម្មករទាំងអស់មានសុវត្ថិភាព និងទទួលបានផលប្រយោជន៍ ដែលនាំមកនូវគុណសម្បត្តិសម្រាប់បុគ្គលិកផង និងអាជីវកម្មផង។

នៅកម្ពុជា ច្បាប់ការងារ ដែលធានាបរិស្ថានការងារសុវត្ថិភាពស្តង់ដាសុវត្ថិភាពហាក់នៅមានកម្រិត ហើយការពង្រឹងការអនុវត្តក៏ជួបការលំបាកដោយហេតុថានិយោជិតខ្វះការយល់ដឹងអំពីហានិភ័យ និងគ្រោះថ្នាក់ដែលអាចកើតមាននៅកន្លែងធ្វើការ និងវិធានការការពារខ្លួន ជាពិសេសកត្តាបរិស្ថានការងារមិនអំណោយផលគ្មានអនាម័យ គ្មានសុវត្ថិភាព និងសុខភាពមិនល្អ។ ម្យ៉ាងវិញទៀត វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនៅមិនទាន់ទូលំទូលាយនិងគ្របដណ្តប់ពេញលេញ ដែលធ្វើឲ្យក្រុមប្រជាជនមួយចំនួន មិនទាន់ទទួលបានការគាំពារ។ ការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គមដូចជាអត្ថប្រយោជន៍ និងកាតព្វកិច្ចក្នុងការចូលរួមរបស់ប្រជាជននៅក្នុងរបប ឬកម្មវិធីនីមួយៗនៅមានកម្រិត។

គ្រោះថ្នាក់ និងហានិភ័យការងារអាចនឹងកើតមានគ្រប់ពេលវេលាកំឡុងពេលបំពេញការងារ ជាពិសេសការងារដែលមានហានិភ័យខ្ពស់មួយចំនួនពាក់ព័ន្ធទៅនឹងគ្រឿងចក្រ ប្រើប្រាស់ដោយថាមពលមេកានិច ខ្យល់ចំហាយកំដៅ ឬអគ្គីសនី អាចបង្កគ្រោះថ្នាក់ដល់មនុស្ស ប្រសិនបើគ្មានការអប់រំបច្ចេកទេសសុវត្ថិភាពជាមុន និង

[54] “ *ការធ្វើពិពិធកម្មសេដ្ឋកិច្ច ទាមទារនូវការបណ្តុះបណ្តាលជំនាញ ដើម្បីប្រែក្លាយឧស្សាហកម្ម ផ្អែកលើអតិពលកម្ម ទៅជាឧស្សាហកម្ម ផ្អែកលើជំនាញ,*” Fresh News, ធ្នូ ១៦, ២០២២ https://freshnewsasia.com/index.php/en/localnews/270023-2022-12-16-07-15-03.html

ឧបករណ៍ការពារសុវត្ថិភាព ឬកង្វះរបាំងសុវត្ថិភាពជាដើម។ល។ ការងារក្នុងមណ្ឌលជាកន្លែងធ្វើការ ដែលតូចចង្អៀត និងមានមាត់រន្ធ ច្រកចូលតូចមិនអាចឲ្យមានការផ្លាស់ប្តូរខ្យល់អាកាសបានគ្រប់គ្រាន់ សម្រាប់ការដកដង្ហើម ដូចជាការងារក្នុងធុងធំ ស៊ីទែន អន្លង់ បាតនាវា ប្រឡាយបង្ហូរក្នុងដី បំពង់លូ អណ្តូង ផ្លូវក្នុងអណ្តូងរ៉ែ បន្ទប់ក្រោមដីជាដើម។

បរិយាកាសការងារមិនល្អអាចបង្ករជាហានិភ័យជីវសាស្ត្រដែលបង្កឡើងដោយសំណល់ វេជ្ជសាស្ត្រ មេរោគ វីរុស ឬជាតិពុលមកពីប្រភពនៃ ជីវសាស្ត្រ ដែលនាំឲ្យប៉ះពាល់ដល់សរីរាង្គរស់ និងសុខភាពរបស់មនុស្ស។ កម្មករក៏អាចប្រឈមនឹងខ្យល់និងកំដៅចេញចូលមិនគ្រប់គ្រាន់ ការប្រឈមនឹងសារធាតុគីមី និងផ្សេងបំពុលនានា។ ឧទាហរណ៍ ការដួលសន្លប់គឺតែងតែកើតឡើងជាញឹកញយ។ ការដឹកជញ្ជូនកម្មករនៅក្នុងឡានដឹកទំនិញគ្មានដំបូលក៏បានក្លាយជាការព្រួយបារម្ភដែរសម្រាប់កម្មករកាត់ដេរ និងកម្មករសំណង់។ ដោយសារកត្តាជីវភាពនៅមានកម្រិត និងជួបការខ្វះខាត កម្មករនិយោជិតត្រូវបានគម្រាមកំហែងដោយកង្វះអាហារូបត្ថម្ភ ការហូបចុកមិនបានគ្រប់គ្រាន់ គ្មានអនាម័យ និងបញ្ហាសុវត្ថិភាពម្ហូបអាហារជាដើមដែលនឹងបង្កជាបញ្ហាសុខភាព ការខាតបង់ប្រាក់ចំណូល ព្រមទាំងអាចឈានដល់ការស្លាប់បាត់បង់ជីវិតក៏មាន។

ការអប់រំអំពីការថែទាំសុខភាពនៅតាមសហគមន៍ គឺនៅមានកម្រិត ខណៈដែលសេវាព្យាបាលសាធារណៈមិនសូវមានភាពច្បាស់លាស់។ ភាពក្រីក្រនៅកម្ពុជាភាគច្រើនកើតឡើងដោយសារតែបញ្ហាសុខភាព ជាឧទាហរណ៍ក្រុមគ្រួសារខ្លះខិតខំធ្វើការរកស៊ីរាប់ឆ្នាំ ប៉ុន្តែនៅពេលសមាជិកគ្រួសារណាម្នាក់ធ្លាក់ខ្លួនឈឺ នោះអាចនឹងត្រូវធ្លាក់ខ្លួនក្រដោយសារតែត្រូវចំណាយលុយមើលជំងឺក៏ថាបាន។ ទាំងអស់នេះហើយជាហេតុធ្វើឲ្យសេដ្ឋកិច្ចយើងមិនអាចលូតលាស់ទៅមុខបាន ដោយសារចំណូលរកបានមិនទាន់នឹងការចំណាយមើលជំងឺ។ ម្យ៉ាងវិញទៀតនៅពេលដែលបុគ្គលិក កម្មករនានាធ្វើការនៅទីតាំងដែលមានបរិស្ថានសណ្តាប់ធ្នាប់មិនល្អ មិនទទួលបានអាហាររូបត្ថម្ភគ្រាប់គ្រាន់ ឬមានគ្រោះថ្នាក់ជាយថាហេតុណាមួយកើតឡើង វានាំឱ្យប៉ះពាល់យ៉ាងខ្លាំងទៅលើផលិតភាពផលិតកម្មទាំងមូល នាំឱ្យមានភាពយឺតយ៉ាវ ទិន្នផលធ្លាក់ចុះ ខាតបង់ប្រាក់ចំណេញ។

### ៣.១.៤. បញ្ហាប្រឈមនាពេលអនាគត

#### ៣.១.៤.១. ការបែងចែកប្លុកសេដ្ឋកិច្ច និងពាណិជ្ជកម្ម

កាលពីរយៈពេលមុន ទំនាក់ទំនងការបរទេសរវាងប្រទេសនីមួយៗពិតជាមានកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតទាំងលើផ្នែកការទូត និងពាណិជ្ជកម្ម ដែលវាមានលក្ខណៈអំណោយផលខ្លាំងដល់សេដ្ឋកិច្ចនៅក្នុងតំបន់ និងសកលលោក។ ការធ្វើឱ្យមាននូវស្ថិរភាពនយោបាយក្នុង និងក្រៅតំបន់តាមរយៈការធ្វើសហ-ប្រតិបត្តិការជាមួយបណ្តាប្រទេសនានាបានបង្កជាលក្ខណៈងាយស្រួលក្នុងទំនាក់ទំនងការទូត និងការដោះដូរពាណិជ្ជកម្មប្រកបដោយសក្តានុពលខ្ពស់ ដោយអាចឱ្យប្រទេសនីមួយៗមានដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចទៅមុខរួមគ្នាប្រកបដោយនិរន្តរភាព។ ប៉ុន្តែ អ្វីៗក៏បានផ្លាស់ប្តូរ ជាពិសេសចាប់តាំងពីប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មនៅលើពិភពលោកហាក់មានការបែកខ្ញែកគ្នាជាប្លុកផ្សេងៗ ហើយការបែកខ្ញែកជាប្លុកសេដ្ឋកិច្ចនេះបានលេចជារូបរាងកាន់តែច្បាស់ និងមានស្ថានភាពកាន់តែធ្ងន់ធ្ងរជាងមុន បន្ទាប់ពីរុស្ស៊ីបានវាយចូលឈ្លានពានអ៊ុយក្រែន ហើយភាពតានតឹងលើពាណិជ្ជកម្មរវាងមហាយក្សចិន និងអាមេរិក ដែលជាមហាអំណាចសេដ្ឋកិច្ចកំពូលទាំងពីរនៅលើពិភពលោកឡើងកម្តៅកាន់តែខ្លាំងឡើង។ ដោយសារតែការប្រណាំងប្រជែងរវាងប្រទេសមហាអំណាចធំៗ ក៏ដូចជាការបែកបាក់ និងភាពប្រទាញគ្នារវាងនិន្នាការពហុប៉ូលសកលូប-នីយកម្ម និងនិន្នាការឯកប៉ូលគាំពារនិយម ដែលធ្វើឱ្យសណ្តាប់ធ្នាប់សកលនាពេលអនាគតកាន់តែស្មុគស្មាញពិបាកក្នុងការព្យាករណ៍ និងពិបាកធ្វើការវាយតម្លៃ។ ជាការពិត និម្មាបនកម្មសេដ្ឋកិច្ចសកលកំពុងប្រែប្រួលយ៉ាងខ្លាំង ដោយមជ្ឈភាពនៃកំណើនសកលកំពុងបន្តនិន្នាការងាកមករកតំបន់អាស៊ី។ ទន្ទឹមនេះ ក្រុមប្រទេសសេដ្ឋកិច្ចកំពុងរីកលូតលាស់ ជាពិសេសក្រុមប្រទេស BRICS ក៏កំពុងចូលរួមចំណែកនាំមុខកំណើនសកល ខណៈដែលសេដ្ឋកិច្ចរបស់បណ្តាប្រទេសលោកខាងលិច ជាពិសេសប្រទេសមហាអំណាចទាំង ៧ (G7) អាចនឹងបន្តថមថយ។ តួយ៉ាង BRICS មានចំនួនប្រជាជនប្រហែល ៤០% នៃចំនួនប្រជាជនសរុបនៅលើពិភពលោក ហើយមានផលិតផលក្នុងស្រុកសរុប (GDP) ជិតមួយភាគបួននៃផលិតផលក្នុងស្រុកសរុបសកល ហើយដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចពិភពលោក។ កិច្ចសហប្រតិបត្តិការពហុវិស័យក្នុងក្របខ័ណ្ឌ BRICS មិនត្រឹមតែរួមចំណែកយ៉ាងសំខាន់ក្នុងការធានានូវកំណើនប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសជាសមាជិកប៉ុណ្ណោះទេ ថែមទាំងជម្រុញការងើបឡើងវិញនៃសេដ្ឋកិច្ចសកលផងដែរ។

ជាក់ស្តែង បើមើលទៅលើក្រាហ្វិកទី ២៣ ចំណែកនៃ GDP in PPP រវាងក្រុមប្រទេស BRICS និងលោកខាងលិច ក្រាហ្វិកខាងក្រោមបានបង្ហាញថា ចាប់ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៧ ក្រុមប្រទេសមហាអំណាចសេដ្ឋកិច្ចទាំង ៧ បាននាំមុខ និងមានចំណែក GDP in PPP ដែលមានអត្រាចំណែកអប្បបរមា ៣១,៧៧% ក្នុងឆ្នាំ ២០១៧ និងមានចំណែកអតិបរមា ៤២,៧៨% ក្នុងឆ្នាំ ២០០០ ដោយតួលេខនេះមានចំណែក GDP in PPP ច្រើនជាងគេក្នុងពិភពលោក។ បើទោះបីជាយ៉ាងណាក៏ដោយ បើគិតចាប់ពីឆ្នាំ ២០១៧ ចំណែក GDP in PPP របស់ក្រុមប្រទេសមហាអំណាចសេដ្ឋកិច្ចទាំង ៧ មានសភាពប្រែប្រួលថយចុះនូវចំណែក GDP របស់ខ្លួន ខណៈពេលដែលមានការលេចឡើងនូវការងើបយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចរបស់ក្រុម

ប្រទេស BRICS ដោយក្រុមប្រទេសនេះមានចំណែក GDP in PPP កើនពីអត្រា ៣១.៧៧% ទៅ ៣៤.៩២% ក្នុងឆ្នាំ ២០២៤។[55]

**ក្រាហ្វិកទី២៣៖ បង្ហាញពីចំណែកនៃGDP in PPP រវាងក្រុមប្រទេស BRICS និងលោកខាងលិច**




ប្រភព៖ IMF & Statista

បន្ថែមលើនេះ និន្នាការគាំពារនិយម និងការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចអាចនឹងបង្កើនល្បឿននៃចរន្តបដិសកលភាវូបនីយកម្ម និងជម្រុញនិន្នាការតំបន់ូបនីយកម្មនៅថ្ងៃអនាគត ដែលនឹងប៉ះពាល់ដល់លំហូរទំនិញ សេវា ការវិនិយោគ កម្លាំងពលកម្ម ការផ្ទេរបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការអន្តរជាតិកាន់តែច្រើនជាងមុនបន្ថែមទៀត។ ជាក់ស្តែង រចនាសម្ព័ន្ធខ្សែច្រវាក់ផ្គត់ផ្គង់ និងផលិតកម្មក្នុងតំបន់ និងសកលកំពុងត្រូវបានរៀបចំឡើងវិញតាមរយៈការផ្លាស់ប្តូរមូលដ្ឋានផលិតកម្មមកក្នុងប្រទេសវិញ ឬទៅប្រទេសជាសម្ព័ន្ធមិត្ត ដែលផ្តោតសំខាន់លើកត្តាភូមិសាស្ត្រនយោបាយ ជាពិសេសសម្រាប់ទំនិញយុទ្ធសាស្ត្រ។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់អន្តរជាតិក៏ត្រូវប្រឈមនឹងហានិភ័យនៃការបែងចែកដាច់ពីគ្នាតាមតំបន់នៃកិច្ចសហប្រតិបត្តិការនីមួយៗ ដែលអាចជះឥទ្ធិពលអវិជ្ជមាន ដល់ប្រសិទ្ធភាពនៃការទូទាត់ ខណៈការបង្កើតស្ថាប័នហិរញ្ញវត្ថុអន្តរជាតិថ្មីៗនឹងដើរតួនាទីសំខាន់ក្នុងការកៀរគរធនធានសម្រាប់ការអភិវឌ្ឍ។ ការបែកខ្ញែកនេះ បានធ្វើឱ្យមានការបែងចែកជាប្លុកនៃការគាំទ្រសម្រាប់បណ្តាប្រទេសផ្សេងៗ ដែលកត្តានេះបានធ្វើឱ្យការធ្វើពាណិជ្ជកម្ម និងស្ថានភាពសេដ្ឋកិច្ចពិភពលោកប្រឈមនឹងបញ្ហាផ្សេងៗ និងមានភាពមិនច្បាស់លាស់កាន់តែខ្លាំង។

---

[55] "*Brics and G7 countries' share of the world's total GDP in PPP,*" Statista Research Department, Jul 15, 2024, https://www.statista.com/statistics/1412425/gdp-ppp-share-world-gdp-g7-brics/

### ៣.១.៤.២. បរិវត្តកម្មឌីជីថល

ពិភពលោកបានរីកចម្រើនយ៉ាងខ្លាំង និងឈានទៅរកយុគសម័យថ្មីនៃបច្ចេកវិទ្យាទំនើប ស្របតាមការធ្វើសមាហរណកម្មរវាងមនុស្ស និងម៉ាស៊ីននានាដែលបញ្ជាតាមឌីជីថល ពោលគឺការធ្វើបរិវត្តកម្មឌីជីថល ដែលជាការចាប់យក និងទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងបច្ចេកវិទ្យាឌីជីថលដើម្បីគាំទ្របដិវត្តន៍ឧស្សាហកម្មទី៤ ដែលបង្កើនផលិតភាព ជម្រុញកំណើនសេដ្ឋកិច្ចជាតិ និងកសាងសង្គម និងសេដ្ឋកិច្ចឌីជីថល ដែលផ្តល់ផលប្រយោជន៍ដល់ពលរដ្ឋឌីជីថល និងសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចមួយខ្ពស់ឡើងជាលំដាប់។

ការរីកចម្រើនយ៉ាងលឿននៃប្រព័ន្ធឌីជីថលនេះ ច្បាស់ណាស់នឹងពាំនាំមកជាមួយនូវបញ្ហាប្រឈម និងក្តីកង្វល់ដល់ប្រទេសមួយចំនួន ជាក់ស្តែងកម្ពុជាដែលការធ្វើឌីជីថលូបនីយកម្ម និងការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា កំពុងស្ថិតនៅដំណាក់កាលចាប់ផ្តើមនៅឡើយ។ តាមការវាយតម្លៃជាអន្តរជាតិ ការត្រៀមខ្លួនរបស់កម្ពុជាជារួមក្នុងការចាប់យកវិស័យឌីជីថល ស្ថិតនៅ ក្នុងកម្រិតមួយទាប ។ ជាក់ស្តែង សម្រាប់កត្តាជម្រុញការត្រៀមខ្លួន កម្ពុជាឈរនៅលេខរៀងទី ១០២ ក្នុង ចំណោមប្រទេស ១៤១ ឬ លេខរៀងទី ៧ ក្នុងចំណោមប្រទេសសមាជិកអាស៊ានទាំង ៩ (លើកលែងប្រទេសព្រុយណេ) ដែលត្រូវបានចាត់ទុកថា ជាប្រទេសក្នុងចំណោមប្រទេសមានល្បឿនទាបក្នុងការត្រៀម ខ្លួនឌីជីថល ឬមានការត្រៀមខ្លួនឌីជីថលតិចតួច ជាពិសេសលើផ្នែកការអភិវឌ្ឍធនធានមនុស្ស ការចាប់យកបច្ចេកវិទ្យា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងការកែសម្រួលបរិយាកាសធុរកិច្ច។ យ៉ាងណាមិញ វិសាលភាពគ្របដណ្តប់ការប្រើប្រាស់សេវាអ៊ីនធឺណិត និងទូរស័ព្ទចល័ត ភាគច្រើនប្រមូលផ្តុំនៅតាមទីក្រុង និងទីប្រជុំជនធំៗ ហើយគុណភាពសេវាក៏កំពុងក្លាយជាបញ្ហាប្រឈមចំពោះការប្រើប្រាស់ និងការសាយភាយចំណេះដឹងផ្នែកបច្ចេកវិទ្យាដល់ប្រជាជននៅទីដាច់ស្រយាល។

បើយោងតាមរបាយការណ៍ស្តីអំពីក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥ បានលើកឡើងពីបញ្ហាប្រឈមសំខាន់ៗ ៣ នៃបរិវត្តឌីជីថលមកកាន់សេដ្ឋកិច្ចកម្ពុជារួមមាន៖

- ការផ្លាស់ប្តូររចនាសម្ព័ន្ធកម្លាំងពលកម្ម និងការងារ៖ ការងារបែបប្រពៃណីមួយចំនួនអាចប្រឈមខ្ពស់នឹងការបាត់បង់ ខណៈសេដ្ឋកិច្ចឌីជីថលនឹងបង្កើតប្រភេទការងារថ្មីដែលទាមទារឱ្យមានចំណេះដឹង និងជំនាញខ្ពស់ជាងមុន ជាពិសេសជំនាញឌីជីថលតាមរយៈរបៀបធ្វើការងារ, ការជំនួសការងារដោយម៉ាស៊ីនស្វ័យប្រវត្តិ និង គ្រឿងយន្ត, ការបង្រួញខ្សែច្រវាក់ផលិតកម្ម និង ការរីកកាន់តែធំនៃគម្លាតឌីជីថល (Digital Divide) ក្នុងចំណោមតួអង្គពាក់ព័ន្ធ ដែលនាំឱ្យអ្នកដែលមិនអាចសម្របខ្លួនបានប្រឈមនឹងការបាត់បង់ការងារ ដែលនាំទៅរកស្ថានភាពគ្មានការងារធ្វើនៅក្នុងវិស័យមួយចំនួន ឬ និកម្មភាពរចនាសម្ព័ន្ធ (Structural Unemployment)។
- ការប្រែប្រួលមូលដ្ឋាននៃការប្រមូលចំណូលពន្ធ៖ ការណ៍នេះក៏អាចបង្កើតជាបច្ច័យអវិជ្ជមានមួយចំនួនដល់ការប្រមូលចំណូលសារពើពន្ធ ក្នុងរូបភាពជា៖ (១). ការបាត់បង់ចំណូលពន្ធ និង មូលដ្ឋានពន្ធ

ដោយសារអវត្តមានរូបវន្តបុគ្គល/អាជីវកម្មក្នុងស្រុក ព្រោះថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពុំមានដែនកំណត់ (Borderless) ឡើយ, (២). ការកំណត់និយមន័យចំណូល (Income Characterization) មិនទាន់មានភាពច្បាស់លាស់ ខណៈពុំទាន់មានយន្តការល្អក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមាន និង(៣). យន្តការប្រមូលអាករលើតម្លៃបន្ថែមមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមិនទាន់មានប្រសិទ្ធភាពខ្ពស់ក្នុងបរិការណ៍នៃពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក។

- ការបង្វែរអាទិភាពនៃចំណាយវិនិយោគសាធារណៈ៖ រាជរដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការដឹកនាំ និង ការជម្រុញការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ឆ្លើយតបទៅនឹងតម្រូវការ ដែលនេះទាមទារឱ្យមានការកៀរគរធនធានសម្រាប់ការវិនិយោគ។ ជាលទ្ធផល ការណ៍នេះនឹងក្លាយជាបន្ទុកសម្រាប់ការប្រមូលចំណូលដើម្បីបំពេញតម្រូវការនៃការវិនិយោគ ព្រមទាំងនឹងក្លាយជាសម្ពាធលើការចែករំលែកធនធានដែលមានកំណត់សម្រាប់ការអភិវឌ្ឍវិស័យនេះ ដែលតម្រូវឱ្យមានការថ្លឹងថ្លែងលើអាទិភាពវិនិយោគសាធារណៈទាំងមូល។[56]

### ៣.១.៤.៣. ការប្រែប្រួលអាកាសធាតុ

ពីមួយថ្ងៃទៅមួយថ្ងៃ ការប្រែប្រួលអាកាសធាតុបាននឹងកំពុងបង្កឱ្យលេចឡើងជាបញ្ហាគ្រោះធម្មជាតិលើបណ្តាប្រទេសនានានៅលើសកលលោក ដែលមានដូចជាការឡើងកំដៅភពផែនដី កំណើនសីតុណ្ហភាព រលកកម្តៅ ភាពរាំងស្ងួត ការឡើងកម្ពស់ទឹកសមុទ្រ កំណើនទឹកប្រៃ កង្វះទឹកសាប ការរលាយភ្នំទឹកកក ទឹកជំនន់ ដីស្ងួត ហួតហែងខ្សោះដីជាតិ និងបញ្ហាគ្រោះមហន្តរាយផ្សេងៗ។ ការកើតមាននូវគ្រោះមហន្តរាយធម្មជាតិនេះគឺបណ្តាលមកពីកត្តាធម្មជាតិ និងសកម្មភាពមនុស្ស ដែលសកម្មភាពមនុស្សនាពេលសព្វថ្ងៃបាននឹងកំពុងបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់សម្បត្តិធនធានធម្មជាតិ និងប្រព័ន្ធគម្របបរិស្ថាន។ ជាការពិត ការបំភាយឧស្ម័នផ្ទះកញ្ចក់បាននឹងកំពុងបន្តតាមរយៈសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច ស្របពេលដែលប្រទេសនៅលើពិភពលោកកំពុងតែជម្រុញនូវការអភិវឌ្ឍរបស់ខ្លួន ដែលជាប្រភពនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស។ ឧស្ម័នផ្ទះកញ្ចក់ជាដើមហេតុនៃការឡើងកម្តៅផែនដី ក្នុងនោះក៏មានឧស្ម័នមួយចំនួន ដែលកើតចេញពីសកម្មភាពរបស់មនុស្សដូចជាការចរាចរណ៍ឡាន ម៉ូតូ ម៉ាស៊ីនរោងចក្រ ឬរោងចក្រផលិតអគ្គិសនីដើរដោយធ្យូងថ្មជាដើមសុទ្ធសឹងជាសកម្មភាពបំភាយឧស្ម័នកាបូនិចទៅក្នុងបរិយាកាស។ ការកើនឡើងនៃឧស្ម័នផ្ទះកញ្ចក់ និងឧស្ម័នកាបូនិចនឹងធ្វើឱ្យស្រទាប់ភពផែនដីកាន់តែមានគ្រោះថ្នាក់ និងផ្តល់នូវរលកកម្តៅ និងគ្រោះរាំងស្ងួតយ៉ាងធ្ងន់ធ្ងរដល់ជីវភាព និងការរស់នៅរបស់ពលរដ្ឋសកលទាំងមូល។ បន្ថែមពីលើនេះទៀត ការកាប់បំផ្លាញព្រៃឈើ ក៏ជាដើមហេតុមួយដែរ ដែលនាំឱ្យផែនដីឡើងកម្តៅព្រោះព្រៃឈើជួយស្រូបឧស្ម័នកាបូនិកពីក្នុងបរិយាកាស។ កាលណា

---

[56] រាជរដ្ឋាភិបាលកម្ពុជា, *"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០២៥,"* ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចកម្ពុជា, ឧសភា ២០២១ https://asset.cambodia.gov.kh/mptc/2021/05/Printed-_Digital-Economy-and-Society-Framework.pdf

បរិមាណព្រៃឈើធ្លាក់ចុះ សមត្ថភាពក្នុងការស្រូបឧស្ម័នកាបូនិកក៏ត្រូវធ្លាក់ចុះ ហើយវាធ្វើឱ្យបរិមាណឧស្ម័នកាបូនិចនៅក្នុងបរិយាកាសមានការកើនឡើង ដែលជាដើមហេតុនាំឱ្យផែនដីឡើងកម្តៅ។ ការកើនឡើងកម្តៅនឹងធ្វើឱ្យពិភពលោកជួបគ្រោះទុរភិក្ស ដីគ្មានជីវជាតិខ្សោះទឹក កង្វះប្រភពទឹក និងភាពរាំងស្ងួត។ តួយ៉ាង បើតាមរយៈតួលេខរបស់កម្មវិធីស្បៀងអាហារពិភពលោក (WFP) បានបង្ហាញថា ភាពអត់ឃ្លានធ្ងន់ធ្ងរបានកើនឡើងជាបន្តបន្ទាប់នៅទូទាំងពិភពលោកក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយគិតត្រឹមឆ្នាំ២០២៣ មនុស្សចំនួនជាង ៣៣០ លាននាក់កំពុងបានស្ថិតក្នុងស្ថានភាពនេះ ពោលគឺអាចគម្រាមកំហែងដល់អាយុជីវិតភ្លាមៗមួយរំពិច ក្នុងករណីខ្វះខាតវិធានការជួយសង្គ្រោះ។ លើសពីនេះទៅទៀត កម្តៅដ៏ក្តៅបំផុត និងព្យុះកាន់តែខ្លាំងឡើងកំពុងតែគម្រាមកំហែងដល់ជីវភាពរស់នៅ សុខភាព ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងការដំឡើងមូលដ្ឋានការពារជាតិនៅក្នុងប្រទេសនានានៅទូទាំងតំបន់ប៉ាស៊ីហ្វិក។ ការធ្វើចំណាកស្រុកដែលជាលទ្ធផល ការប្រកួតប្រជែងដើម្បីធនធាន អសន្តិសុខស្បៀង និងផលវិបាកពីបញ្ហាអាកាសធាតុផ្សេងទៀត បង្កើតបានជាបញ្ហាប្រឈមផ្នែកសន្តិសុខដ៏ស្មុគស្មាញមួយសម្រាប់ទ្វីបតំបន់ប៉ាស៊ីក។ ក្នុងនោះ បម្រែបម្រួលអាកាសធាតុអាចជះឥទ្ធិពលដល់ជាង ៨០% នៃចំនួនប្រជាជនតំបន់ប៉ាស៊ីហ្វិកនៅឆ្នាំ ២០៥០ នេះបើយោងតាមមជ្ឈមណ្ឌលឧត្តមភាពគ្រប់គ្រងគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌ (CFE-DM) របស់ទីបញ្ជាការដ្ឋានតំបន់តំបន់ប៉ាស៊ីហ្វិករបស់អាមេរិក។ នៅទូទាំងពិភពលោក ការកើនឡើងកម្រិតទឹកសមុទ្រ និងទឹកជំនន់តាមឆ្នេរសមុទ្រត្រូវបានគេរំពឹងថានឹងបង្ខំឱ្យមនុស្សជាង ២០០ លាននាក់ចាកចេញពីលំនៅឋានរបស់ពួកគេ ដោយមានបណ្តាលប្រទេសក្នុងតំបន់ Blue Pacific ដែលស្ថិតក្នុងចំណោមប្រទេសដែលរងផលប៉ះពាល់ខ្លាំងជាងគេបំផុតផងដែរ។ ក្រៅពីតំបន់នេះ បើមើលក្នុងតំបន់អាស៊ីវិញ តាមរយៈការព្យាករណ៍របស់អ្នកជំនាញ ត្រឹមឆ្នាំ២០៣០ ការបំភាយឧស្ម័នផ្ទះកញ្ចក់របស់អាស៊ីនឹងកើនឡើងដល់ ៤៥% ហើយមានប្រទេសចំនួន ៦ ដែលងាយរងគ្រោះបំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិករួមមាន ហ្វីលីពីន ឥណ្ឌា ប៉ាគីស្ថាន ឡាវ វៀតណាម និងកម្ពុជា។ ការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យម្ហូបអាហារកើនឡើង ១០% ដែលជាហេតុធ្វើឱ្យមនុស្ស ៦៤ លាននាក់ធ្លាក់ចូលក្នុងភាពក្រីក្រ។ ចំណែកឯមនុស្សស្លាប់នៅដោយសារគ្រោះធម្មជាតិវិញមានចំនួន ១.៧ លាននាក់ ហើយខាតបង់ទឹកប្រាក់ប្រមាណ ៥៣.៧ ពាន់លានដុល្លារ។[57] តាមរយៈនេះ បញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុបាននឹងកំពុងក្លាយជាឧបសគ្គបង្អាក់ដល់កំណើនសេដ្ឋកិច្ចសកល កាត់បន្ថយសុខុមាលភាពរបស់ពលរដ្ឋសកល និងរារាំងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ជាពិសេសបង្កជាហានិភ័យខ្ពស់ដល់ជីវិតមនុស្ស សត្វ ប្រព័ន្ធជីវៈចម្រុះ និងការរស់នៅរបស់ពលរដ្ឋទូទាំងសកលលោក ដែលក្នុងនោះបណ្តាប្រទេសជាច្រើនលើពិភពលោកបានជួបប្រទះ ប្រឈមមុខ និងរងការគម្រាមកំហែងទៅថ្ងៃអនាគតដោយសារទំហំនៃការបំពុលបរិស្ថាន, ការរិចរិលធនធានធម្មជាតិ, ការបាត់បង់ប្រព័ន្ធជីវៈចម្រុះ, និងការប្រែប្រួលអាកាសធាតុមានការកើនឡើងជារៀងរាល់ថ្ងៃ ដែលជះផលអវិជ្ជមានដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដូចជាអសន្តិសុខ

[57] Maria Cecilia, " *វិធានអន្តរជាតិ និងការអនុវត្តល្អបំផុតនៃច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ,*" សីហា ២២,២០១៧, https://www.ajne.org/sites/default/files/event/7113/session-materials/session-6-climate-change-law-kh.pdf

ស្បៀងអាហារសកល ភាពកង្វះខាតថាមពល អស្ថិរភាពសង្គម និងបាត់លំនឹងប្រព័ន្ធអេកូឡូស៊ីទាំងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ ក៏ដូចជាពិភពលោកទាំងមូល។

❖ **ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើប្រទេសកម្ពុជា**

ការប្រែប្រួលអាកាសធាតុនៅលើភពផែនដីនឹងមានឥទ្ធិពលយ៉ាងខ្លាំងមកលើធាតុអាកាស និងគម្រាមកំហែងដល់សុខុមាលភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិកម្ពុជា។ កាលពីប៉ុន្មានឆ្នាំមុន ប្រជាជនកម្ពុជាភាគច្រើនជាកសិករ ដោយប្រកបរបរក្នុងវិស័យកសិកម្ម ដែលពឹងផ្អែកលើអាកាសធាតុ ដូច្នេះការប្រែប្រួលអាកាសធាតុនឹងប៉ះពាល់យ៉ាងខ្លាំងមកលើជីវភាពរស់នៅរបស់ពួកគេ។ ផលប៉ះពាល់ចម្បងនៃអាកាសធាតុនៅប្រទេសកម្ពុជារួមមានការកើនឡើងសីតុណ្ហភាព និងរដូវវស្សាកាន់តែមានរយៈពេលខ្លីជាងមុន។ គ្រោះមហន្តរាយធម្មជាតិដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួតបាននឹងកំពុងកើតឡើងជាញឹកញាប់ និងមានភាពធ្ងន់ធ្ងរជាងមុន។ លុះមកដល់ឆ្នាំបច្ចុប្បន្ន និងថ្ងៃអនាគត ការវិវត្តន៍លើវិស័យឧស្សាហកម្មកាន់តែរីកចម្រើនទៅមុខ កម្ពុជាបានប្រើប្រាស់ថាមពលនៅក្នុងកត្តាផលិតកម្មច្រើន ដែលនាំឱ្យកម្ពុជាប្រឈមមុខនឹងបញ្ហាអាកាសធាតុ និងបរិស្ថានបន្ថែមទៀតដោយសារការកើនឡើងនៃឧស្ម័នពុលចូលទៅក្នុងបរិយាកាស។ បើតាមស្ថិតិរបស់អង្គការអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) ស្ថានភាពនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជាត្រូវបានប៉ាន់ស្មានថា រហូតដល់ឆ្នាំ ២០៦០ សីតុណ្ហភាពនឹងកើនឡើងចន្លោះ ពី ០,៧°C ទៅ ២,៧°C និងរហូតដល់ឆ្នាំ២០៩០ សីតុណ្ហភាពជាមធ្យមនឹងកើនឡើង ចន្លោះពី ១,៤°C ទៅ ៤,៣°c។

ជាក់ស្តែង ប្រជាពលរដ្ឋកម្ពុជាស្ថិតនៅក្នុងចំណោមអ្នកទទួលរងគ្រោះធ្ងន់ធ្ងរជាងគេពីការប្រែប្រួលអាកាសធាតុ ដោយក្នុងនោះពលរដ្ឋប្រមាណ៨០% រស់នៅជនបទបានទទួលរងគ្រោះពីបាតុភូតអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ ការកើនឡើងនូវការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ បានបង្កជាបច្ច័យអវិជ្ជមានដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។ តាមការព្យាករណ៍ ទឹកជំនន់ទំនងជានឹងបង្កការខាតបង់កាន់តែច្រើនឡើងដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់, ស្ពាន, អគារ, រោងចក្រ, ផ្ទះសម្បែង និងសាលារៀន ជាពិសេសបណ្តាលឱ្យសេវាកម្ម និងខ្សែចង្វាក់ផ្គត់ផ្គង់សំខាន់ៗមានភាពរអាក់រអួលទៀតផង។ ជាងនេះទៅទៀត បម្រែបម្រួលអាកាសធាតុត្រូវបានព្យាករណ៍ថានឹងបណ្តាលឱ្យទិន្នផលរបស់ដំណាំសំខាន់ៗ និងជលផលធ្លាក់ចុះ និងធ្វើឱ្យផលិតភាពនៃកត្តាផលិតកម្មនៅក្នុងវិស័យឧស្សាហកម្មថយចុះផងដែរ ដោយបង្កជាបញ្ហាប្រឈមដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ សីតុណ្ហភាពកាន់តែខ្ពស់ និងភ្លៀងធ្លាក់ខ្លាំងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពពលរដ្ឋកម្ពុជា ដែលបង្កឱ្យកើតមានឡើងនូវករណីជំងឺថ្មីគ្រោះថ្នាក់និងកាចសាហាវជាងមុន។[58]

[58] Julian Hilton, *ប្រព័ន្ធធារាសាស្ត្រខ្នាតតូចធន់នឹងការប្រែប្រួលអាកាសធាតុ,* (គម្រោងក្រសួងកសិកម្ម, ឧសភា ០១, ២០១៥)

# ជំពូកទី ៤

# ការវិភាគទិន្នន័យ និង

# បកស្រាយលទ្ធផល

# ជំពូកទី ៤

# ការវិភាគទិន្នន័យ និងបកស្រាយលទ្ធផល

## ៤.១. ការវិភាគទិន្នន័យ

នៅក្នុងការវិភាគទិន្នន័យ យើងបានប្រើប្រាស់ការវិភាគតាមបែប Multiple Regression Linear ដើម្បីសិក្សា និងវិភាគទៅលើទំនាក់ទំនងរវាងអថេរមួយចំនួន ដោយក្នុងនោះ យើងបានកំណត់នូវអថេរនៃទំហំផលិតផលក្នុងស្រុកសរុប (GDP) ជាអថេរអាស្រ័យ (Dependent Variable) និងអថេរពន្យល់ចំនួន ៣ ទៀតរួមមាន អថេរនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) អថេរនៃការនាំចូល (Export) និងអថេរនៃការនាំចេញ (Import) ដែលសុទ្ធសឹងជាអថេរឯករាជ្យ (Independent Variables) សម្រាប់ធ្វើការសិក្សា និងវិភាគពីតួនាទីនៃអថេរពន្យល់ទាំងបី ដែលមានឥទ្ធិពលមកលើទំហំផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជា។

សម្រាប់ការប្រើប្រាស់ទិន្នន័យ យើងបានជ្រើសរើសយកទិន្នន័យនៃអថេរនីមួយៗក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០២២ ដែលមានរយៈពេល ១៥ឆ្នាំ ដោយអថេរទាំងនោះមានឯកតាគិតជាពាន់លានដុល្លារសហរដ្ឋអាមេរិក។ ខាងក្រោមនោះជាតារាងទិន្នន័យ ដែលយកមកធ្វើការសិក្សា និងវិភាគ៖

**តារាងទី៤ ៖ បង្ហាញពីទំហំ GDP, FDI, Export និងImport ក្នុងប្រទេសកម្ពុជាពីឆ្នាំ ២០០៨ ដល់ឆ្នាំ ២០២២**

| Year | GDP | FDI | Export | Import |
|---|---|---|---|---|
| 2008 | 10.35 | 0.82 | 6.78 | 7.02 |
| 2009 | 10.40 | 0.93 | 5.12 | 5.82 |
| 2010 | 11.24 | 1.40 | 6.08 | 6.69 |
| 2011 | 12.83 | 1.54 | 6.94 | 7.63 |
| 2012 | 14.05 | 1.99 | 8.14 | 8.81 |
| 2013 | 15.23 | 2.07 | 9.50 | 10.30 |
| 2014 | 16.70 | 1.85 | 10.46 | 11.19 |
| 2015 | 18.05 | 1.82 | 11.14 | 11.94 |
| 2016 | 20.02 | 2.48 | 12.27 | 13.14 |
| 2017 | 22.18 | 2.79 | 13.46 | 14.22 |
| 2018 | 24.57 | 3.21 | 15.14 | 15.55 |
| 2019 | 27.09 | 3.66 | 16.55 | 16.92 |
| 2020 | 25.87 | 3.62 | 16.13 | 15.95 |
| 2021 | 26.96 | 3.48 | 18.00 | 16.81 |
| 2022 | 29.50 | 3.50 | 20.16 | 16.18 |

(ទិន្នន័យខាងលើគិតជាប៊ីលានដុល្លារសហរដ្ឋអាមេរិក)

ប្រភព៖ ធនាគារពិភពលោក World Bank

**ដែល** GDP (Gross Domestic Product) : ជាទំហំផលិតផលក្នុងស្រុកសរុប

FDI (Foreign Direct Investment) : ជាទំហំការវិនិយោគផ្ទាល់ពីបរទេស

X (Export) : ជាទំហំនៃការនាំចូល

M (Import) : ជាទំហំនៃការនាំចេញ

➢ ការវិភាគទិន្នន័យតាមរយៈ Regression ដោយប្រើប្រាស់ Excel (យោងតាមឧបសម្ព័ន្ធទី៣):

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.996993229 |
| R Square | 0.993995499 |
| Adjusted R Square | 0.992357907 |
| Standard Error | 0.581944957 |
| Observations | 15 |

តាមតារាងលទ្ធផលសង្ខេបខាងលើ មេគុណពហុទំនាក់ទំនង R = 0.997 ដោយនេះមានន័យថាទំហំផលិតផលក្នុងស្រុកសរុប (GDP) មានទំនាក់ទំនងលីនេអ៊ែរវិជ្ជមាន (Positive Linear Correlation) ជាមួយនឹងអថេរ FDI, Export និង Import។ រីឯមេគុណទំនាក់ទំនង $R^2$ = 0.994 ដែលមានន័យថាទំហំផលិតផលក្នុងស្រុកសរុប (GDP) មានភាពជាប់ពាក់ព័ន្ធគ្នាខ្លាំង និងអាចបកស្រាយបានទាំងស្រុងជាមួយអថេរទាំងបីផ្សេងទៀតរួមមានអថេរ FDI, Export និង Import។

- **សមីការរ៉ារ្យង់:**

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 3 | 616.6858341 | 205.5619 | 606.9863 | 1.70249E-12 |
| Residual | 11 | 3.725259268 | 0.33866 | | |
| Total | 14 | 620.4110933 | | | |

តាមរយៈតារាងវិភាគសមីការរ៉ារ្យង់ (ANOVA) យើងបានសមីការរ៉ារ្យង់: TSS = ESS + RSS (ដែល ESS = 616.68 ; RSS = 3.72) នោះ TSS = 620.40។ ចំណែកឯ ពិន្ទុ F( Fisher) = 606.98 ដែលនាំឱ្យគំរូវិភាគមានអំណះអំណាង និងអាចពន្យល់បានច្បាស់លាស់។

- **តារាងវិភាគប៉ារ៉ាម៉ែត្រព្យាករណ៍:**

| អថេរវិភាគ | Coefficients | Standard Error | t Stat | P-value | Lower 95% | Upper 95% |
|---|---|---|---|---|---|---|
| Intercept | 1.898 | 0.600 | 3.165 | 0.009 | 0.578 | 3.218 |
| FDI | 1.606 | 0.600 | 2.676 | 0.022 | 0.285 | 2.927 |
| Export | 0.847 | 0.142 | 5.948 | 0.000 | 0.533 | 1.160 |
| Import | 0.287 | 0.198 | 1.455 | 0.174 | -0.147 | 0.722 |

យោងតាមតាមលទ្ធផលនៃការវិភាគប៉ារ៉ាម៉ែត្រព្យាករណ៍ សមីការវិភាគមានទម្រង់ជា៖

$$\widehat{GDP} = 1.898 + 1.606\,FDI + 0.847\,X + 0.287\,M + e_i , i = \overrightarrow{1,15}$$

$$SE: \quad (0.600) \quad (0.600) \quad (0.142) \quad (0.198)$$

$$R^2 = 0.994\,;\ n = 15$$

## ៤.២. ការបកស្រាយលទ្ធផលនៃការវិភាគ

ឆ្លងតាមការវិភាគទិន្នន័យ និងសមីការវិភាគខាងលើ លទ្ធផលនៃការវិភាគអថេរពន្យល់នីមួយៗត្រូវបានបកស្រាយដូចតទៅ៖

- **មេគុណអថេរ FDI :**

ដោយផ្អែកតាមសមីការវិភាគខាងលើបានបង្ហាញឱ្យឃើញថា អថេរនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) មានមេគុណវិជ្ជមានស្មើនឹង ១.៦០៦ ដែលនេះមានន័យថា នៅពេលការវិនិយោគផ្ទាល់ពីបរទេសកើនបាន ១% នោះទំហំផលិតផលក្នុងស្រុកសរុបកើនឡើង ១.៦០៦% ដោយមានកំណើនប្រហែលជាទ្វេដង។ ក្នុងន័យនេះ ទំនាក់ទំនងរវាងអថេរទាំងពីរពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញនូវការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដោយកាលណាមានការវិនិយោគផ្ទាល់ពីបរទេសកាន់តែច្រើននៅក្នុងប្រទេសកម្ពុជា វានឹងជួយបង្កើននូវទំហំផលិតផលក្នុងស្រុកសរុបកាន់តែច្រើនបន្ថែមទៀតតាមរយៈការបង្កើនផលិតភាពការងារ និងការពង្រីកសមត្ថភាពផលិតកម្ម។ ជាមួយនឹងការបកស្រាយលទ្ធផលនៃការវិភាគទិន្នន័យរវាងអថេរទាំងពីរនេះ ក៏មានទ្រឹស្តី និងគំរូសេដ្ឋកិច្ចមួយចំនួនបានលើកឡើង និងបង្ហាញពីគោលគំនិតស្របគ្នាផងដែរក្នុងទំនាក់ទំនងរវាងការវិនិយោគផ្ទាល់ពីបរទេស និងទំហំផលិតផលក្នុងស្រុកសរុប ដែលវាមានមូលដ្ឋានគំនិត និងជាអំណះអំណាងគាំទ្របន្ថែមលើការវិភាគទិន្នន័យ ដោយក្នុងនោះមានទ្រឹស្តីកំណើនរបស់ទស្សន: Neo-Classic, ទ្រឹស្តីកំណើន Endogenous, គំរូ Heckscher-Ohlin, ទ្រឹស្តី Investment Development Path (IDP) និងគំរូ Electric Paradigm (OLI) របស់លោក John Dunning ដែលសុទ្ធសឹងបង្ហាញពីតួនាទីដ៏សំខាន់នៃការវិនិយោគផ្ទាល់ពីបរទេស (FDI) ក្នុងការបង្កើនប្រភពដើមទុន មូលធន និងទំហំទីផ្សារ ជាពិសេសណែនាំ ផ្ទេរ និងទទួលបាន

បច្ចេកវិទ្យាថ្មីៗ ព្រមទាំងផ្ទេរចំណេះ ជំនាញដល់កម្មករក្នុងការបង្កើននូវផលិតការងារ សមត្ថភាពផលិតកម្ម និងផលិតភាពសម្រាប់ជម្រុញឱ្យមានការកើនឡើងនូវទំហំផលិតផលក្នុងស្រុកសរុប និងផ្សារភ្ជាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច ដែលនាំឱ្យទំហំសេដ្ឋកិច្ចមានកំណើនខ្ពស់។[59] សរុបជារួម លទ្ធផលនៃការបកស្រាយអថេរទាំងពីរតាមរយៈការវិភាគទិន្នន័យពិតជាមានភាពត្រឹមត្រូវ មានភាពពាក់ព័ន្ធគ្នាខ្លាំង និងអាចបកស្រាយបានយ៉ាងច្បាស់លាស់ ដោយមានគោលគំនិតស្របគ្នាទៅនឹងទ្រឹស្តី និងគំរូសេដ្ឋកិច្ចមួយចំនួន។

➢ **មេគុណអថេរ Export :**

យោងតាមសមីការវិភាគ អថេរនៃការនាំចេញទំនិញ និងសេវាកម្ម (Export) ក៏មានមេគុណវិជ្ជមានស្មើនឹង 0.847 ផងដែរ ដោយនេះមានន័យថា កាលណាការនាំចេញទំនិញ និងសេវាកម្ម កើនបាន ១% នោះនឹងនាំឱ្យផលិតផលក្នុងស្រុកសរុបកើនឡើង ០.៨៤៧%។ តាមរយៈនេះ អថេរនៃការនាំចេញ (Export) ជាកត្តាមួយផ្សេងទៀត ដែលជះឥទ្ធិពលវិជ្ជមានដល់ទំហំផលិតផលក្នុងស្រុកសរុប (GDP)។ ក្នុងន័យនេះ នៅពេលកម្ពុជាមានការនាំចេញទំនិញ និងសេវាកម្មកាន់តែច្រើនទៅកាន់ទីផ្សារអន្តរជាតិ នោះវានឹងរួមចំណែកជួយជម្រុញ និងបង្កើននូវទំហំផលិតផលក្នុងស្រុកសរុបបន្ថែមទៀតតាមរយៈការបង្កើនការវិនិយោគ ការបង្កើតឱកាសការងារ និងជម្រុញផលិតកម្មក្នុងស្រុកឱ្យកាន់តែមានប្រសិទ្ធិភាព។ ក្រៅពីការបកស្រាយលទ្ធផលតាមរយៈការវិភាគទិន្នន័យ ទំនាក់ទំនងរវាង GDP និង Export ក៏មានសេដ្ឋវិទូមួយចំនួនបានលើកឡើងពីភាពពាក់ព័ន្ធរវាងអថេរទាំងពីរ ដែលមានគោលជំហ និងអំណះអំណាងស្របគ្នាក្នុងការគាំទ្របន្ថែមទៅលើលទ្ធផលនៃការវិភាគទិន្នន័យ។ តួយ៉ាងមានទ្រឹស្តី និងគំរូមួយចំនួន ដែលបានពន្យល់ពីទំនាក់ទំនងរវាងផលិតផលក្នុងស្រុកសរុប និងការនាំចេញ ដោយក្នុងនោះមានដូចជា ទ្រឹស្តីពាណិជ្ជកម្មបុរាណរបស់លោក Adam Smith និងលោក David Ricardo ផ្តោតទៅលើអត្ថប្រយោជន៍ដាច់ខាត (Absolute Advantage) និងអត្ថប្រយោជន៍ប្រៀបធៀប (Comparative-Advantage) តាមរយៈការធ្វើឯកទេសកម្មក្នុងការផលិតប្រកបដោយប្រសិទ្ធភាពខ្ពស់ដើម្បីទទួលបានទិន្នផលអតិបរមា និងកាត់បន្ថយថ្លៃដើមផលិតកម្ម ដោយវានឹងជម្រុញដល់ផលិតកម្មក្នុងស្រុក និងទទួលបានផលតបស្នងពីការនាំចេញជាអតិបរមា។ ស្រដៀងគ្នានេះ បើតាមម៉ូដែល Heckscher-Ohlin ក៏បានបង្ហាញពីការនាំចេញអាចបង្កើនផលិតផលក្នុងស្រុកសរុបដោយទាញយកអត្ថប្រយោជន៍ប្រៀបធៀប និងការបែងចែកធនធានក្នុងការផលិតទំនិញ និងសេវាកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់។ រីឯទ្រឹស្តី កំណើន Export-Led ក៏បានបកស្រាយដោយផ្តោតលើការបង្កើនការនាំចេញ ដែលវានឹងនាំឱ្យកើនឡើងប្រាក់នូវប្រាក់ចំណូលជាតិសរុប និងនាំឱ្យមាន

[59] G. Djokoto, *"Level of income and the Investment Development Path Theory,"* (SageJornals, Nov 23,2021)
Vintila Denisia, *"FDI Theories," December, 2020* https://ejist.ro/files/pdf/357.pdf

វិហូរបច្ចេកវិទ្យា ចំណេះជំនាញចូលមកក្នុងប្រទេសរបស់ខ្លួន។[60] ជារួមគោលគំនិតក្នុងទ្រឹស្តីខាងលើទាំងអស់នេះនឹងនាំឱ្យមានការកើនឡើងនូវទំហំ GDP ដែលវាមានដំណើរស្របទៅតាមលទ្ធផលនៃការវិភាគទិន្នន័យ។

➢ **មេគុណអថេរ Import :**

តាមរយៈសមីការវិភាគបានបង្ហាញឱ្យឃើញថា អថេរនៃការនាំចូលទំនិញ និងសេវាកម្ម (Import) មានមេគុណវិជ្ជមានស្មើនឹង ០.២៨៧ ដោយនេះមានន័យថា កាលណាការនាំចូលទំនិញ និងសេវាកម្មមានកំណើន ១% នោះធ្វើឱ្យផលិតផលក្នុងស្រុកសរុបកើនឡើង ០.២៨៧ %។ បើប្រៀបធៀបរវាងការនាំចូល និងការនាំចេញ អថេរនៃការនាំចូលរួមចំណែកជួយដល់កំណើនផលិតផលក្នុងស្រុកសរុបតិចជាងការនាំចេញ ព្រោះការនាំចូលទំនិញ និងសេវាកម្មពីបរទេសនឹងធ្វើឱ្យមានវិហូរសាច់ប្រាក់ទៅកាន់ក្រៅប្រទេស ដែលនាំឱ្យបាត់បង់នូវចំណូលក្នុងស្រុកមួយផ្នែកតូច ក៏ប៉ុន្តែ វាមិនមានន័យថា ការនាំចូលធ្វើឱ្យមានការធ្លាក់ចុះនៃទំហំផលិតផលក្នុងស្រុកសរុបនោះទេ។ ជាក់ស្តែង បើយោងតាមក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចបើកចំហ ការនាំចូលមូលធនមួយចំនួនដូចជាវត្ថុធាតុដើម គ្រឿងយន្ត ម៉ាស៊ីន និងបច្ចេកវិទ្យាត្រូវបានប្រើប្រាស់សម្រាប់បង្កើននូវផលិតភាពកត្តាផលិតកម្មដែលវាអាចជួយដល់ការពង្រឹង និងពង្រីកសមត្ថភាពផលិតភាពកាន់តែខ្ពស់ជាងមុន ដោយនឹងបង្កើនដល់ទំហំផលិតផលក្នុងស្រុកសរុប និងកសាងភាពធន់នៃវិស័យឧស្សាហកម្មក្នុងរយៈពេលវែង។[61] ជាងនេះទៅទៀត តាមរយៈទ្រឹស្តីពាណិជ្ជកម្មរបស់លោក David Ricardo បានបង្ហាញថាការនាំចូលអាចបំពេញនូវតម្រូវការក្នុងស្រុកជំនួសឱ្យផលិតផលខ្លះ ខ្លួនមិនមានឯកទេសកម្មលើការផលិតនោះទេ ដែលនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចទិញទំនិញយ៉ាងទូលំទូលាយនិងសម្បូរបែបក្នុងតម្លៃទាបជាងការផលិតដោយខ្លួនឯង ដើម្បីទាញយកផលចំណេញពីចំណាយឱកាស និងការធ្វើពាណិជ្ជកម្ម។ ស្របពេលជាមួយការមិនផលិតនូវទំនិញដែលខ្លួនមិនមានឯកទេសកម្ម ប្រទេសនេះអាចផ្តោតខ្លាំងទៅលើផលិតផលណាដែលខ្លួនមានឯកទេសកម្មដើម្បីនាំចេញទទួលបានប្រាក់ចំណេញអតិបរមា និងជួយជម្រុញដល់កំណើនសេដ្ឋកិច្ចជាតិ។[62] ដូចនេះ តាមរយៈការបង្ហាញពីទស្សនៈផ្សេងៗគ្នាសម្រាប់អថេរនៃការនាំចូល វាបានបកស្រាយឱ្យឃើញថាការនាំចូលនៅតែមានឥទ្ធិពលវិជ្ជមានដល់ទំហំផលិតផលក្នុងស្រុកសរុប ព្រោះការនាំចូលនូវទំនិញមួយចំនួននឹងជួយពង្រឹងដល់សមត្ថភាពផលិតកម្មដែលនាំឱ្យបង្កើននូវទំហំផលិតផលក្នុងស្រុកសរុប និងទាញយកផលចំណេញជាអតិបរមាពីការធ្វើពាណិជ្ជកម្មជាពិសេសទទួលបានចំណាយឱកាសទាប ដោយនេះវានឹងរុញច្រានឱ្យមានកំណើនសេដ្ឋកិច្ច។

សរុបជារួម ឆ្លងកាត់តាមរយៈលទ្ធផលនៃការវិភាគទិន្នន័យ និងអំណះអំណាងនៃទ្រឹស្តី និងគំរូសេដ្ឋកិច្ចមួយចំនួន អថេរនៃការវិនិយោគផ្ទាល់ពីបរទេស (FDI), អថេរនៃការនាំចេញ (Export) និងអថេរនៃការនាំចូល

60 *"Export Led Growth," StudySmarter, n.d*
*https://www.studysmarter.co.uk/explanations/macroeconomics/international-economics/export-led-growth*

61 Mankiw, *Macroeconomics* (Worth Publishers: 10th ed., 2019)

62 Krugman, Obstfeld, M., and Melitz, M. J, *International Economics: Theory and Policy* (Pearson: 11th ed., 2018)

(Import) គឺសុទ្ធតែមានទំនាក់ទំនង និងមានភាពពាក់ព័ន្ធគ្នាខ្លាំងជាមួយនឹងអថេរផលិតផលក្នុងស្រុកសរុប (GDP) ជាពិសេសអាចបកស្រាយបានយ៉ាងក្បោះក្បាយ ដែលអថេរទាំងបីពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញដល់កំណើនផលិតផលក្នុងស្រុកសរុប និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

## ៤.៣. ការព្យាករណ៍ទិន្នន័យលើចក្ខុវិស័យឆ្នាំ ២០៣០

កម្ពុជា បានសម្រេចការផ្លាស់ប្តូរឆ្នាំគោលគណនេយ្យជាតិ ឬឆ្នាំគោល ផ.ស.ស. ពីឆ្នាំ២០០០ មកឆ្នាំ ២០១៤ ដើម្បីធ្វើបច្ចុប្បន្នភាពកំណើនសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែមានភាពប្រាកដនិយមខ្ពស់ និងឆ្លុះបញ្ចាំងតថភាពជាក់ស្តែង (យោងតាមឧបសម្ព័ន្ធទី៥)។ ការណ៍នេះ ធ្វើឱ្យទំហំសេដ្ឋកិច្ចកើនឡើងប្រមាណ ៣២% បើធៀបទៅនឹងស៊េរីទិន្នន័យឆ្នាំគោលចាស់ ។ ក្នុងនោះ ចំណូលសម្រាប់មនុស្សម្នាក់ (GDP per capita) ក្នុងឆ្នាំ ២០២២ បានកើនឡើងដល់ប្រមាណ ២ ៣៨៥ ដុល្លារអាមេរិក បើធៀបទៅនឹង ១ ៧៨៤ ដុល្លារអាមេរិក។ ទោះជាយ៉ាងនេះក្តី តួលេខ GNI per capita ពុំទាន់ត្រូវបានគណនានិងប្រើប្រាស់ជាផ្លូវការនៅឡើយ។ ក្នុងន័យនេះ ការសិក្សានេះប្រើប្រាស់ GDP per capita វិញ។

តាមគោលការណ៍របស់ធនាគារពិភពលោកឆ្នាំ ២០២២ ប្រទេសមួយអាចក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់លុះត្រាតែមានប្រាក់ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់ចាប់ពី ៤ ២៥៦ ដុល្លារ ហើយ បើគិតទៅតាម GDP per capita ឆ្នាំគោលថ្មីត្រឹមឆ្នាំ ២០២២ ខាងលើ កម្ពុជានៅខ្វះ ១ ៩១១ ដុល្លារអាមេរិកទៀត ទើបគ្រប់លក្ខខណ្ឌរបស់ WB។ មានន័យថារយៈពេល ៨ ឆ្នាំ គិតចាប់ពីឆ្នាំ ២០២២ កម្ពុជាត្រូវមានកំណើនប្រាក់ចំណូលជាតិសរុបក្នុងពលរដ្ឋម្នាក់ជាមធ្យម ២៣៩ ដុល្លារអាមេរិកក្នុងមួយឆ្នាំ ឬមានកំណើនជាមធ្យមប្រមាណ ១0% ក្នុងមួយឆ្នាំទើបអាចសម្រេចបានចក្ខុវិស័យខាងលើ។

## ៤.៤. ដំណោះស្រាយ

ទោះបីជាតួលេខនៃអត្រាកំណើនខាងលើមើលទៅមានសភាពខ្ពស់ ដែលហាក់មិនអាចសម្រេចបានសម្រាប់សេដ្ឋកិច្ចកម្ពុជាលើមាគ៌ាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់យ៉ាងណាក្តី កម្ពុជាក៏អាចសម្លឹងមើល និងចាប់យកដំណោះស្រាយ និងវិធានការមួយចំនួនដើម្បីកសាងមូលដ្ឋានសេដ្ឋកិច្ច និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្ទៃក្នុងរបស់ខ្លួនឱ្យកាន់តែរឹងមាំក្នុងការសម្រេចមហិច្ឆតាក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅពេលក្រោយតាមរយៈការធ្វើកំណែទម្រង់ និងបង្កើនប្រសិទ្ធភាពលើកត្តាមួយចំនួន។ ក្នុងនោះ មានការដាក់ចេញនូវដំណោះស្រាយ និងវិធានការគោលនយោបាយមួយចំនួនក្នុងការឆ្លើយតបទៅនឹងបញ្ហា ដែលមានដូចជា៖

❖ **ការធ្វើពិពិធកម្មសេដ្ឋកិច្ច**

កម្ពុជាមានជម្រើសច្រើនសម្រាប់ដោះស្រាយបញ្ហាខ្វះពិពិធកម្មក្នុងសេដ្ឋកិច្ច និង សម្រាប់កសាងឡើងវិញឱ្យកាន់តែប្រសើរជាងមុន។ យ៉ាងណាមិញ ការធ្វើពិពិធកម្មសេដ្ឋកិច្ច គឺជាគោលនយោបាយដ៏សំខាន់មួយនៅក្នុង "យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ » និង «វិធានការគន្លឹះរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា» ក៏បានគូសបញ្ជាក់ពីការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង ដែលក្នុងនេះ រាជរដ្ឋាភិបាលបន្តផ្តោតលើកិច្ចការអាទិភាព ចំនួន ៥ គឺ ៖ (១), ការអភិវឌ្ឍ វិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច, (២). ការលើកកម្ពស់ការតភ្ជាប់ និង ការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និង ឡូជីស្ទីក, វិស័យថាមពល វិស័យទឹកស្អាត និង វិស័យឌីជីថល, (៣). ការកែលម្អបរិយាកាស ធុរកិច្ច និង ការវិនិយោគ, (៤). ការពង្រឹង ប្រសិទ្ធភាព និង ភាពទាក់ទាញ នៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូល នូវ សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម, និង តំបន់ពាណិជ្ជកម្មសេរី (Free-Trade Zone), (៥). ការធ្វើទំនើបកម្ម យន្តការហិរញ្ញប្បទាន និង ផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រ ដល់ការវិនិយោគ។[63]

បើតាមការចុះផ្សាយរបស់ធនាគារពិភពលោក ៣១ មករា ២០២២ កម្ពុជាចាំបាច់ត្រូវពិនិត្យទៅលើការធ្វើពិពិធកម្មមួយចំនួន ដោយក្នុងនោះរួមមាន៖ ការវិនិយោគទៅលើធនធានមនុស្ស, ការធ្វើឱ្យការបែងចែកធនធានឱ្យកាន់តែមានប្រសិទ្ធផលតាមរយៈការកែលម្អសមត្ថភាពស្ថាប័នទីផ្សារ, និងការបង្កើនការគ្រប់គ្រងការវិនិយោគសាធារណៈទាំងអស់នេះស្ថិតក្នុងចំណោមជម្រើស ដែលអាចជួយជម្រុញផលិតភាពក្នុងសេដ្ឋកិច្ច, ការបង្កើនការរួមចំណែករបស់ខ្លួនទៅក្នុងខ្សែច្រវាក់តម្លៃសាកល, ការបង្កើតតម្លៃបន្ថែមក្នុងវិស័យកសិកម្ម, និងការពង្រីកភាពប្រកួតប្រជែងនៅក្នុងវិស័យសេវាកម្ម ក៏នឹងអាចជួយធ្វើឱ្យការនាំចេញកាន់តែមានភាពសម្បូរបែបផងដែរ ជាពិសេសការវិនិយោគក្នុងស្រុកនឹងទទួលបានប្រយោជន៍ថែមទៀត ពីការលើកកម្ពស់ការសន្សំប្រាក់ក្នុងស្រុកឱ្យមានកម្រិតកាន់តែខ្ពស់, ការលើកទឹកចិត្តដល់ការវិនិយោគបរទេសនៅតាមវិស័យមានផលិតភាពខ្លាំងជាងគេ និងការពង្រីកលទ្ធភាពក្នុងការស្វែងរកបានហិរញ្ញវត្ថុសម្រាប់យកមកធ្វើអាជីវកម្ម។ កម្ពុជាក៏គួរគិតគូរការ

[63] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ និងវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា,* CMF, Aug 24, 2023 https://pressocm.gov.kh/archives/83956

ដាក់ចេញទិសដៅពាណិជ្ជកម្ម និងការវិនិយោគ ដោយកសាងរៀបចំនូវតំបន់សេដ្ឋកិច្ចពិសេសតាមរូបមន្តដែលយើងមានស្រាប់។[64]

### ❖ ការកាត់បន្ថយថ្លៃដើមធុរកិច្ច

ក្នុងនាមជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣នេះ បានបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ ក្នុងការបន្តប្រឹងប្រែងកែលម្អបរិយាកាសធុរកិច្ច និងវិនិយោគ តាមរយៈការកាត់បន្ថយការចំណាយ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់វិនិយោគិន មកពីគ្រប់មជ្ឈដ្ឋាន។ ក្នុងនោះដែរអ្នកជំនាញសេដ្ឋកិច្ចរបស់ធនាគារពិភពលោក (World Bank) ផ្តល់អនុសាសន៍គន្លឹះដើម្បីជួយដល់ការវិនិយោគរបស់វិស័យឯកជន ដោយកម្ពុជាចាំបាច់ត្រូវពង្រឹងភាពព្យាករណ៍ បានរបស់បរិស្ថានបទប្បញ្ញត្តិ និងពង្រីកលទ្ធភាពរកបានធនធានហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs)។

ដើម្បីពង្រឹងផលិតកម្មក្នុងស្រុក និងជៀសផុតពីសេដ្ឋកិច្ចដែលមានរចនាសម្ព័ន្ធចំណាយតម្លៃខ្ពស់នោះ ប្រទេសកម្ពុជាគួរតែលើកបញ្ហានេះជាសកម្មភាពអាទិភាពដ៏សំខាន់មួយ សម្រាប់ការអភិវឌ្ឍស៊ីជម្រៅក្នុងវិស័យសេដ្ឋកិច្ច និងសង្គមក្នុងពេលអនាគត។ ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ថាមពលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការផ្លាស់ប្តូរឆ្ពោះទៅរកឧស្សាហកម្មផលិត និងកែច្នៃកសិផលដែលមានតម្លៃបន្ថែមខ្ពស់។ វិស័យថាមពលត្រូវការការវិនិយោគខ្នាតធំថែមទៀត ឆ្លើយតបទៅនឹងការកើនឡើង នៃតម្រូវការអគ្គិសនី (តាមការព្យាករតម្រូវការអគ្គិសនីនឹងកើនឡើង ៤ដង ពី ១២ ៤០០ហ្គីហ្កាវ៉ាត់ម៉ោង (GWh) នៅឆ្នាំ ២០២០ ទៅដល់ ៥៤ ៦០០ហ្គីហ្កាវ៉ាត់ម៉ោង នៅឆ្នាំ២០៤០) ជាពិសេសសម្រេចឱ្យបានគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណង បង្កើនចំណែកថាមពលកកើតឡើងវិញរបស់ខ្លួនឱ្យបានយ៉ាងហោចណាស់ឱ្យបាន ៧០ភាគរយត្រឹមឆ្នាំ ២០៣០ ដោយ រួមចំណែកដល់គោលដៅបរិស្ថាននិងកំណើនសេដ្ឋកិច្ច ដោយផ្តោតលើប្រសិទ្ធភាពថាមពល។[65] ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ កម្ពុជាបានចាប់ផ្តើមបញ្ចុះតម្លៃអគ្គិសនីជំហានដំបូងចំនួន២សេនក្នុងមួយគីឡូវ៉ាត់ម៉ោង សម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ចាប់ពីឆ្នាំ ២០១៩ តទៅ និងសិក្សាលទ្ធភាពបញ្ចុះថ្លៃជាបន្តបន្ទាប់ទៀត។ ការវិនិយោគក៏ត្រូវការចាំបាច់ផងដែរ ដើម្បីកែលម្អឱ្យប្រសើរឡើងនូវសេវាជាមូលដ្ឋានក្នុងទីក្រុង មានដូចជា ប្រព័ន្ធទុយោទឹកស្អាត, អនាម័យ, ការគ្រប់គ្រងសំណល់រឹង, ទូរគមនាគមន៍ និងការដឹកជញ្ជូន និងការពង្រឹងផែនការរៀបចំក្រុង។ ការប្រកួតប្រជែងកាន់តែច្រើននឹងជម្រុញការកាត់បន្ថយការចំណាយ និងលើកកម្ពស់នវានុវត្តន៍ និងកំណើនផលិតភាព ដោយបង្វែរទិសនៃចំណែកទីផ្សារធុរកិច្ច ឆ្ពោះទៅរកផលិតករដែលមានប្រសិទ្ធភាពខ្ពស់ជាង ហើយក៏ជួយលើកទឹកចិត្ត ក្រុមហ៊ុនឱ្យកាន់តែមានផលិតភាពឡើងដែរ។

---

[64] លក្ខិណា, *"ធនាគារពិភពលោកផ្តល់អនុសាសន៍ដល់កម្ពុជាក្នុងការជម្រុញសេដ្ឋកិច្ចរបស់ខ្លួនឱ្យងើបឡើងវិញ,"* Cambodia Financial Times, មករា ៣១, ២០២២, https://cambodiafinancialtimes.com/archives/21827

[65] Sebastian Eckardt and Faya Hayati, *Cambodia 2030: Economic slowdown offers opportunity to speed up reforms*, Dec 13, 2023

ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងឡជីស្ទីករបស់កម្ពុជា គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការបង្កើនផលិតភាព និងសមត្ថភាពប្រកួតប្រជែងអន្តរជាតិ។ កម្ពុជានៅតែមានការខ្វះច្រើននូវហិរញ្ញប្បទានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគជាចាំបាច់ ដែលនឹងធ្វើឱ្យប្រសើរឡើងនូវសកម្មភាពពាណិជ្ជកម្ម តាមច្រករបៀងកើត-លិច ឆ្លងកាត់ប្រទេសថៃ កម្ពុជា និងវៀតណាម បន្ថែមពីលើផ្លូវច្រករបៀងតែមួយគត់ ដែលតភ្ជាប់ប្រទេសកម្ពុជា ជាមួយប្រទេសឡាវ និងការតភ្ជាប់ផ្លូវទឹកផ្ទៃក្នុងប្រទេសជាមួយវៀតណាម និងប្រតិបត្តិការផ្លូវដែក និងបណ្ដាញភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ជាមួយប្រទេសថៃ និងកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតត្រូវតែត្រូវបានធ្វើឡើងដើម្បីកាត់បន្ថយថ្លៃដឹកជញ្ជូន និងដឹកជញ្ជូនដោយបង្កើនការតាមដានត្រួតពិនិត្យប្រសិទ្ធភាពនៃច្រកទ្វារពាណិជ្ជកម្មសំខាន់ៗ ដូចជាកំពង់ផែ និងច្រកព្រំដែន។

យ៉ាងណាមិញ គម្រោងព្រែកជីកហ្វូណនតេជោនឹងក្លាយមធ្យោបាយដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមនានាលើវិស័យដឹកជញ្ជូនរបស់កម្ពុជាដោយចូលរួមកាត់បន្ថយរយៈពេល ចម្ងាយ និងតម្លៃនៃការដឹកជញ្ជូននាពេលបច្ចុប្បន្ន ការបង្កើតតំបន់ពាណិជ្ជកម្ម និង មជ្ឈមណ្ឌលភស្តុភារកម្មការអភិវឌ្ឍផែរណបថ្មីៗជាច្រើន។[66]

❖ **ការសម្រួលបរិយាកាសធុរកិច្ច**

**សម្ដេចធិបតី** ក៏បានគូសរំលេចអំពីគោលនយោបាយ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតនូវក្របខ័ណ្ឌសម្រាប់វិនិយោគិនបរទេស ដែលរួមមានដូចជាៈ ការដាក់ចេញនូវច្បាប់ស្ដីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លិខិតបទដ្ឋានគតិយុត្ត និងវិធានការចាំបាច់នានា ជាមួយនឹងកញ្ចប់វិធានការលើកទឹកចិត្តដែលបង្កើតនូវបរិយាកាសវិនិយោគ ដែលមានលក្ខណៈអំណោយផល អាចប៉ាន់ប្រមាណបាន និងសម្បូរបែប។ ក្នុងនោះដែរ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការងារមួយចំនួនរួមមាន (១.) ការកាត់បន្ថយកម្រៃបំពេញបែបបទគយ (Customs Processing Fee), (២.) ការសម្រួលលើការដឹកជញ្ជូនឆ្លងកាត់ និងការអនុវត្តនីតិវិធីគយនៅមាត់ច្រកព្រំដែន, និង (៣.) ការធ្វើសាមញ្ញកម្មនីតិវិធីគយក្នុងការស្នើសុំជាធុរជនល្អបំផុត (Best Trader) ឬប្រតិបត្តិករសេដ្ឋកិច្ចទទួលបានការអនុញ្ញាត (AEO) ជាដើម។[67]

យ៉ាងណាមិញ ការដាក់ឱ្យប្រើប្រាស់នូវការបំពេញបែបបទគយមុនពេលទំនិញមកដល់ និងជាពិសេសប្រព័ន្ធបញ្ជរតែមួយជាតិគឺជាការរួមចំណែកមួយដ៏សំខាន់ក្នុងការកែលម្អបរិយាកាសធុរកិច្ច និងការជម្រុញសកម្មភាពពាណិជ្ជកម្ម និងលើកកម្ពស់កំណើនសេដ្ឋកិច្ចនៅកម្ពុជា មានតួនាទីសំខាន់ក្នុងការចូលរួមចំណែកលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្មអន្តរជាតិ ស្របតាមយុទ្ធសាស្ត្រ និង គោលនយោបាយរបស់រាជរដ្ឋាភិបាលតាមរយៈការផ្ដល់ និងជាការបង្វិតសេវាសាធារណៈទៅជិតអ្នកប្រើប្រាស់តាមរយៈការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម

[66] ក្រសួងព័ត៌មាន, "*គម្រោងព្រែកជីកហ្វូណនតេជោនឹងផ្ដល់អត្ថប្រយោជន៍ជាច្រើនដល់ប្រទេសកម្ពុជា ជាពិសេសវិស័យដឹកជញ្ជូន អចលនទ្រព្យ និងការវិនិយោគផ្សេងៗ,*" វិទ្យុជាតិកម្ពុជា, កក្កដា ១៤,២០២៣https://www.information.gov.kh/articles/109268

[67] អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, "*កិច្ចប្រជុំបន្តការភាពជាដៃគូគយ-ផ្នែកឯកជនលើកទី៩,*" Facebook, Dec 22, 2022 https://www.facebook.com/share/p/AauKw4fkJnjKUDEg/

និង ថ្នាលបច្ចេកវិទ្យា ក្នុងការផ្តល់សេវាសាធារណៈ ដើម្បីសម្រួលនីតិវិធី កាត់បន្ថយពេល និង ចំណាយពាក់ព័ន្ធផ្សេងៗ។ សមិទ្ធផលនេះ ក៏ជាការបន្តជម្រុញការកែទម្រង់ស៊ីជម្រៅ និង ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល និងបង្កើតការប្រកួតប្រជែងដោយស្មើភាពក្នុងការធ្វើធុរកិច្ច និងការវិនិយោគ និងដើម្បីកាត់បន្ថយបន្ទុកចំណាយលើការបំពេញតាមកាតព្វកិច្ច និងនីតិវិធីសារពើពន្ធ។[68]

ប្រព័ន្ធបញ្ជរតែមួយជាតិរបស់កម្ពុជា ដែលមានការតភ្ជាប់ទៅកាន់ប្រព័ន្ធបញ្ជរតែមួយអាស៊ាន ដើម្បីផ្លាស់ប្តូរទិន្នន័យជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន នឹងកែសម្រួលនីតិវិធីនៃការស្នើសុំអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត, វិញ្ញាបនបត្រ និង ឯកសារតម្រូវនានា ពាក់ព័ន្ធនឹងការនាំចេញ-នាំចូលទំនិញ។ ប្រព័ន្ធនេះ រួមជាមួយនឹងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា) នឹងជួយសម្រួលដល់ ការធ្វើពាណិជ្ជកម្មនៅកម្ពុជា ដោយផ្លាស់ប្តូររបៀបរបបការងារពីការពឹងផ្អែកលើក្រដាស (Paper-based)ទៅជាការមិនប្រើក្រដាស (Paperless) ។ ក្នុងន័យនេះ ប្រព័ន្ធបញ្ជរតែមួយជាតិ នឹងក្លាយជាតួអង្គដ៏សំខាន់មួយនៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ដែលធ្វើឱ្យកិច្ចសម្រួលពាណិជ្ជកម្មរបស់យើងកាន់តែមានប្រសិទ្ធភាព និងមានលទ្ធភាពតភ្ជាប់ទៅនឹងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ចផ្សេងទៀតក្នុងតំបន់ និងលើសកលលោក។

ម្យ៉ាងវិញទៀត ដើម្បីជួយដល់វិស័យទេសចរណ៍ ការកាត់បន្ថយថ្លៃដើម និងថ្លៃសេវានានា (ដូចជាទិដ្ឋាការ ការស្នាក់នៅ អាហារ ថ្លៃដឹកជញ្ជូន និងថ្លៃសំបុត្រចូល) រួមទាំងការលុបបំបាត់ថ្លៃសេវាក្រៅផ្លូវការផង នឹងជួយទាក់ទាញភ្ញៀវអន្តរជាតិឱ្យមកកម្ពុជាកាន់តែច្រើនឡើង។

❖ **បង្កើនសមត្ថភាពកម្លាំងពលកម្មបច្ចុប្បន្ន និងអនាគត**

ដោយសារកម្ពុជាប្រាថ្នាចង់ក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ការផ្តល់អាទិភាពដល់ការអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការអប់រំពិតជាមានសារៈសំខាន់។ ចំណេះដឹងមូលដ្ឋានដ៏រឹងមាំជម្រុញដល់ការយល់ដឹងកម្រិតខ្ពស់ បច្ចេកទេស និងជំនាញខាងអារម្មណ៍សង្គមនៅពេលអនាគតរបស់កុមារ។ ជំនាញទាំងនេះមានសារៈសំខាន់សម្រាប់ការជម្រុញសេដ្ឋកិច្ចដែលជម្រុញដោយបច្ចេកវិទ្យា និងនវានុវត្តន៍ លើកកម្ពស់ផលិតភាពកម្លាំងពលកម្ម និងអាចឱ្យប្រទេសកម្ពុជាផ្លាស់ប្តូរដោយជោគជ័យទៅកាន់ឋានៈដែលមានប្រាក់ចំណូលខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ការសម្រេចបាននូវគោលដៅនេះនឹងតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយបញ្ហាប្រឈមកង្វះជំនាញដែលកើតមាននៅក្នុងប្រព័ន្ធអប់រំតាមរយៈការៈ

- រៀបចំកុមារឱ្យបានរៀនសូត្រ ដោយជម្រុញការចុះឈ្មោះចូលរៀនក្នុងការអប់រំដល់កុមារតូច
- ធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានសាលាបឋមសិក្សាដោយសមធម៌
- ផ្តល់ការបណ្តុះបណ្តាល និងលើកទឹកចិត្តគ្រូបង្រៀន
- កែលម្អអភិបាលកិច្ចសាលា

[68] រាជរដ្ឋាភិបាលកម្ពុជា, *"ប្រព័ន្ធបញ្ជរតែមួយជាតិជួយឱ្យចំណេញពេល កាត់បន្ថយចំណាយ និងមិនចាំបាច់ត្រូវរត់ការពីស្ថាប័នមួយទៅស្ថាប័នមួយទៀតទេ,"* Press OCM, ឧសភា ០៧,២០២៤ https://pressocm.gov.kh/archives/96274

- បង្កើនអត្រាសិស្សបញ្ចប់ថ្នាក់មធ្យមសិក្សា
- ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ពង្រឹងភាពចល័តនៃកម្លាំងពលកម្ម និងការផ្គូផ្គងជាមួយការងារ ដោយពង្រឹងប្រព័ន្ធផ្តល់ព័ត៌មានតម្រូវការ និងការផ្គត់ផ្គង់ទីផ្សារការងារ

ត្រង់នេះឆ្លុះបញ្ចាំងអំពីផលជះអវិជ្ជមានទៅលើឱកាសសម្រាប់ក្មេងកម្ពុជា ក្នុងការចូលរួម និងរួមចំណែកដល់វិបុលភាពរបស់ប្រទេសទៅថ្ងៃអនាគត។ ការបង្កើនលទ្ធផលនៃការអប់រំ តម្រូវឱ្យមានអភិក្រមច្រើនមុខព្រួញ។ ការពង្រីកលទ្ធភាពទទួលបានការរៀនសូត្រប្រកបដោយគុណភាពក៏សំខាន់ដែរ។ យ៉ាងណាក៏ដោយ ប្រការលើកទឹកចិត្តនានា ដូចជាការផ្តល់សាច់ប្រាក់លើកទឹកចិត្ត ដើម្បីបង្កើនលទ្ធភាពឱ្យក្មេង ជាពិសេសមកពីគ្រួសារក្រីក្រ នៅបន្តរៀនបានយូរជាងមុន។[69] (យោងតាមឧបសម្ព័ន្ធទី៤)

តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជរដ្ឋាភិបាលកម្ពុជា បានលើកទឹកចិត្តសមាជិកដែលចង់បណ្តុះបណ្តាល ឬបង្កើនសមត្ថភាពបុគ្គលិក មកចុះឈ្មោះបណ្តុះបណ្តាលតាមគ្រឹះស្ថានអប់រំសិក្សារបស់ក្រសួងដែលនឹងផ្តល់ការបណ្តុះបណ្តាលដោយឥតគិតថ្លៃតាំងពីកម្រិតបច្ចេកទេសវិជ្ជាជីវៈកម្រិត១ រហូតដល់កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស (ឌីប្លូម៉ា)។ បន្ថែមពីនេះ ប្រមុខរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវកម្មវិធីថ្នាក់ជាតិលើការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈដល់ក្រុមយុវជនមកពីគ្រួសារក្រីក្រ និងងាយរងហានិភ័យចំនួន ១,៥លាននាក់ ដែលទទួលបានការបណ្តុះបណ្តាលដោយឥតគិតថ្លៃ និងប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលចំនួន ២៨ម៉ឺនរៀល ក្នុងមួយខែ ដោយឡែកយុវជននានា រួមទាំងបុគ្គលនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងបងប្អូនកម្មករនិយោជិត ក៏អាចចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនេះ ដោយមិនបង់ថ្លៃផងដែរ ដើម្បីចាប់យកជំនាញមួយពិតប្រាកដមុនចូលទីផ្សារការងារ ឬផ្លាស់ប្តូរជំនាញ ឬបង្កើនជំនាញរបស់ខ្លួន។ នៅក្នុងនោះដែរ **សម្តេចធិបតី** ក៏បានដាក់ចេញផែនការជម្រុញឱ្យវិស័យឯកជនទទួលយកសិក្ខាកាម សិស្សនិស្សិតហាត់ការនៅកន្លែងធ្វើការងារ ដើម្បីផ្សារភ្ជាប់ទ្រឹស្តី និងបទពិសោធន៍ដែលមាននៅរោងជាង វិទ្យាស្ថាន និងមជ្ឈមណ្ឌល ទៅនឹងការអនុវត្តជាក់ស្តែងនៅតាមសហគ្រាស គ្រឹះស្ថាន។[70]

- **ការពង្រឹងប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម**

ក្នុងអាណត្តិទី៧ នេះ រាជរដ្ឋាភិបាលបន្តដើរតួនាទីប្រៀបបានទៅនឹងអាណាព្យាបាលរបស់គូស្វាមីភរិយាមួយគូ គឺនិយោជក និងកម្មករ-និយោជិត តាមបណ្តារោងចក្រសហគ្រាស ដើម្បីរក្សាបាននូវសុខដុមនីយកម្មតាមរយៈការលើកកម្ពស់លក្ខខណ្ឌការងារ សិទ្ធិសេរីភាព អត្ថប្រយោជន៍របបសន្តិសុខសង្គម អត្ថប្រយោជន៍នានារបស់បងប្អូនកម្មករនិយោជិត និងពង្រឹងយន្តការបង្ការ និងដោះស្រាយវិវាទការងារ ដែលអាចកើតមានឡើង

---

[69] "*Cambodia Economic Update*," World Bank, June, 2024

[70] **សម្តេចធិបតី ហ៊ុន ម៉ាណែត**, "សំណេះសំណាលជាមួយថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ," Facebook, ភ្នំពេញ, មេសា ២៨, ២០២៤ https://www.facebook.com/share/p/3dHPciDzj39bZWEJ/

ជាសត្យានុម័ត សំដៅធ្វើឱ្យមានភាពកាន់តែល្អប្រសើរឡើងនៃទំនាក់ទំនងវិជ្ជាជីវៈនៅកន្លែងធ្វើការងារ រក្សាបាននូវភាពសុខសាន្តនៅគ្រប់ទីតាំងសហគ្រាស ដើម្បីជាប្រយោជន៍រួមដល់ប្រជាពលរដ្ឋ ជាពិសេសបងប្អូនកម្មករនិយោជិត ក្រោមម្លប់ដ៏ត្រជាក់នៃសន្តិភាព។ ដើម្បីពង្រឹងប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដៃគូពាក់ព័ន្ធទាំងអស់ ដែលបានខិតខំសម្រេចបាននូវលទ្ធផលការងារគួរជាទីមោទនៈជាច្រើនក្នុងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអនុវត្តប្រកបដោយជោគជ័យក្នុងការអនុវត្តអនុសាសន៍គន្លឹះទាំងនេះ ជាពិសេសចំណុចដែលសម្តេចធិបតីបានដាក់ចេញនាពេលចុងឆ្នាំ២០២៣ ចំណុចដែលសម្តេចធិបតីបានដាក់ចេញនាពេលចុងឆ្នាំ២០២៣ កន្លងទៅនេះដូចជា បានដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២៤ ពី២០២ ដល់ ២០៤ដុល្លារអាម៉េរិក ក្នុងមួយខែ ហើយបើបូករួមទាំងប្រាក់រង្វាន់អតីតភាពការងារ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗទទួលបានប្រាក់ឈ្នួលជាមធ្យមចាប់ពី ២២១ ទៅ ២៣២ដុល្លារអាម៉េរិក ក្នុងមួយខែ។ បានពង្រីករបបថែទាំសុខភាពជូនអ្នកនៅក្នុងបន្ទុកសមាជិកបេឡាជាតិសន្តិសុខសង្គម(ប.ស.ស.) និងបុគ្គលនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងផ្តើមចេញពីបុគ្គលស្វ័យនិយោជន៍ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅ។ បានបន្តនិរន្តរភាព និងបង្កើនប្រសិទ្ធភាពបើកផ្តល់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ មុនពេលសម្រាលកូន និងក្រោយពេលសម្រាលកូន រហូតដល់កូនអាយុ ២ឆ្នាំ ចំនួន ១៤លើក ដោយ ១លើក ទទួលបានថវិកាចំនួន ៨ម៉ឺនរៀល និងប្រាក់ឧបត្ថម្ភពេលសម្រាលកូន ចំនួន ៤០ម៉ឺនរៀល ដើម្បីលើកកម្ពស់សុខុមាលភាពមាតា និងទារក រួមចំណែកដោះស្រាយកង្វះអាហារូបត្ថម្ភ ព្រមទាំងជម្រុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតីរបស់កូនចៅបងប្អូនកម្មករនិយោជិត។ បង្កើតបរិយាកាសវិនិយោគប្រកបដោយបរិយាប័ន្ន ហើយបានផ្សារភ្ជាប់សុខទុក្ខជាមួយប្រជាជន ជាពិសេស បងប្អូនកម្មករនិយោជិតទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅគ្រប់ដំណាក់កាល បង្កើតជាមូលដ្ឋានគ្រឹះដ៏រឹងមាំជម្រុញឱ្យមានការអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យ និងបានជួយកែប្រែជីវភាពរស់នៅ ប្រាក់ចំណូល និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ជាពិសេស បងប្អូនកម្មករនិយោជិត រួមទាំងការទទួលបាននូវកិច្ចគាំពារសង្គមកាន់តែប្រសើរ មានឱកាសទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឱកាសការងារកាន់តែទូលំទូលាយទាំងក្នុង និងក្រៅប្រទេស។

ក្រៅពីនេះ រាជរដ្ឋាភិបាល នឹងបន្តតាមដាន និងជម្រុញយ៉ាងយកចិត្តទុកដាក់ដល់ចលនាប្រឡងប្រណាំង" សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ "ការបង្កើតឱ្យមានទារកដ្ឋាន និងមត្តេយ្យសហគមន៍ នៅតាមតំបន់ដែលមានរោងចក្រ ឱ្យបានមុនដំណាច់ឆ្នាំ២០២៥ ដោយមានការចូលរួមទ្រទ្រង់ពីនិយោជក កម្មករនិយោជិត និងភាគីពាក់ព័ន្ធនានា, ការកែលម្អកន្លែងហូបបាយ ឬអាហារដ្ឋាននៅតាមរោងចក្រ ដែលកំពុងដំណើរការឱ្យបានសមរម្យសម្រាប់កម្មករនិយោជិត និងតម្រូវឱ្យមានការរៀបចំកន្លែងហូបបាយ ឬអាហារដ្ឋាន សម្រាប់រោងចក្រដែលត្រូវបង្កើតថ្មី ដោយរួមបញ្ចូលទាំងការគិតគូរអំពីកត្តាអនាម័យ រំហូរខ្យល់ និងសីតុណ្ហភាពទាំងនៅកន្លែងហូបបាយ និងកន្លែងធ្វើការឱ្យបានល្អ ជាពិសេសនៅរដូវប្រាំង ការផ្លាស់ប្តូរជាបណ្តើរៗនូវមធ្យោបាយដឹក-

ជញ្ជូនកម្មករនិយោជិត ដែលស្របតាមបទដ្ឋានបច្ចេកទេស និងផាសុកភាពជាងមុនត្រឹមឆ្នាំ២០២៧ និងកម្មវិធីធ្វើតេស្តទទួលស្គាល់ជំនាញ ដែលជាឱកាសសម្រាប់បងប្អូនកម្មករនិយោជិត និងពលករទេសន្តរប្រវេសន៍អាចទទួលបានវិញ្ញាបនបត្រទទួលស្គាល់ជំនាញមួយ សមត្ថភាព និងកម្រិតជំនាញ ដើម្បីយកទៅប្រើប្រាស់ជាប្រយោជន៍របស់បងប្អូនកម្មករនិយោជិត ក៏ដូចជាពលករទេសន្តរប្រវេសន៍។[71]

❖ **បរិវត្តកម្មឌីជីថល**

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា បានកំណត់យកនូវចក្ខុវិស័យ "កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក ដើម្បីជម្រុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម ផ្អែកលើ ប្រក្រតីភាពតាមគន្លងថ្មី" ។ ចក្ខុវិស័យនេះត្រូវសម្រេចឱ្យបានក្នុងរយៈពេល១៥ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០៣៥ ហើយអនុលោមតាមគោលការណ៍ចំនួនបីគឺៈ "ការកសាងមូលដ្ឋានគ្រឹះឌីជីថល-ការចាប់យកឌីជីថល-ការធ្វើបរិវត្តកម្មឌីជីថល" ដែលក្នុងនោះរាល់វិធានការគោលនយោបាយត្រូវអនុវត្តដំណាលគ្នា ប៉ុន្តែផ្តល់អាទិភាព ទៅលើវិធានការដែលឆ្លើយតបទៅនឹងគោលការណ៍នីមួយៗ។ មានន័យថា បរិវត្តកម្មឌីជីថល គឺជាគោលដៅចុងក្រោយ ដែលសំដៅសម្រេចបាននូវការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថល ដោយពឹងផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល យ៉ាងទូលំទូលាយក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ច និង គ្រប់សកម្មភាពសេដ្ឋកិច្ច ដែលផ្សារភ្ជាប់, មានអន្តរទំនាក់ទំនង ជាមួយគ្នា និង បំពេញបន្ថែមឱ្យគ្នា។ បន្ថែមលើនេះ, ក្របខណ្ឌគោលនយោបាយនេះផ្តោតលើសមាសធាតុចំនួនប្រាំ ដែលចែកចេញជាគ្រឹះចំនួនពីរ រួមមាន (១). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និង (២). ការកសាងទំនុកចិត្ត និង ភាពជឿជាក់ លើប្រព័ន្ធឌីជីថល និងសសរស្តម្ភចំនួនបីរួមមាន (១). ការកសាងពលរដ្ឋឌីជីថល, (២). ការកសាងរដ្ឋាភិបាល ឌីជីថល និង (៣). ការជម្រុញធុរកិច្ចឌីជីថល ។ ឈរលើគោលគំនិត "ទាញយកប្រយោជន៍ពីសេដ្ឋកិច្ច និង សង្គម ឌីជីថលឱ្យបានជាអតិបរមា ព្រមទាំងស្រូបយក និង កាត់បន្ថយផលប៉ះពាល់ ឬបច្ច័យអវិជ្ជមានឱ្យស្ថិតក្នុងកម្រិត អប្បបរមា" វិធានការគោលនយោបាយត្រូវបានរៀបចំទៅតាមសមាសធាតុនីមួយៗ គួបផ្សំនឹងការគិតគូរក្នុងទិដ្ឋភាព សេដ្ឋកិច្ច និង សង្គមដើម្បីធានាបាននូវការកាត់បន្ថយបច្ច័យអវិជ្ជមានផងដែរ។

ដើម្បីដើរទាន់សម័យកាល ក៏ដូចជាកាត់បន្ថយផលជះអវិជ្ជមាននៃវឌ្ឍនភាពដ៏ឆាប់រហ័សរបស់ប្រព័ន្ធឌីជីថល រាជរដ្ឋាភិបាលកម្ពុជាត្រូវពន្លឿនការអភិវឌ្ឍន៍ បណ្តុះបណ្តាលធនធានមនុស្សដែលកាន់តែមានសមត្ថភាព និងបរិយាកាប្រព័ន្ធអេកូឡូស៊ីដែលកាន់តែអំណោយផល ជម្រុញឱ្យមានសង្គមឌីជីថលដែលមានការចូលរួម និងការប្រើប្រាស់បច្ចេកវិទ្យាកាន់តែខ្ពស់ តាមរយៈចាប់យន្តការលើកទឹកចិត្តប្រភេទពលកម្មដែលគ្មានជំនាញ ឬ ជំនាញទាប ឱ្យចាប់យកជំនាញឌីជីថលកម្រិតមូលដ្ឋាន ដើម្បីរក្សាការងារ ឬ មុខរបរទាំងនោះ ។ ឧទាហរណ៍ អ្នករត់ម៉ូតូឌុប ឬ អ្នកបើកម៉ូកកង់បីត្រូវចេះប្រើប្រាស់កម្មវិធី (Application) ដូចជា កម្មវិធីផែនទី, ការទូទាត់តាម

[71] **សម្តេចធិបតី ហ៊ុន ម៉ាណែត**, "សំណេះសំណាលជាមួយថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ," Facebook, ភ្នំពេញ, មេសា ២៨, ២០២៤ https://www.facebook.com/share/p/3dHPciDzj39bZWEJ/

ប្រព័ន្ធធនាគារ រីឯពាណិជ្ជករ ឬ អាជីវករខ្នាតតូច ត្រូវចេះប្រើប្រាស់កុំព្យូទ័រ និង ទូរស័ព្ទឆ្លាត ក្នុងការលក់ទំនិញ ឬ សេវាតាមប្រព័ន្ធអេឡិចត្រូនិក និង ទទួលយក ការទូទាត់សងប្រាក់តាមប្រព័ន្ធធនាគារ។ ទន្ទឹមនឹងនេះកម្ពុជាក៏ត្រូវបង្កើនប្រសិទ្ធភាពក្នុងការតភ្ជាប់បណ្តាញសេវាអ៊ីនធឺណិត និងទូរស័ព្ទចល័តបន្ថែម ជាពិសេសនៅតាមទីជនបទដើម្បីឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់ និងមានលទ្ធភាពក្នុងការយល់ដឹងកាន់តែច្បាស់ពីបច្ចេកវិទ្យាផ្សេងៗ។[72]

❖ **ការប្រែប្រួលអាកាសធាតុ**

បើតាមរយៈឯកសារ**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១** ការឆ្លើយតបនឹងបញ្ហាការប្រែប្រួលអាកាសធាតុត្រូវបានបង្ហាញនៅក្នុងយុទ្ធសាស្ត្របញ្ចកោណទី៤ ស្ថិតក្នុងមុំទី៥ ដែលសម្តៅដល់ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង។ គោលដៅជាយុទ្ធសាស្ត្រគឺការកាត់បន្ថយការបំពុល និងផលប៉ះពាល់បរិស្ថានជាអតិបរមា, ការពង្រឹងការគ្រប់គ្រងទឹក និងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ជាពិសេសចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសកលដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងនោះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាពដូចជា៖

- ការលើកកម្ពស់ការអភិវឌ្ឍបៃតង និងសេដ្ឋកិច្ចចក្រតាមរយៈការអនុវត្តគោលនយោបាយថាមពលស្អាត និងប្រសិទ្ធភាពថាមពល ដោយបន្តលើកទឹកចិត្ត និងបង្កើនការវិនិយោគលើថាមពលស្អាតដែលមានតម្លៃសមរម្យ, គោលនយោបាយកសិកម្មវៃឆ្លាត និងបៃតង, គោលនយោបាយនវានុវត្តក្នុងដំណើរការឧស្សាហកម្ម និងការប្រើប្រាស់ផលិតផល, គោលនយោបាយទីក្រុងវៃឆ្លាត និងការដឹកជញ្ជូនបៃតង, និងគោលនយោបាយគ្រប់គ្រងសំណល់ រឹង រាវ ឧស្ម័ន និងសំណល់គ្រោះថ្នាក់, និងការពង្រឹងការវាយតម្លៃផលប៉ះពាល់បរិស្ថានចំពោះគម្រោងអភិវឌ្ឍទាំងនៅក្នុងស្រុក និងក្រៅស្រុកប្រកបដោយប្រសិទ្ធភាព។
- ការបន្តជម្រុញ និងកសាងហេដ្ឋារចនាសម្ព័ន្ធទឹករួមទាំងប្រព័ន្ធប្រព្រឹត្តកម្មដើម្បីធានានូវសន្តិសុខទឹក និងចីរភាពបរិស្ថាន និងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។
- ការបន្តបង្កើនការប្រើប្រាស់បច្ចេកវិទ្យា ភាតរបរិស្ថាន និងភាតរអាកាសធាតុដូចជាបច្ចេកវិទ្យា, ដំណោះស្រាយតាមបែបធម្មជាតិ, និងការប្រើប្រាស់ម៉ូដែល និងបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតទៅក្នុងការគ្រប់គ្រងសុវត្ថិភាពទឹក និងបរិស្ថានជាដើម។
- ការបន្តពង្រឹងក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធបរិស្ថាន ទឹក និង គ្រោះមហន្តរាយធម្មជាតិ ក៏ដូចជាការងារការទូតបៃតងដើម្បីធានានិរន្តរភាពប្រព័ន្ធអេកូឡូស៊ី និងការរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

---

[72] រាជរដ្ឋាភិបាលកម្ពុជា, "*ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០២៥,*" ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចកម្ពុជា, ឧសភា ២០២១ https://asset.cambodia.gov.kh/mptc/2021/05/Printed-_Digital-Economy-and-Society-Framework.pdf

- ការបន្តអភិវឌ្ឍសមត្ថភាពជំនាញ និងចំណេះដឹងបច្ចេកទេស ព្រមទាំងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រលើផ្នែកបរិស្ថាន, ការអភិវឌ្ឍបៃតង, សន្តិសុខទឹក, ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់, ការបន្ស៊ាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងការចងក្រងផលិតឯកសារឧបទេស សម្រាប់ការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅដើម្បីជម្រុញ និងលើកទឹកចិត្តការចូលរួមអនុវត្តន៍សាលារៀន និងវត្តអារាម ភាគរបរិស្ថាន និងគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពប្រកបដោយអនាម័យ, សោភ័ណភាព និងបរិស្ថានល្អ។[73]

[73] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១,* ២០២៣, ទំព័រទី៨៧-៨៨

# សេចក្តីសន្និដ្ឋាន និង
# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ចក្ខុវិស័យឆ្នាំ ២០៣០ របស់កម្ពុជាក្នុងដំណើរក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់គឺជាផែនទីគោលដៅដ៏សំខាន់ក្នុងការប្រែក្លាយជីវភាពភាពប្រជាជនកម្ពុជាឱ្យមានភាពល្អប្រសើរ តាមរយៈការបង្កើនប្រាក់ចំណូលក្នុងមួយឆ្នាំរបស់ពលរដ្ឋម្នាក់យ៉ាងតិច ៤ ៥១៦ ដុល្លារ ដល់ ១៤ ០០៥ ដុល្លារ ដែលធ្វើឱ្យការរស់នៅរបស់ប្រជាជនល្អប្រសើរប្រកបដោយសុខុមាលភាព កសាងមូលដ្ឋានសេដ្ឋកិច្ចដ៏រឹងមាំ ទាក់ទាញវិនិយោគិន កាត់បន្ថយភាពក្រីក្រ លើកកម្ពស់មុខមាត់ ជាពិសេសនឹងបោះជំហានឆ្ពោះទៅរកសេដ្ឋកិច្ចចម្រុះមុននឹងឆ្ពោះទៅរកការសម្រេចបាននូវឋានៈជាចំណូលខ្ពស់នៅឆ្នាំ២០៥០។

ទោះបីជាកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងអត្រាដ៏ខ្ពស់គួរឱ្យកត់សម្គាល់ពោលគឺក្នុងអត្រា ៧,៧ ភាគរយក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ ២០១៩ និងការងើបឡើងយ៉ាងឆាប់រហ័សពីវិបត្តិសកលកូវីដ-១៩ នោះក្តី ការសម្រេចបាននូវគោលដៅឆ្នាំ២០៣០ គឺជាកិច្ចការប្រកបដោយមហិច្ឆតាមួយក្នុងពេលដែលមានបញ្ហាប្រឈមផ្នែកភូមិសាស្ត្រនយោបាយ និងការប្រែប្រួលយ៉ាងរហ័សនៃបរិយាកាសសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។ ជាក់ស្តែង បញ្ហាជំងឺរាតត្បាតកូវីដ-១៩ បញ្ហាសង្គ្រាមរវាងប្រទេសរុស្ស៊ី-អ៊ុយក្រែន ភាពតានតឹងភូមិសាស្ត្រនយោបាយ ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុពីសំណាក់ប្រទេសមហាអំណាច បញ្ហាការប្រែប្រួលអាកាសធាតុនៅលើភពផែនដី និងការថមថយសេដ្ឋកិច្ចសកលបានជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចតាមវិស័យសំខាន់ៗរបស់កម្ពុជា ហើយភាពមិនប្រាកដប្រជាពីកត្តាខាងក្រៅទាំងអស់នេះនឹងធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាជួបប្រទះនឹងហានិភ័យ និងបង្កជាផលខាតបង់មកលើសេដ្ឋកិច្ចកម្ពុជាដោយផ្ទាល់ និងដោយប្រយោល។ ទន្ទឹមនឹងនេះ កម្ពុជានៅមានបញ្ហាជារចនាសម្ព័ន្ធផ្ទៃក្នុងប្រទេសមួយចំនួន ដែលត្រូវដោះស្រាយជាចាំបាច់ ជាពិសេសបញ្ហាល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ថ្លៃដើមក្នុងការចាប់ផ្តើមធុរកិច្ច ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ ប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម។ លើសពីនេះទៅទៀត សេដ្ឋកិច្ចកម្ពុជាក៏ត្រូវយកចិត្តទុកដាក់ និងត្រៀមខ្លួនទប់ទល់ទៅនឹងបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាមួយចំនួនផ្សេងទៀតដែលអាចនឹងកើតមានឡើងនាពេលអនាគតពាក់ព័ន្ធទៅនឹងការបន្តយាយីនៃការបែងចែកប្លុកសេដ្ឋកិច្ច និងពាណិជ្ជកម្ម បរិវត្តកម្មឌីជីថល និងការប្រែប្រួលអាកាសធាតុ ជាដើម។

ដើម្បីសម្រេចចក្ខុវិស័យឆ្នាំ ២០៣០ ប្រកបដោយនិរន្តរភាព កម្ពុជាត្រូវបង្កើនកំណើនទៀងទាត់ឡើងវិញបានតាមរយៈការជម្រុញពិពិធកម្មសេដ្ឋកិច្ច ការបង្កើនផលិតភាពរបស់ក្រុមហ៊ុន និងពលករ តាមរយៈការកសាងមូលធនមនុស្ស ពង្រឹងសុខុមាលភាពកម្លាំងពលកម្ម និងចាត់វិធានការនានាឈានទៅជម្រុញការវិនិយោគក្នុងស្រុកថែមទៀតសំដៅដល់ការ ជាពិសេសការកែលម្អហេដ្ឋារចនាសម្ព័ន្ធសង្គម សម្តៅដល់ការកាត់បន្ថយថ្លៃដើមធុរកិច្ច ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងកាកិច្ចសម្រួលពាណិជ្ជកម្មនានា ដែលជាប្រភពដ៏សំខាន់

ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជា។ យ៉ាងណាមិញ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញផែនការយុទ្ធសាស្ត្រជាច្រើន ដោយក្នុងនោះយុទ្ធសាស្ត្របញ្ចកោណជាផែនការគោលក្នុងការកសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជម្រុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិ ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

## ២. ការផ្តល់អនុសាសន៍

បន្ទាប់ពីបានសិក្សាស៊ីជម្រៅទៅលើប្រធានបទខាងលើរួចមក ខ្ញុំបាទបានយល់ច្បាស់អំពី ឧបសគ្គ និង បញ្ហាប្រឈមមួយចំនួនរបស់កម្ពុជាក្នុងមាគ៌ាឆ្ពោះទៅសម្រេចឱ្យបានចក្ខុវិស័យឆ្នាំ ២០៣០ ទៅតាមការគ្រោងទុក។ ដោយបានមើលឃើញអំពីហានិភ័យ និងចន្លោះខ្វះខាតមួយចំនួនដែលកម្ពុជាត្រូវដោះស្រាយ យើងខ្ញុំសូមចូលរួមចំណែកនូវការផ្តល់ជាអនុសាសន៍ និងការសំណូមពរមួយចំនួនទៅលើបញ្ហាដូចខាងក្រោម៖

❖ **បញ្ហាសកល**

- **ការកើនឡើងថ្លៃទំនិញសកល**

➢ កម្ពុជាត្រូវកាត់បន្ថយការនាំចូលវត្ថុធាតុដើម និងទំនិញណាដែលយើងអាចមានលទ្ធភាពក្នុងការផលិត និងកែច្នៃដោយខ្លួនឯង
➢ ផ្លាស់ប្តូរពីការប្រើប្រាស់ទំនិញនាំចូល ដោយជំនួសមកវិញនូវការគាំទ្រ និងប្រើប្រាស់ទំនិញក្នុងស្រុក
➢ អនុគ្រោះលើប្រព័ន្ធពន្ធសម្រាប់ធានា និងទប់ស្កាត់ថ្លៃកុំឱ្យហក់ឡើងខ្ពស់
➢ គាំទ្រដល់គំនិតផ្តួចផ្តើមស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យាក្នុងវិស័យផលិតកម្មដើម្បីជម្រុញដល់ការពង្រីកសមត្ថភាពផលិតកម្ម និងលើកកម្ពស់ប្រសិទ្ធភាពអាជីវកម្មក្នុងស្រុកឱ្យកាន់តែទូលំទូលាយជាងមុន
➢ គួរតម្លើងអត្រាការប្រាក់គោលក្នុងគោលដៅលើកទឹកចិត្តដល់អ្នកប្រើប្រាស់ក្នុងស្រុកឱ្យសន្សំកាន់តែច្រើនជាងមុន ដោយអាចកាត់បន្ថយតម្រូវការក្នុងការនាំចូលទំនិញ។

- **តម្រូវការសកលធ្លាក់ចុះ**

➢ កម្ពុជាត្រូវសិក្សាស្រាវជ្រាវស្វែងរកទីផ្សារអន្តរជាតិថ្មីបន្ថែមទៀតដើម្បីចាប់យកនូវគោលដៅទីផ្សារថ្មីសម្រាប់ការនាំចេញទំនិញ ដោយកាត់បន្ថយការពឹងផ្អែកទាំងស្រុងលើទីផ្សារដែលមានស្រាប់
➢ ផ្តោតលើការផលិតទំនិញដែលមានតម្រូវការជាក់ស្តែងពីប្រភពខាងក្រៅ
➢ ផ្តល់ការគាំទ្រជាជំនួយហិរញ្ញវត្ថុ ការឧបត្ថម្ភធន និងការបន្ធូរបន្ថយពន្ធដល់ឧស្សាហកម្ម ដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយការថយចុះតម្រូវការសកល ជាពិសេសឧស្សាហកម្មក្មេងខ្ចី
➢ ផ្តល់ប្រាក់កម្ចីក្នុងរយៈពេលខ្លី ដែលមានអត្រាការប្រាក់ទាបដល់អ្នកប្រើប្រាស់សម្រាប់ជម្រុញតម្រូវការក្នុងស្រុក
➢ ពង្រឹងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងភាពជាដៃគូ និងបន្តចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយដៃគូផ្សេងៗក្នុង និងក្រៅតំបន់ដើម្បីទទួលបានការអនុញ្ញាតលើការផ្គត់ផ្គង់ទំនិញ ការផ្លាស់ប្តូរទៅកាន់ទីផ្សារជំនួសថ្មី អនុគ្រោះលើការនាំចេញផលិតផល និងកែសម្រួលលក្ខខណ្ឌពាណិជ្ជកម្មមួយចំនួនសម្រាប់បង្កជាលក្ខណៈងាយស្រួលដល់ការធ្វើពាណិជ្ជកម្ម

- ជម្រុញ និងលើកកម្ពស់ការនាំចេញមុខទំនិញ ដែលបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី ជាមួយប្រទេសសម្ព័ន្ធមិត្តក្នុងគោលដៅទាញយកឲ្យបានជាអតិបរមានូវអត្ថប្រយោជន៍ពីការចុះកិច្ចព្រមព្រៀងនោះ
- ជម្រុញ និងបង្កើនតម្រូវការក្នុងស្រុកដោយអនុវត្តគោលនយោបាយ ដែលជម្រុញអំណាចទិញដូចជាការលើកទឹកចិត្តពន្ធសម្រាប់អ្នកប្រើប្រាស់ និងការគាំទ្រអាជីវកម្មក្នុងស្រុក ជាពិសេសគាំទ្រដល់ការកែច្នៃ និងខ្សែចង្វាក់ក្នុងវិស័យដែលមានតម្លៃបន្ថែមខ្ពស់។

- **តម្លៃរូបិយវត្ថុជាតិធ្លាក់ចុះ**

ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការកើនឡើងតម្លៃរូបិយប័ណ្ណបរទេស និងការធ្លាក់ចុះនៃរូបិយប័ណ្ណជាតិ កម្ពុជាត្រូវបង្កើនការប្រើប្រាស់ជាប្រាក់រៀល និងត្រូវចាកចេញពីដុល្លារូបនីយកម្មជាបណ្តើរៗ ដោយក្នុងនោះកម្ពុជាត្រូវអំពាវនាវដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រោងចក្រ ក្រុមហ៊ុន-សហគ្រាស ម្ចាស់អាជីវកម្ម ប្រជាពលរដ្ឋទូទៅ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តរួមចំណែកប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការរបស់ខ្លួនឱ្យកាន់តែច្រើនឡើងដូចជា តាមរយៈការទូទាត់ ការបិទស្លាកតម្លៃទំនិញនិងសេវានានា និងការសន្សំជាប្រាក់រៀល ព្រមទាំងផ្តល់លក្ខខណ្ឌអនុគ្រោះឱ្យបានច្រើន ចំពោះការប្រើប្រាស់ប្រាក់រៀល ហើយជាពិសេសកម្ពុជាគួរៈ

- លើកទឹកចិត្តដល់ធនាគារ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុដាក់ចេញនូវការផ្តល់ប្រាក់កម្ចីជាប្រាក់រៀល ដោយកាត់បន្ថយការផ្តល់កម្ចីជាប្រាក់ដុល្លារ
- បន្តកាត់បន្ថយជាបណ្តើរៗនូវបរិមាណសាច់ប្រាក់ដុល្លារ ដោយចាប់ផ្តើមពីការប្រមូល និងស្តុកទុកក្រដាសប្រាក់តូចៗដូចជាក្រដាសប្រាក់១ដុល្លារ ២ដុល្លារ និង៥ដុល្លារ ហើយជំនួសមកវិញនូវការប្រើប្រាស់ប្រាក់រៀល
- បន្តជម្រុញការតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសជិតខាង និងក្នុងតំបន់ដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជា ដែលមានគណនីជាប្រាក់រៀលអាចទូទាត់បានតាមប្រព័ន្ធ QR code បានងាយស្រួលនៅក្នុងប្រទេសទាំងនោះ ហើយការតភ្ជាប់នេះក៏គួររួមបញ្ចូលឱ្យទេសចរបរទេសអាចទូទាត់ជាប្រាក់រៀលនៅតាមហាងទំនិញនានានៅកម្ពុជាផងដែរ
- សិក្សាស្រាវជ្រាវ និងកំណត់លើការទូទាត់ប្រាក់ឈ្នួលនៅក្នុងវិស័យឯកជនជាប្រាក់រៀល
- បន្តសហការជាមួយភាគីពាក់ព័ន្ធក្នុងការទទួលប្តូរក្រដាស់ប្រាក់រៀលចាស់ ទក់ រហែក និងជំនួសវិញនូវក្រដាសប្រាក់ថ្មីគ្រប់ប្រភេទជូនសាធារណជនដោយមិនគិតកម្រៃសេវា
- ផ្សព្វផ្សាយឲ្យប្រជាជនយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់ក្រដាសប្រាក់រៀល។

- **វំហូរវិនិយោគផ្ទាល់ពីបរទេសចូលមកក្នុងស្រុកធ្លាក់ចុះ**

- បន្ធូរបន្ថយគោលការណ៍ ឬលក្ខខណ្ឌនៃច្បាប់វិនិយោគ និងសម្របសម្រួលដល់នីតិវិធីរដ្ឋបាលឱ្យមានលក្ខណៈកាន់តែងាយស្រួលជាងមុន ជាពិសេសលើកទឹកចិត្ត និងអនុគ្រោះលើប្រព័ន្ធពន្ធក្នុងការវិនិយោគ
- គាំទ្រផ្នែកបទបញ្ញត្តិសម្រាប់ការពារនូវទ្រព្យសម្បត្តិឯកជន និងធានាការការពារកម្មសិទ្ធិបញ្ញា រួមទាំងយន្តការដោះស្រាយវិវាទនានា
- ត្រូវបង្កើននូវសន្ទុះបណ្តុះបណ្តាលចំណេះ ជំនាញបច្ចេកទេសដល់ពលករឱ្យកាន់តែមានគុណភាពខ្ពស់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង

- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន កំពង់ផែ និងព្រលានយន្តហោះដើម្បីធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ក្នុងការធ្វើដំណើរ និងការដឹកជញ្ជូនឱ្យចំណាយពេល និងថ្លៃដឹកជញ្ជូនតិចជាងមុន ដែលបង្កលក្ខណៈងាយដល់ប្រតិបត្តិការអាជីវកម្ម ជាពិសេសបន្តពង្រីកការកសាងប្រព័ន្ធថាមពលអគ្គិសនីដើម្បីធានានូវការផ្គត់ផ្គង់ថាមពលឱ្យមានស្ថិរភាព
- បន្តជម្រុញកំណើនសេដ្ឋកិច្ច រក្សាស្ថិរភាពនយោបាយ និងបង្កើតឱ្យមានបរិយាកាសធុរកិច្ចនៅក្នុងទីផ្សារឱ្យកាន់តែសម្បូរបែបដើម្បីជម្រុញឱ្យមានឱកាសវិនិយោគ
- កែលម្អប្រព័ន្ធអភិបាលកិច្ច និងកាត់បន្ថយអំពើពុករលួយជាអតិបរមា។

- **ការថយចុះនៃភ្ញៀវទេសចរណ៍អន្តរជាតិ**

- បន្ធូរបន្ថយនីតិវិធីនៃការធ្វើដំណើរឱ្យមានលក្ខណៈងាយស្រួលជាងមុន ដោយពង្រីកការលើកលែងទិដ្ឋាការ និងផ្តល់ទិដ្ឋាការក្នុងរយៈពេលសមល្មមសម្រាប់ឱ្យជនបរទេសមកទេសចរក្នុងប្រទេសបានកាន់តែយូរ
- ត្រូវលើកទឹកចិត្តដល់ភ្នាក់ងារទេសចរណ៍ អ្នកផ្សព្វផ្សាយ និងអ្នកធ្វើមាតិកាល្បីៗមកផ្សព្វផ្សាយតំបន់បេតិកភណ្ឌជាតិ វប្បធម៌ អរិយធម៌ ប្រពៃណី សេវាកម្មមគ្គុទេសក៏ទេសចរណ៍ និងមុខម្ហូបខ្មែរឱ្យកាន់តែទូលំទូលាយទៅកាន់ឆាកអន្តរជាតិដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ពីបណ្តាប្រទេសនានាលើសកលលោក
- ត្រូវបន្តចែករំលែក និងផ្សព្វផ្សាយពីសក្តានុពលនៃតំបន់អេកូទេសចរណ៍
- បន្តពង្រីកនូវប្រព័ន្ធមធ្យោបាយធ្វើដំណើរឱ្យមានលក្ខណៈកាន់តែសម្បូរបែប ចំណាយពេលវេលាតិច និងងាយស្រួលជាងមុន
- ត្រូវធានាឱ្យមាននូវសុខសុវត្ថិភាពគ្រប់ទីកន្លែង ជាពិសេសតំបន់ទេសចរណ៍ជាតិ
- ត្រូវពង្រឹងវិធានការសុខភាព និងអនាម័យឱ្យកាន់តែមានស្តង់ដារ និងភូគាអនាម័យខ្ពស់
- ត្រូវបង្កើននូវសេវាកម្មបដិសណ្ឋារកិច្ច។

❖ **អនុសាសន៍ទៅលើបញ្ហាក្នុងស្រុក**

- **ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច៖** យ៉ាងណាមិញ ការដាក់ចេញជាគោលនយោបាយតែមួយមុខ មិនទាន់មានឥទ្ធិពលគ្រប់គ្រាន់ក្នុងការជម្រុញល្បឿនពិពិធកម្មនោះទេ ពោលគឺទាមទារបន្ថែមការធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និងកាន់តែឆាប់រហ័ស ជាពិសេសផ្តោតលើបញ្ហាសំខាន់ និងបញ្ហាប្រឈមចំពោះមុខ ជាពិសេសបញ្ហារចនាសម្ព័ន្ធការងារព្រមទាំងធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់នៃការអនុវត្តគោលនយោបាយទាំងនោះ។
- **ថ្លៃដើមធុរកិច្ចនៅមានកម្រិតខ្ពស់៖** ប្រមុខរាជរដ្ឋាភិបាល មានតួនាទីយ៉ាងសំខាន់ណាស់ក្នុងការជម្រុញខ្សែច្រវាក់ផលិតកម្មនៅកម្ពុជាសំដៅជួយបង្កើនតម្លៃនៃការផលិតក្នុងស្រុក កាត់បន្ថយថ្លៃដើម ដើម្បីជួយដល់អ្នកផលិតឱ្យទទួលបានផលចំណេញខ្ពស់ ដោយលើកបញ្ហានេះជាសកម្មភាពអាទិភាពដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍស៊ីជម្រៅក្នុងវិស័យសេដ្ឋកិច្ច និងសង្គមក្នុងពេលអនាគត។
- **ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច៖** ដើម្បីជួយដល់ការវិនិយោគរបស់វិស័យឯកជន កម្ពុជាចាំបាច់ត្រូវពង្រឹងការព្យាករណ៍ និងពង្រីកលទ្ធភាពរកបានធនធានហិរញ្ញវត្ថុ

សម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs)។ លើសពីនេះ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រួលលក្ខខណ្ឌតម្រូវស្មុគស្មាញ និងតឹងរ៉ឹងសម្រាប់ការបើកធុរកិច្ច អមជាមួយនឹងការធ្វើឱ្យប្រសើរឡើង ដល់ដំណើរការនៃក្របខណ្ឌក្ស័យធនផង វានឹងជួយកាត់បន្ថយការចំណាយរបស់ក្រុមហ៊ុននៅពេលបើករកស៊ី និងពេលបិទទៅវិញ។ ការសម្រួលនីតិវិធីឱ្យសាមញ្ញ និងការធ្វើឌីជីថលកម្មនៃសេវាធុរកិច្ចដោយប្រើបច្ចេកវិទ្យាសម្រួលដល់ការស្នើសុំ រយៈពេលខ្លី មិនមានភាពស្មុគស្មាញ និងមិនបង្កការលំបាកបន្ថែមទៀតដល់អ្នកវិនិយោគគឺជាការចាំបាច់ ជាពិសេសការចេញអាជ្ញាបណ្ណ និងការអនុញ្ញាតសម្រាប់អាជីវកម្ម នឹងជួយកាត់បន្ថយការចំណាយនានាដែលពាក់ព័ន្ធថ្លៃដើម។

- **បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញនៅមានកម្រិត៖** រដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ គួរតែបន្ថែម និងពង្រឹងកម្មវិធីសិក្សានៅតាមសាលា ជាពិសេសសាកលវិទ្យាល័យ ឱ្យត្រូវតាមតម្រូវការការងារជាក់ស្តែង។ មិនតែប៉ុណ្ណោះ ក្រសួង ឬសាលាខ្លួនឯង ត្រូវមានការសហការជាមួយស្ថាប័ន ឬក្រុមហ៊ុនឯកជននានាដើម្បីទទួលសិស្សយកទៅស្ម័គ្រចិត្តធ្វើការ ឬហាត់ការ ដើម្បីដកពិសោធន៍នាកំឡុងពេលសិក្សា ជាជាងរៀនចប់ចេញរកការងារទាំងគ្មានជំនាញ និងបទពិសោធ។ ម្យ៉ាងទៀត យុវជន ឬនិស្សិត គួរចាប់ជំនាញសិក្សាឱ្យបានច្បាស់លាស់ ប្រសើរជាងជ្រើសរើសជំនាញស្រួលរៀនលុះនៅពេលមានជំនាញ និងបានចេញធ្វើការមានបទពិសោធន៍គ្រប់គ្រាន់ ទោះថ្ងៃក្រោយចង់ប្រកបអាជីវកម្មក៏ងាយស្រួល និងមានឱកាសជោគជ័យច្រើន។
- **ភាពកម្សោយនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម៖** វាមានភាពចាំបាច់ណាស់ក្នុងការពង្រឹង និងយកចិត្តទុកដាក់ទៅលើប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ជាពិសេសសម្រាប់និយោជិកទាំងអស់ ដោយហេតុថាពួកគាត់ជាកម្លាំងពលកម្មដ៏សំខាន់ក្នុងការជម្រុញផលិតភាពរបស់រោងចក្រសហគ្រាសទាំងអស់ និងត្រូវចងចាំថាសុខុមាលភាពរបស់និយោជិត គឺជាទ្រព្យសម្បត្តិរបស់និយោជក។ ដូច្នេះ ម្ចាស់រោងចក្រសហគ្រាស គ្រឹះស្ថាន ប្រតិភូបុគ្គលិក និងសហជីពទាំងអស់ត្រូវត្រូវយកចិត្តទុកដាក់ និងចូលរួមក្នុងកិច្ចការវិស័យការងារ សន្តិសុខសង្គម និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវចាត់ទុករោងចក្រសហគ្រាសជាផ្ទាំងបាយរួមរបស់បងប្អូនកម្មករនិយោជិត និងនិយោជក។ ទន្ទឹមនឹងនោះ រដ្ឋាភិបាលក៏ត្រូវបន្តតាមដានដើម្បីធានាបានថាសមត្ថភាព និងសុខុមាលភាពរបស់កម្លាំងពលកម្មដើរទន្ទឹមគ្នា។

❖ **អនុសាសន៍ទៅលើបញ្ហាប្រឈមនាពេលអនាគត**

- **ការបែងចែកប្លុកសេដ្ឋកិច្ច និងពាណិជ្ជកម្ម៖** ប្រវត្តិសាស្ត្របានបង្រៀនយើងហើយថា ការបែងចែកសេដ្ឋកិច្ចពិភពលោកទៅជាប្លុកប្រកួតប្រជែងគ្នា និងការបែរខ្នងដាក់ប្រទេសក្រីក្របំផុតមិនបាននាំពិភពលោកដើរឆ្ពោះទៅរកភាពរុងរឿង ឬសន្តិភាពឡើយ ដូច្នេះបណ្តាប្រទេស និងអង្គការ ស្ថាប័នអន្តរជាតិនានាត្រូវតែធ្វើការរួមសហការណ៍គ្នា ដើម្បីសម្រួលដល់ការដោះដូរពាណិជ្ជកម្ម នៅចំពេលដែលបញ្ហាអតិផរណា កំពុងតែដាក់សម្ពាធយ៉ាងខ្លាំងទៅលើខ្សែសង្វាក់ផ្គត់ផ្គង់សំខាន់ៗ។

- **បរិវត្តកម្មឌីជីថលៈ** ជំនាញឌីជីថលបានក្លាយជាភាពចាំបាច់ និងពុំគួរមើលរំលងក្នុងពេលបច្ចុប្បន្ននេះ និងអនាគត ដូចនេះកម្ពុជាត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការចាប់យកឌីជីថល ដោយហេតុថាបច្ចេកវិទ្យាឌីជីថលបានដើតួរយ៉ាងសកម្មក្នុងការប្រែក្លាយនិងជម្រុញសកម្មភាពពាណិជ្ជកម្ម ប្រតិបត្តិការធុរកិច្ច ប្រព័ន្ធផ្សព្វផ្សាយ និងសេវាកម្សាន្តជាច្រើនផ្សេងទៀត ជាពិសេសវាក៏អាចផ្តល់នូវឱកាសការងារ និងលទ្ធភាពបង្កើនប្រាក់ចំណូលផងដែរ។
- **ការប្រែប្រួលអាកាសធាតុៈ** នាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត កម្ពុជាត្រូវបង្កើនការប្រុងប្រយ័ត្នលើបញ្ហាគ្រោះធម្មជាតិ ដោយត្រូវផ្តោតលើវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុដូចជាការទប់ស្កាត់ និងការបង្ក្រាបការកាប់ព្រៃឈើខុសច្បាប់ និងការដាំដើមឈើ ការជម្រុញការធ្វើអន្តរកាលថាមពលពីការប្រើប្រាស់ផូស៊ីលឥន្ទនៈឆ្ពោះទៅរកប្រភពថាមពលស្អាត ការអនុវត្តកម្មវិធីប្រសិទ្ធភាពថាមពល ការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង ការជម្រុញហិរញ្ញប្បទានបៃតង ការផលិតផលិតផលដែលគិតគូរពីចីរភាពបរិស្ថាន ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រង ការតាមដានការប្រើប្រាស់ ការផលិត ការលើកទឹកចិត្តប្រព័ន្ធដឹកជញ្ជូនបៃតង និងការបន្សាំក្នុងវិស័យសំខាន់ៗជាដើម។

ជារួម ជោគវាសនាអនាគតសេដ្ឋកិច្ចកម្ពុជា គឺស្ថិតនៅលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល។ ក្រោយពីការដាក់ចេញនូវយុទ្ធសាស្ត្រ ដំណោះស្រាយ និងទទួលបានអនុសាសន៍ ជាពិសេសពីសំណាក់ដៃគូអភិវឌ្ឍន៍នានា រាជរដ្ឋាភិបាលកម្ពុជាត្រូវប្រកាន់ខ្ជាប់ខិតខំលៃលកយកដំណោះស្រាយទាំងនោះមកអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ធ្វើយ៉ាងណាសម្រេចឲ្យបានចក្ខុវិស័យឆ្នាំ ២០៣០ តាមរយៈការសម្រេចឲ្យបានអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យមក្នុងរង្វង់ ១០% ស្របទៅតាមការព្យាករណ៍។ ទោះជាយ៉ាងណាក្តី កម្ពុជាមិនគួរគិតត្រឹមតែខិតខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យមានកំណើនសេដ្ឋកិច្ច និងសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ បានទាន់ពេលវេលាប៉ុណ្ណោះទេ ផ្ទុយទៅវិញ កម្ពុជាត្រូវតែធានាថាកំណើននោះគឺប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន ជាពិសេសការផ្តល់អាទិភាពលើគោលនយោបាយ និងការអភិវឌ្ឍរយៈពេលវែងឆ្ពោះទៅសម្រេចបាននូវឋានៈជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ផងដែរ ស្របពេលដែលដំណើរនៅខាងមុខនឹងមានរយៈពេលយូរ និងពោរពេញដោយភាពមិនច្បាស់លាស់។ ជាក់ស្តែង ប្រទេសឥណ្ឌូនេស៊ី ដែលបានឈានដល់ស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០១៩ ប៉ុន្តែបានត្រឡប់ទៅជាប្រទេសប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០២០។ ស្រដៀងគ្នានេះដែរ ប្រទេសស្រីលង្កាបានផ្លាស់ប្តូរចំណាត់ថ្នាក់ទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០១៨ ប៉ុន្តែបានត្រលប់ទៅប្រទេសដែលមានចំណូលមធ្យមកម្រិតទាបវិញនៅឆ្នាំ ២០១៩។ ទន្ទឹមគ្នានឹងនោះដែរ កម្ពុជាត្រូវធានាឱ្យបាននូវសុខសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាកត្តាដ៏សំខាន់ក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ច ជាពិសេសរៀបចំហេដ្ឋរចនាសម្ព័ន្ធខាងក្នុង អភិបាលកិច្ច កាត់បន្ថយអំពើពុករលួយ ដើម្បីផ្តល់សេចក្តីទុកចិត្តដល់វិនិយោគិន ក្នុងការមកបណ្តាក់ទុននៅកម្ពុជា។

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


1. រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១,* ២០២៣
2. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *ថវិកាសង្ខេបឆ្នាំ ២០២១-២០២៤,* ២០២៣
3. ហង់ ជួនណារ៉ុន, *សេដ្ឋកិច្ចនៃប្រទេសកម្ពុជា,* (ភ្នំពេញ, ២០១៥)
4. រាជរដ្ឋាភិបាលកម្ពុជា, *ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧,* ២០២៤
5. រាជរដ្ឋាភិបាលកម្ពុជា, "*ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០២៥,*" ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចកម្ពុជា, ឧសភា ២០២១
6. ក្រសួងការបរទេស, "*សុន្ទរកថាឯកឧត្តម ប្រាក់ សុខុនក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២២ និងទិសដៅឆ្នាំ២០២៣,*" មីនា ០១, ២០២៣
7. អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស, "*សុន្ទរកថារបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ថ្លែងក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣,*" *វិច្ឆិកា ២៣, ២០២៣,* https://pressocm.gov.kh/archives/89000
8. រាជរដ្ឋាភិបាលកម្ពុជា, "*ប្រព័ន្ធបញ្ជរតែមួយជាតិជួយឱ្យចំណេញពេល កាត់បន្ថយចំណាយ និងមិនចាំបាច់ត្រូវរត់ការពីស្ថាប័នមួយទៅស្ថាប័នមួយទៀតទេ,*" Press OCM, ឧសភា ០៧,២០២៤ https://pressocm.gov.kh/archives/96274
9. **សម្តេចធិបតី ហ៊ុន ម៉ាណែត**, "សំណេះសំណាលជាមួយថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ," Facebook, ភ្នំពេញ, មេសា ២៨, ២០២៤ https://www.facebook.com/share/p/3dHPciDzj39bZWEJ/
10. ក្រសួងព័ត៌មាន, , "*កំណើនសេដ្ឋកិច្ចសកល និងតំបន់នៅតែឈមនឹងភាពមិនប្រាកដប្រជាខ្ពស់,*" (ភ្នំពេញ, កញ្ញា ០៦, ២០២២, https://www.information.gov.kh/articles/85543
11. *ធុន សេងហុង, «តើគោលនយោបាយរូបិយវត្ថុជាអ្វី?,» Tmey Tmey News, តុលា ១២, ២០២៣,* https://thmeythmey.com/?page=detail&id=130758
12. CamboFinance, "*ភាពខុសគ្នានៃ GDP, GNI និង GNP,* " Facebook, ឧសភា ០៦, ២០២១
13. ឆន ឌីណា, " *តើសង្គ្រាមរុស្ស៊ីអ៊ុយក្រែនធ្វើឱ្យភាពក្រីក្រ និងថ្លៃទំនិញសកលកើនឡើងរបៀបណា?,*" rfi, ធ្នូ ១២, ២០២២, https://www.rfi.fr/km/
14. សន ស៊ុនលី, "*ឆ្វេងយល់ពីពិភពលោកពហុប៉ូល,*" , AMS Economy, August 31, 2023, https://economy.ams.com.kh/economic/news/understanding-the-world-with-multipolar-system/

15. ថាំង ស៊ីណន និងហ៊ុន សំរិទ្ធកេតិស័ក្ត, *"ហេតុអ្វីបានជាតៃវ៉ាន់សំខាន់សម្រាប់អាមេរិក,"* គ្រាប់ពូជកម្ពុជា, កញ្ញា ១៣, ២០២១, https://www.theseedcambodia.com/article/7706/
16. តាំង សុខងី និងទន់ លីណាសុផាឫទ្ធិ, *"ការកើនឡើងភាពតានតឹងបច្ចុប្បន្នជុំវិញបញ្ហាកោះតៃវ៉ាន់,"* Asian Vision Institute, សីហា ២៩, ២០២២, https://www.asianvision.org/archives/15442
17. បោង ច័ន្ទសម្បត្តិ និងទន់ លីណាសុផាឫទ្ធិ, *"កង្វះខាតជាសកល Semiconductor និងផលប៉ះពាល់លើឧស្សាហកម្មបច្ចេកវិទ្យា,"* Asian Vision Institute, តុលា ១៣, ២០២១ https://www.asianvision.org/archives/12238
18. *"តើសង្គ្រាមអ៊ីស្រាអែល និងហាម៉ាសនឹងបញ្ឈប់ទៅវិញដោយវិធីណា?,"* សារព័ត៌មានថ្មីៗ, តុលា ១១, ២០២៣
19. ប៊ុន, *"ដើមហេតុនៃសង្គ្រាមរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន,"* The Other Truth, ធ្នូ ២៩, ២០២៣ https://theothertruth.info/history-of-the-israeli-palestinian-conflict/
20. យឿន ពុធធីតា, *"ការវាយប្រហារនៅសមុទ្រក្រហមអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក,"* AMS Economy, មករា ១៦, ២០២៤ https://economy.ams.com.kh/economic/news/the-red-sea-crisis-could-seriously-affect-global-economic-recovery/
21. Fivision, *"ទស្សនវិស័យសេដ្ឋកិច្ចឆ្នាំ ២០២៣"*, F.I Vision Capital, កុម្ភៈ ១៩, ២០២៣, https://fivisioncapital.com/news/
22. ប៊ូ សារឿន, *"ផលិតភាព, ពិពិធកម្ម និងការវិនិយោគក្នុងស្រុកជាកត្តាគន្លឹះសម្រាប់ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា,"* World Bank Group, មករា ៣១, ២០២២ https://www.worldbank.org/km/news/press-release/2022/01/31/productivity-diversification-domestic-investment-are-key-to-cambodia-s-economic-recovery
23. ទូន សុផល, *"ថ្លៃដើមខ្ពស់ ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា ចំណាយច្រើនជាងចំណេញលើវិស័យឧស្សាហកម្ម និងសេវាកម្ម,"* Kampucheatmey, មករា ០៣, ២០២៤, https://www.kampucheathmey.com/local-news/635642
24. ម៉ៃ គុណមករា, *"កម្ពុជាចំណាយជាង ២,១៧ ពាន់លានដុល្លារ លើការនាំចូលប្រេង,"* ភ្នំពេញប៉ុស្តិ៍, មករា ១៦, ២០២៤,https://www.postkhmer.com/business/2024-1-15-2012-257585
25. ចេង ឆហួត, *"ថ្លៃឡជីស្ទីកនៅកម្ពុជានៅតែខ្ពស់ និងមិនសូវមានស្ថិរភាពតម្រូវឲ្យមានការផ្លាស់ប្តូរមួយចំនួនទាំងក្នុងរយៈពេលខ្លី និងមធ្យម,"* CNC News, មិថុនា ០៦,២០២២, https://cnc.com.kh/detail/news/30960

26. ហ៊ុល រស្មី, *"របាយការណ៍សហរដ្ឋអាមេរិកស្តីពីបរិយាកាសវិនិយោគនៅកម្ពុជាមិនអំណោយផល ឆ្នាំ ២០២៤,"* VOA, កក្កដា ១៩, ២០២៤, https://khmer.voanews.com/amp/us-report-says-investment-climate-in-cambodia-not-benefitial-to-us-investors-due-to-corruption/7704777.html
27. *"ការធ្វើពិពិធកម្មសេដ្ឋកិច្ច ទាមទារនូវការបណ្តុះបណ្តាលជំនាញ ដើម្បីប្រែក្លាយឧស្សាហកម្ម ផ្អែកលើអតិពលកម្ម ទៅជាឧស្សាហកម្មផ្អែកលើជំនាញ,"* Fresh News, ធ្នូ ១៦, ២០២២ https://freshnewsasia.com/index.php/en/localnews/270023-2022-12-16-07-15-03.html
28. Maria Cecilia, *" វិធានអន្តរជាតិ និងការអនុវត្តល្អបំផុតនៃច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ,"* សីហា ២២,២០១៧, https://www.ajne.org/sites/default/files/event/7113/session-materials/session-6-climate-change-law-kh.pdf
29. Julian Hilton, *ប្រព័ន្ធធារាសាស្ត្រខ្នាតតូចធន់នឹងការប្រែប្រួលអាកាសធាតុ,* (គម្រោងក្រសួងកសិកម្ម, ឧសភា ០១, ២០១៥)
30. លក្ខិណា, *"ធនាគារពិភពលោកផ្តល់អនុសាសន៍ដល់កម្ពុជាក្នុងការជម្រុញសេដ្ឋកិច្ចរបស់ខ្លួនឱ្យងើបឡើងវិញ,"* Cambodia Financial Times, មករា ៣១, ២០២២, https://cambodiafinancialtimes.com/archives/21827
31. ក្រសួងព័ត៌មាន, *" គម្រោងព្រែកជីកហ្វូណនតេជោនឹងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រទេសកម្ពុជា ជាពិសេសវិស័យដឹកជញ្ជូន អចលនទ្រព្យ និងការវិនិយោគផ្សេងៗ,"* វិទ្យុជាតិកម្ពុជា, កក្កដា ១៤,២០២៣https://www.information.gov.kh/articles/109268
32. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, *" កិច្ចប្រជុំយន្តការភាពជាដៃគូគយ-ផ្នែកឯកជនលើកទី៩,"* Facebook, Dec 22, 2022 https://www.facebook.com/share/p/AauKw4fkJnjKUDEg/

# ឯកសារជាភាសាបរទេស


1. Mamidi Long, *Macroeconomics First Edition,* (ភ្នំពេញ, ២០២០)
2. Tejvan Pettinger, "Diagrams for Supply and Demand," 2019, https://www.economicshelp.org/blog/1811/markets/diagrams-for-supply-and-demand/
3. Leslie Kramer, "*Fiscal Policy,*" *Investopedia,* August 29, 2023, https://www.investopedia.com/insights/what-is-fiscal-policy/
4. Jason Fernando, "*Gross Domestic Product,*" *Investopedia,* June 03, 2024, Gross Domestic Product (GDP) Formula and How to Use It (investopedia.com)
5. *What is the World Bank Atlas method?," World Bank, n.d,* What is the World Bank Atlas method? – World Bank Data Help Desk
6. Venkatachalam Anbuomozhi and Xianin Yao, *The Case of Flying Geese Model,* (ADB, October, 2017)
7. John Stephen Agbenyo, *The Structural Change Theory,* (Faculty of Social Science, January, 2020)
8. Eric Metreau et al., "*World Bank Country Classifications,*" World Bank, July 01, 2024 World Bank country classifications by income level for 2024-2025
9. Lynge Nielsen and Catherine Pattillo, *Classifications of Countires on Their Level of Development,* (IMF, February, 2011)
10. "*What is the criteria of UNDP to classify countires,*" EduRev, n.d, What is the criteria of UNDP to classify countries - EduRev Class 10 Question
11. *Cambodia Economics Updated,* World Bank Report, Nov 2023
12. " *World Trade Report 2021,*" WTO Org, 2021, https://www.wto.org/english/res_e/booksp_e/wtr21_e/01_c_wtr21_e.pdf
13. "*Impact of the Covid-19 Pandemic on Trade and Development,*" UNCTAD, 2022, https://unctad.org/system/files/official-document/osg2022d1_en.pdf
14. Michael Ray, " *Russia-Ukraine War,*" Britannica, Sep 01,2024, https://www.britannica.com/event/2022-Russian-invasion-of-Ukraine
15. Einar H. Dyvik, "*Annual inflation rate for consumer prices worldwide,*" Statista, July 04, 2024, https://www.statista.com/statistics/1325670/inflation-rate-continent/
16. Charlie Vest et al., " *The Global Economic Disruptions from a Taiwan Conflict,*" Rhodium Group, December 14, 2022 https://rhg.com/research/taiwan-economic-disruptions/

17. Energy Literacy PH, *"Asean Residential Electricity Rates 2024."* Facebook, March 27, 2024
18. *" Brics and G7 countries' share of the world's total GDP in PPP,"* Statista Research Department, Jul 15, 2024, https://www.statista.com/statistics/1412425/gdp-ppp-share-world-gdp-g7-brics/
19. G. Djokoto, *" Level of income and the Investment Development Path Theory,"* (SageJornals, Nov 23,2021)
20. Vintila Denisia, *"FDI Theories," December, 2020 https://ejist.ro/files/pdf/357.pdf*
21. *"Export Led Growth," StudySmarter, n.d https://www.studysmarter.co.uk/explanations/macroeconomics/international-economics/export-led-growth*
22. Mankiw, *Macroeconomics* (Worth Publishers: 10th ed., 2019)
23. Krugman, Obstfeld, M., and Melitz, M. J, *International Economics: Theory and Policy* (Pearson: 11th ed., 2018)
24. Sebastian Eckardt and Faya Hayati, *Cambodia 2030: Economic slowdown offers opportunity to speed up reforms*, Dec 13, 2023

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ គំរូម៉ូដែលសត្វក្ងានហោះ






## ឧបសម្ព័ន្ធទី២៖ គំនូសបំព្រួញស្តីពី យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១



## ឧបសម្ព័ន្ធទី៣៖ លទ្ធផលនៃការវិភាគទិន្នន័យតាមរយៈ Regression

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.996993229 |
| R Square | 0.993995499 |
| Adjusted R Square | 0.992357907 |
| Standard Error | 0.581944957 |
| Observations | 15 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 3 | 616.6858341 | 205.5619 | 606.98631 | 1.7E-12 |
| Residual | 11 | 3.725259268 | 0.33866 | | |
| Total | 14 | 620.4110933 | | | |

| អថេរភាព | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | 1.898 | 0.600 | 3.165 | 0.009 | 0.578 | 3.218 | 0.578 | 3.218 |
| FDI | 1.606 | 0.600 | 2.676 | 0.022 | 0.285 | 2.927 | 0.285 | 2.927 |
| Export | 0.847 | 0.142 | 5.948 | 0.000 | 0.533 | 1.160 | 0.533 | 1.160 |
| Import | 0.287 | 0.198 | 1.455 | 0.174 | -0.147 | 0.722 | -0.147 | 0.722 |

RESIDUAL OUTPUT

| *Observation* | *Predicted Y* | *Residuals* |
|---|---|---|
| 1 | 29.2374734 | 0.262526602 |
| 2 | 27.55748451 | -0.597484506 |
| 3 | 25.95178144 | -0.081781444 |
| 4 | 26.65037701 | 0.439622988 |
| 5 | 24.34024421 | 0.229755785 |
| 6 | 21.8611627 | 0.318837304 |
| 7 | 20.04544278 | -0.025442779 |
| 8 | 17.68404637 | 0.365953635 |
| 9 | 16.94092325 | -0.240923248 |
| 10 | 16.22557068 | -0.995570683 |
| 11 | 14.5173998 | -0.467399796 |
| 12 | 12.43967776 | 0.390322236 |
| 13 | 11.21657611 | 0.023423895 |
| 14 | 9.399036319 | 1.000963681 |
| 15 | 10.97280367 | -0.62280367 |

## ឧបសម្ព័ន្ធទី៤៖ តារាងសង្ខេបពីឧបសគ្គ និងការផ្តល់អនុសាសន៍

| Area | Challenges | Recommendations for the next 5 years |
|---|---|---|
| **Improve the business environment for firms** | The high cost of establishing and operating a business (i.e., high start-up, logistics, and electricity costs) as well as a poor overarching business-enabling environment (i.e., high perceptions of corruption, declining rule of law, lack of competition in domestic product markets). | • Further lower electricity prices by institutionalizing competitive processes for power procurement.<br>• Fully digitize the business registration portal and continue to expand the list of institutions connected.<br>• Establish a complete inventory of licenses and permits, introduce and implement risk-based approaches to licensing, and streamline sectoral licenses.<br>• Support the implementation of an effective competition policy framework.<br>• Improve the enforcement of commercial contracts through the introduction of specialized commercial courts and increased court transparency and digitalization.<br>• Strengthen the insolvency framework, including by adopting the Regulations of Insolvency Administrators and Code of Conduct.<br>• Strengthen the public-private dialogue forum by holding annual or semi-annual high-level meetings and increase the transparency of the dialogue. |
| **Boost public and private investment in infrastructure** | The infrastructure gap remains large which is increasing the cost of basic infrastructure services (transport, energy, urban, water) and constraining trade and regional connectivity. | • Maximize the impact of public infrastructure investment by strengthening prioritization and selection of infrastructure projects.<br>• De-risk and ensure successful implementation of more public-private partnership (PPP) projects, including by operationalizing the new PPP law and building capacity of executing agencies, and by ensuring that competitive bidding is the primary method of procurement.<br>• Make investments to address specific infrastructure gaps in regional connectivity: improve the East-West corridor among Thailand, Cambodia, and Vietnam (and the only road corridor connecting Cambodia with Lao PDR); improve the inland waterway connection with Vietnam; and improve the existing railway operations and infrastructure links with Thailand.<br>• Accelerate the growth of electricity supply in an affordable and sustainable manner by: introducing least-cost planning and competitive procurement; enhancing the grid and develop cross-border transmission links; accelerating renewable energy development; and encouraging private sector participation and mobilization of green funds.<br>• Moderate the growth in electivity demand by promoting and enforcing higher energy efficiency standards as well as clean cooking.<br>• Enhance access to water and sanitation infrastructure by modernizing the operation of public water utilities (PWOs) and help them become creditworthy; providing more support to PWOs to allow them to expand their service; setting up a clear institutional mandate for operation and maintenance of wastewater at the municipality level; and establishing a tariff framework for urban sanitation. |

| | | |
|---|---|---|
| **Upgrade the skills of the existing and future workforce** | Low enrollment in early childhood education and unsatisfactory and deteriorating learning outcomes in primary schools are leading to a lack of basic foundations in reading and numeracy. This has knock-on effects, contributing to low secondary school enrollment and high dropout rates. It has also contributed to major skills shortages across the economy, which is hindering economic upgrading and labor productivity. | • Prepare young children to learn by: boosting enrolment in early childhood education, including by expanding quality provision of public and private preschools while adopting measures to stimulate demand; and including education interventions in existing health, nutrition, and social protection services.<br>• Improve equitable access to primary school, including by: constructing more schools and rehabilitating schools with poor infrastructure; measuring learning regularly, especially when it is early enough to make changes, such as grades 2 and 3; and better targeting financial and other forms of support to students at high risk of dropping out.<br>• Enable and motivate schoolteachers, including by: making pre-service teacher education programs more selective and practical; improving professional development by providing teachers the right training and the right tools; ensuring that training programs are clear, doable and rewarding; and incentivizing teacher effort through fair redeployments, promotions, salary and accountability measures.<br>• Improve school governance, including by strengthening data systems for better decision-making, improving school leadership, and strengthening school-based management.<br>• Increase secondary school completion rates by alleviating: the lack of foundational skills via remediation programs; gender barriers; economic and financial pressures; and high opportunity costs driving high dropout rates.<br>• Upgrade the quality of technical and vocational education and training education, including by enhancing the autonomy of institutions and strengthening partnerships with industry.<br>• Enhance labor mobility and matching by strengthening labor market demand and supply information. |

# ឧបសម្ព័ន្ធទី៥៖ ការផ្លាស់ប្តូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំ ២០០០ ទៅឆ្នាំ ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ
លេខ :..........✓..........

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការផ្លាស់ប្តូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំ២០០០ ទៅឆ្នាំ២០១៤

ក្រសួងផែនការ មានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនសាធារណជន អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ អ្នកសារព័ត៌មាន អ្នកសិក្សាស្រាវជ្រាវ ស្តីអំពីការបិទបញ្ចប់ការងារផ្លាស់ប្តូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំគោល២០០០ ទៅឆ្នាំគោល២០១៤។ ក្រសួងផែនការបានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសិក្ខាសាលាប្រកាសផ្សព្វផ្សាយលទ្ធផលការផ្លាស់ប្តូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំ២០០០ ទៅឆ្នាំ២០១៤ ក្រោមអធិបតីភាពឯកឧត្តម **ប៊ិន ត្រឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ នៅសណ្ឋាគារសុខាភ្នំពេញ។ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) គឺជាការគណនាតម្លៃជារូបិយវត្ថុ នៃផលិតផល និងសេវាកម្មសម្រេចសរុប របស់ប្រទេសមួយតាមថ្លៃទីផ្សារក្នុងមួយឆ្នាំ។

ឆ្នាំគោលគណនេយ្យជាតិ ឬឆ្នាំគោល ផ.ស.ស. គឺជាដំណើរការនៃការជំនួសឡើងវិញឆ្នាំគោលចាស់ (ឆ្នាំ២០០០) ដែលបានប្រើប្រាស់សម្រាប់ចងក្រង ផ.ស.ស. ជាងម្ភៃឆ្នាំមកហើយ ជាមួយនឹងឆ្នាំគោលថ្មី (ឆ្នាំ២០១៤) ដើម្បីធ្វើការគណនាថ្លៃថេរ ផ.ស.ស. សម្រាប់វាស់វែងទំហំនិងកំណើនសេដ្ឋកិច្ច។ ក្នុងរយៈពេលមួយដ៏វែងនេះ សេដ្ឋកិច្ចកម្ពុជាមានការប្រែប្រួលថ្លៃ និងរចនាសម្ព័ន្ធ វាជាការចាំបាច់ក្នុងការផ្លាស់ប្តូរឆ្នាំគោលថ្មី ជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងប្រែប្រួលនេះ ដើម្បីលើកកម្ពស់គុណភាព និងរបាយការណ៍ ផ.ស.ស.។ តាមអនុសាសន៍របស់នាយកដ្ឋានស្ថិតិអង្គការសហប្រជាជាតិ (UN Statistics Department-UNSD) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ស្នើឱ្យប្រទេសជាសមាជិកផ្លាស់ប្តូរឆ្នាំគោល ផ.ស.ស. រៀងរាល់៥ឆ្នាំ ឬយូរបំផុត១០ឆ្នាំម្តង។

ការងារផ្លាស់ប្តូរឆ្នាំគោល ផ.ស.ស. ឆ្នាំ២០១៤ មានរយៈពេលជាង២ឆ្នាំ ចាប់ផ្តើមនាចុងឆ្នាំ២០១៧ និងបានបញ្ចប់នាចុងខែធ្នូ ឆ្នាំ២០១៩ ក្រោមជំនួយបច្ចេកទេសពីគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក(UNESCAP) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍

អន្តរជាតិស៊ុយអែត(SIDA) ដែលបានចាត់បញ្ជូនអ្នកជំនាញស្ថិតិគណនេយ្យជាតិពីស្ថាប័នស្ថិតិចក្រភពអង់គ្លេស (ONS-UK) និងស្ថាប័នស្ថិតិប្រទេសស៊ុយអែត(SCB) មកដឹកនាំមន្ត្រីនាយកដ្ឋានគណនេយ្យជាតិនៃវិទ្យាស្ថានជាតិស្ថិតិរបស់ក្រសួងផែនការដោយផ្ទាល់ និងបានចាត់អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ពីស្ថាប័នស្ថិតិប្រទេសស៊ុយអែត(SCB) មកជួយពិនិត្យលទ្ធផល។

ការផ្លាស់ប្តូរឆ្នាំគោល ផ.ស.ស. ឆ្នាំ២០១៤ បានផ្អែកលើប្រភពទិន្នន័យសំខាន់ៗ រួមមាន៖ ជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ ជំរឿនកសិកម្មឆ្នាំ២០១៣ អង្កេតពាក់កណ្តាលជំរឿនសេដ្ឋកិច្ចឆ្នាំ២០១៤ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៤ និងប្រភពទិន្នន័យរដ្ឋបាលផ្សេងទៀត ដូចជា ជញ្ជីងទូទាត់ (ធនាគារជាតិនៃកម្ពុជា) ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ទិន្នន័យពាណិជ្ជកម្មអន្តរជាតិ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា) និងទិន្នន័យក្រសួង ស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។

លទ្ធផលបឋមការផ្លាស់ប្តូរឆ្នាំគោល ផ.ស.ស. ឆ្នាំ២០១៤ ត្រូវបានត្រួតពិនិត្យគុណភាព និងពិភាក្សាជាច្រើនលើកជាមួយអ្នកជំនាញនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នស្ថិតិប្រទេសស៊ុយអែត រហូតលទ្ធផលចុងក្រោយសម្រេចបាន ដូចមានចំណុចសង្ខេបសំខាន់ៗខាងក្រោម៖

១- ទំហំសេដ្ឋកិច្ច ៨៨,៩ ទ្រីលានរៀល ស្មើនឹង ២២,១ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំគោល២០១៤ បើធៀបនឹងឆ្នាំ២០០០ មានទំហំសេដ្ឋកិច្ច ៦៧,៤ទ្រីលានរៀល បានកើនឡើង ៣១,៩%។

២- រចនាសម្ព័ន្ធសេដ្ឋកិច្ច៖ វិស័យកសិកម្មមានចំណែក ២២% នៃ ផ.ស.ស. (ថយចុះពី ២៩%) វិស័យឧស្សាហកម្មមានចំណែក ៣០% នៃ ផ.ស.ស. (កើនពី ២៦%) វិស័យសេវាកម្មមានចំណែក ៤២% នៃ ផ.ស.ស. (កើនពី ៤០%) នៅឆ្នាំ២០១៤ បើធៀបនឹងឆ្នាំ២០០០ ។

៣- ចំណូលសម្រាប់ម្នាក់ (GDP per capita) កើនពី ១ ១៣១ ដុល្លារអាម៉េរិក ដល់ ១ ៤៨៩ ដុល្លារអាម៉េរិក នៅឆ្នាំ២០១៤។

៤- គិតក្នុងឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាមានទំហំ ១៦០,១ ទ្រីលានរៀលតាមថ្លៃបច្ចុប្បន្ន ស្មើនឹង ៣៩,៥ ប៊ីលានដុល្លារអាម៉េរិក និងកំណើន ៥,១%។ ចំណូលសម្រាប់ម្នាក់ ប៉ាន់ស្មាន ២ ៣៤៥ ដុល្លារអាម៉េរិក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ អ្នកសារព័ត៌មាន អ្នកសិក្សាស្រាវជ្រាវ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១១រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤